# ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៧

## សមត្ថកិច្ចកំពុង តាមចាប់អ្នកទិញ ក្រលៀនមនុស្ស

https://www.dap-news.com/kh/ ថ្ងៃសៅរ៍, ៣០ កញ្ញា ២០១៧ 16:50 ដោយ: ដើមអម្ពិល ID:049

**ភ្នំពេញៈ**សមត្ថកិច្ចកំពុងតាម ចាប់ខ្លួនអ្នកទិញក្រលៀន ពីបុរសរងគ្រោះម្នាក់ នៅស្រុកពាមរក៍ ខេត្តព្រៃវែង និងបន្តស្រាវជ្រាវ យ៉ាងយកចិត្ត ទុកដាក់វែកមុខមេខ្លោង ដែលនៅពីក្រោយខ្នង សំណុំរឿងនេះ។

វិធានការណ៍តាមចាប់ខ្លួន អ្នកទិញក្រលៀនេះបានធ្វើឡើង បន្ទាប់ពីជនរងគ្រោះឈ្មោះ កង វ៉ា ភេទប្រុស អាយុ៣៨ឆ្នាំជនជាតិខ្មែរ មុខរបរលក់ដូរមាន ទីលំនៅភូមិបាទី ឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង បានសារភាព នៅចំពោះមុខនគរបាលថា ខ្លួនគេបានលក់ក្រលៀនឲ្យទៅឈ្មោះ យ៉ុងសុភ័ក្រភេទប្រុសមាន ទីលំនៅភ្នំពេញកាលពី អំឡុង ឆ្នាំ២០១៦តម្លៃជាង ៥០០០ដុល្លារ។ កន្លងមករឿងវះយកក្រលៀនលក់នេះ បានល្បីតៗគ្នាពីមាត់មួយទៅ មាត់មួយ បង្កការភ្ញាក់ផ្អើលយ៉ាងខ្លាំងកាលពី ពេលកន្លងទៅប៉ុន្តែឥឡូវនេះពិតជា មានជាក់ស្តែងមែន។

លោក សេង ពន្លក អធិការស្រុកពាមរក៍ បានឲ្យដឹងថា វាពិតជាមានករណីទិញលក់ក្រលៀន មនុស្សពិត ប្រាកដមែន។ ហើយចំពោះឈ្មោះ កង វ៉ា នេះសមត្ថកិច្ចមិនបាន ធ្វើការឃាត់ខ្លួននោះទេ ព្រោះរូបគាត់ជាជនរង គ្រោះ ដែលចាញ់បោកគេ។ បើតាមការសន្និដ្ឋានរបស់លោកតម្លៃ ក្រលៀនមនុស្សនេះអាចមានតម្លៃ ដល់រាប់ម៉ឺន ដុល្លារឯណោះ។ តែនេះជនរងគ្រោះលក់បានតែជាង ៥០០០ដុល្លារតែប៉ុណ្ណោះ៕

## កម្មករខ្មែរ1នាក់ និងថៃ 2នាក់បានស្លាប់បាត់បង់ជីវិតភ្លាមៗ បន្ទាប់ពីវិលត្រឡប់មកពីព្រំដែនទាំងយប់

http://pheaktraprak.com/archives/ By เพียะตรา ประ October 2, 2017

ជនជាតិថៃ 2នាក់និងពលករខ្មែរម្នាក់បានស្លាប់បាត់ជីវិតនៅហេតុការណ៍គ្រោះថ្នាក់ចរាចរ ដោយសារបើក រថយន្តផ្លូវជ្រុលទៅបុកដើមឈើនៅខេត្តឆាកឈើងសៅ។ ខេត្តឆាកឈើងសៅ÷ កាលពីវេលាម៉ោង 02:00 យប់ ឈានចូលថ្ងៃច័ន្ទ ទី02 ខែតុលា ឆ្នាំ2017 មានករណីគ្រោះថ្នាក់ចរាចរបើករថយន្តធ្លាក់ផ្លូវ ជ្រុលទៅបុកដើមឈើ បណ្តាលឲ្យមនុស្សជិះនៅក្នុងរថយន្តចំនួន 3នាក់បានស្លាប់បាត់បង់ជីវិត។ ហេតុការណ៍នេះបានកើតឡើងនៅវេលា ម៉ោង02យប់ ស្ថិតត្រង់ចំណុចផ្លូវជាតិលេខ304 ផាក់ណុមមហាសាខាម-ឆាក់ឈើងសៅ ខេត្តឆាកឈើងសៅ ប្រទេសថៃ។

នៅកន្លែងកើតហេតុគេឃើញមានរថយន្តម៉ាកToyota ពណ៌ស ពាក់ស្លាកលេខ( 1ห 1355 กทม) ជ្រុលបុក និងដើមឈើក្បែរផ្លូវបណ្តាលអោយរថយន្តខូចខាតទាំងស្រុង ត្រួតពិនិត្យនៅក្នុងរថយន្តមានអ្នកជិះនៅរថយន្តបី នាក់បានស្លាប់បាត់ជីវិត សមត្ថកិច្ចបាននាំយកសពអ្នកស្លាប់ចេញមកខាងក្រៅដើម្បីធ្វើការត្រួតពិនិត្យអត្តសញ្ញាណ តាមការត្រួតពិនិត្យនៅសាកសពអ្នកស្លាប់,មានប៉ាស្ព័រខ្មែរម្នាក់និងអត្តសញ្ញាណប័ណ្ណសញ្ជាតិថៃ 2នាក់ ជនរងគ្រោះ ដែលស្លាប់បាត់បង់នៅហេតុការណ៍គ្រោះថ្នាក់នេះរួមមាន៖

1.ឈ្មោះ ណាក់វ៉ាត់ ស៊ាន់ប្រាក់សឺត ភេទប្រុស សញ្ជាតិ ថៃ 2.ឈ្មោះ ណាវ៉ាស៊ាក់ ភីវ៉ផៃ ភេទប្រុស សញ្ជាតិ ថៃ

3.ឈ្មោះសោ៉មិត មុតមិត ភេទប្រុស សញ្ជាតិ ខ្មែរ កាន់ប៉ាស្ព័រការងារ

សាកសពជនរងគ្រោះទាំងអស់ត្រូវបានភ្នាក់ងារសង្គ្រោះខេត្តតាកឈើងសៅបញ្ជូនយកទៅរក្សាទុកនៅមន្ទីរពេទ្យខេត្តតាកឈើងសៅដើម្បីរង់ចាំប្រគល់ជូនសាច់ញាតិយកទៅធ្វើបុណ្យតាមប្រពៃណី។

## ឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំ ប្រទេសថៃ ផ្តល់លិខិតឆ្លងដែនជូនពលករខ្មែរ 135នាក់ មកពីក្រុមហ៊ុនT.T.S Engineering 2004

http://pheaktraprak.com/archives/ By เพียะตรา ประ October 1, 2017

ប្រទេសថៃ÷នៅរសៀលថ្ងៃសៅរ៍ទី៣០ ខែកញ្ញា ឆ្នាំ២០១៧នេះ នៅស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងបាងកក បានរៀបចំកម្មវិធីចែកលិខិតធ្វើដំណើរជូនដល់ពលករកម្ពុជាធ្វើការនៅបរទេស (TD) ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) និងលិខិតបញ្ជាក់បុគ្គលតែមួយ ជូនដល់ពលករ-ពលការិនីខ្មែរ ចំនួន ១៣៥នាក់ ដែលកំពុងបម្រើការងារនៅក្រុមហ៊ុន T.T.S Engineering 2004 Co.,LTD ក្រោមអធិបតីភាពឯកឧត្តម ឡុង វិសាលោ ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍។

ក្នុងពិធីប្រគល់លិខិតឆ្លងដែនការងារជូនដល់បងប្អូនពលករខ្មែរយើងលើកនេះ ឯកឧត្តម ឯកអគ្គរាជទូត ឡុង វិសាលោ បានជួបសំណេះសំណាលជាមួយបងប្អូនពលករកម្ពុជា ដែលកំពុងនៅធ្វើការ ក្រុមហ៊ុនT.T.S Engineering 2004 Co.,LTD មក្នុងប្រទេសថៃ ហើយក្នុងឱកាសនេះដែរ ឯកឧត្តម បានជម្រាបបងប្អូនទាំងអស់អំពីការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលក្នុងជួយសម្រួល និងដោះស្រាយបញ្ហារបស់បងប្អូនខ្មែរទាំងអស់នៅប្រទេសថៃ។

## ទីតាំងផ្តល់ធ្វើប៉ាស្ព័រជូនពលករខ្មែរ នៅក្នុងខេត្តរះយ៉ង ចាប់ផ្តើមរៀបចំការិយាល័យហើយ ត្រៀមខ្លួន

http://pheaktraprak.com/archives/ By เพียะตรา ประ September 30, 2017

ការិយាល័យត្រួតសញ្ជាតិជូនពលករខ្មែរនៅក្នុងខេត្តរះយ៉ង ប្រទេសថៃ ចាប់ផ្តើមរៀបចំការិយាល័យហើយ។ នៅថ្ងៃសៅរ៍ទី30 ខែកញ្ញា ឆ្នាំ2017 ការិយាល័យធ្វើប៉ាស្ព័រជូនបងប្អូនពលករខ្មែរ នៅក្នុងខេត្តរះយ៉ង ប្រទេសថៃ ចាប់ផ្តើមមានបុគ្គលិកចុះមករៀបចំទីតាំងហើយ ដើម្បីត្រៀមកន្លែងធ្វើប៉ាស័ព្ទរជូនបងប្អូនពលករខ្មែរ នៅខែ10ខាងមុខនេះ។ ដោយធ្វើប៉ាស្ព័រនេះស្ថិតនៅក្នុង( zone otop ) ខេត្តរះយ៉ង។

## កម្មករភូមាជាង300នាក់ ធ្វើកូដកម្មទាមទារឲ្យដំឡើងប្រាក់ខែ អោយស្មើរនិងជាតិថៃ

http://pheaktraprak.com/archives/ By เพียะตรา ประ September 29, 2017

កម្មករបរទេសធ្វើការរោងចក្រផលិតពោតកំប៉ុងប្រមាណជាង300នាក់ ធ្វើបាត់កម្មទាមទារឲ្យអោយម្ចាស់ក្រុមហ៊ុនដំឡើងប្រាក់ខែអោយស្មើរជនជាតិថៃ។ ខេត្តកាណណាក់បុរី÷កាលពីថ្ងៃទី28 ខែកញ្ញា ឆ្នាំ2017 កម្មករកម្មការិនីសញ្ជាតិភូមាធ្វើការនៅក្នុងរោងចក្រផលិតពោតកំប៉ុង ស្ថិតនៅក្នុងស្រុកមឿងខេត្តកាណណាក់បុរី ប្រទេសថៃ នាំគ្នាធ្វើកូដកម្មទាមទារឲ្យម្ចាស់រោងចក្រ ដំឡើងប្រាក់ខែជូនពួកគេបន្ទាប់ពីប្រាក់ឈ្នួលសព្វថ្ងៃបានត្រឹមតែមួយថ្ងៃ 280฿-290฿ ដោយក្រុមកម្មករបានទាមទារស្នើសុំឲ្យដំឡើងចាប់ 305฿ស្មើរគ្នាដើម្បីអោយ សមស្របទៅតាមតំលៃនៃច្បាប់ការងារដែលប្រកាសពេលកន្លងមក។

# ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧

## នីតិវិធីនៃការ បញ្ជាក់អត្តសញ្ញាណ ជូនពលករខ្មែរ កំពុងស្នាក់នៅ និងធ្វើការនៅថៃ

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, 02 តុលា ២០១៧ 17:03 ដោយ: ដើមអម្ពិល ID:049

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**
លេខៈ..............០៣១/១៧.......គ.ផ.ថ/ស.ជ.ណ

**សេចក្ដីជូនដំណឹង**
**ស្ដីពីនីតិវិធីនៃការបញ្ជាក់អត្តសញ្ញាណ**
**ជូនពលករកម្ពុជាដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃ**

គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃទាំងអស់បានជ្រាបថា គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នឹងបើកយុទ្ធនាការបញ្ជាក់អត្តសញ្ញាណជូនបងប្អូនពលករកម្ពុជាដើម្បីទទួលបានលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC)ដែលមានព័ត៌មានដូចខាងក្រោម៖

**I. ទីកន្លែង ថ្ងៃម៉ោងធ្វើការ និងតម្លៃសេវា**

១.ទីកន្លែង ៖

- ទីក្រុងបាងកក៖ អាសយដ្ឋាន អ៊ីមផេរៀល វើល ឡាតប្រាវ (Imperial World Ladphrao) ជាន់ទី៤, លេខ២៥៣៩, ច្រក៨១-៨៣ ផ្លូវឡាតប្រាវ, សង្កាត់ ចៅឃុនស៊ីង, ខណ្ឌ ប៉ុងឡាង, ទីក្រុងបាងកក ១០៣១០
- ខេត្តរ៉ាក់យ៉ង , អាសយដ្ឋាន ផ្សារ អូថប់ម៉ាយ៉ង (OTOP MA YONG) -២០១ភូមិ ៧, ឃុំ ម៉ាខាមយូ, ស្រុក និឃុំផាត់តាណា, ខេត្ត រ៉ាក់យ៉ង ២១១៨០
- ខេត្តសុងក្លា ៖ អាសយដ្ឋាន ផ្សារ ហ្វុកទៀន(Fuk Thian), ៩៩ភូមិ៣, ឃុំ ខ្លងហែរ, ស្រុក ហាត់យៃ, ខេត្ត សុងក្លា

២.ថ្ងៃម៉ោងធ្វើការ ៖ ថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍

- បាងកក ៖ ព្រឹកម៉ោង ១០:០០ ដល់ ៦:៣០ ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៥:០០ ល្ងាច
- ខេត្តរ៉ាក់យ៉ង ៖ ព្រឹកម៉ោង ៨:៣០ ដល់ ៥:០០ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៣:៣០ ល្ងាច
- ខេត្តសុងក្លា ៖ ព្រឹកម៉ោង ៨:៣០ ដល់ ៥:០០ ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៣:៣០ ល្ងាច

ទំព័រ ១


៣.តម្លៃសេវាផ្លូវការក្នុងការធ្វើ និងបើកផ្តល់សំណុំឯកសារក្នុងថ្ងៃតែមួយដែលភាគីថៃ និងកម្ពុជាបាន ឯកភាពគ្នាគឺ ២ ៣៥០ (ពីរពាន់បីរយហាសិប)បាត។

**II. ឯកសារតម្រូវសម្រាប់ពលករមកស្នើសុំធ្វើលិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស**

១.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ច្បាប់ដើម និងច្បាប់ថតចម្លងចំនួន២ច្បាប់

២.ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណស៊ីជម្ពូ) ឬលិខិតបញ្ជាក់ទំនាក់ទំនងរវាងនិយោជក និងពលករ ដែលចេញដោយក្រសួងការងារថៃ ឬមន្ទីរការងារថៃច្បាប់ដើម និងច្បាប់ថតចម្លងចំនួន២ច្បាប់

៣.ប័ណ្ណអនុញ្ញាតការងារផ្នែកនេសាទ (សម្រាប់ពលករផ្នែកនេសាទ)

៤.ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់និយោជក

៥.ពលករត្រូវមកដោយផ្ទាល់ និងថតរូបដោយផ្ទាល់

**III. អ្នកក្នុងបន្ទុករបស់ពលករអាយុក្រោម ១៥ឆ្នាំមិនយកតម្លៃសេវា**

១. ត្រូវនាំកូន ឬអ្នកក្នុងបន្ទុកមកដោយផ្ទាល់ និងថតរូបដោយផ្ទាល់

២. សំបុត្រកំណើតកូន ឬសំបុត្រពេទ្យ

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាអនុវត្តទៅតាម ខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការ**

**អ៊ិត សំហេង**

## គណៈកម្មការធ្វើប៉ាស្ព័រ ចាប់ផ្តើមប្រកាសបើកធ្វើប៉ាស្ព័រជូនបងប្អូនពលករខ្មែរនៅក្នុងប្រទេសថៃហើយ

http://pheaktraprak.com/archives/ By เพียะตรา ประ October 2, 2017

ក្រសួងការងារកម្ពុជាចេញសេចក្តីប្រកាសអំពាវនាវឲ្យបងប្អូនពលករខ្មែរ ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃត្រៀមខ្លួន ត្រួតសញ្ជាតិ ដើម្បីប្តូរប័ណ្ណស៊ីជម្ពូយកប៉ាស្ព័រការងារនៅក្នុងសប្តាហ៍ខាងមុខនេះ។ សេចក្តីប្រកាសជូនដំណឹង÷គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់បងប្អូនពលករខ្មែរ កំពុងធ្វើការនៅក្នុងប្រទេសថៃ សូមប្រកាសជូនដំណឹងដល់បងប្អូនពលករកម្ពុជាអោយជ្រៀប ជាពិសេសបងប្អូនសាធារណៈជនដែលធ្វើរស់នៅធ្វើការនៅក្នុងប្រទេសថៃ អោយបានជ្រៀបថា ។ គណៈកម្មការផ្តល់ភាពស្របច្បាប់នៅប្រទេសថៃនិងចាប់ផ្តើមបើកយុទ្ធនាការត្រួតអត្តសញ្ញាណ(ត្រួតសញ្ជាតិ) ជូនបងប្អូនពលករខ្មែរ ដើម្បីទទួលបានលិខិតធ្វើដំណើរពលករកម្ពុជា(ប៉ាស្ព័រការងារ)នៅបរទេស(TD) និងប័ណ្ណពលករកម្ពុជាធ្វើការនៅបរទេស(OCWC)ដែលមានព័ត៌មានលំអិតដូចខាងក្រោម៖

1.ទីក្រុងបាងកក អាស័យដ្ឋាន អ៊ីមជើរៀលវើល ឡាតប្រាវ(Imperial World Ladphrao) ជាន់ទី 4 លេខ2539 ច្រក81-83 ផ្លូវឡាតប្រាវ សង្កាត់ចៅយុនស៊ឹង ខណ្ឌចុងឡាង ទីក្រុងបាងកក 10310។

2.ខេត្តរ៉ាក់យ៉ង. អាស័យដ្ឋានផ្សារ អូថប់យ៉ង(OTOP MA Yong). 201-ភូមិ7 ឃុំម៉ាខាយ,ស្រុក និឃុំផាត់តាណា, ខេត្តរ៉ាក់យ៉ង 21180។

3.ខេត្តសុងក្លា អាស័យដ្ឋាន ផ្សារហុកទៀង( Fuk Thai ) 99 ភូមិ3. ឃុំ ខ្លងហែរ ស្រុកហាតយ៉ៃ ខេត្តសុងក្លា។

*តារាងពេលវេលាម៉ោងធ្វើការរបស់ទីតាំងត្រួតសញ្ជាតិជូនពលករខ្មែរ*

-ទីក្រុងបាងកក ចាប់ពីម៉ោង10:00 ព្រឹក ដល់ម៉ោង 06:30 ល្ងាច

-ខេត្តរ៉ាក់យ៉ង ចាប់បើកពីម៉ោង08:30 ព្រឹក ដល់ម៉ោង05:00 ល្ងាច

-ខេត្តសុងក្លា ចាប់បើកពីម៉ោង08:30ព្រឹក ដល់ម៉ោង05:00 ល្ងាច បញ្ជាក់ពលករត្រូវមកដល់មុនម៉ោង30:30 ល្ងាច

-តម្លៃសេវាជាផ្លូវការក្នុងការធ្វើជូន និងបើកផ្តល់សំណុំឯកសារក្នុងថ្ងៃតែមួយដែលភាគីថៃ និងកម្ពុជាបានឯកភាពគ្នាគឺ 2350฿ ( ពីពាន់បីរយហាសិប ) បាត។

*ឯកសារតម្រូវសម្រាប់ពលករមកស្នើសុំលិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជាធ្វើការនៅបរទេស*

1.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើតច្បាប់ដើម និងច្បាប់ថតចំម្លងចំនួន 2សន្លឹក

2.ប័ណ្ណមិនមែនសញ្ជាតិថៃ( ប័ណ្ណស៊ីជម្ពូ ) ឬលិខិតបញ្ជាក់ ទំនាក់ទំនងជាមួយរវាងនិយោជក( ថៅកែ ) ដែលចេញដោយក្រសួងការងារថៃ ឬមន្ត្រីការងារថៃច្បាប់ដើម និងច្បាប់ថតចម្លងចំនួន 2សន្លឹក។

3.ប័ណអនុញ្ញាតការងារផ្នែកនេសាទ( សម្រាប់ពលករធ្វើការនេសាទ )

4.ឈ្មោះ អាស័យដ្ឋាន លេខរបស់និយោជក( ថៅកែ )

5.ពលករត្រូវមកដោយផ្ទាល់ និងថតរូបផ្ទាល់

*អ្នកក្នុងបន្ទុកក្រោមអាយុ 15ឆ្នាំមិនយកតម្លៃសេវា*

1.ត្រូវនាំកូន ឬអ្នកក្នុងបន្ទុកមកដោយផ្ទាល់ ថតរូបផ្ទាល់

2.សំបុត្រកំណើតកូន ឬសំបុត្រពេទ្យរបស់កូន

អាស្រ័យហេតុនេះសូមបងប្អូនពលករខ្មែរទាំងអស់ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃទាំងអស់មេត្តាជ្រាប។

## ការិយាល័យធ្វើប៉ាស្ព័រជូនពលករខ្មែរក្នុងខេត្តរ៉ាក់យ៉ង ចាប់បើកនៅថ្ងៃពុធខាងមុខនេះ

http://pheaktraprak.com/archives/ By เพียะตรา ประ October 2, 2017

ការិយាល័យត្រួតសញ្ជាតិជូនកម្មករខ្មែរនៅក្នុងខេត្តរ៉ាក់យ៉ង បើកកន្លះថ្ងៃត្រូវផ្អាក់វិញដោយសារភ្នាក់ងារក្រសួងការងារថៃមិនទាន់ចុះមកធ្វើការ។ កាលពីព្រឹកថ្ងៃច័ន្ទទី02 ខែកញ្ញា ឆ្នាំ2017 នេះ គណ:កម្មការផ្តល់លិខិតឆ្លងដែនស្របច្បាប់ជូនពលករខ្មែរនៅក្នុងខេត្តរ៉ាក់យ៉ងប្រទេសថៃ ចាប់ផ្តើមបើកការិយាល័យ ត្រួតសញ្ជាតិជូនដល់បងប្អូនពលករខ្មែរនៅខេត្តរ៉ាក់យ៉ងជាថ្ងៃដំបូង តែត្រូវបានផ្អាក់វិញបន្ទាប់ពីភ្នាក់ងារក្រសួងការងារថៃ,ភ្នាក់ងារតម្រួតអន្តោប្រវេសន៍ថៃ,ភ្នាក់ងារពេទ្យថៃ មិនទាន់ចុះមកដំណើរការ។ ចំណែកឯភ្នាក់ងារគណ:កម្មការធ្វើប៉ាស្ព័រ ខាងប្រទេសកម្ពុជាយើងវិញបានត្រៀមឧបករណ៍ត្រួត, ថត,ធ្វើប៉ាស្ព័រជូនបងប្អូនពលករខ្មែរ។

បើតាមការបញ្ជាក់របស់ក្រុមនិយោជកថៃមួយចំនួន ដែលបានទៅកាន់កន្លែងការិយាល័យធ្វើប៉ាស្ព័រអូថប់ខេត្ត កាលពីព្រឹកមិញនេះបានឲ្យដឹងថា នៅថ្ងៃពុធខាងមុខនេះគណ:កម្មការផ្តល់លិខិតឆ្លងដែនស្របច្បាប់កម្ពុជា និងចាប់ផ្តើមបើកការិយាល័យត្រួតសញ្ជាតិម្តងទៀត ដោយជំហានដំបូងគឺធ្វើការត្រួតសញ្ជាតិជូនកម្មករផ្នែកនេសាទមុនគេ។ ចំណែកឯអ្នកដែលគាត់ប័ណ្ណស៊ីជម្ពូធ្វើការនៅលើគោគ និងអ្នកដែលសម្ភាសន៍ រួចត្រូវរង់ចាំភាគីក្រសួងការងារថៃប្រកាសជាផ្លូវការម្តងទៀតនៅពេលក្រោយ។

## តើថៃប្រកាសបើកធ្វើប៉ាស្ព័រជូនពលករខ្មែរនៅពេលណា.? អានចម្លើយនៅខាងក្នុង

http://pheaktraprak.com/archives/ By เพียะตรา ประ October 3, 2017

ចម្ងល់របស់បងប្អូនពលករខ្មែរនៅក្នុងបណ្តាញសង្គមហ្វេសប៊ុក ដែលតែងតែសួរមកផេករបស់យើងខ្ញុំ ចម្លើយ÷ហេតុផលដែលក្រសួងការងារថៃមិនទាន់ប្រកាសបើកអោយធ្វើការត្រួតសញ្ជាតិជូនពលករខ្មែរនៅពេលនេះ

គឺបន្ទាប់ពីមានបញ្ហារឿងបង់ប្រាក់គ្រួតសញ្ញាតិជូនកម្មករភូមា ក្រសួងការងារថៃបានផ្អាកអោយកម្មករភូមា បង់ប្រាក់បណ្តោះអាសន្ន ដើម្បីកែសម្រួលរឿងការបង់អោយបានត្រឹមត្រូវដើម្បីកុំអោយមានបញ្ហាដូចលើកមុនទៀត។ ដោយសារតែហេតុនេះហើយបានជាក្រសួងការងារថៃមិនទាន់ប្រកាសបើកធ្វើប៉ាស្ព័រជូនបងប្អូនពលករខ្មែរតែក៏មិនយូរដែរ។ សប្តាហ៍ខាងមុខនេះបងប្អូនពលករខ្មែរដែលកំពុងរង់ចាំប្តូរប័ណ្ណស៊ីជម្ពូយកប៉ាស្ព័រការងារមានដំណឹងជាក់ជាមិនខាន។ ដូច្នេះហើយបងប្អូនពលករខ្មែរដែលចម្ងល់សូមមេត្តារង់ចាំតាមដានព័ត៌មានបន្ថែមនៅពេលខាងមុខទៀតនេះ។

## ចាប់ខ្លួនដាក់ឡានឆ្អើលពេញភូមិ... រឿងនាំពលករ

http://www.kaoh-santiphap-news.html ដោយ ៖ ហួត សុងហាក់ ថ្ងៃអង្គារ ទី៣ ខែតុលា ឆ្នាំ២០១៧

ខេត្តបាត់ដំបង ៖ មានការភ្ញាក់ផ្អើលពេញភូមិ បន្ទាប់ពីបុរសចំណាស់ម្នាក់អាយុជាង៦០ឆ្នាំ ត្រូវបានកម្លាំងមានឯកសណ្ឋានប៉េអឹម និងប្រដាប់ដោយអាវុធជាច្រើននាក់ បានចុះទៅចាប់ខ្លួនដល់លំនៅឋានរបស់គាត់ រួចដាក់ខ្នោះដៃរុញចូលក្នុងរថយន្តយ៉ាងប្រញាប់ប្រញាល់ រួចត្រឡប់ទៅវិញ ដោយពុំបានបង្ហាញដីកាចាប់ ឬនាំខ្លួនឱ្យសាមីខ្លួនបានដឹងឡើយ ។

ការឆ្មក់ចាប់ខ្លួនបុរសចំណាស់ខាងលើ បានធ្វើឡើងនៅចំណុចភូមិអូរក្រូច ឃុំតាគោក ស្រុកសំឡូត ខេត្តបាត់ដំបង កើតឡើងកាលពីវេលាម៉ោង១០ព្រឹកថ្ងៃទី៣០ កញ្ញា ។ បន្ទាប់ពីចាប់ខ្លួនបុរសចំណាស់រូបនោះបានកន្លះម៉ោង ប្រពន្ធរបស់គាត់ ក៏បានជួលម៉ូតូឌុបដេញតាមរថយន្តរបស់សមត្ថកិច្ច ដើម្បីចង់ដឹងថា សមត្ថកិច្ចនាំខ្លួនប្តីរបស់គាត់យកទៅណា តែតាមមិនទាន់ ប៉ុន្តែអស់រយៈពេលជាង៣ម៉ោងក្រោយមក ទើបរូបគាត់បានទទួលដំណឹងពីប្តីគាត់តាមទូរស័ព្ទយ៉ាងខ្លីថា រូបគាត់ (ប្តី) ត្រូវបានគេឃុំខ្លួននៅក្នុងទីបញ្ជាការដ្ឋានប៉េអឹមខេត្តបន្ទាយមានជ័យ ។

ក្រុមគ្រួសារជនរងគ្រោះបាននិយាយថា ពួកគាត់នៅមិនទាន់ដឹងពីមូលហេតុនៃការចាប់ប្តី និងឪពុករបស់គាត់ច្បាស់លាស់ឡើយទេ មកដល់ត្រឹមរសៀលថ្ងៃទី០២ តុលា ហើយសមត្ថកិច្ចនៅតែបន្តឃុំខ្លួនដដែល ។ ពួកគាត់បញ្ជាក់ទៀតថា រយៈពេលឃុំខ្លួនប្តី និងឪពុករបស់គាត់លើស៤៨ម៉ោងហើយ គិតត្រឹមម៉ោង១រសៀលថ្ងៃទី០២ តុលា នេះ ។ ពួកគាត់សំណូមពរឱ្យស្ថាប័នសារព័ត៌មានទាំងអស់ មេត្តាជួយតាមឃ្លាំមើលរឿងអយុត្តិធម៌នេះផង ។ ប្រភពព័ត៌មានពីសមត្ថកិច្ចប្រាប់ថា ការចាប់ខ្លួនកញ្ជក់កណ្តៀតបែបនេះ គឺពាក់ព័ន្ធរឿងនាំពលករខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ ។ គាត់ជាមេខ្យលនៃរឿងនេះ ។

## ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី ជួយពលករ-ពលការិនីខ្មែរ ១៦នាក់ បន្ទាប់ពីមិនអាចស៊ូទ្រាំជាមួយការងារបាន

http://www.freshnewsasia.com/index.php/en/localnews/ 2017-10-03

**(ភ្នំពេញ)៖** ក្រសួងការបរទេសកម្ពុជា បានឲ្យដឹងថា ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី បានអន្តរាគមន៍ជួយពលករ-ពលការិនីខ្មែរចំនួន ១៦នាក់ឲ្យបានត្រឡប់មកប្រទេសកម្ពុជាវិញ បន្ទាប់ពីពួកគេមិនអាចស៊ូទ្រាំជាមួយការងារបាន។ លោក ជុំ សុន្ទរី អ្នកនាំពាក្យក្រសួងការបរទេស បានឲ្យដឹងនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧នេះថា ពលករពលការិនីទាំង១៦នាក់នេះ បានទៅធ្វើការនៅម៉ាឡេស៊ីចន្លោះពីឆ្នាំ២០១៤-២០១៧។ ពួកគេមកពីខេត្តក្រចេះ កំពង់ធំ កំពត ត្បូងឃ្មុំ កំពង់ចាម និងសៀមរាបជាដើម។ លោក ជុំ សុន្ទរី បានឲ្យដឹងដែរថា បន្ទាប់ការជួយ

អន្តរាគមន៍ពីស្ថានទូតកម្ពុជានៅម៉ាឡេស៊ី ដោយមានការទាមទារប្រាក់ខែ និងប្រាក់បំណាច់ជាដើមនោះ ពលករ ពលការិនីទាំង ១៦នាក់បានត្រឡប់មកដល់ប្រទេសកម្ពុជាវិញហើយ កាលពីថ្ងៃទី៣០ ខែកញ្ញា កន្លងទៅនេះ៕

## ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧

## ចាប់មេខ្យល់ដែលនាំពលករខ្មែរចូលកាប់ឈើក្នុងទឹកដីថៃ

https://kohsantepheapdaily.com.kh ដោយ ៖ ប៊ុន ធឿន ថ្ងៃអង្គារ (03-10-2017 16:55)

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងកងរាជអាវុធហត្ថឃាត់ខ្លួន មេខ្យល់ប្រមូលកម្មករស៊ីឈ្នួលកាប់ឈើគ្រញូង ក្នុងទឹកដីថៃ ឃាត់ខ្លួនបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ចាត់ការតាមច្បាប់ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ ២០១៧ ។

លោកវរសេនីយ៍ទោ ប៊ុន ណាំអៀង មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ បានប្រាប់ថា ៖ ជនសង្ស័យឃាត់ខ្លួនមានឈ្មោះ គឹម ណារុន ហៅកុង ភេទប្រុស អាយុ៦២ឆ្នាំ រស់នៅភូមិអូរក្រូច ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង ។ លោកបានបញ្ជាក់ថា ៖ នៅពេលឃាត់ខ្លួនជនសង្ស័យ គឺកាលពីអំឡុងថ្ងៃទី១៥ ដល់១៨ ខែកញ្ញា ឆ្នាំ២០១៧ សមត្ថកិច្ចថៃបានឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរចំនួន១៨នាក់ ក្នុងចំណោម២៧នាក់ ដែលលួចចូលកាប់ឈើគ្រញូងក្នុងតំបន់ឧទ្យានជាតិថាប់ទីបីខ្លងម៉ាន់ ប្រទេសថៃ បានរត់គេចខ្លួនរួច ពីការចាប់ខ្លួនពីសមត្ថកិច្ចថៃ ។

លោកវរសេនីយ៍ទោ ប៊ុន ណាំអៀង បានបញ្ជាក់ថា ៖ ក្រោយពេលសមត្ថកិច្ចថៃចាប់ខ្លួនប្រជាពលរដ្ឋខ្មែរ ចំនួន១៨នាក់ ដែលចោទប្រកាន់លួចចូលកាប់ឈើគ្រញូងក្នុងតំបន់ឧទ្យាជាតិ ប្រទេសថៃ ។ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៧ កម្លាំងមន្ទីរស្រាវជ្រាវព័ត៌មាន និងសន្តិសុខកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ស្រាវជ្រាវរកឃើញមានប្រជាពលរដ្ឋខ្មែរ២នាក់ ដែលរត់គេចខ្លួន ពីការចាប់ខ្លួនមាន ទី១.ឈ្មោះ ហ៊ើល គឿន ភេទប្រុស អាយុ២៤ឆ្នាំ និងទី២.ឈ្មោះ រ៉េន ពុំ ភេទប្រុស អាយុ២៧ឆ្នាំ ទាំង២នាក់រស់នៅភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ។

លោកបានប្រាប់ថា ៖ ពួកគាត់ទៅស៊ីឈ្នួលកាប់ឈើគ្រញូងក្នុងទឹកដីថៃ ហើយត្រូវបានសមត្ថកិច្ចថៃចាប់ បាន១៨នាក់ ក្នុងចំណោម២៧នាក់ ដែលពួកគាត់ទៅតាមរយៈមេខ្យល់ឈ្មោះ គឹម ណារ៉ុន ហៅកុង ក្រោយពេលទទួលព័ត៌មានហើយ ដោយមានការសម្របសម្រួលពីលោក មាស ច័ន្ទពិសិដ្ឋ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបន្ទាយមានជ័យ បានឃាត់ខ្លួនឈ្មោះ គឹម ណារ៉ុន ហៅកុង កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ នៅភូមិអូរក្រូច ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង ។

លោកវរសេនីយ៍ទោ ប៊ុន ណាំអៀង បានបញ្ជាក់ថា ៖ ក្រោយពេលឃាត់ខ្លួនជនសង្ស័យហើយ ដោយយោងតាមការសារភាព និងចម្លើយជនរងគ្រោះ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ចាត់ការតាមច្បាប់ ៕

## បុគ្គលិកជាប់កិច្ចសន្យា៣នាក់ ជាប់អន្ទាក់សមត្ថកិច្ច រឿងអ្នកសុំទាន

https://kohsantepheapdaily.com.kh ដោយ ៖ ឃឹម ប៊ុនណាក់ ថ្ងៃអង្គារ (03-10-2017 17:49)

រាជធានីភ្នំពេញ ៖ កងរាជអាវុធហត្ថរាជធានីភ្នំពេញបានបញ្ជូនជនសង្ស័យ៣នាក់ ពាក់ព័ន្ធករណីកេងប្រវ័ញ្ចពលកម្ម កុមារមនុស្សចាស់ជរា និងញុះញង់អនិតិជនឲ្យដើរសុំទានទៅតុលាការនៅថ្ងៃទី ០៣ ខែតុលា ដើម្បីផ្តន្ទាទោសតាមច្បាប់។

ជនសង្ស័យទាំង៣នាក់នេះរួមមាន ១.ឈ្មោះ យុត នឹម ហៅ តាលឹម អាយុ៥៥ឆ្នាំ ជាបុគ្គលិកជាប់កិច្ចសន្យាមន្ទីរសង្គមកិច្ចរាជធានី ២.ឈ្មោះ ហឹង សារុំ ហៅ តារុំ អាយុ៤២ឆ្នាំ ជាបុគ្គលិកជាប់កិច្ចសន្យា នៃមន្ទីរសង្គមកិច្ចរាជធានី និង ៣.ឈ្មោះ សាន សិត ភេទប្រុស អាយុ៤១ឆ្នាំ អតីតជាអ្នកសុំទាន នឹងពេលនេះជាអ្នកដើរប្រមូលលុយ ពីអ្នកសុំ ទានតាមភ្លើងស្តុប នឹងតាមសួនច្បារមាត់ទន្លេវិញ ។

តាមការស្រាវជ្រាវរបស់សមត្ថកិច្ច និងចម្លើយអះអាងរបស់ជនសង្ស័យបានឲ្យដឹងថា ពួកគេបានធ្វើសកម្មភាពប្រមូលលុយពីអ្នកសុំទានរៀងរាល់ថ្ងៃ នៅតាមភ្លើងស្តុប នឹងតាមសួនច្បារ ដោយអ្នកសុំទានម្នាក់ត្រូវបង់១ម៉ឺន ទៅ១ម៉ឺន២ពាន់រៀលក្នុង១ថ្ងៃ ហើយ១សប្តាហ៍ ទើបឈ្មោះ សាន សិត យកលុយប្រគល់ឲ្យ តាលឹម និងតារុំតែម្តង ដោយតាលឹម យកចំណែកអ្នកដើរសុំនៅស្តុបអាងទឹក ស្តុបពេទ្យចិន ស្តុបផ្សារដើមគោ និងភូមិសាស្ត្រក្បែរគ្នា រីឯតារុំ យកចំណែកអ្នកដើរសុំនៅស្តុបកាណាឌីយ៉ា ស្តុបបូកគោ និងសួនមាត់ទន្លេ ។

ការយកលុយរបស់តាលឹម និងតារុំ ពីអ្នកសុំទាននេះ ជាថ្នូរជាមួយនឹងការផ្តល់ព័ត៌មាននៅពេលណាដែលមន្ទីរសង្គមកិច្ច និងសមត្ថកិច្ចចុះបោសសំអាតប្រមូលអ្នកសុំទាន អ្នកញៀនថ្នាំ និងក្មេងអានាថាតាមដងផ្លូវ តែបើពួកអ្នកសុំទានទាំងនោះ មិនព្រមបង់លុយឲ្យ ឈ្មោះ សាន សិត គំរាមថា នឹងរាយការណ៍ឲ្យខាងមន្ទីរសង្គមកិច្ច និងសមត្ថកិច្ចចុះចាប់ពួកគេ ក្នុងនោះក៏មានអ្នកសុំទានជាច្រើនពិតជាត្រូវបានឈ្មោះ សាន សិត រាយការណ៍ឲ្យតាលឹម និងតារុំ នាំក្រុមការងារសង្គមកិច្ចចុះបង្ក្រាបមែន ពេលដែលពួកគេមិនព្រមបង់លុយតាមការទាមទារ ៕

## អាជ្ញាធរថៃ បញ្ជូនសពពលករខ្មែរម្នាក់ មកកម្ពុជាវិញ តាមច្រកទ្វារអន្តរជាតិដូង

http://ann.com.kh/site/news/.html ថ្ងៃពុធ, 4 ខែតុលា 2017 8:27 ព្រឹក

**ខេត្តបាត់ដំបង៖** សាកសពពលករខ្មែរម្នាក់ ត្រូវបានអាជ្ញាធរប្រទេសថៃ បញ្ជូនមកស្រុកកំណើតវិញ កាលពីវេលាម៉ោង១១ និង៣០នាទី ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៧ តាមច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង។ សាកសពជនរងគ្រោះឈ្មោះ សយ សារី ភេទស្រី អាយុ៣១ឆ្នាំ មានស្រុកកំណើតនៅភូមិព្រៃស្ពោ ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដោយសារជំងឺខ្លាញ់រុំបេះដូង បណ្តាលឲ្យគាំងស្លាប់ នៅខេត្តឈុនបូរី ប្រទេសថៃ កាលពីព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧។

បច្ចុប្បន្នសព ត្រូវបានអាជ្ញាធរខ្មែរប្រចាំនៅច្រកទ្វារអន្តរជាតិដូង ប្រគល់ជូនក្រុមគ្រួសារយកទៅធ្វើបុណ្យនៅឯស្រុកកំណើតទៅតាមប្រពៃណី៕ **ដោយ៖ រៀម សាលី**

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃថា រយៈពេលជាងកន្លះឆ្នាំ២០១៧នេះ ថៃបានបញ្ជូនសាកសព ពលករខ្មែរជាង៥០០

http://cambodiapolice.com/blog/archives/ 12:12 pm 4 តុលា 2017 20

**បន្ទាយមានជ័យ ៖** សពពលករខ្មែរជាង៥០០នាក់ត្រូវបានអាជ្ញាធរថៃ បញ្ជូនមកស្រុកកំណើតវិញ ក្នុងរយៈពេលជាងកន្លះឆ្នាំ២០១៧នេះ បើតាមមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ លើកឡើងក្នុងសិក្ខាសាលានាព្រឹកថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ។ លោកស្រី ប៉ុក ណាឌី អភិបាលរងខេត្តបន្ទាយមានជ័យបានមានប្រសាសន៍ថា ខេត្តបន្ទាយមានជ័យគឺខេត្តមួយដែលជាប់ព្រំដែននិងប្រទេសថៃមានចំនួន ៥ស្រុកក្រុងមានច្រកអន្តរប៉ោយប៉ែតនិងច្រកតំបន់ព្រំដែនម៉ាឡៃ និងច្រកតំបន់ព្រំដែនបឹងត្រកួនដែលជាច្រកសេដ្ឋកិច្ចសម្រាប់ដោះដូរទំនិញរវាងប្រទេសកទាំងពីរ។ លោកស្រីបានបញ្ជាក់ថា ប្រជាពលរដ្ឋដែលរស់នៅតាមបន្ទាត់ព្រំដែនបានចេញចូលទៅរកការងារព្រឹកវិលល្ងាចជាមុខរបរមួយក្រោយពេលដែលភាគីថៃបានអនុវត្តន៍ច្បាប់ការងារប្រជាពលរដ្ឋបានបត់បង់ការងារតាមបន្ទាត់ព្រំដែនបាននាំចូលធ្វើដោយស្របច្បាប់នៅប្រទេសថៃ។

លោកទំទាវ ជូ គឹមអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃមានប្រសាសន៍ថា សិក្ខាសាលាស្តីពីកិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្មដែលធ្វើរយៈពេល២ថ្ងៃក្នុងគោលបំណង៖ ទី១-ពង្រឹងកិច្ចសហការរវាងស្ថាប័ននិងដៃគូពាក់ព័ន្ធដើម្បីឆ្លើយតបនិងបញ្ហាជួញដូរពលកម្ម ទី២-ជំរុញនិងពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីការបង្ក្រាបអំពើរជួញដូរមនុស្សនិងអំពើរធ្វើអាជីវកម្មផ្លូវភេទនិងបង្កើនការឆ្លើយតបចំពោះអំពើជួញដូរពលកម្ម និងទី៣-លើកកម្ពស់បង្កើនសមត្ថភាពនិងការគាំទ្រសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះការបញ្ជូនករណីនិងសេវាថៃទាំជនរងគ្រោះ។

លោកជំទាវបានបញ្ជាក់ថា យោងតាមរបាយការណ៍ជាងកន្លះឆ្នាំ២០១៧នេះ ថៃបានបញ្ជូនសាកសពពលករខ្មែរប្រជូនសាច់ញាតិមានប្រមាណជាង៥០០នាក់ហើយនៅអំឡុងឆ្នាំ២០១៤ថៃបានចាប់បញ្ជូនពលករខ្មែរយ៉ាងកំហុកមកកម្ពុជាវិញមានប្រមាណជាង២០ម៉ឺននាក់ហើយតាមទូរលេខពលករខ្មែរដែលធ្វើការងារនៅប្រទេសថៃទាំងមានច្បាប់និងមិនទាន់មានច្បាប់មានប្រមាណជាង១លានកន្លះ ក្រោយពេលថៃអនុវត្តន៍ច្បាប់ការងាររាជរដ្ឋាភិបាលកម្ពុជាបានធ្វើការងារដល់ពលករខ្មែរបានប្រមាណ៣០ភាគរយហើយ ៕ ដោយៈចន្ទ្រា

## ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧
## អន្តរសភាអាស៊ានផ្តោតលើសុខភាពស្ត្រីពលករចំណាកស្រុក

http://www.v-o-a-news.html 04 តុលា 2017 ម៉ែន គឹមសេង

វ៉ាស៊ីនតោន៖ បញ្ហាសុខភាពរបស់ស្ត្រីជាពលករចំណាកស្រុក ត្រូវបានក្រុមអ្នកតំណាងរាស្ត្រក្នុងបណ្តាប្រទេសអាស៊ានផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំង។ នៅក្នុងសម័យប្រជុំលើកទី៣៨របស់សមាគមអន្តរសភាអាស៊ាននៅក្នុងទីក្រុងម៉ានីល ប្រទេសហ្វីលីពីនកាលពីខែកញ្ញា ក្រុមអ្នកតំណាងរាស្ត្រជាស្ត្រីមកពីប្រទេសជាសមាជិកអាស៊ានទាំង១០ បានអនុម័តសេចក្តីសម្រេចមួយដែលស្នើឱ្យបង្កើតយន្តការមួយតាមដាននិងបង្កើនថវិការ ដើម្បីលើកកម្ពស់សុខភាពស្ត្រីជាពលការីនីចំណាកស្រុក។

អង្គការសហប្រជាជាតិបានរកឃើញថា ពលករិនីចំណាកស្រុកក្នុងតំបន់អាស៊ានទាំងមូល គឺមានជាង៣លាននាក់។ រីឯប្រទេសកម្ពុជាវិញ មានពលករិនីចំណាកស្រុកនៅក្នុងតំបន់សរុបជិត៧០០.០០០នាក់។ នេះបើតាមការបញ្ជាក់របស់លោកស្រី មូរ សុខហួរ។

ពលករិនីខ្មែរម្នាក់ឈ្មោះ ដាំ ស្រីគៀន ដែលធ្វើការនៅក្នុងប្រទេសថៃ ដោយមិនមានឯកសារគ្រប់គ្រាន់ត្រឹមត្រូវតាមច្បាប់បានបញ្ជាក់ពីការលំបាកក្នុងការទទួលបានសេវាសុខាភិបាល ដោយអ្នកស្រីត្រូវបង់ថ្លៃសេវាពេទ្យឯកជនក្នុងតម្លៃខ្ពស់។ អ្នកស្រី ដាំ ស្រីគៀន បានបន្ថែមថា៖ «ក្នុងការព្យាបាលហ្នឹងគឺយើងសន្សំពីកម្លាំងរបស់យើងក្នុងការដែលយើងធ្វើការហ្នឹងតែម្តង។ ...អីចឹងក្នុងការព្យាបាលរបស់នាងខ្ញុំ គឺមានការបង់ថ្លៃសេវាច្រើនព្រោះខ្ញុំអត់មានបៅកែត្រឹមត្រូវ គឺខ្ញុំចូលមកដោយខុសច្បាប់»។

ក្នុងខណៈពេលដែលពលករិនីម្នាក់ទៀត ដែលធ្វើការដោយស្របច្បាប់នៅក្នុងរោងចក្រនៅប្រទេសថៃ ទទួលបានសេវាព្យាបាល និងពិនិត្យសុខភាពយ៉ាងត្រឹមត្រូវនិងទៀងទាត់។ អ្នកស្រី ឃឹម ស្រីមុំ ពលករិនីរោងចក្រកាបូប បានបញ្ជាក់ថា៖ «នៅពេលដែលជួបបញ្ហាសុខភាពខ្ញុំមានពេទ្យមើលការខុសត្រូវ។ .... ក្នុងមួយខែជួនកាលត្រូវជួបពេទ្យពីរដងឬបីដងដែរ»។ ប៉ុន្តែពលករិនីចំណាកស្រុកខ្មែរលើកឡើងថា ពួកគេទទួលបានសេវាសុខភាពនៅទីនោះល្អជាងក្នុងប្រទេសកម្ពុជា៕

## ផលប៉ះពាល់ពីការធ្វើចំណាកស្រុកទៅលើកុមារ

http://www.rfa.org/khmer/news/ ដោយ អាស៊ីសេរី 2017-10-04

មូលនិធិសហប្រជាជាតិដើម្បីកុមារហៅកាត់ថា អង្គការយូនីសហ្វ (UNICEF) បានចេញរបាយការណ៍សិក្សាស្រាវជ្រាវសង្ខេបមួយ ស្តីពីផលប៉ះពាល់លើកុមារនៃការធ្វើចំណាកស្រុកក្នុងរាជធានីខេត្ត គោលដៅនៃប្រទេសកម្ពុជា។ របាយការណ៍នោះគឺជាការសិក្សាជំហានដំបូង ពីផលប៉ះពាល់ទៅលើកុមារ ទាំងកុមារដែលត្រូវឪពុកម្តាយទុកចោលនៅផ្ទះ និងកុមារដែលធ្វើចំណាកស្រុកទៅជាមួយពួកគេ។ អង្គការយូនីសហ្វក៏បានផ្តល់អនុសាសន៍មួយចំនួនទៅរដ្ឋាភិបាល និងភាគីពាក់ព័ន្ធមួយចំនួន ដើម្បីកែលម្អផលប៉ះពាល់ទាំងនោះ។ របាយការណ៍សង្ខេបកម្រាស់២០ទំព័រចេញផ្សាយកាលពីថ្ងៃទី២ ខែ តុលារបស់អង្គការយូនីសេហ្វ រកឃើញថា មានផលប៉ះពាល់ដោយប្រយោលពីការធ្វើចំណាកស្រុករបស់ឪពុកម្តាយ ទៅលើកុមារ ក្នុងនោះរួមមាន ផលប៉ះពាល់លើផ្នែកការរស់នៅ ការអប់រំ កិច្ចការពារកុមារសុខុមាលភាព ផ្លូវអារម្មណ៍ និងផ្លូវចិត្តកុមារ។

ក្នុងរបាយការណ៍នោះបង្ហាញដែរថា ដោយសារមានការកើនឡើងនូវចំណាកស្រុកក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះទើបយូនីសេហ្វ បានរៀបចំអោយមានការសិក្សានេះឡើង ដើម្បីវាយតម្លៃលើផលប៉ះពាល់លើកុមារ។ ការប្រមូលទិន្នន័យធ្វើឡើងតាមរយៈការពិភាក្សាក្រុមគោលដៅចំនួន២៩ មានអ្នកចូលរួមចំនួន២៥១នាក់ (មនុស្សពេញវ័យ ជាឪពុកម្តាយ អាណាព្យាបាល និងជីដូនជីតា ចំនួន៦២នាក់ និងកុមារ១៨៩នាក់ ទាំងកុមារធ្វើចំណាកស្រុកជាមួយឪពុកម្តាយ និងត្រូវទុកចោលតាមភូមិ) ដោយបានធ្វើនៅរាជធានីភ្នំពេញ និងខេត្តគោលដៅ មានបាត់ដំបង ប៉ោយប៉ែត បន្ទាយមានជ័យ ព្រៃវែង និងសៀមរាប។

ការសិក្សានេះបានរកឃើញជាថ្មីម្តងទៀត ដែលបញ្ជាក់អោយកាន់តែច្បាស់ថា ហេតុផលធំជាងគេដែលនាំអោយគ្រួសារធ្វើចំណាកស្រុកគឺហេតុផលហិរញ្ញវត្ថុគ្រួសារ។ ក្នុងចំណោមករណីសិក្សាចំនួន៧ គឺមានចំនួន៦ ដែល

មានបញ្ហាស្រដៀងៗគ្នា ក្នុងនោះគឺមានសមាជិកគ្រួសារម្នាក់ធ្លាក់ខ្លួនឈឺ ហើយប្រើប្រាស់ដីជាវត្ថុបញ្ចាំ ដើម្បីខ្ចីលុយមករ៉ាប់រងថ្លៃព្យាបាល។ ជារឿយៗ ពួកគេក៏បានខ្ចីពីម្ចាស់បំណុលមួយយកទៅសងម្ចាស់បំណុលមួយទៀត។ ក្នុងនោះពួកគេបានជំពាក់បំណុលចន្លោះពី ១ពាន់ (១.០០០) ទៅ១ម៉ឺន (១០.០០០) ដុល្លារ។

របាយការណ៍ដដែលរកឃើញថា កម្ពុជាជាប្រទេសហត្ថលេខី នៃអនុសញ្ញាស្តីពីសិទ្ធិកុមារដែលមាត្រា១២ ចែងថា គួរមានការពិចារណាពីទស្សនៈរបស់កុមារពាក់ព័ន្ធនឹងការសម្រេចចិត្ត ដែលប៉ះពាល់ដល់ជីវិត និងសុខុមាលភាពរបស់ពួកគេ។ ប៉ុន្តែកុមារភាគច្រើនក្នុងចំណោម ១៨៩នាក់ ដែលបានសាកសួរបញ្ជាក់ថាពុំមានការពិគ្រោះយោបល់ជាមួយកុមារឡើយនៅពេល ដែលឪពុកម្តាយរបស់ពួកគេសម្រេចចិត្តធ្វើចំណាកស្រុក។ ក្នុងនោះមានតែកុមារ២នាក់ត្រូវបានសាកសួរថាតើពួកគេចង់ទៅជាមួយឪពុកម្តាយរបស់គេឬអត់។ កុមារតូចៗជាច្រើនត្រូវបានទុកចោលអោយនៅជាមួយជីដូនជីតា ឬសាច់ញាតិខណៈកុមារអាយុលើស១៥ ឆ្នាំច្រើនតែធ្វើដំណើរទៅតាមឪពុកម្តាយ ឬសាច់ញាតិ ជាទូទៅពួកគេទៅធ្វើការដែរ។

ចំពោះកុមារដែលត្រូវទុកចោលច្រើនតែបោះបង់ការសិក្សា ជាពិសេសកុមារី ដោយហេតុថាពួកគេត្រូវរួមចំណែកធ្វើការងារផ្ទះ និងរកចំណូលជួយគ្រួសារ ឬមានចំណាប់អារម្មណ៍តិចតួច លើការរៀនសូត្រ។ ប៉ុន្តែក៏មានការអះអាងពីលទ្ធផលនៃការសិក្សាកាន់តែល្អរបស់កុមារដែរ ដោយសារជីវភាពពួកគេកើនឡើង។ ជាញឹកញយកុមារជួបប្រទះនឹងការគំរាមកំហែងចំពោះសុវត្ថិភាព ការបំពារបំពានផ្លូវភេទ និងផ្លូវកាយនៅពេលទុកអោយនៅជាមួយសាច់ញាតិ។ កុមារតូចៗរហូតដល់អាយុ២ឆ្នាំធ្លាប់ត្រូវទុកចោលអោយនៅតែឯងយូរអាចជាច្រើនថ្ងៃ ច្រើនសប្តាហ៍ ទាំងដឹងថាអាចមានគ្រោះថ្នាក់សម្រាប់ពួកគេ ប៉ុន្តែត្រូវពន្យល់ថាគឺដោយសារពុំអាចរកអ្នកណាអោយជួយមើលបាន។ ពួកគេក៏ទទួលរងផលប៉ះពាល់អវិជ្ជមានជាច្រើនខាងផ្លូវអារម្មណ៍ និងផ្លូវចិត្តដូចជាការរំខានទំនាក់ទំនងរវាងឪពុកម្តាយ និងកូនជាដើម។

ត្រង់ចំណុចនេះ ចំពោះអ្នកសិក្សាការអភិវឌ្ឍសង្គមជាពិសេស លោក បណ្ឌិត កែម ឡី កាលលោកនៅមានជីវិតធ្លាប់បានលើកឡើងថា ភូមិដែលមានអ្នកចំណាកស្រុកច្រើនគឺជាភូមិយាយចាស់មានកូនខ្ចី ពោលគឺបន្ទុកថែទាំកុមារត្រូវធ្លាក់ទៅលើជីដូនជីតាវ័យចាស់ និងមានជំងឺប្រចាំកាយ៖ «ភាគច្រើនយុវជនគាត់ចំណាកស្រុកគាត់ទុកកូនៗនៅស្រុកឲ្យយាយៗ តាៗជួយមើល ជាបន្ទុកមួយ។ បើកូននោះផ្ញើលុយមកមិនអីទេ ប៉ុន្តែបើកូនខ្លះគាត់អត់មានលទ្ធភាពផ្ញើលុយមកទេ យាយតានោះលំបាកជាមួយចៅហើយ ដែលនេះហើយទាក់ទងការអប់រំ»។

ចំណែកកុមារទៅតាមឪពុកម្តាយរបាយការណ៍របស់អង្គការយូនីសេហ្វដដែលបង្ហាញថា បញ្ហាធំរបស់ពួកគេគឺការសិក្សា បញ្ហាការពារកុមារ និង ពលកម្មកុមារ។ កុមារដែលចំណាកស្រុកមកកាន់ទីក្រុង ជួបការលំបាកក្នុងការចុះឈ្មោះចូលរៀនឡើងវិញដោយសារបញ្ហាសំបុត្រកំណើត និងកម្រៃសេវាក្រៅផ្លូវការ។ នៅពេលបានចូលរៀនកុមារក្នុងគ្រួសារក្រីក្រជួបការលំបាកដោយសារចំណាយខ្ពស់ក្នុងការបង់ថ្លៃសាលារៀនក្រៅផ្លូវការ។ ការសិក្សាក្នុងឆ្នាំ២០១២ បានបង្ហាញថា កុមារពុំមានលទ្ធភាពបង់ថ្លៃសាលានឹងត្រូវគេធ្វើអោយអាម៉ាស់មុខ ហាមឃាត់មិនអោយចូលរួមពេញលេញក្នុងថ្នាក់រៀន ឬអាចប្រឡងមិនជាប់ដើម្បីបានឡើងថ្នាក់។

ចំណែកកុមារដែលចំណាកស្រុកទៅប្រទេសថៃជួបប្រទះនឹងបញ្ហាមួយចំនួនក្នុងការទទួលបានការអប់រំដែរ បញ្ហាទាំងនោះរួមមានខ្វះខាតឯកសារត្រឹមត្រូវ ភាពចាំបាច់ក្នុងការរកប្រាក់ចំណូល និងការប្រែប្រួលនៃ រយៈពេលស្នាក់នៅ និងភាពមិនស្របច្បាប់។ កុមារដែលមានអាយុពី១៥ ដល់១៨ឆ្នាំពិបាកនឹងបានបន្តការសិក្សា នៅពេលដែលវ័យរបស់ពួកគេសមស្របនឹងធ្វើការងារពេញម៉ោង។

ករណីខ្លះទៀតកុមារដែលសម្រេចចិត្តធ្វើចំណាកស្រុកតែឯងគឺកាន់តែប្រឈមនឹងការកេងប្រវ័ញ្ច និងគ្រោះថ្នាក់ផ្សេងៗ។ ជាមួយគ្នានេះកុមារមានអាយុច្រើនត្រូវទៅធ្វើការងារសំណង់ដែលត្រូវចាត់ទុកថាជាការងារប្រឈមនឹងគ្រោះថ្នាក់។ កុមារដែលទៅធ្វើការនៅប្រទេសថៃ ជួបប្រទះបញ្ហាមួយចំនួនទៀតដូចជាការបង្ខំអោយសុំទាន ធ្វើការងារដោយគ្មានច្បាប់ត្រូវតម្រួតថៃចាប់ខ្លួន បញ្ជូនមកវិញ ដោយបែកខ្ញែកពីឪពុកម្តាយ កុមារខ្លះត្រូវបញ្ជូនមកវិញភ្លាមខ្លះទៀតត្រូវ ឃុំក្នុងមណ្ឌល ពី៨ខែទៅជាង១ឆ្នាំ។

ក្នុងមណ្ឌលទាំងនោះមានលាយឡំដោយមនុស្សអនាថាដែលពេញវ័យ ហើយបុគ្គលិកក្នុងមណ្ឌលត្រូវចាត់ទុកជាអ្នកត្រួតពិនិត្យកុមារ មិនមែនអ្នកថែទាំកុមារឡើយ ដែលពេលខ្លះក៏មានករណីរំលោភបំពានផ្លូវកាយ និងផ្លូវភេទកុមារកើតឡើង។ កុមារជាច្រើនត្រូវបញ្ជូនមកកម្ពុជាវិញ ហើយត្រូវបានគេនាំទៅស្នាក់នៅមណ្ឌលសំចតនៅប៉ោយប៉ែត ដែលទីនោះមានការខិតខំជួយស្វែងរកឪពុកម្តាយ។

ទាក់ទិននឹងផលប៉ះពាល់ពីការធ្វើចំណាកស្រុកមកលើកុមារនេះនៅមិនទាន់មានលើកឡើងណាមួយពីមន្រ្តីរដ្ឋាភិបាលនៅឡើយទេ។

កន្លងទៅទាំងលោកនាយករដ្ឋមន្រ្តី ហ៊ុន សែន និងមន្រ្តីរដ្ឋាភិបាលពាក់ព័ន្ធគឺតែងលើកឡើងពីអត្ថប្រយោជន៍នៃការធ្វើចំណាកស្រុករបស់ពលករខ្មែរ ជាពិសេសចំណាកស្រុកទៅក្រៅប្រទេសខណៈការងារក្នុងស្រុកខ្វះខាត និងប្រាក់ខែទាប។

អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក ហេង ធ្លាប់លើកឡើងថា ការគ្រប់គ្រងចំណាកស្រុកបានល្អគឺជាអត្ថប្រយោជន៍៖ «ចំណាកស្រុកមិនមែនជាចំណុចអវិជ្ជមានទេ បើគ្រប់គ្រងបានល្អហើយពេលនេះប្រទេសក្នុងតំបន់ជាច្រើនកំពុងប្រកួតគ្នាដើម្បីមានការផ្លាស់ប្តូរកម្លាំងពលកម្ម»។

សម្រាប់អង្គការយូនីសេហ្វដែលបង្ហាញអោយឃើញពីផលប៉ះពាល់ចំពោះកុមារនេះក៏បានលើកឡើងពីសេវាកម្មមួយចំនួនដែលអង្គការសង្គមស៊ីវិលបានផ្តល់កុមាររងគ្រោះ ដែលរួមមានសេវាមណ្ឌលសំចត ការប្រឹងប្រែងអោយពលករចំណាកស្រុកបានច្បាប់អនុញ្ញាតបំពេញការងារ និងការជួយសង្គ្រោះកុមារជាដើម។ លើសពីនេះរបាយការណ៍ដដែលក៏បានលើកស្នើនូវអនុសាសន៍មួយចំនួនទាក់ទិននឹងការគ្រប់គ្រងចំណាកស្រុករួមមានរដ្ឋាភិបាលតាមរយៈក្រសួងពាក់ព័ន្ធគួរផ្តល់អាទិភាពប្រមូលនិងវិភាគទិន្នន័យពីជនចំណាកស្រុក និងកូនៗរបស់ពួកគេនៅពេលដែលពុំមានតួលេខច្បាស់លាស់ពីពួកគេនៅឡើយ ពន្លឿនវិសាលភាពកិច្ចគាំពារសង្គម ដោយផ្តោតលើគ្រួសារក្រីក្រដើម្បីកាត់បន្ថយការជាប់បំណុលដោយសារការចំណាយខ្ពស់លើសេវាសុខភាព ពិនិត្យ និងរៀបចំ ឡើងវិញពីនីតិវិធីកំណត់គ្រួសារក្រីក្រ បង្កើនចំនួនមន្ត្រីសង្គមកិច្ច តាមស្រុក និងឃុំ ដើម្បីកំណត់កុមារងាយរងគ្រោះ និងពិនិត្យលទ្ធភាពផ្តល់សេវាទារកដ្ឋានបម្រើដល់គ្រួសារចំណាកស្រុក។

ស្របគ្នានេះក្រសួងអប់រំគួរធានាផ្តល់ព័ត៌មានពិតពីបែបបទក្នុងការចុះឈ្មោះសិស្ស និងត្រូវបត់បែនជួយអោយកុមារចំណាកស្រុកអាចចុះឈ្មោះចូលរៀន ពង្រឹងប្រព័ន្ធតាមដានទីតាំងសិស្ស ពង្រឹងសេវាពិសេសអប់រំយ៉ាងហោចកម្រិតអប់រំមូលដ្ឋានសម្រាប់កុមារចំណាកស្រុកអាយុពី១៥ ដល់ ១៨ឆ្នាំ និងទទួលស្គាល់សាលារៀនសហគមន៍នៅតាមតំបន់របស់ជនចំណាកស្រុក។ ចំពោះទីភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលវិញគឺគួរគាំទ្រគំនិតផ្តួចផ្តើម ស្រាវជ្រាវថ្មីៗ ដើម្បីបំពេញភាពខ្វះខាតចំណេះដឹងពីផលប៉ះពាល់លើកុមារចំណាកស្រុក គាំទ្រក្រុមប្រឹក្សាឃុំកំណត់រកកុមារងាយរងគ្រោះ ពិនិត្យតាមដានសុខុមាលភាពរបស់ពួកគេដូច

ជាផ្តល់ជំនួយសង្គម និងការពារកុមារ កសាងសមត្ថភាព ក្រសួងសង្គមកិច្ច ដើម្បីផ្តល់សេវាសុខុមាលភាពសង្គមនៅមូលដ្ឋាន៕

## តុលាការ ឃុំខ្លួន បុរស ៣នាក់ ពាក់ព័ន្ធរឿង យកលុយពី កុមារៗ និងអ្នកសុំទាន

http://ann.com.kh/site/news/15107.html ថ្ងៃព្រហស្បតិ៍, 5 ខែតុលា 2017 1:43 ល្ងាច

ភ្នំពេញ៖ យោងតាមប្រភពពី សមត្ថកិច្ចកងរាជអាវុធហត្ថបានឱ្យដឹងថា នៅព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧នេះ លោក ពេជ្រ វិជ្ជាធរ ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាបង្គាប់ឱ្យឃុំខ្លួនសរុប ៣នាក់ ដែលបាន ដើរប្រមូលលុយពីកុមារៗ និងអ្នកសុំទាននៅតាមស្តុប នៅពន្ធនាគារជាបណ្តោះអាសន្នហើយ។ យោងតាមប្រភពដដែលបានបញ្ជាក់ថា លោក ហោ លីណា ជាតំណាងអយ្យការកាន់សំណុំរឿង បានពិនិត្យ និងចោទប្រកាន់លើ៖ -ទី១ឈ្មោះ យុត នឹម ហៅ តាលឹម ភេទប្រុស អាយុ ៥៥ឆ្នាំ ជាបុគ្គលិកជាប់កិច្ចសន្យា មន្ទីរសង្គមកិច្ច-ទី២ឈ្មោះ ហ៊ឹង សារ៉ូម ហៅ តារ៉ុំ ភេទប្រុសអាយុ ៤២ឆ្នាំ ជាបុគ្គលិកជាប់កិច្ចសន្យា មន្ទីរសង្គមកិច្ច -និងទី៣ឈ្មោះ សាន សិត ភេទប្រុស អាយុ៤១ឆ្នាំ អតីតជាអ្នកសុំទាន បច្ចុប្បន្នជាអ្នកដើរប្រមូលលុយពីអ្នកសុំទានតាមភ្លើងស្តុប ឲ្យទៅឈ្មោះ យុត នឹម ហៅតាលឹម និងឈ្មោះ ហ៊ឹង សារ៉ូម ហៅ តារ៉ុំ។

ជននេះត្រូវជាប់ចោទ ចំនួន២បទ៖ -ទី១ បទ ញុះញង់អនីតិជនឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម -និងទី២ បទ កំហែងយកដោយមានស្ថានទម្ងន់ទោស ទាក់ទងទៅនឹងជនរងគ្រោះ ប្រព្រឹត្តនៅរាជធានីភ្នំពេញ យោងតាមមាត្រា ៣៤៤ មាត្រា ៣៦៣ និងមាត្រា ៣៦៥ នៃក្រមព្រហ្មទណ្ឌ។

សូមបញ្ជាក់ថា កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៧កន្លងទៅ កម្លាំងកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានបញ្ជូនបុរស ទាំង ៣នាក់ខាងលើ ទៅកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការបន្តតាមនីតិវិធីពាក់ព័ន្ធករណី កេងប្រវ័ញ្ចពលកម្មកុមារ និងប្រើហិង្សាគម្រាមកុមារឱ្យដើរសុំទាន។

បុរសទាំង ៣នាក់ខាងលើត្រូវបានសមត្ថកិច្ចកងរាជអាវុធហត្ថរាជធានីភ្នំពេញ សហការជាមួយ លោកស្រី មុំ ចាន់ដានី ជាប្រធានស្តីទី នៃមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងស្តារនិតិសម្បទា រាជធានីភ្នំពេញ ឃាត់ខ្លួនកាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៧ កន្លងទៅ ក្រោយពីរកឃើញថាពួកគេបាន ទទួលយកផលប្រយោជន៍ពីអ្នកសុំទាន និងជានេកក្នុងផ្តល់ព័ត៌មានដល់អ្នកសុំទាន ធ្វើការគេចខ្លួនពីការ ចុះបង្ក្រាប របស់មន្ទីរសង្គមកិច្ច និងសមត្ថកិច្ចផងដែរ។ នៅចំពោះមុខសមត្ថកិច្ច បុរសទាំង ៣នាក់ បានសារភាពថា ពួកគាត់ពិតជាបានធ្វើសកម្មភាពប្រមូលលុយ ពីអ្នកសុំទានរៀងរាល់ថ្ងៃ នៅតាមភ្លើងស្តុប ដោយអ្នកសុំទានម្នាក់ត្រូវបង់ ១ម៉ឺន ទៅ ១២,០០០ រៀលក្នុង១ថ្ងៃ។

ដោយមានឈ្មោះសាន សិត ជាអ្នកដើរប្រមូលលុយប្រចាំថ្ងៃ និងក្នុងមួយអាទិត្យ ទើបយកលុយប្រគល់ឲ្យឈ្មោះ តាលឹម និងឈ្មោះ តារ៉ុំ ម្តង។ ឈ្មោះ តាលឹម យកចំណែកអ្នកដើរសុំនៅស្តុបអាងទឹក ស្តុបពេទ្យចិន ស្តុបផ្សារដើមគោ និងភូមិសាស្ត្រក្បែរគ្នា។ ឈ្មោះ តារ៉ុំ យកចំណែកអ្នកដើរសុំនៅស្តុបកាណាឌីយ៉ា ស្តុបបូកគោ និងប៉ែកខាងមាត់ទន្លេ។

ការយកលុយរបស់ តាលឹម និងតារ៉ុំ ពីអ្នកសុំទាននេះ ជាថ្នូរជាមួយនឹងការផ្តល់ព័ត៌មាន នៅពេលណាដែលមន្ទីរសង្គមកិច្ច និងសមត្ថកិច្ចចុះបោសសំអាតប្រមូលអ្នកសុំទាន អ្នកញៀនថ្នាំ និងក្មេងអានាថាតាមដងផ្លូវ តែបើ

ពួកអ្នកសុំទានទាំងនោះ មិនព្រមបង់លុយឱ្យទេ ឈ្មោះ សាន សិត គម្រាមថា នឹងរាយការណ៍ឱ្យខាងមន្ទីរសង្គមកិច្ចនិងសមត្ថកិច្ច ចុះចាប់ពួកគេ ក្នុងនោះក៏មាន អ្នកសុំទានជាច្រើន ពិតជាត្រូវបាន ឈ្មោះ សាន សិត រាយការណ៍ឱ្យ តាលឹម និងតារុំ នាំក្រុមការងារសង្គមកិច្ចចុះបង្ក្រាបមែន ពេលដែលពួកគេមិនព្រមបង់លុយតាមការទាមទារ៕
ដោយៈ ឡុក សំរិត

## កម្មករខ្មែរ4នាក់ បើករថយន្តជួបគ្រោះថ្នាក់ចរាចរ ស្លាប់2នាក់ របួសធ្ងន់2 នាក់

http://pheaktraprak.com/archives/ By เพียะตรา ประ October 5, 2017

កម្មករខ្មែរ 4នាក់ បើករថយន្តមួយគ្រឿងជ្រុលទៅបុកឡានដឹកទំនិញធុនធំមួយគ្រឿងបណ្ដាលឲ្យភ្លើងឆេះស្លាប់ 2នាក់នៅខេត្តរ៉ាក់យ៉ងប្រទេសថៃ។ កាលពីវេលាម៉ោង 02យប់ ថ្ងៃព្រហស្បតិ៍ ទី05 ខែតុលា ឆ្នាំ2017 មានករណីគ្រោះថ្នាក់ចរាចររវាងរថយន្តប៊ីកអាប់ម៉ាក់Toyota មួយបាងមួយគ្រឿង បានបុកគ្នាជាមួយរថយន្តដឹកទំនិញធុនធំមួយគ្រឿង បណ្ដាលអោយអគ្គិភ័យឆាបឆេះរថយន្តធ្វើឲ្យមានមនុស្សស្លាប់និងរងរបួសនៅនិងកន្លែងកើតហេតុ។ ហេតុការណ៍នេះបានកើតឡើងនៅត្រង់ចំណុចបរិវេណទួលបាងប៉ាកកុង ផ្លូវជាតិលេខ13 ក្បែរមាត់ផ្លូវលេខ7-8 ស្ថិតនៅក្នុងភូមិ1 ឃុំម៉ាខាយ,ស្រុក និឃុំផាត់តាណា,ខេត្តរ៉ាក់យ៉ង នៅនិងកន្លែងកើតហេតុសមត្ថកិច្ចថៃបានប្រទះឃើញរថយន្ត Toyota មួយបាងពាក់ស្លាកលេខ(ฆฉ5483) កំពុងស្ថិតក្នុងស្ថានភាពភ្លើងឆេះយ៉ាងសន្ធោសន្ធៅ សមត្ថកិច្ចហៅ ពន្លត់អគ្គិភ័យមកបាញ់ទឹកពន្លត់អស់រយៈពេលជាង15នាទីទើបភ្លើងរលត់។ ក្នុងការត្រួតពិនិត្យក្នុងរថយន្តដែលត្រូវភ្លើងឆេះសមត្ថកិច្ចប្រទះឃើញសាកសពមនុស្សស្លាប់នៅក្នុង2នាក់ សមត្ថកិច្ចបឹងយកសាកសពចេញមកក្រៅដើម្បីត្រួតពិនិត្យ។ ប្រភពបឋមបានអោយដឹងថាជនរងគ្រោះនិងអ្នកស្លាប់ជាជនជាតិកម្ពុជា មានឈ្មោះដូចខាងក្រោម។

1.ឈ្មោះមៀន ជា ភេទប្រុស អាយុ 33ឆ្នាំ សញ្ជាតិខ្មែរ(ត្រូវភ្លើងឆេះស្លាប់)
2.ឈ្មោះនិត ជា ភេទប្រុស អាយុ 36ឆ្នាំ សញ្ជាតិខ្មែរ(ត្រូវភ្លើងឆេះស្លាប់)
3.ឈ្មោះផល ភេទប្រុស អាយុ 36ឆ្នាំ សញ្ជាតិខ្មែរ (រងរបួសស្រាល)
4.ឈ្មោះសួន ចាន់ថា ភេទប្រុស អាយុ 33ឆ្នាំ សញ្ជាតិខ្មែរ (រងរបួសត្រូវភ្លើងតាមរាងកាយ)

ជនរងគ្រោះទាំងពីរនាក់ត្រូវបានភ្នាក់ងារសង្គ្រោះឃុំបាត់តាណាធ្វើការបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្តរ៉ាក់យ៉ង ចំណែកឯសាកសពអ្នកស្លាប់ត្រូវសមត្ថកិច្ចបញ្ជូនយកទៅរក្សាទុកនៅមន្ទីរពេទ្យដើម្បីធ្វើកោសលវិច័យម្តងទៀត។ ចំណែកឯមូលហេតុដែលបង្កឲ្យកើតគ្រោះថ្នាក់ចរាចរលើកនេះសមត្ថកិច្ចថៃកំពុងធ្វើការស្រាវជ្រាវ។

## គណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជា បន្តផ្តល់លិខិតឆ្លងដែនជូនបងប្អូនពលករខ្មែរនៅប្រទេសថៃ

http://pheaktraprak.com/archives/ By เพียะตรา ประ October 4, 2017

គណៈកម្មការផ្តល់ភាពស្របច្បាប់កម្ពុជាប្រចាំប្រទេសថៃ អំពាវនាវដល់ពលករខ្មែររស់នៅក្នុងប្រទេសថៃប្រញាប់រួសរាន់មកស្នើសុំដកលិខិតឆ្លងដែនការងារ។

ទីក្រុងបាងកក÷កាលពីថ្ងៃពុធ ទី04 ខែតុលា ឆ្នាំ2017នេះ គណៈកម្មការផ្តល់ភាពស្របច្បាប់កម្ពុជាប្រចាំប្រទេសថៃ បានបន្តផ្តល់លិខិតឆ្លងដែនជូនដល់បងប្អូនពលករខ្មែរ ដែលកំពុងរស់នៅធ្វើការក្នុងប្រទេសថៃ តាមនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការខិតខំប្រឹងប្រែងជួយសម្រួលដល់បងប្អូនពលករកម្ពុជាដែលកំពុងធ្វើការនិងរស់នៅក្នុងប្រទេសថៃ បានធ្វើការប្រកាសអំពាវនាវដល់បងប្អូនពលករខ្មែរ ដែលមិនបានទទួលប៉ាស្ព័រពី

គណៈកម្មការរដល់ភាពស្របច្បាប់ អោយប្រញាប់ប្រញាល់រួសរាន់មកសរសេរពាក្យស្នើសុំដកប៉ាស្ព័រអោយបានគ្រប់គ្នាដើម្បីយកទៅវ៉ៃត្រាវីសារនិងស្នើសុំច្បាប់អនុញ្ញាតធ្វើការអោយបានត្រឹមត្រូវតាមច្បាប់របស់ប្រទេសថៃ។

ក្នុងនោះដែរក៏មានបងប្អូនពលករខ្មែរមួយចំនួនធំបានមកទទួលដកប៉ាស្ព័រការងារ ពីក្រុមគណៈកម្មការផ្តល់ភាពស្របច្បាប់ នៅក្នុងបរិវេណស្ថានទូតកម្ពុជាប្រចាំទីក្រុងបាងកក ប្រទេសថៃជារៀងរាល់ថ្ងៃផងដែរ។ ព្រោះបងប្អូនពលករខ្មែរដែលមិនទាន់បានត្រួតសញ្ជាតិប្តូរយកប៉ាស្ព័រ គណៈកម្មការធ្វើប៉ាស្ព័រកម្ពុជានិងចាប់ផ្តើមបើកធ្វើប៉ាស្ព័រជូនបងប្អូននាពេលឆាប់ខាងនេះ នៅតាមទីតាំងដែលគណៈកម្មការបានប្រកាសកាលពីពេលថ្មីកន្លងទៅនេះ។ អាស្រ័យហេតុនេះសូមបងប្អូនពលករខ្មែរទាំងអស់រងចាំសេចក្តីប្រកាសម្តងទៀតពីខាងភាគីថៃ។

## នាំដីកាចាប់ខ្លួនម្ចាស់ក្រុមហ៊ុនទទួលរត់ការឯសារនិងនាំចូលពលករMOU

http://pheaktraprak.com/archives/ By เพียะตรา ประ October 5, 2017

សមត្ថកិច្ចក្រសួងការងារថៃ នាំដីកាចាប់ខ្លួនស្ត្រីម្នាក់ជាម្ចាស់ក្រុមហ៊ុននាំចូលពលករបរទេស ពីបទក្លែងបន្លំឯកសារខុសច្បាប់ កាលពីពេលថ្មីកន្លងទៅនេះ សមត្ថកិច្ចថៃក្រសួងការងារថៃ បាននាំដីកាចាប់ខ្លួនម្ចាស់ក្រុមហ៊ុនទទួលរត់ការឯសារនិងធ្វើប៉ាស្ព័រជូនពលករបរទេស បន្ទាប់ពីម្ចាស់ក្រុមហ៊ុននេះលួចបន្លំឯកសាររបស់អ្នកជួលយកទៅដើររឿងធ្វើឯកសារជូនពលករបរទេសខុសច្បាប់ប្រមាណជាង100នាក់ ដោយគ្មានច្បាប់អនុញ្ញាតចេញពីម្ចាស់ដើម។

ករណីឃាត់ខ្លួនស្ត្រីម្ចាស់ក្រុមហ៊ុននាំចូលពលករបរទេសខាងលើនេះបានកើតឡើង បន្ទាប់ពីមាននិយោជកថៃ បានដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចក្រសួងការងារថៃ អោយធ្វើការស៊ើបអង្កេតលើម្ចាស់ក្រុមហ៊ុនទទួលរត់ការឯសារពលករបរទេសមួយ ដោយសារម្ចាស់ក្រុមហ៊ុននោះបានលួចបន្លំឯកសាររបស់អ្នកជួល យកទៅដើររឿងស្នើរសុំតច្បាប់អនុញ្ញាតការងារជូនពលករបរទេសខុសច្បាប់ប្រមាណជាង100 នាក់ ធ្វើអោយម្ចាស់ឯកសាររងផលប៉ះពាល់យ៉ាងធ្ងន់ដល់ម្ចាស់ឯកសារដែលមកជួលក្រុមហ៊ុននេះអោយរត់ការជូន។

ម្ចាស់ក្រុមហ៊ុនខាងលើត្រូវគេថាឈ្មោះ งามพรรณ มหาบุญนาค (ចេរង៉ាម) ជាម្ចាស់ក្រុមហ៊ុនរត់ការឯសារពលករបរទេសនិងធ្វើប៉ាស្ព័រMOU នៅក្នុងប្រទេសថៃ បច្ចុប្បន្នសមត្ថកិច្ចក្រសួងការងារថៃកំពុងបើកការស៊ើបអង្កេតលើក្រហ៊ុននេះ ដើម្បីតាមចាប់ខ្លួនបក្សពួកនៅក្នុងក្រុមហ៊ុនខាងលើយកមក ផ្តន្ទាទោសតាមផ្លូវច្បាប់។

## ថៃបង្ក្រាបទីតាំងម៉ាស្សាផ្លូវភេទ ឃាត់ខ្លួនបាននារីឡាវ 31នាក់

http://pheaktraprak.com/archives/ By เพียะตรา ประ October 4, 2017

កម្លាំងអាជ្ញាធរមូលដ្ឋានថៃសហការជាមួយកម្លាំងតម្រួតទាហាន ចុះបង្ក្រាបទីតាំង បំរើសេវាកម្មផ្លូវភេទ ឃាត់ខ្លួនបាននារីសញ្ជាតិឡាវ31នាក់។ កាលពីយប់ថ្ងៃអង្គារទី03 ខែតុលា ឆ្នាំ2017 សមត្ថកិច្ចថៃ ស្រុក ស៊ីរាចឆា ខេត្តឈុនបុរី ប្រទេសថៃ បានដឹកនាំកម្លាំងតម្រួតទាហានប្រមាណជាង50នាក់ ចុះបង្ក្រាបទីតាំងបម្រើសេវាកម្មផ្លូវភេទមួយកន្លែង ស្ថិតនៅក្នុងស្រុកស៊ីរាចឆា ក្នុងការចុះបង្ក្រាបសមត្ថកិច្ចថៃ ឃាត់ខ្លួនបានស្ត្រីមេខ្លោងជនជាតិថៃម្នាក់ និងនារីសញ្ជាតិឡាវ ចំនួន 31នាក់។

ប្រភពពីសមត្ថកិច្ចថៃ បានឲ្យដឹងថាកន្លែងបើកសេវាផ្លូវភេទនេះបានលួចលាក់បើកអស់រយៈជាច្រើនខែមកហើយ ដោយមាននារីជនជាតិឡាវអាយុចាប់ពី 25ឆ្នាំដល់ 35ឆ្នាំជាអ្នកទទួលភ្ញៀវនៅក្នុងហាងលើនេះ សមត្ថកិច្ចបាននាំខ្លួននារីទាំងអស់យកទៅធ្វើការសាកសួរនៅអធិការដ្ឋានប៉ូលិសប៉ុស្តិ៍ស៊ីរាចឆាដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧

## លោក ហ៊ុន ម៉ានី ចុះសួរសុខទុក្ខពលករខ្មែរ កំពុងបម្រើការនៅប្រទេសថៃ និងប្រាប់ពីការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា

http://freshnewsasia.com/index.php/en/localnews/ 2017-10-08

**(ថៃ)៖** លោក ហ៊ុន ម៉ានី តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៧នេះ អមដំណើរដោយថ្នាក់ដឹកនាំ និងក្រុមការងារជាច្រើនរូប ពិតជាទទួលជោគជ័យធំធេងណាស់ ចំពោះវត្តមានរបស់លោក តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ និងគណៈប្រតិភូក្នុងដំណើរទស្សនៈកិច្ច នៅប្រទេសថៃ និងសាកសួរសុខទុក្ខ សំណេះសំណាល ដល់បងប្អូនពលករខ្មែរប្រមាណជាង៤០០នាក់ ដែលកំពុងបម្រើការងារនៅក្រុមហ៊ុន CPF Co.,Ltd ស្ថិតនៅខេត្តឆាក់ឈើងសៅ។

លោក ហ៊ុន ម៉ានី បានលើកឡើងអំពីកិច្ចគាំពារ និងការយកចិត្តទុក្ខដាក់យ៉ាងខ្លាំងក្លារបស់ រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយសម្តេចតេជោ ហ៊ុន សែន ចំពោះបងប្អូនពលករខ្មែរ ដែលនៅធ្វើការងារនៅក្រៅប្រទេស ជាពិសេសស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា ដែលបានខិតខំសម្របសម្រួលបំពេញឯកសារស្របច្បាប់ ជូនដល់ពលករខ្មែរ ដែលមិនទាន់មានភាពស្របច្បាប់ក្នុងការធ្វើការងារ។

លោក ហ៊ុន ម៉ានី បន្តថា រាជរដ្ឋាភិបាល នឹងបន្តសម្របសម្រួលជូនដល់ពលករខ្មែរ រហូតដល់ទទួលបានភាពស្របច្បាប់គ្រប់ៗគ្នា។

បន្ទាប់ពីបញ្ចប់កម្មវិធីសំណេះសំណាល លោក ហ៊ុន ម៉ានី បានបន្តដឹកនាំគណៈប្រតិភូ អញ្ជើញជួបសួរសុខទុក្ខដោយផ្ទាល់ បងប្អូនពលករខ្មែរ មានភាពរីករាយ រាក់ទាក់ ចំពោះប្រតិភូកម្ពុជា ព្រមទាំងបាននាំគ្នាថតរូបជុំគ្នាយ៉ាងសប្បាយរីករាយ និងគាំទ្រចំពោះដំណើរទស្សនៈកិច្ចនាពេលនេះយ៉ាងក្រៃលែង៕

## ការបញ្ជាក់អត្តសញ្ញាណជូនពលករខ្មែរ នៅថៃ នឹងធ្វើឡើងសប្តាហ៍ក្រោយនេះហើយ

http://kleykley.sabay.com.kh/article/ សៅរ៍, 7 តុលា 2017 16:30

ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ បានចេញសេចក្តីប្រកាសកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៧ថា គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នឹងបើកយុទ្ធនាការបញ្ជាក់អត្តសញ្ញាណ ជូនពលករកម្ពុជា ចាប់ពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧។

ការបញ្ជាក់អត្តសញ្ញាណ គឺដើម្បីឲ្យពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ទទួលបានលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC)៕

ព្រះរាជាណាចក្រកម្ពុជា

ស្ថានទូតព្រះរាជាណាចក្រកម្ពុជា
ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ៦៧២ /១៧/សកប៤

# សេចក្តីប្រកាសព័ត៌មាន

យោងសេចក្តីជូនដំណឹងរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ សូមជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករទាំងអស់ជ្រាបថា គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នឹងបើកយុទ្ធនាការបញ្ជាក់អត្តសញ្ញាណជូនបងប្អូនពលករកម្ពុជា ដើម្បីទទួលបានលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) ចាប់ពី**ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧** តទៅ ដែលមានព័ត៌មានដូចខាងក្រោម៖

**ក. ទីកន្លែង ថ្ងៃម៉ោងធ្វើការ និងតម្លៃសេវា សម្រាប់ការបញ្ជាក់អត្តសញ្ញាណ**

**ក-១. ទីកន្លែង**

១-ការិយាល័យទីក្រុងបាងកក៖ អាសយដ្ឋាន អ៊ីមផើរៀល វើល ឡាតព្រាវ (Imperial World Ladphrao) ជាន់ទី៤, លេខ២៥២៥, ច្រក៨១-៨៣, ផ្លូវឡាត់ព្រាវ, សង្កាត់ចៅឃុនស៊ីង, ខណ្ឌវ៉ាងថុងឡាង ទីក្រុងបាងកក ១០៣១០

២-ការិយាល័យខេត្តរ៉ាក់យ៉ង៖ អាសយដ្ឋាន ផ្សារអូថប់ម៉ាយ៉ង (OTOP MA YONG) -២០១ ភូមិ៧, ឃុំម៉ាខាមឃូ, ស្រុកនិឃុំផាត់តាណា, ខេត្តរ៉ាក់យ៉ង ២១១៨០

៣-ការិយាល័យខេត្តសុងក្លា៖ អាសយដ្ឋាន ផ្សារហ្វុកទៀន(Fuk Thian), ៩៩ភូមិ៣, ឃុំខ្លងហែរ, ស្រុកហាត់យៃ, ខេត្តសុងក្លា

**ក-២. ថ្ងៃម៉ោងធ្វើការ៖ ថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍**

- បាងកក ៖ ព្រឹកម៉ោង ១០:០០ ដល់ ៦:៣០ ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៥:០០ ល្ងាច
- ខេត្តរ៉ាក់យ៉ង ៖ ព្រឹកម៉ោង ៨:៣០ ដល់ ៥:០០ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៣:៣០ ល្ងាច
- ខេត្តសុងក្លា ៖ ព្រឹកម៉ោង ៨:៣០ ដល់ ៥:០០ ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៣:៣០ ល្ងាច

**ក-៣. តម្លៃសេវា**

តម្លៃសេវាផ្លូវការក្នុងការធ្វើ និងបើកផ្តល់សំណុំឯកសារក្នុងថ្ងៃតែមួយដែលភាគីថៃ និងកម្ពុជាបានឯកភាពគ្នា គឺ ២ ៣៥០(ពីរពាន់បីរយហាសិប)បាត។

ខ. ឯកសារតម្រូវសម្រាប់ពលករមកស្នើសុំធ្វើលិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស

១-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ច្បាប់ដើម និងច្បាប់ថតចម្លងចំនួន ២ច្បាប់

២-ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណស៊ីជម្ពូ) ឬលិខិតបញ្ជាក់ទំនាក់ទំនងរវាងនិយោជក និងពលករ ដែលចេញដោយក្រសួងការងារថៃ ឬមន្ទីរការងារថៃច្បាប់ដើម និងច្បាប់ថតចម្លងចំនួន ២ច្បាប់

៣-ប័ណ្ណអនុញ្ញាតការងារផ្នែកនេសាទ (សម្រាប់ពលករផ្នែកនេសាទ)

៤-ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់និយោជក

៥-ពលករត្រូវមកដោយផ្ទាល់ និងថតរូបដោយផ្ទាល់

គ. អ្នកក្នុងបន្ទុករបស់ពលករអាយុក្រោម ១៥ឆ្នាំមិនយកកម្រៃសេវា

១-ត្រូវនាំកូន ឬអ្នកក្នុងបន្ទុកមកដោយផ្ទាល់ និងថតរូបដោយផ្ទាល់

២-សំបុត្រកំណើតកូន ឬសំបុត្រពេទ្យ។

ក្នុងករណីបងប្អូនពលករដែលមានចម្ងល់ពាក់ព័ន្ធនឹងបញ្ហាបញ្ជាក់អត្តសញ្ញាណនេះ សូមទាក់ទងមកទូរស័ព្ទមន្ត្រីស្ថានទូតកម្ពុជានៅទីក្រុងបាងកក លេខ **០៨២ ៤២២ ០០១១/ ០៨២ ៤២២ ០០៤៤/ ០២ ៩៥៧ ៥៨៥២/ ០៩២ ៨០៥ ០៥៦១ /០៩៤ ០៩២ ៥៩០៥ /០៨៦ ៧៩៩ ៩៩៥៧ /០៦៤ ៧៥៥ ៧៤០១។**

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសបងប្អូនពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃជ្រាបជាព័ត៌មាន និងអនុវត្តទៅតាមខ្លឹមសារខាងលើនេះ។

ទីក្រុងបាងកក ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧

## នៅធ្វើការខ្លាចតម្រួតចាប់ នាំគ្នាចុះនៅផ្ទះគ្រូវទាហានថៃចាប់តាមផ្លូវទៀត

http://pheaktraprak.com/archives/ By เพียะตรา ประ October 9, 2017

ពលករខ្មែរប្រុសស្រីចំនួន17នាក់ ត្រូវកម្លាំងទាហានឈុតខ្មៅថៃ ចាប់ខ្លួននៅពេលកំពុងឆ្លងដែនវិញត្រឡប់ទៅស្រុកកំណើតវិញ។ ខេត្តស្រះកែវ÷ កាលពីវេលាម៉ោង09ព្រឹកថ្ងៃអាទិត្យ ទី08 ខែតុលា ឆ្នាំ2017នេះ ពលករខ្មែរប្រុសស្រីចំនួន17នាក់មកពីខេត្តឈុនបុរីនិងបាធុមថានី ប្រទេសថៃ ត្រូវកម្លាំងទាហានឈុតខ្មៅថៃចាប់ខ្លួន ហេតុការណ៍នេះបានកើតឡើងនៅត្រង់ចំណុចព្រៃក្បែរច្រកព្រំដែនថៃ-ខ្មែរខាងក្រោយផ្សារលុងភ្លឿស្រុកអារញ្ញ ខេត្តស្រះកែវ។

យោងតាមប្រភពព័ត៌មានថៃដែលបានចុះផ្សាយកាលពីថ្ងៃទី08មិ្សលមិញនេះ បានអោយដឹងថា ពលករខ្មែរចំនួន 17នាក់ ដែលត្រូវបានទាហានឈុតខ្មៅចាប់នោះ បានធ្វើដំណើរមកពីខេត្តឈុនបុរីនិងបាធុមថានី ហើយកំពុងមុជបន្លាលួសត្រៀម និងឆ្លងដែនទៅខាងទឹកដីប៉ោយប៉ែតប្រទេសកម្ពុជាតែត្រូវកម្លាំងទាហានថៃល្បាតព្រំដែនមកទាន់ហៅឈប់សួររកឯកសារតែពួកខ្លួនប្រាប់ថាគ្មាន ទាហានឃាត់ខ្លួនយកទៅកន្លែងដើម្បីសាកសួរ។

តាមចម្លើយសារភាពរបស់ពលករខ្មែរទាំងអស់បានអោយដឹងថា ពួកគេទាំងអស់គ្នាធ្វើការនៅក្នុងខេត្តឈុនបុរី និងខ្លះទៀតធ្វើការនៅក្នុងខេត្តបាធុមថានី តែដោយសារគ្មានលិខិតធ្វើការត្រឹមត្រូវនៅស្រុកគេបានសម្រេចចិត្តនាំគ្នាវិលត្រឡប់ទៅស្រុកកំណើតវិញ ព្រោះភ័យខ្លាចសមត្ថកិច្ចថៃចាប់ខ្លួនហើយមានទោសធ្ងន់។

## ឈ្មួញវៀតណាមជួល ពលរដ្ឋខ្មែរ អោយដឹកទំនិញខុសច្បាប់ចូលប្រទេសថៃ

http://pheaktraprak.com/archives/ By เพียะตรา ประ October 8, 2017

ខេត្តស្រះកែវ÷កាលពីថ្ងៃសុក្រ ទី06 ខែតុលា ឆ្នាំ2017 កម្លាំងទាហានឈុតខ្មៅថៃ ប្រចាំច្រកទ្វារព្រំដែនផ្សារលុងភ្លឿរ ស្រុកអារញ្ញ ខេត្តស្រះកែវ បានធ្វើការបង្រ្កាបទំនិញល្មើសច្បាប់ដែលនាំចូលវៀតណាម តាមរយៈច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត។ ការបង្រ្កាបរឹបអូសទំនិញខុសច្បាប់ដែលនាំចូលពីប្រទេសវៀតណាមនេះ បានធ្វើឡើងបន្ទាប់ពី កម្លាំងទាហានថៃ ត្រួតពិនិត្យរទេះដឹកឥវ៉ាន់របស់ពលរដ្ឋខ្មែរម្នាក់ នៅត្រង់ចំណុចកុងត្រួលត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិថៃ-ខ្មែរ បានឆែករកឃើញសារាយសមុទ្រមកពីប្រទេសវៀតណាមចំនួនជិត100ថង់ ដែលលាក់នៅខាងក្រោមបាត់រទេះដឹកឥវ៉ាន់។ យោងតាមសារព័ត៌មានរបស់ថៃ បានចុះផ្សាយថា សារាយសមុទ្រទាំងអស់ ជារបស់ឈ្មួញវៀតណាម ដែលតែងតែលបលួចនាំចូលយកមកលក់អោយជនជាតិថៃ នៅក្នុងផ្សារលុងភ្លឿរ ដែលជារបស់ខុសច្បាប់ ដែលបរទេសថៃហាមឃាត់មិនអោយនាំចូល។

## ស្វែងយល់ពីប៉ាស្ព័រការងារ ពលករកម្ពុជានៅក្នុងប្រទេសថៃ

http://pheaktraprak.com/archives/ By เพียะตรา ประ October 9, 2017

មានដឹងទេថាក្រសួងការងារថៃ កំណត់រយៈពេល15ថ្ងៃ អោយពលករបរទេសត្រួតសញ្ជាតិរួចយកប៉ាស្ព័រទៅវ៉ៃត្រាវីសារនិង workpermit រួចរាល់។ បងប្អូនពលករកម្ពុជាយេ៊ីងមានដឹងទេថា នៅក្រោយពេលត្រួតសញ្ជាតិហើយរួចរាល់ ពលករកម្ពុជាយើងនិងទទួលបានប៉ាស្ព័រការងារស្របច្បាប់ដូចជា ,PP/TD/TD ក្នុងករណីខាងនេះក្រសួងការងារថៃ បានបញ្ជាក់ថា ក្រោយពេលពលករបរទេសទទួលបានប៉ាស្ព័រការងារស្របច្បាប់ដូចខាងលើ ត្រូវយកប៉ាស្ព័រខាងលើទៅវ៉ៃត្រាវីសារអោយបានត្រឹមត្រូវ រួចយកទៅស្នើសុំច្បាប់អនុញ្ញាតការងារ (workpermit) អោយបានចប់សព្វគ្រប់ក្នុងរយៈពេល 15ថ្ងៃ ។

បើសិនជាបងប្អូនមិនបានដំណើរការដូចការរៀបរាបខាងលើទេ ប៉ាស្ព័រការងាររបស់បងប្អូននិងអស់សុពលភាពដោយស្វ័យប្រវត្តិ ដូច្នេះបងប្អូនមិនអាចស្នាក់នៅធ្វើការក្នុងប្រទេសថៃ បានទៀតឡើយអាស្រ័យហេតុនេះសូមបងប្អូនពលករកម្ពុជាទាំងអស់ ដែលទទួលបានប៉ាស្ព័រការងារដូចខាងលើត្រូវប្រញាប់យកទៅដំណើរការអោយបានរួសរាន់ទាន់ពេលវេលាដែលបានកំណត់។ សម្រាប់ពត៌មានលំអិតទាក់ទងនឹងពលករនៅក្នុងប្រទេសថៃ សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទក្រសួងការងារថៃ 1694 ចាប់ពីម៉ោង08ព្រឹក ដល់ ម៉ោង06ល្ងាច។

## ក្រសួងការងារថៃ ព្រមានចាត់វិធានការលើកម្មករខ្មែរ,ភូមា,ឡាវ ដែលលក់ដូរនៅផ្សារ

http://pheaktraprak.com/archives/ By เพียะตรา ประ October 9, 2017

យោងតាមប្រភពព័ត៌មានថៃចុះផ្សាយកាលពីថ្ងៃអាទិត្យទី 7 ខែតុលាឆ្នាំ 2017នេះ អគ្គនាយកដ្ឋានក្រសួងការងារថៃ ប្រកាសចាត់វិធានការ លើពលករខ្មែរ, ភូមា, ឡាវ ដែលកំពុង ធ្វើការលក់ដូរបន្លែនៅក្នុងផ្សារស៊ីមុំមឿង ស្ថិតក្នុងខេត្តបាធុមថានី ប្រទេសថៃ។ ការលើកដូច្នេះលោក Waranon Petitwan អគ្គនាយកដ្ឋានក្រសួងការងារថៃ បានមានប្រសាសន៍ថា សព្វថ្ងៃនេះច្បាប់ការងារលក់ដូរនៅផ្សារ និងតាមតូបឬរទេះរុញបានស្ថិតនៅក្នុងចំណោមច្បាប់ការងារទាំង 39អាជីព ដែលហាមឃាត់មិនអោយកម្មករបរទេសធ្វើឡើយ។ បច្ចុប្បន្ននេះច្បាប់ការងារលក់ដូរនៅក្នុងផ្សារ កំពុងតែស្ថិតនៅក្នុងការពិចារណារបស់គណៈរដ្ឋមន្ត្រីថៃ និងមិនទាន់ចេញជាសេចក្តីម្រេច អនុញ្ញាតឲ្យកម្មករបរទេសធ្វើការនៅឡើយទេ។

ក្នុងនោះលោក Waranon Petitwan បានបញ្ជាក់បន្ថែមទៀតថា នៅពេលនេះកម្មករបរទេសដែលកំពុងលក់ដូរបន្លែ, ឥវ៉ាន់នៅតាមតូបក្នុងផ្សារ នៅអាចធ្វើបាន ព្រោះមានច្បាប់មាត្រា44 បានអនុគ្រោះដល់ពលករបរទេសលេខ 33/2017 ដែលអនុញ្ញាតដោយគណៈរក្សាភាពស្ងប់ស្ងាត់របស់ថៃឬហៅកាត់ថា(ក,ស,ធ) នៅក្រោយពេលច្បាប់អនុគ្រោះនេះបានផុតកំណត់នៅដើមឆ្នាំ2018 ខាងមុខនេះ សមត្ថកិច្ចក្រសួងការងារថៃនិងចុះចាត់វិធានការយ៉ាងដាច់ខាតចំពោះពលករបរទេសដែលកំពុងធ្វើការខុសច្បាប់លក្ខខ័ណ្ឌនៃច្បាប់ការងារនេះ។

## ឃើញជីវិតកម្មករខ្មែរ ទើបនិងហូបបាយហើយ ត្រូវខ្សែភ្លើងឆក់ស្លាប់យ៉ាងអាណោចអាធ័ម

http://pheaktraprak.com/archives/ By เพียะตรา ประ October 7, 2017

ខេត្តឈុនបុរី÷កាលពីវេលាម៉ោង 08:20 នាទី យប់ថ្ងៃសុក្រទី06 ខែតុលា ឆ្នាំ2017 មានករណីឆ្លងចរន្តអគ្គិសនីឆក់កម្មករខ្មែរម្នាក់ស្លាប់យ៉ាងអាណោចអាធ័ម ហេតុការណ៍នេះបានកើតឡើងក្នុងបន្ទប់ស្នាក់នៅរបស់កម្មករសំណង់មួយរបស់ក្រុមហ៊ុនបុរីសែត ស្ថិតនៅក្នុងច្រកលេខ71 ភូមិ 1 ឃុំបាងប្រាក់ ស្រុកស៊ីរាចា ខេត្តឈុនបុរី។ ជនរងគ្រោះដែលស្លាប់ឈ្មោះ យ៉ន តុនតាន អាយុ17ឆ្នាំសញ្ជាតិខ្មែរ ជាកម្មករសំណង់ធ្វើការនៅក្នុងបុរីខាងលើ។

ប្រភពពីកម្មករស្នាក់នៅបន្ទប់ក្បែរនោះបានប្រាប់អោយដឹងថា នៅមុនពេលកើតហេតុអ្នកស្លាប់អង្គុយហូបបាយលួចជុំគ្នាជាមួយបងប្អូនដែលស្នាក់នៅបន្ទាប់ក្បែរគ្នា ក្រោយហូបបាយរួចបានបែកគ្នាចូលបន្ទាប់ដេករៀងៗខ្លួន។ បន្ទិចក្រោយមកសម្រាប់តែ លឺសំលេងលាន់ប៉ូង អ្នកនៅបន្ទប់ជិតខាងបានបើកទ្វារមើលស្រាប់តែប្រទះឃើញជនរងគ្រោះដេកដួលផ្កាប់មុខទៅនិងជញ្ជាំងសាំងកាសី បានហៅរថយន្តសង្គ្រោះបន្ទាន់បញ្ជូនជនរងគ្រោះទៅសង្គ្រោះនៅមន្ទីរពេទ្យ តែគួរសោកស្តាយជនរងគ្រោះបានស្លាប់បាត់បង់ជីវិតទៅហើយ។ តាមការសន្និដ្ឋានពីកន្លែងកើតហេតុ គេសង្ស័យថាប្រហែលជាឆ្លងចរន្តអគ្គិសនីពីខ្សែភ្លើងទៅជញ្ជាំងសាំងកាសី ទើបបណ្តាលអោយឆក់ជនរងគ្រោះស្លាប់បែបនេះ។

## ឆ្នក់ចាប់ខ្លួនកម្មករភូមាពីរនាក់ នៅកន្លែងត្រួតសញ្ជាតិ បន្ទាប់ពីធ្វើការខុសលក្ខខ័ណ្ឌនៃច្បាប់ការងារ

http://pheaktraprak.com/archives/ By เพียะตรา ประ October 8, 2017

កាលពីថ្ងៃសៅរ៍ទី07 ខែតុលា ឆ្នាំ2017 សមត្ថកិច្ចក្រសួងការងារថៃ ឆ្នក់ចាប់កម្មករភូមាពីនាក់ខណៈកំពុងបំពេញសំណុំបែបបទត្រួតសញ្ជាតិ នៅក្នុងការិយាល័យធ្វើប៉ាស្ព័រ ខេត្តសាមុតប្រាកាន ប្រទេសថៃ។ ករណីនេះបានកើតឡើងបន្ទាប់ពីសមត្ថកិច្ចក្រសួងការងារថៃ ស្រាវជ្រាវដឹងថា កម្មករភូមាទាំងពីរនាក់ ជាអ្នកស៊ីឈ្នួលបំពេញឯកសារការងារ និងលក់លេខរៀងតម្រង់ជួរ ចូលត្រួតសញ្ជាតិអោយកម្មករភូមាដទៃទៀតដែលឈរងចាំធ្វើប៉ាស្ព័រ ដោយគិតថ្លៃឈ្នួលក្នុងម្នាក់ពី400฿-500฿ ។

កម្មករភូមាទាំងពីរនាក់ត្រូវបានកម្លាំងសមត្ថកិច្ចក្រសួងការងារថៃ បញ្ជូនទៅធ្វើការសាកសួរនៅអធិការប៉ូលិសខេត្តសាមុតប្រាកាន ព្រមទាំងធ្វើការចោទប្រកាន់ពីបទ ធ្វើការការខុសលក្ខខ័ណ្ឌនៃច្បាប់ការងារ តាមមាត្រា 70 នៃច្បាប់ការងារថៃ បច្ចុប្បន្នសមត្ថកិច្ចថៃកំពុងកសាងសំណុំរឿងលើកម្មករភូមាទាំងពីរនាក់ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ពលករខ្មែរជាង៥០០នាក់ស្លាប់នៅដីថៃក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ

http://www.rfa.org/khmer/news/.html ដោយ អាស៊ីសេរី 2017-10-05

ពលករខ្មែរដែលធ្វើចំណាកស្រុក ទៅរកការងារធ្វើនៅប្រទេសថៃ ត្រូវប្រថុយប្រថានគ្រោះថ្នាក់ ជារៀងរាល់ថ្ងៃ។ អ្នកខ្លះរងគ្រោះរហូតដល់បាត់បង់ជីវិតថែមទៀតផង។ ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ មានសពកម្មករខ្មែររាប់រយនាក់ ត្រូវបានសមត្ថកិច្ចថៃបញ្ជូនមកខ្មែរវិញ។

មន្ត្រីក្រសួងមហាផ្ទៃ ប្រាប់អាស៊ីសេរី នៅថ្ងៃទី៥ ខែតុលានេះ ថាគិតមកត្រឹមថ្ងៃនេះ ពោលគឺក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ មានសាកសពពលករខ្មែរ មិនតិចជាង ៥០០នាក់ទេ ដែលអាជ្ញាធរថៃ បានបញ្ជូនមកដល់កម្ពុជា។ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អ្នកស្រី ជូ ប៊ុនអេង បញ្ជាក់ថា ក្នុងចំណោមពលករខ្មែរទាំងជាង ៥០០នាក់នេះ អ្នកខ្លះស្លាប់ដោយសារការបាញ់បង្ក្រាបពីទាហានថៃ ដោយសារពួកគាត់ឆ្លងដែន ដោយខុសច្បាប់។ អ្នកខ្លះទៀតស្លាប់ដោយសារត្រូវគ្រាប់មីន នៅក្នុងព្រៃ។ អ្នកខ្លះទៀត ស្លាប់ដោយគ្រោះថ្នាក់ចរាចរ ពេលខំប្រឹងរត់គេច ពីការដេញដេញប៉ផាប់ចាប់ពភីង ពីសំណាក់សមត្ថកិច្ចថៃ។ អ្នកខ្លះទៀត បាត់បង់ជីវិតដោយគ្រោះថ្នាក់ក្នុងការងារ ដូចជាការធ្លាក់ពីលើអគារ ការប្រើប្រាស់ឧបករណ៍ខុសបច្ចេកទេស និងលង់ទឹកស្លាប់ ពេលទូកនេសាទបុកគ្នា និងការឈ្លោះទាស់ទែងគ្នា កាប់ចាក់គ្នារវាងពលករខ្មែរគ្នាឯង ឬជាមួយកម្មករថៃ ឬឈ្លោះគ្នាជាមួយកម្មករភូមាជាដើម៖ « ក្នុងចំណោមពលករចំណាកស្រុកទាំងអស់ មិនមែនសុទ្ធតែនាំលាភសំណាង មកស្រុកវិញនោះទេ អ្នកខ្លះស្លាប់»។

ដោយសារបញ្ហាជីវភាព តម្លៃពលកម្មទាបនៅកម្ពុជា បើប្រៀបធៀបទៅនឹងតម្លៃពលកម្មនៅប្រទេសថៃ និងភាពខ្វះការងារដែលមានប្រាក់កម្រៃសមរម្យ មានពលរដ្ឋខ្មែរ ជាងមួយលាននាក់ បានឆ្លងដែន ទៅរកការងារធ្វើនៅប្រទេសថៃទាំងស្របច្បាប់ និងខុសច្បាប់។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ ពលករខ្មែរដែលធ្វើចំណាកស្រុក ទៅរកការងារធ្វើនៅប្រទេសថៃ ទាំងខុសច្បាប់ និងស្របច្បាប់ មានចំនួន ១លាន ៥ម៉ឺននាក់ ក្នុងចំណោមពលករទាំងនោះ មានពលករជាង ៧០ម៉ឺននាក់ ជាពលករស្របច្បាប់ ខណៈដែលជាង ៣០ម៉ឺននាក់ទៀតជាពលករខុសច្បាប់។

ស្របពេលដែលក្រសួងការងារ ទើបតែប្រកាសកំណត់យកប្រាក់ខែអប្បបរមា ១៧០ ដុល្លារ សម្រាប់កម្មករក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងស្បែកជើង ប្រាក់ប៉ុណ្ណេះនៅមានចំនួនតិចតួចនៅឡើយ បើប្រៀបធៀបទៅនឹងការចំណាយ ដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ ចំពោះគ្រូបង្រៀនវិញ ពួកគាត់កំពុងទាមទារឲ្យដំឡើងប្រាក់ខែពួកគាត់ឲ្យបានយ៉ាងតិច ៥០០ ដុល្លារ ទើបអាចដោះស្រាយជីវភាពប្រចាំថ្ងៃបាន៕

## ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ សហការជាមួយសមត្ថកិច្ចចិនអន្តរាគមន៍ ជួយនារីខ្មែរ៣នាក់ ឲ្យត្រឡប់មកស្រុកកំណើតវិញក្រោយចាញ់បោកមេខ្យល់

http://freshnewsasia.com/index.php/en/localnews/ 2017-10-06

**(ភ្នំពេញ)៖** ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងសៀងហៃ បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចចិន ជួយសង្គ្រោះស្ត្រីខ្មែរ៣នាក់ ដែលចាញ់បោកមេខ្យល់ ធ្វើដំណើរទៅប្រទេសចិន ដើម្បីទៅរៀបការជាមួយជនជាតិចិន។ នេះបើតាមសេចក្តីប្រកាសរបស់ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៧នេះ។

ក្រសួងការបរទេស បានបញ្ជាក់ថា ស្ថានអគ្គកុងស៊ុលកម្ពុជា បានទទួលយកស្ត្រីរងគ្រោះទាំង៣នាក់ មកស្នាក់នៅបណ្តោះអាសន្ននៅ ស្ថានអគ្គកុងស៊ុល ផ្តល់អាហារបរិភោគគ្រប់គ្រាន់ និងរៀបចំឯកសារធ្វើដំណើរដល់ស្ត្រីខ្មែរទាំង៣នាក់ ហើយពួកគេបានមកដល់ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៧នេះ វេលាម៉ោង១៧៖៥៥នាទី៕

## ប្រទេសម៉ាឡេស៊ី សិង្ហបុរីនិងថៃ ជាមជ្ឈមណ្ឌលដ៏ធំ សម្រាប់ទេសន្តប្រវេសន៍ ក្នុងតំបន់អាស៊ាន

https://www.dap-news.com/kh/.html ថ្ងៃច័ន្ទ, 09 តុលា ២០១៧ 10:44 ដោយ: ប្រយុទ្ធ ID:014

ភ្នំពេញ៖ធនាគារពិភពលោក នៅថ្ងៃទី៩ ខែតុលានេះ បានបង្ហាញរបាយការណ៍ ស្តីពីទេសន្តប្រវេសន៍ ក្នុងតំបន់អាស៊ាន ដែលក្នុងនោះ ទេសន្តប្រវេសន៍អន្តរតំបន់ ក្នុងប្រទេសអាស៊ាន បានកើតឡើងយ៉ាងខ្លាំង រវាងឆ្នាំ១៩៩៥ និងឆ្នាំ២០១៥ ដែលបានធ្វើឲ្យប្រទេសម៉ាឡេស៊ី សិង្ហបុរី និងប្រទេសថៃ ក្លាយជាមជ្ឈមណ្ឌលដ៏ធំ សម្រាប់ទេសន្តប្រវេសន៍ក្នុងតំបន់ ដែលមានអន្តរទេសន្តប្រវេសន៍ ប្រមាណ៦,៥លាននាក់ ឬប្រមាណជា ៩៦ ភាគរយ នៃចំនួនពលករទេសន្តប្រវេសន៍ទាំងអស់ នៅក្នុងប្រទេសអាស៊ាន។

របាយការណ៍បង្ហាញថា ពលករទេសន្តប្រវេសន៍នៃប្រទេសអាស៊ាន ដែលមានជំនាញទាប និងគ្មានឯកសារ បានចូលស្វែងរកឱកាសសេដ្ឋកិច្ចភាគច្រើន ក្នុងវិស័យសំណង់ ចំការធំ និងវិស័យសេវាកម្មតាមផ្ទះ។ របាយការណ៍បំលាស់ ទីដើម្បីស្វែងរកឱកាសពិភាក្សា អំពីការប្រឈមនានា ដែលពលករទេសន្តប្រវេសន៍ក្នុងតំបន់ ជួបប្រទះព្រមទាំងការផ្តោតលើរបាំងនានា នៃការបំលាស់ទី ដែលកំពុងមាន។ ការងារដែលមានប្រាក់កម្រៃខ្ពស់ គឺអាចរកមានប៉ុន្តែភាគច្រើន ពលករមិនទទួលបានឱកាសនេះទេ។ របាយការណ៍លើកបង្ហាញទៀតថា អ្វីដែលបាត់បង់នៅពេលដែលពួកគាត់ បាត់ឱកាសនេះ ក៏ដូចជាលើកបង្ហាញ អំពីគោលនយោបាយសំខាន់នានា ដែលអាចទាញយកផលចំណេញ ពីឱកាសដែលមាននេះ។

របកគំហើញនៃរបាយការណ៍នេះ នឹងជម្រាបជូនដោយប្រធានសេដ្ឋវិទូ របស់ធនាគារពិភពលោក ប្រចាំតំបន់អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក លោក ស៊ុឌៀ សេតទី និង ម៉ារ៉ូ តេស្តាវើឌី អ្នកដឹកនាំការតាក់តែង របាយការណ៍នេះ និងជាសេដ្ឋវិទូនៃនាយកដ្ឋានសកល សម្រាប់ការគាំពារសង្គម និងការងាររបស់ធនាគារពិភពលោក ពីទីក្រុងសិង្ហបុរី ក្នុងកម្មវិធីសន្និសីទសារព័ត៌មាន៕

## ធនាគារពិភពលោក ៖ ការគ្រប់គ្រង ការធ្វើចំណាកស្រុក បានប្រសើរ អាចជួយបង្កើន សុខភាព និងកំណើន សេដ្ឋកិច្ចនៅអាស៊ាន

https://www.dap-news.com/kh/.html ថ្ងៃច័ន្ទ, 09 តុលា ២០១៧ 12:23 ដោយ: អេង ប៊ូឆេង ID:012

ភ្នំពេញ ៖ របាយការណ៍ របស់ធនាគារពិភពលោក បានឲ្យដឹងថា ការបន្ធូរបន្ថយ ការរឹតត្បិត លើទេសន្តប្រវេសន៍ ការធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារធ្វើ អាចជួយបង្កើន សុខមាលភាព របស់កម្មករ និងបង្កើនការធ្វើសមាហរណកម្ម សេដ្ឋកិច្ចក្នុង តំបន់នៅអាស៊ាន កាន់តែប្រសើរ។ របាយការណ៍បន្តថា ចំណាកស្រុកទៅក្រៅប្រទេស នៅក្នុងតំបន់អាស៊ាន បានកើនឡើង គួរឲ្យកត់សម្គាល់ ក្នុងចន្លោះពីឆ្នាំ១៩៩៥ ដល់ ២០១៥ ដោយបានប្រែក្លាយប្រទេស ម៉ាឡេស៊ី សិង្ហបុរី និងថៃ ទៅជាទីកន្លែង សម្រាប់ពលករចំណាកស្រុកចំនួន ៦,៥លាននាក់ រស់នៅក្នុងតំបន់នេះ គឺស្មើនឹង ៩៦ភាគរយ នៃចំនួនពលករ ចំណាកស្រុក នៅក្នុងតំបន់អាស៊ាន។ ប្រាក់ដែលពលករផ្ញើទៅកាន់ ប្រទេសកំណើនរបស់ខ្លួន នៅក្នុងតំបន់ អាស៊ាន មានប្រមាណ ៦២ពាន់លានដុល្លារ នៅឆ្នាំ២០១៥។

បន្ថែមពីលើរបាយការណ៍នេះ លោក ស៊ុឌៀ សេតទី ប្រធានសេដ្ឋកិច្ចវិទូ របស់ធនាគារពិភពលោក ប្រចាំតំបន់ អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ក្នុងសន្និសីទសារព័ត៌មាននៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៧ បានមានប្រសាសន៍ថា "ជា មួយនឹងការជ្រើសរើស គោលនយោបាយដ៏ត្រឹមត្រូវ ប្រទេសបញ្ជូនពលករចេញ អាចទទួល បានអត្ថប្រយោជន៍ ផ្នែកសេដ្ឋកិច្ច នៃចំណាកស្រុកទៅក្រៅប្រទេស ស្របពេលដែលមានការគាំពារ ពលករចំណាក ស្រុកដែលជ្រើស រើសទៅធ្វើការក្រៅប្រទេស "។ លោកបន្តថា ក្នុងប្រទេសទទួលយកពលករ នឹងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ប្រសិន បើគោល នយោបាយទេសន្តប្រវេសន៍ដើរស្របគ្នា ជាមួយនឹងតម្រូវការផ្នែកសេដ្ឋកិច្ច គោលនយោបាយមិនសមស្រប និងស្ថាប័នមិនមានប្រសិទ្ធិភាពមានន័យថា តំបន់នេះ កំពុងតែបាត់បង់ឱកាសទទួលបានប្រយោជន៍ដ៏ពេញលេញ ពីទេសន្តប្រវេសន៍ ។ លោកបញ្ជាក់ថា ក្នុងប្រទេសថៃ ការវិភាគថ្មីៗនេះបានរកឃើញថា បើគ្មានពលករអន្តោប្រវេសន៍ ក្នុងកម្លាំង ពលកម្មទេ នោះផលិតផលសរុបក្នុងស្រុកនឹងធ្លាក់ចុះ០,៧៥ភាគរយ។

ចំណែកអ្នកសេដ្ឋកិច្ចវិទូ ផ្នែកការគាំពារសង្គម និងការងាររបស់ធនាគារពិភពលោក លោក ម៉ារ៉ូ តេស្តាវើដ បានថ្លែងថា "មិនថាពលករចង់ធ្វើចំណាកស្រុកទៅកាន់ទីណាទេ នៅក្នុងតំបន់អាស៊ាននេះ ពួកគេប្រឈម នឹងបម្លាស់ទីដែលត្រូវចំណាយ បីឬបួន ដងនៃប្រាក់បៀវត្សរ៍មធ្យមប្រចាំឆ្នាំរបស់ខ្លួន។ ការកែលម្អដំណើរ ការនៃ ការធ្វើចំណាកស្រុក អាចជួយកាត់បន្ថយថ្លៃចំណាយរបស់ពលករទាំងនេះ នាពេលអនាគត និងជួយប្រទេស ទាំងនេះឆ្លើយតបបានប្រសើរទៅនឹងតម្រូវការទីផ្សារពលកម្មរបស់ខ្លួន"។ លោកបន្ថែមថា ការធ្វើចំណាកស្រុកអាចផ្តល់ឲ្យពលករនានា ដែលមកពីប្រទេសមានប្រាក់ចំណូលទាបជាងគេ នូវឱកាសសម្រាប់បង្កើនប្រាក់ចំណូលរបស់ខ្លួន។ ផលប៉ះពាល់នៃការផ្ញើប្រាក់ទៅកាន់ប្រទេសកំណើនរបស់ខ្លួន លើផលិតផលសរុបក្នុងស្រុករបស់ជាតិ ក៏មានទំហំធំដែរ។ លោកអះអាងថា ប្រទេសវៀតណាម អាចទទួលបានអត្ថប្រយោជន៍ពីយុទ្ធសាស្ត្រទេសន្តប្រវេសន៍ជាតិ ដើម្បីដឹក នាំការធ្វើកំណែទម្រង់នានា។ ដំណើរការផ្លូវការងាយៗ អាចជួយកាត់បន្ថយតម្លៃពលករ ចំណាកស្រុក ចេញក្រៅ ប្រទេស ជាពិសេស ក្នុងប្រទេសដែលមានប្រាក់ចំណូលទាបជាងគេ ដូចជា កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា៕

## ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧

## ប្រសាសន៍សំខាន់ៗរបស់សម្តេចតេជោ ហ៊ុន សែន អញ្ជើញជួបសំណេះសំណាលជាមួយកម្មករមកពីរោងចក្រចំនួន១១ នៅតាមបណ្តោយផ្លូវវេងស្រេង រាជធានីភ្នំពេញ

http://freshnewsasia.com/index.php/en/localnews/ 2017-10-11

(ភ្នំពេញ)៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅព្រឹកថ្ងៃទី១១ ខែតុលា ២០១៧ សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ក្រៅពីការពង្រីកការងារនៅក្នុងស្រុកហើយនោះ រាជរដ្ឋាភិបាល ក៏បានខិតខំពង្រីកការងារនៅក្រៅប្រទេសផងដែរ។ បច្ចុប្បន្នរាជរដ្ឋាភិបាលកំពុងប្រឹងប្រែង ជួយសម្របសម្រួលឲ្យពលរដ្ឋខ្មែរធ្វើការនៅក្រៅប្រទេស ដែលមិនទាន់ស្របច្បាប់ឲ្យក្លាយជាពលករស្របច្បាប់វិញ ហើយឲ្យទទួលបានអត្ថប្រយោជន៍ផ្សេងៗដូចប្រជាពលរដ្ឋរបស់ប្រទេសទាំងនោះផងដែរ។

## នគរបាលប្រឆាំង ការជួញដូរមនុស្ស ចុះបង្ក្រាបទីតាំង ម៉ាស្សាបង្កប់ សេវាកម្មផ្លូវភេទ ឃាត់ខ្លួនជនសង្ស័យ ២នាក់

http://www.daem-ampil-news.html ថ្ងៃពុធ, ១១ តុលា ២០១៧ 06:44 ដោយ: ដើមអម្ពិល ID:049

**ភ្នំពេញ៖**កម្លាំងនគរបាលនៃនាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស នៅម៉ោងប្រមាណ ៨៖០០នាទីយប់ថ្ងៃទី១០ ខែតុលាឆ្នាំ២០១៧នេះ បានចុះបង្ក្រាបទីតាំង ម៉ាស្សាកោសជប់ មួយកន្លែងដែលបង្កប់សេវាកម្មផ្លូវភេទ នៅផ្លូវ២០០៤ ភូមិត្រពាំងល្វា១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ ដោយឃាត់ខ្លួនមនុស្ស២នាក់ និងរំដោះនារីរងគ្រោះបាន៦នាក់។

បើតាមមន្ត្រីនគរបាលបានឲ្យដឹងថា ជនសង្ស័យដែលត្រូវឃាត់ខ្លួននោះ ទី១. ឈ្មោះ អាត់ សល់ អាយុ ៣៦ឆ្នាំត្រូវជាប្តីនិងស្ត្រីដែលត្រូវ ជាប្រពន្ធឈ្មោះ ហេង គីមលាង អាយុ ៣៥ឆ្នាំ ជាម្ចាស់បើកកន្លែងកោសជប់ និងសំរួលសរសៃ ស្ថិតនៅតាមបណ្តោយ ផ្លូវលេខ២០០៤ ភូមិត្រពាំងល្វា១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ។ ឯនារីរងគ្រោះពួកគាត់ មានអាយុចន្លោះពី១៨ឆ្នាំ ទៅ៤០ឆ្នាំ៕

## លោក សុខ ឥសាន បង្ហាញពី ជោគជ័យ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរកទីផ្សារ ពលកម្មជូនពលករ

http://www.daem-ampil-news.html អង្គារ, ១០ តុលា ២០១៧ 17:43 ដោយ: ស៊ាន កុសល ID:049

**ភ្នំពេញ៖** លោក សុខ ឥសាន អ្នកនាំពាក្យគណបក្ស ប្រជាជនកម្ពុជា នៅរសៀលថ្ងៃទី១០ តុលានេះ បានបង្ហាញ ពីជោគជ័យ របស់ រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរកទីផ្សារពលកម្ម ជូនពលករ នោះក៏ព្រោះរាជរដ្ឋាភិបាលកម្ពុជា មាននយោបាយការបរទេស ត្រឹមត្រូវ ទើបប្រទេសជាមិត្ត នានា បានផ្តល់ភាពអនុគ្រោះឲ្យកម្ពុជា បញ្ជូនពលករទៅអ្វីការនៅប្រទេសគេ ។ លោក សុខ ឥសាន បានបញ្ជាក់ទៀតថា "ការបានទៅធ្វើការនោះ មិនមែនគ្រាន់តែជាការដោះស្រាយបានទីផ្សារពលកម្ម សម្រាប់យុវជន យើង និងប្រជាជនយើងទេ តែក៏បាននាំមកនូវអត្ថប្រយោជន៍ ផ្សេងៗទៀតដល់ក្រុមគ្រួសារ និងប្រទេសជាតិដែរ ។ ចំណូលដែលបានមកពី ការងារ នៅក្រៅប្រទេស ក្នុងមួយឆ្នាំៗមានប្រមាណជា ២០០០ លានដុល្លារអាមេរិក ដែលរួមចំណែកទ្រទ្រង់ ជីវភាព ក្រុមគ្រួសារបានធូរជា ដូចជា

មានទុនអាចប្រកបមុខរបររកស៊ី មានប្រាក់សម្រាប់សាងសង់ផ្ទះ ធំទ្រនំខ្ពស់ មានប្រាក់ទិញពូជ ដី និង ទិញឧបករណ៍កសិកម្មបម្រើការងារ បង្កបង្កើនផលកសិកម្ម" ។ល។

លោក សុខ ឥសាន ក៏បញ្ជាក់បន្ថែមទៀតថា "ម្យ៉ាងទៀត បងប្អូនពលករយើង ឆ្លៀតឱកាសរៀនសូត្រ ដកពិសោធន៍និងក្រេបជញ្ជក់ យកបច្ចេកវិជ្ជាទំនើបជឿនលឿន របស់ប្រទេសម្ចាស់ផ្ទះ ត្រឡប់មកស្រុកកំណើតវិញពេលចប់កិច្ចសន្យាការងារ ដើម្បីប្រកបរបររក សើជាឯកជន ឬ បើកក្រុមហ៊ុនធុនតូច ឬ ជា សិប្បកម្មខ្នាតតូចបាន ឬក៏អាចមានលទ្ធភាពសុំការងារ នៅក្នុងក្រុមហ៊ុនណាមួយបានដែរ ។

បញ្ហាខាងលើនេះ សុទ្ធតែជាអត្ថប្រយោជន៍ បានមកពីការចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស ។ ប្រទេសណាក៏ដូវប្រទេសណាដែរនៅលើពិភពលោក តែងតែមានពលករចំណាកស្រុក ។ សព្វថ្ងៃនេះ នៅលើពិភពលោកមានពលករ ចំណាកស្រុករហូតដល់ទៅ ៣០០ - ៤០០ លាននាក់ឯណោះ ដែលរកចំណូលឲ្យ ក្រុមគ្រួសាររាប់ពាន់លានដុល្លាអាមេរិក ប្រមាណពី ២-៥ ភាគរយ នៃ សរុបផលិតផលក្នុងស្រុក ។ ដូច្នេះ ការនិយាយថា រាជរដ្ឋាភិបាលយកកូនចៅប្រជាជន ឲ្យទៅធ្វើខ្ញុំកញ្ជះប្រទេសគេ ជាការប្រមាថ មើលងាយពលករខ្មែរយើងយ៉ាងអសីលធម៌ពិតប្រាកដ៕

## ក្រសួងមហាផ្ទៃកំពុងរកទីតាំង សម្រាប់ធ្វើលិខិតធ្វើដំណើរ ជូនពលករនៅបាត់ដំបង និង បន្ទាយមានជ័យ

http://www.daem-ampil-news.html អង្គារ, ១០ តុលា ២០១៧ 14:17 ដោយ: បាន សុខរិទ្ធិ ID:013

ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានលើកឡើងថា បច្ចុប្បន្នក្រសួងមហាផ្ទៃ កំពុងស្វែងរកទីតាំងសមគួរ ដើម្បីធ្វើលិខិតធ្វើដំណើរ ជូនពលករកម្ពុជា ដែលមានបំណងរកការងារធ្វើ នៅក្រៅប្រទេស សម្រាប់អ្នកខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ។

ក្នុងពិធីបើកសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី កតិកាសញ្ញាជាសកល ស្តីពី ទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ភាពស្របច្បាប់ និងប្រក្រតីភាព នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ នាសណ្ឋាគារអ៊ីជីខន សម្តេចក្រឡាហោម បានមានប្រសាសន៍ថា "ការផ្សព្វផ្សាយអប់រំគឺជាកត្តាសំខាន់ ដែលធ្វើឱ្យប្រជាពលរដ្ឋ យល់ដឹងបានខ្ពស់ អំពីបញ្ហាទាំងនេះ អីចឹងហើយ បានជាក្រសួងមហាផ្ទៃ បានប្រជុំបង្កើតការិយាល័យ ផ្តល់លិខិតធ្វើដំណើរជូនពលករកម្ពុជា ដែលមានបំណង រកការងារធ្វើសម្រាប់អ្នកខេត្តបាត់ដំបង និងបន្ទាយមានជ័យ គ្រាន់តែមិនទាន់កំណត់ទីតាំង គួរដាក់នៅតាមព្រំដែន ឬនៅស្នងការដ្ឋាននគរបាលខេត្ត" ។ ក្នុងឱកាសនោះ សម្តេចបានជំរុញដល់អាជ្ញាធរ នគរបាលអន្តោប្រវេសន៍ និងក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ ទប់ស្កាត់បញ្ហាជួញដូរមនុស្ស អំពើរត់ពន្ធជនទេសន្តរប្រវេសន៍ និងទម្រង់នៃទាសភាពសម័យថ្មី ឲ្យបានល្អផងដែរ ។

សូមបញ្ជាក់ថា ក្នុងសិក្ខាសាលានេះភាគីពាក់ព័ន្ធ បាននិងកំពុងពិគ្រោះយោបល់គ្នា ទៅលើវិស័យចំនួន៦ ទី១. សិទ្ធិមនុស្សរបស់ជនទេសន្តរប្រវេសន៍ ជាពិសេស ស្ត្រី កុមារ ភាពរើសអើង និងបែងចែកជនទេសន្តរប្រវេសន៍, ទី២. ការឆ្លើយតបទៅនឹងកត្តា ដែលនាំឱ្យមានទេសន្តរប្រវេសន៍ រាប់ទាំងកត្តាប្រែប្រួលអាកាសធាតុ, ទី៣. កិច្ចសហប្រតិបត្តិការណ៍អន្តរជាតិ និងការគ្រប់គ្រងទេសន្តរប្រវេសន៍ គ្រប់ទិដ្ឋភាព, ទី៤. ការរួមចំណែករបស់ជនទេសន្តរប្រវេសន៍ ដល់ការអភិវឌ្ឍន៍គ្រប់វិស័យ ប្រកបដោយចីរភាព, ទី៥. ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើរត់ពន្ធជនទេសន្តរប្រវេសន៍ និងទម្រង់នៃទាសភាពសម័យថ្មី និងទី៦. វិធានការចំពោះទេសន្តរប្រវេសន៍មិនប្រក្រតី និងដំណើរការឱ្យមានប្រក្រតីភាព និងភាពស្របច្បាប់ នៃទេសន្តរប្រវេសន៍ ៕

# សម្តេច ស ខេងៈ «ពិភពលោកមានវិបត្តិមនុស្សធម៌ ព្រោះការបំពាន និងកេងប្រយោជន៍ ជនទេសន្តរប្រវេសន៍»

http://www.thmey-thmey-news.html 10, Oct 2017 , 10:59 pm ដោយ: ខន ចំប៉ា

សម្តេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងថា ការរំលោភបំពាន និងកេងប្រវ័ញ្ចយកផលចំណេញជនទេសន្តរប្រវេសន៍ ពីសំណាក់ជនទុច្ចរិត បានធ្វើឲ្យពិភពលោកមានវិបត្តិខាងមនុស្សធម៌។ ជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សផង សម្តេច ស ខេង បន្ថែមទៀតថា បញ្ហាទេសន្តរប្រវេសន៍ ក៏បង្កជាគំនំសងសឹក ជម្លោះទាស់ទែងគ្នា ពីបុគ្គល ក្រុម ឬរហូតដល់កម្រិតប្រទេស និងប្រទេស និងបង្កើតភាពចលាចល សង្គ្រាម និងការបំផ្លិចបំផ្លាញគ្នាទៅវិញទៅមកផងដែរ។

ការរំលោភបំពាន និងកេងប្រវ័ញ្ចផលចំណេញជនទេសន្តរប្រវេសន៍ ពីសំណាក់ជនទុច្ចរិត បានធ្វើឲ្យពិភពលោកមានវិបត្តិមនុស្សធម៌ ដែលបង្កការឈឺចាប់ដល់មនុស្សរាប់លាននាក់។ សម្តេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ថ្លែងដូច្នេះក្នុង សិក្ខាសាលាពិគ្រោះយោបល់ស្តីពី«ទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ស្របច្បាប់ និងប្រក្រតីភាព» នៅព្រឹកថ្ងៃទី ១០ ខែតុលា។ ជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សផង សម្តេច បន្ថែមទៀតថា បញ្ហាជនទេសន្តរប្រវេសន៍ ក៏បន្សល់ទុកភាពរងគ្រោះ ការនិរាសព្រាត់ប្រាស់ ឬផលប៉ះពាល់ដល់សុខភាពផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ទ្រព្យធន ឬអាយុជីវិតរបស់ជនទេសន្តរប្រវេសន៍ ឬសង្គមជាតិដែរ។ មិនត្រឹមតែប៉ុណ្ណោះ វាក៏បង្កជាគំនំសងសឹក ជម្លោះទាស់ទែងគ្នា ពីបុគ្គល ក្រុម ឬរហូតដល់កម្រិតប្រទេស និងប្រទេស និងបង្កើតភាពចលាចល សង្គ្រាម និងការបំផ្លិចបំផ្លាញគ្នាទៅវិញទៅមក កាន់តែធំទៅ និងជ្រៅទៅៗទៀតផង។

យ៉ាងណាក៏ដោយ សម្តេចស ខេង ក៏បានគូសបញ្ជាក់ពីសារៈសំខាន់ នៃសិក្ខាសាលាដែលមានភាគីពាក់ព័ន្ធចូលរួមនេះ។ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថាសិក្ខាសាលានេះ នឹងជាឱកាសសម្រាប់ពិភាក្សាគ្នាឲ្យបានល្អិតល្អន់ ដើម្បីលើកកម្ពស់សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ជនទេសន្តរប្រវេសន៍ និងវិធីសាស្ត្រល្អៗ ក្នុងការគ្រប់គ្រងស្ថានភាពលំហូរទេសន្តរប្រវេសន៍ ឆ្លងកាត់ព្រំដែន ដែលបាន និងកំពុងក្លាយជាប្រធានបទក្តៅគគុក មួយត្រូវយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លា។ សម្តេច ស ខេង បន្ថែមដូច្នេះ៖«ដោយកម្ពុជា ជាប្រទេសប្រភពនៃទេសន្តរប្រវេសន៍ និងទេសន្តរប្រវេសន៍ឆ្លងកាត់ យើងត្រូវរួមចំណែកគិតគូរ រកឲ្យឃើញតម្រូវការចាំបាច់ដែលរលូន និងឯកភាពគ្នា សម្រាប់អនុវត្ត ជាមួយប្រទេសពាក់ព័ន្ធទាំងឡាយលើពិភពលោក ក្នុងការផ្តល់នូវសុវត្ថិភាព ភាពស្របច្បាប់ សិទ្ធិ និងផលប្រយោជន៍ ឲ្យបានសមស្របដល់ជនទេសន្តរប្រវេសន៍ និងក្រុមគ្រួសាររបស់ពួកគេ»។

កិច្ចពិភាក្សាគ្នានេះ ក៏ជាឱកាសសម្រាប់រាជរដ្ឋាភិបាលកម្ពុជា បានសិក្សា និងកំណត់រកធាតុចូល ជាចំណុចគន្លឹះសម្រាប់ការរៀបចំកត្តិកាសញ្ញាជាសាកល ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ភាពស្របច្បាប់ និងប្រក្រតីភាព។ លទ្ធផលនៃការពិភាក្សានេះ នឹងលើកយកទៅពិភាក្សា និងដាក់បញ្ចូលនៅក្នុងកិច្ចពិភាក្សាថ្នាក់តំបន់ ដែលនឹងប្រព្រឹត្តិទៅនៅក្នុងខែវិច្ឆិកាខាងមុខ មុននឹងលើកយកទៅពិភាក្សានៅថ្នាក់ពិភពលោក។ នេះបើតាមសម្តេច ស ខេង ដែលបន្តដោយអំពាវនាវឲ្យតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ពិភាក្សាគ្នាដោយផ្តោតលើបទពិសោធន៍ដែលពួកគេបានអនុវត្តកន្លងមក ដោយប្រមូលផ្តុំលើច្បាប់ គោលនយោបាយ បទដ្ឋានដែលពាក់ព័ន្ធ ដើម្បីជួយដល់ការថែរក្សាសន្តិសុខ សុវត្ថិភាព ប្រជាពលរដ្ឋ ក្នុងអំឡុងពេលទេសន្តរប្រវេសន៍ តាំងពីការសម្រេចចិត្ត ការចាកចេញ ការធ្វើការងារ និងការត្រឡប់មកជួបជុំក្រុមគ្រួសារវិញប្រកបដោយសុវត្ថិភាព៕

## សម្តេច ស ខេង៖ កម្ពុជា ជាប្រភពនៃទេសន្តរប្រវេសន៍

http://kleykley.sabay.com.kh/article/ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ ម៉ោង 10:30

សម្តេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បាននិយាយថា កម្ពុជាជាប្រទេសដែលជាប្រភពនៃទេសន្តរប្រវេសន៍ និងមានទេសន្តរប្រវេសន៍ឆ្លងកាត់។ ការលើកឡើងនេះ ធ្វើឡើងក្នុង សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីកតិកាសកលទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ភាពស្របច្បាប់ និងប្រក្រតីភាព នៅព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ នៅសណ្ឋាគារ អីនធើខនធីណិនថល។

សម្តេច ស ខេង បានបញ្ជាក់ថា «*យើងត្រូវរួមចំណែកក្នុងការគិតគូរ ដើម្បីកេឲ្យឃើញនូវសេចក្តីត្រូវការជាចាំបាច់សម្រាប់ការអនុវត្តដែលឯកភាពគ្នា និងរលូនជាមួយគ្នារវាងប្រទេសពាក់ព័ន្ធទាំងឡាយលើពិភពលោកក្នុងការផ្តល់នូវសុវត្ថិភាព ភាពស្របច្បាប់ សិទ្ធិ និងផលប្រយោជន៍ឲ្យបានសមស្របដល់ជនទេសន្តរប្រវេសន៍ និងក្រុមគ្រួសាររបស់ពួកគេ*»។ សម្តេច ស ខេង បានមានប្រសាសន៍ថា កិច្ចពិភាក្សានេះ នឹងជាឱកាសសម្រាប់ការពិភាក្សាគ្នាឲ្យបានល្អិតល្អន់ ដោយខិតខំរិះគិត និងជួយផ្តល់យោបល់ទៅលើជាតុចូលពាក់ព័ន្ធបញ្ហាទេសន្តរប្រវេសន៍ ដែលបានមកពីបទពិសោធន៍ជាក់ស្តែងដែលបាន និងជួបប្រទះ និងអនុវត្តកន្លងមក។ កិច្ចពិភាក្សានេះ ក៏នឹងរកវិធីសាស្ត្រល្អៗ ក្នុងការគ្រប់គ្រងស្ថានភាពលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន ដែលបាននឹងកំពុងតែក្លាយជាប្រធានបទក្តៅគគុក១ ត្រូវយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លា៕

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អំពាវនាវដល់ភាគីពាក់ព័ន្ធ ជួយទេសន្តរប្រវេសន៍

http://ann.com.kh/site/news/ ថ្ងៃពុធ, 11 ខែតុលា 2017 7:14 ព្រឹក

ភ្នំពេញ៖រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅក្នុងសិក្ខាសាលាមួយស្តីពីទេសន្តរប្រវេសន៍ កាលពីថ្ងៃទី១០ តុលា ម្សិលមិញ ឯស ណ្ឋា គារអាំងទែរកុងទីណង់តាល់ បានធ្វើការអំពាវនាវ ដល់ភាគីពាក់ព័ន្ធដែលមានបទពិសោធន៍ ធ្វើយ៉ាងណាជួយដល់ទេសន្តប្រវេសន៍ ។

បើតាមសម្តេចក្រឡាហោម ស ខេង ភាគីទាំងនោះដែលមានដូចជាតំណាងក្រសួង ស្ថាប័នពាក់ គួរតែពិភាក្សាគ្នាដោយផ្តោតលើបទពិសោធន៍ដែលពួកគេបានអនុវត្តកន្លងមក ដើម្បីប្រមូលផ្តុំលើច្បាប់ គោលនយោបាយ បទដ្ឋានដែលពាក់ព័ន្ធ ដើម្បីជួយដល់ការថែរក្សាសន្តិសុខ សុវត្ថិភាព ប្រជាពលរដ្ឋ ក្នុងអំឡុងពេលទេសន្តរប្រវេសន៍ ឬចំណាកស្រុក តាំងពីការសម្រេចចិត្ត ការចាកចេញ ការធ្វើការងារ និងការត្រឡប់មកជួបជុំក្រុមគ្រួសារវិញប្រកបដោយសុវត្ថិភាព ។

ជាមួយគ្នាសម្តេចក៏បានលើកឡើងផងដែរថា ការរំលោភបំពាន និងកេងប្រវ័ញ្ចយកផលចំណេញ លើជនទេសន្តរប្រវេសន៍ ពីសំណាក់ជនទុច្ចរិត បានធ្វើឲ្យពិភពលោកមានវិបត្តិខាងមនុស្សធម៌ ដែលបង្កឲ្យមានគំនុំសងសឹក ជម្លោះទាស់ទែងគ្នា ពីបុគ្គល ក្រុម ឬរហូតដល់កម្រិតប្រទេស និងប្រទេស និងបង្កើតភាពចលាចល សង្គ្រាម និងការបំផ្លិចបំផ្លាញគ្នាទៅវិញទៅមកផងដែរ។ ដូច្នេះតាមរយៈសិក្ខាសាលានេះ សម្តេចបានថ្លែងថា វានឹងជាឱកាសសម្រាប់ពិភាក្សាគ្នាឲ្យបានល្អិតល្អន់ ដើម្បីលើកកម្ពស់សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ជនទេសន្តរប្រវេសន៍ និងវិធី

សាស្ត្រល្អៗ ក្នុងការគ្រប់គ្រងស្ថានភាពលំហូរទេសន្តរប្រវេសន៍ ឆ្លងកាត់ព្រំដែន ដែលបាន និងកំពុងក្លាយជាប្រធានបទ ក្តៅគគុក មួយ ដែលត្រូវយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លា។

ទាក់ទងកម្ពុជា សម្តេចបានថ្លែងថា ដោយកម្ពុជា ជាប្រទេសប្រភព នៃទេសន្តរប្រវេសន៍ និងទេសន្តរប្រវេសន៍ឆ្លងកាត់ យើងត្រូវរួមចំណែកគិតគូរ រកឲ្យឃើញ នូវតម្រូវការចាំបាច់ដែលរលូន និងឯកភាពគ្នា សម្រាប់អនុវត្តជាមួយប្រទេសពាក់ព័ន្ធទាំងឡាយលើពិភពលោក ក្នុងការផ្តល់នូវសុវត្ថិភាព ភាពស្របច្បាប់ សិទ្ធិ និងផលប្រយោជន៍ ឲ្យបានសមស្របដល់ជនទេសន្តរប្រវេសន៍ និងក្រុមគ្រួសាររបស់ពួកគេ៕ ដោយៈ កែវ រំចង់

## លោក ស ខេង បង្កើតក្រុមវាយតម្លៃផលប៉ះពាល់ពលករចំណាកស្រុក

http://www.phnompenh-post-news.html Wed, 11 October 2017 គង់ មេត្តា and Yesenia Amaro

**ភ្នំពេញៈ** លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកាលពីម្សិលមិញបានប្រកាសបង្កើតក្រុមវាយតម្លៃមួយដែលមានតំណាងមកពីនាយកដ្ឋានអត្តសញ្ញាណកម្ម និងទេសន្តរប្រវេសន៍នៃក្រសួងមហាផ្ទៃ និងក្រសួងការងារដើម្បីសិក្សាអំពីបញ្ហាដែលប៉ះពាល់ដល់ពលករចំណាកស្រុកកម្ពុជា ហើយផ្តល់អនុសាសន៍ដើម្បីកែលម្អបញ្ហាទាំងនេះ។ ការប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានធ្វើឡើងក្នុងអំឡុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីកតិកាសញ្ញាជាសកលស្តីពីទេសន្តរប្រវេសន៍ ប្រកបដោយសុវត្ថិភាព ភាពស្របច្បាប់ និងប្រក្រតីភាព។ លោក ខេង ថ្លែងថាពលករចំណាកស្រុកកម្ពុជាខុសច្បាប់ជាមធ្យម ១០០ នាក់ត្រូវបាននិរទេសមកពីប្រទេសថៃជារៀងរាល់ថ្ងៃ។ លោកសួរថា៖ «តើយើងនឹងដោះស្រាយបញ្ហានេះជារៀងរាល់ថ្ងៃដូចម្តេច?»។

«យើងត្រូវការសិក្សា [បញ្ហានេះ] ហើយស្វែងរកដំណោះស្រាយ។ យើងមិនទម្លាក់កំហុសលើពួកគេទេយើងមានអារម្មណ៍អាណិតពួកគេពីព្រោះពួកគេមិនយល់អំពី [ដំណើរការ] ហើយពួកគេជឿតាមមេខ្យល់ដែលយកប្រយោជន៍ពីពួកគេ។ យើងមានអារម្មណ៍សោកស្តាយចំពោះពួកគេ ហើយយើងមិនគួរទុកពួកគេដូច្នោះទេ»។ ដើម្បីដោះស្រាយបញ្ហានេះលោក ខេង បានឲ្យបង្កើតក្រុមវាយតម្លៃថ្មីដើម្បីនិយាយទៅកាន់ពលករចំណាកស្រុកផ្ទាល់ និងសួរសំណួរពួកគេដូចជា តើពួកគេមកពីណា? តើមូលហេតុអ្វីបណ្តាលឲ្យពួកគេចំណាកស្រុក? តើនរណាយកពួកគេទៅប្រទេសថៃ? តើពួកគេពិតជាមានការងារឬអត់? លោកបានថ្លែងបន្តថា៖ «យើងត្រូវការស្វែងរកប្រភពព័ត៌មានទាំងនោះ ហើយបន្ទាប់មកយើងអាចកំណត់យុទ្ធសាស្ត្រសមស្របមួយ»។ ក្រុមវាយតម្លៃនេះនឹងផ្តល់អនុសាសន៍ដល់ក្រសួងមហាផ្ទៃ និងក្រសួងការងារអំពីរបៀបដំណើរការឯកសារចំណាកស្រុកដែលមានលក្ខណៈសាមញ្ញ។ លោក ខេង បានថ្លែងថាក្រុមមន្ត្រីក៏កំពុងពិចារណាលទ្ធភាពបើកការិយាល័យលិខិតឆ្លងដែនមួយនៅប៉ោយប៉ែត និងបាត់ដំបងនៅស្នងការដ្ឋាននគរបាលខេត្ត ឬនៅច្រកព្រំដែនអន្តរជាតិដើម្បីបង្កភាពងាយស្រួលដល់កម្មករ។ ទោះយ៉ាងណាក្តីនោះនឹងមិនដោះស្រាយបញ្ហារបស់កម្មករបាននៅឡើយទេ ដោយសារកម្មករនៅត្រូវការទិដ្ឋាការ និងប័ណ្ណការងារ។

លោក ឃុន ថារ៉ូ នៅមជ្ឈមណ្ឌលសាមគ្គីដែលជាអង្គការសិទ្ធិការងារបានថ្លែងថាវាជាការល្អដែលមានក្រុមពិនិត្យមើលបញ្ហាចំណាកស្រុក។ ទោះយ៉ាងណាក្តី ក្រុមនេះត្រូវពិនិត្យមើលឲ្យលើសពីបញ្ហាមូលដ្ឋានដែលប៉ះពាល់ដល់ពលករចំណាកស្រុកដូចជា ការការពារផ្នែកសង្គម និងលក្ខខណ្ឌរស់នៅ។ លោកបន្តថា៖ «អ្នកមិនអាចបញ្ឈប់ប្រជាពលរដ្ឋមិនឲ្យចំណាកស្រុកបានទេដោយសារកត្តាសេដ្ឋកិច្ច»។

លោក Federico Barreras អ្នកគ្រប់គ្រងគម្រោងសម្រាប់វិទ្យាស្ថានបើកទូលាយសង្ឃឹមថាសិក្ខាសាលាដែលកំពុងធ្វើឡើងស្តីពីបញ្ហាទេសន្តរប្រវេសន៍នឹងពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេស និងប្រទេសដែលមាន

លក្ខណៈសំខាន់ផងដែរ។ លោកថ្លែងថា៖ «ខ្ញុំសង្ឃឹមថាប្រទេសនានាក្នុងតំបន់អាចយល់ដឹងប្រសើរជាងមុនអំពីបញ្ហារបស់ប្រទេសមួយទៀត»។

លោក ថារ៉ូ បានបន្ថែមថា ប៉ុន្តែរដ្ឋាភិបាលកម្ពុជាគួរចាប់ផ្ដើមគិតអំពីការអនុវត្តប្រាក់ឈ្នួលអប្បបរមានៅក្នុងឧស្សាហកម្មដទៃៗផងដែរក្រៅពីវិស័យកាត់ដេរ ហើយគួរពិនិត្យធ្វើឲ្យវិស័យក្រៅប្រព័ន្ធមួយចំនួនដូចជាវិស័យសំណង់ក្លាយជាវិស័យក្នុងប្រព័ន្ធផងដែរ៕ PS

## ធនាគារពិភពលោក ថាជនបរទេសហូរចូលស្រុកខ្មែរខណៈពលរដ្ឋខ្មែរនាំគ្នាទៅក្រៅស្រុក

http://www.rfa.org/khmer/news/ ដោយ អាស៊ីសេរី 2017-10-10

ធនាគារពិភពលោក ថា ជនបរទេសហូរចូលស្រុកខ្មែរ ស្របពេលពលរដ្ឋខ្មែរ នាំគ្នាធ្វើចំណាកស្រុកទៅក្រៅប្រទេសកាន់តែមានចំនួនកើនឡើង។ របាយការណ៍ធនាគារពិភពលោកស្ដីពី «ចំណាកស្រុកដើម្បីស្វែងរកឱកាស៖ ជម្នះឧបសគ្គចំពោះបម្លាស់ទីពលកម្មក្នុងតំបន់អាស៊ីអាគ្នេយ៍» ចេញផ្សាយថ្ងៃទី៩ ខែតុលា នេះ ឲ្យដឹងថា ក្នុងចន្លោះឆ្នាំ១៩៩៥ ដល់ឆ្នាំ២០១៥ ប្រទេសថៃ ម៉ាឡេស៊ី និងសិង្ហបុរី បានក្លាយជាប្រទេសគោលដៅចម្បងនៃការធ្វើចំណាកស្រុកក្នុងតំបន់អាស៊ាន ដែលបានស្រូបយក ៩៦ភាគរយ នៃចំនួនជនចំណាកស្រុកសរុបក្នុងតំបន់អាស៊ានជាង ៦,៥លាននាក់។ របាយការណ៍ឲ្យដឹងថា ប្រទេសកម្ពុជា ឡាវ ម៉ាឡេស៊ី និងភូមា គឺជាប្រទេសដែលបញ្ជូនពលករចំណាកស្រុក ទៅធ្វើការក្នុងប្រទេសដទៃទៀតក្នុងតំបន់អាស៊ាន ច្រើនជាងគេបំផុត។ ភាគច្រើននៃពលករចំណាកស្រុកមកពីប្រទេសកម្ពុជា (៩៨%) ឡាវ (៩៩%) និងភូមា (៨៨%) ជ្រើសរើសយកប្រទេសថៃ ធ្វើជាគោលដៅចម្បងដើម្បីស្វែងរកការងារធ្វើក្នុងវិស័យកសិកម្ម បម្រើការតាមផ្ទះ សំណង់ និងរោងចក្រជាដើម។

របាយការណ៍គូសបញ្ជាក់ថា ខណៈប្រទេសកម្ពុជា ជាប្រទេសមួយដែលល្បីខាងបញ្ជូនពលករចំណាកស្រុកទៅធ្វើការងារក្នុងតំបន់អាស៊ាន ប្រទេសវៀតណាម បានបញ្ជូនជនចំណាកស្រុករបស់ខ្លួន តាមរយៈការឆ្លងកាត់ព្រំដែនចូលមកប្រទេសកម្ពុជា ដើម្បីធ្វើការក្នុងវិស័យនេសាទ និងសំណង់។ ក្នុងឆ្នាំ២០១៥ ពលករចំណាកស្រុកវៀតណាមស្មើនឹង ២៦% នៃចំនួនសរុបជិត ១សែន ៥ម៉ឺននាក់ នៃជនជាតិវៀតណាមដែលធ្វើចំណាកស្រុក ទៅធ្វើការក្នុងតំបន់អាស៊ាន បានធ្វើចំណាកស្រុកចូលមកកាន់ប្រទេសកម្ពុជា។ ប្រទេសហ្វីលីពីន និងប្រទេសវៀតណាម គឺជាប្រទេសប្លែកពីគេក្នុងតំបន់អាស៊ាន ដែលភាគច្រើននៃពលករចំណាកស្រុករបស់ខ្លួន បានធ្វើចំណាកស្រុកទៅធ្វើការក្នុងប្រទេសផ្សេងដទៃទៀតក្រៅពីប្រទេសក្នុងតំបន់អាស៊ាន ក្នុងនោះមានប្រទេសនៅតំបន់អាមេរិកខាងជើង មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង។

របាយការណ៍គូសបញ្ជាក់ថា ពលករចំណាកស្រុកនៃប្រទេសអាស៊ាន នៅមានជំនាញទាប ភាគច្រើនគ្មានលិខិតស្នាមត្រឹមត្រូវ ហើយធ្វើបម្លាស់ទីដើម្បីស្វែងរកឱកាសសេដ្ឋកិច្ច។ តំបន់អាស៊ានអាចបង្កើតការងារដែលផ្ដល់ប្រាក់ចំណូលខ្ពស់ ក៏ប៉ុន្តែពលករមកពីប្រទេសក្នុងតំបន់នេះ នៅតែមិនអាចទាញយកប្រយោជន៍បានច្រើនអំពីឱកាសការងារទាំងនេះ។ ជារួម របាយការណ៍លើកឡើងថា នីតិវិធីស្ដីពីការធ្វើចំណាកស្រុក ឬទេសន្តរប្រវេសក៍នៅទូទាំងតំបន់អាស៊ាន នៅមានសភាពរឹតត្បិតនៅឡើយ។ ឧបសគ្គមួយចំនួនដូចជា ដំណើរការជ្រើសរើសពលករចំណាកស្រុក នៅមានតម្លៃថ្លៃ និងប្រើរយៈពេលយូរ ការរឹតត្បិតកូតាទៅលើចំនួននៃពលករបរទេសដែលត្រូវអនុញ្ញាតឲ្យធ្វើការក្នុងប្រទេសទទួល និងគោលនយោបាយការងារតឹងរ៉ឹង បានរារាំងដល់ជម្រើសធ្វើចំណាកស្រុករបស់ពលករ ហើយប៉ះពាល់ដល់សុខុមាលភាពពួកគេ។

លោក ស៊ុឌៀ សេតទី (Sudhir Shetty) ប្រធានសេដ្ឋកិច្ចវិទូរបស់ធនាគារពិភពលោក ប្រចាំតំបន់អាស៊ីប៉ូ ស៊ីហ្វិក មានប្រសាសន៍ថា ការជ្រើសរើសគោលនយោបាយដ៏ត្រឹមត្រូវ អាចឲ្យប្រទេសបញ្ជូនពលករចេញ ទទួលបានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចពីចំណាកស្រុកទៅក្រៅប្រទេស។ លោកថា ដោយឡែកក្នុងប្រទេសទទួល យកពលករបរទេស អាចបំពេញនូវកង្វះខាតកម្លាំងពលកម្ម និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ប្រសិនបើគោលនយោបាយទេសន្តរប្រវេសន៍ដើរស្របគ្នាជាមួយនឹងតម្រូវការផ្នែកសេដ្ឋកិច្ច៕

## ពលករកម្ពុជានៅថៃ មានចំនួនជាង ១លាននាក់

http://kleykley.sabay.com.kh/article/ ច័ន្ទ, 9 តុលា 2017 21:03

លោកទេសរដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជាក់ថា ពលករកម្ពុជានៅប្រទេសថៃមានចំនួនជាង ១លាននាក់ ដែលក្នុងនោះ មានប្រមាណ ១ភាគ៣ប៉ុណ្ណោះ ដែលជា ពលករស្របច្បាប់ និង ២ភាគ៣ទៀត គឺជាពលករដែលមិនទាន់មានលក្ខណៈស្របច្បាប់នៅឡើយ។ ការថ្លែង បញ្ជាក់នេះ បានធ្វើឡើងនៅក្នុងជំនួបពិភាក្សាជាមួយលោកស្រី Nenette MOTUS នាយកប្រចាំតំបន់អាស៊ី និងប៉ា ស៊ីហ្វិកនៃអង្គការទេសន្តប្រវេសន៍អន្តរជាតិ (IOM) នៅទីស្តីការក្រសួងការបរទេស នៅរសៀលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ នេះ។ លោករដ្ឋមន្ត្រីបានបន្តថា រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែង ក្នុងដំណើរការធ្វើឲ្យពលករ ខ្មែរនៅប្រទេសថៃទាំងអស់ទទួលនៅស្ថានភាពស្របច្បាប់ ក្នុងការរស់នៅ និងការបំពេញការងារនៅប្រទេសថៃ។

លោកទេសរដ្ឋមន្ត្រី ប្រាក់ សុខុន បានបន្តទៀតថា កិច្ចសហប្រតិបត្តិការដ៏ល្អរវាងអង្គការទេសន្តប្រវេសន៍ អន្តរជាតិ មានសារៈសំខាន់ និងសារៈប្រយោជន៍យ៉ាងច្រើននៅក្នុងការជួយដល់ពលករខ្មែរ ដែលកំពុងតែបំពេញ ការងារនៅប្រទេសថៃ។ លោករដ្ឋមន្ត្រី ក៏បានអរគុណអង្គការទេសន្តប្រវេសន៍អន្តរជាតិ ដែលបានផ្តល់កិច្ចសហការ យ៉ាងល្អនៅលើបញ្ហានេះ ពិសេសការផ្តល់នៅសំបុត្រយន្តហោះជូនដល់ពលករខ្មែរ និងស្ត្រីរងគ្រោះខ្មែរក្នុងដំណើរ ការធ្វើមាតុភូមិនិវត្តន៍ត្រឡប់មកកម្ពុជាវិញ៕

## ថៃបញ្ជូនសពពលករខ្មែរ២នាក់ ប្រគល់ឲ្យសាច់ញាតិ

https://kohsantepheapdaily.com.kh/article/ ដោយ ៖ ម៉ុត សារុន ថ្ងៃអង្គារ (10-10-2017 22:50)

ខេត្តបន្ទាយមានជ័យ ៖ សាកសពពលករខ្មែរចំនួន២នាក់ ត្រូវបានភាគីថៃធ្វើការបញ្ជូនប្រគល់ឲ្យសាច់ញាតិ នៅល្ងាច និងយប់ថ្ងៃទី១០ តុលា ២០១៧នេះ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត បន្ទាប់ពីពលករទាំង២រូបនោះបាន ស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ និងខ្យល់គ នៅខេត្តរ៉ាក់យ៉ង និងខេត្តឈុនបូរី ប្រទេសថៃ។ជនរងគ្រោះដោយគ្រោះ ថ្នាក់ចរាចរណ៍ឈ្មោះ អឿង សុផូង ភេទប្រុស អាយុ១៦ឆ្នាំ មានទីលំនៅភូមិធ្លក ឃុំត្រាំសសរ ស្រុកស្រីស្នំ ខេត្ត សៀមរាប។ ដោយសាច់សាច់ញាតិប្រញាប់ដឹកសពចេញមិនបានប្រាប់ពីមូលហេតុនៃកាគ្រោះថ្នាក់ចរាចរណ៍ និង ការងាររបស់ជនរងគ្រោះឡើយ បានត្រឹមតែប្រាប់ថា ជនរងគ្រោះត្រូវរថយន្តបុកស្លាប់កាលពីវេលាម៉ោងជិត៦ព្រឹក ថ្ងៃទី១០ តុលា ២០១៧នេះ នៅខេត្តរ៉ាក់យ៉ង។

ដោយឡែកសពស្លាប់ដោយជំងឺខ្យល់គឈ្មោះ ប៉ូ ចូច ភេទប្រុស អាយុ៣៤ឆ្នាំ ជាកម្មករស៊ីឈ្នួលលក់បាយ ម្ហូបឲ្យជនជាតិថៃ នៅខេត្តឈុនបូរី និងមានទីលំនៅភូមិទួលខ្លុង ឃុំអូរសោរ៉ាយ ស្រុកត្រាំកក់ ខេត្តតាកែវ។សាច់ ញាតិប្រាប់ថា ជនរងគ្រោះក្រោយញ៉ាំបាយរួចម៉ោងជិត១១យប់ ថ្ងៃទី៩ តុលា ២០១៧ ដើរទៅបន្ទប់ទឹក ស្រាប់តែ

មានអាការៈវិលមុខដួល ហើយស្លាប់ពេលបញ្ជូនទៅមន្ទីរពេទ្យតែម្តង។ សពទាំង២ ក្រោយពីភាគីថៃបញ្ជូនដល់កម្ពុជា ក្រុមសាច់ញាតិបានដួលរថយន្តដឹកបន្តទៅស្រុកកំណើត ដើម្បីធ្វើបុណ្យតាមប្រពៃណី៕

## ពលរដ្ឋខ្មែររស់នៅក្នុងខេត្តបន្ទាយមានជ័យម្នាក់ ត្រូវសមត្ថកិច្ចថៃចាប់ខ្លួន

http://pheaktraprak.com/archives/ By เพียะตรา ประ October 10, 2017

ខេត្តស្រះកែវ÷ ពលរដ្ឋកម្ពុជាម្នាក់ត្រូវបានកម្លាំង អភិរក្សសត្វព្រៃឧទ្យានជាតិបាងស៊ីដា ស្ថិតនៅក្នុងស្រុកវ៉ាត់ណា ខេត្តស្រះកែវ ប្រទេសថៃធ្វើការចាប់ខ្លួន បន្ទាប់ពីពលរដ្ឋខ្មែររូបនោះចូលទៅកាប់ឈើគ្រញូងខុសច្បាប់នៅក្នុងទឹកដីថៃ។ ពលរដ្ឋកម្ពុជាដែលត្រូវកម្លាំងអភិរក្សសត្វព្រៃថៃចាប់នោះមានឈ្មោះ អឿន ទា អាយុ 50ឆ្នាំ សញ្ជាតិខ្មែររស់នៅក្នុងខេត្តបន្ទាយមានជ័យ។

យោងតាមប្រភពព័ត៌មានថៃបានអោយដឹងថា កាលពីថ្ងៃទី08 ខែតុលា ឆ្នាំ2017 កម្លាំងអភិរក្សសត្វព្រៃនៅក្នុងឧទ្យានជាតិបាងស៊ីដា បានធ្វើការល្បាតព្រៃអភិរក្សខាងលើ បានជួបប្រទះឃើញពលករខ្មែរប្រមាណជាង10នាក់កំពុងស្នាក់នៅក្នុងព្រៃនិងកន្លែងកើតហេតុ ចូលឃាត់ខ្លួនតែពលករខ្មែរទាំងអស់នោះបាននាំគ្នារត់ចូលក្នុងព្រៃគេចខ្លួនបាត់អស់ នៅសល់តែបុរសឈ្មោះអឿនទារត់មិនទាន់ក៏ត្រូវបានកម្លាំងសមត្ថកិច្ចថៃចាប់ខ្លួនបានតែម្តង។

## ជិះឡានម៉ៅទៅផ្ទះ ត្រូវទាហានចាប់តាមផ្លូវទៀត

http://pheaktraprak.com/archives/ By เพียะตรา ประ October 9, 2017

ខេត្តស្រះកែវ÷ កាលពីថ្ងៃច័ន្ទ ទី09 ខែតុលា ឆ្នាំ2017 កម្លាំងអាជ្ញាធរ ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃធ្វើការឃាត់រថយន្តស៊ីឈ្នួលដឹកពលករខ្មែរពីទីក្រុងបាងកកទៅព្រំដែនកម្ពុជា។ ករណីបង្ក្រាបរថយន្តស៊ីឈ្នួលដឹកកម្មករបរទេសទៅព្រំដែននេះ បានកើតឡើងនៅត្រង់ចំណុចភូមិណងមួង ស្រុកគោកសូង ខេត្តស្រះកែវ រថយន្តដែល កម្លាំងអាជ្ញាធរថៃ ចាប់នោះម៉ាក Chevrolet មួយបាងដាក់ទ្រុងពីក្រោយ បើកបរដោយយុវជនថៃរស់នៅក្នុងខេត្តប៉ាក់យ៉ងម្នាក់ ក្នុងការឆែកឆេរនៅក្នុងរថយន្ត អាជ្ញាធរថៃរកឃើញពលករកម្ពុជាប្រុសស្រីចំនួន 9នាក់ នៅខាងក្រោយរថយន្ត ក្នុងនោះមានមនុស្សប្រុស 3នាក់ មនុស្សស្រី 4នាក់កុមារី2នាក់។

យោងតាមប្រភពព័ត៌មានថៃបានចុះផ្សាយឲ្យដឹងថា ពលករកម្ពុជាទាំងអស់ធ្វើការខុសច្បាប់នៅទីក្រុងបាងកក ហើយដោយសារតែមួយរយៈពេលនេះកម្លាំងសមត្ថកិច្ចថៃ បានធ្វើការចុះបង្ក្រាបរាល់ថ្ងៃ ដោយសារភ័យខ្លាចត្រូវតម្រួតថៃចាប់ ពួកគាត់បាននាំគ្នាធ្វើដំណើរវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ ដោយហៅរថយន្តម៉ៅអោយមកទទួលដឹកទៅព្រំដែនក្នុងតំលៃមនុស្សម្នាក់1800฿ ។ ក្រោយធ្វើការការសាកសួររួចពលករកម្ពុជាទាំងអស់ត្រូវបានអាជ្ញាធរថៃប្រគល់ជូនតម្រួតអន្តោប្រវេសន៍ស្រុកអារញ្ញយកទៅចាត់វិធានការតាមផ្លូវច្បាប់។

## ស្ថានទូតកម្ពុជានៅម៉ាឡេស៊ីអន្តរាគមន៍ជួយពលករ-ពលការិនីខ្មែរ១៧នាក់

http://www.nokor-wat-news.html ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៧

ភ្នំពេញ៖ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៧ ក្រសួងការបរទេសបានប្រកាសថា ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានអន្តរាគមន៍ជួយរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន១៧នាក់ ។

កម្មករ កម្មការិនីទាំងនោះ ដូចមានរាយនាមខាងក្រោមៈ
(១) ពលការិនី ឈិន ឡាញ់ អាយុ ៣៤ឆ្នាំ មកពីស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
(២) ពលការិនី ផាត់ សូរិយា អាយុ ២៧ឆ្នាំ មកពីស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
(៣) ពលករ ឈិត ជី អាយុ ៣៦ឆ្នាំ មកពីស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
(៤) ពលករ ហុង ពុទ អាយុ ២០ឆ្នាំ មកពីស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
(៥) ពលករ កូប ម៉ាត់អាលី អាយុ ២១ឆ្នាំ មកពីស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
(៦) ពលករ កៅ ស៊ុបអ៊ី អាយុ ៣០ឆ្នាំ មកពីស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
(៧) ពលករ វ៉េត នុត អាយុ ២៤ឆ្នាំ មកពីស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
(៨) ពលករ ឡុង ឡន អាយុ ៤៥ឆ្នាំ មកពីស្រុកក្រចេះ ខេត្តក្រចេះ
(៩) ពលករ សៀង សំអាត អាយុ ៣៥ឆ្នាំ មកពីស្រុកក្រចេះ ខេត្តក្រចេះ
(១០) ពលការិនី ឡន ស្រីឡី អាយុ ២០ឆ្នាំ មកពីស្រុកក្រចេះ ខេត្តក្រចេះ
(១១) ពលការិនី ម៉ា សុភាន់ អាយុ ២៦ឆ្នាំ មកពីស្រុកចំការលើ ខេត្តកំពង់ចាម
(១២) ពលការិនី សេង នៅរីយះ អាយុ ៣០ឆ្នាំ មកពីខេត្តកំពង់ចាម
(១៣) ពលការិនី សូត្រ ពន់ អាយុ ៣៥ឆ្នាំ មកខេត្តតាកែវ
(១៤) ពលករ នុន គា អាយុ ២៣ឆ្នាំ មកពីស្រុកសៀមបូក ខេត្តស្ទឹងត្រែង
(១៥) ពលការិនី លី រដ្ឋា អាយុ២២ឆ្នាំ មកពីស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ
(១៦) ពលការិនី អ៊ូច ចន្ទ្រា អាយុ២៧ឆ្នាំ មកពីស្រុកកំពង់ហាវ ខេត្តកំពង់ឆ្នាំង និង
(១៧) ពលការិនី ប៊ុន ពិសី អាយុ២៩ឆ្នាំ មកពីស្រុកត្រាំកក់ ខេត្តតាកែវ

ក្រសួងការបរទេសបញ្ជាក់ថា ពលករ-ពលការិនី១៤នាក់ (លេខរៀងទី១ដល់១៤) បានធ្វើដំណើរតាមរថយន្តឆ្លងកាត់ប្រទេសថៃ ទៅធ្វើការនៅរោងចក្រប្លាស្ទិក នៅរដ្ឋ Johor ប្រទេសម៉ាឡេស៊ី កាលពីឆ្នាំ២០១៦ តាមរយៈមេខ្យល់។ ដោយចង់ត្រឡប់មកកម្ពុជាវិញ ពួកគេបានទៅស្នើសុំស្ថានទូតជួយអន្តរាគម នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១៧ ។

ប្រភពបន្តទៀតថា ពលការិនី២នាក់ (លេខរៀងទី១៥និង១៦) បានធ្វើដំណើរតាមរថយន្តឆ្លងកាត់ប្រទេសថៃដោយខ្លួនឯង និងធ្វើការងារតាមផ្ទះនៅម៉ាឡេស៊ី កាលពីឆ្នាំ២០១៥។ ចំណែកពលការិនីលេខរៀងទី១៧ បានទៅធ្វើការងារតាមផ្ទះនៅម៉ាឡេស៊ី កាលពីខែតុលា ឆ្នាំ២០១៥ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយចង់ត្រឡប់មកកម្ពុជាវិញ ពួកគេបានស្នើសុំកិច្ចអន្តរាគមន៍ពីស្ថានទូតនៅថ្ងៃទី០២ និងទី០៣ ខែតុលា ឆ្នាំ២០១៧។

ពលករ-ពលការិនី១៦នាក់ (លេខរៀងទី១ដល់១៦) បានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង០៧:៣៥នាទីព្រឹក តាមជើងយន្តហោះ AK536 ។ រីឯ ពលការិនី ប៊ុន ពិសី បានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង១២:៥៥នាទីរសៀល តាមជើងយន្តហោះ AK538 ។

ក្នុងអំឡុងពេលរង់ចាំត្រឡប់មកកម្ពុជាវិញ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ អាហារបរិភោគ ចេញលិខិតធ្វើដំណើរ និងសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ជូនពលករ-ពលការិនីទាំង១៧នាក់ផងដែរ។ ឋាច់ យ៉ាត

# ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧
# សង្គមស៊ីវិលថា ក្រសួងគួរបង្កើតកន្លែងធ្វើលិខិតឆ្លងដែននៅខេត្តផ្សេងក្រៅពីបន្ទាយមានជ័យ និងបាត់ដំបង

http://km.rfi.fr/cambodia/civil ដោយ អេង គីមហុង 11/10/2017

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង នៅថ្ងៃទី១០ខែតុលាម្សិលមិញ បានបង្ហើបពីគម្រោងបង្កើតការិយាល័យធ្វើលិខិតឆ្លងដែននៅខេត្តជាប់ព្រំដែនថៃ គឺបន្ទាយមានជ័យ និងបាត់ដំបង។ ចំណែកសង្គមស៊ីវិលថា ក្រសួងគួរសិក្សាលើគម្រោងបង្កើតការិយាល័យធ្វើលិខិតឆ្លងដែន នៅខេត្តផ្សេងទៀតក្រៅពីបន្ទាយមានជ័យ និងបាត់ដំបង។

លោក សន ជ័យ ប្រធានអង្គការសម្ព័ន្ធគណនេយ្យសង្គមចាត់ទុកនេះគឺជាដំណើរការវិវត្តន៍មួយដ៏ល្អដែលក្រសួងមានគម្រោងបង្កើតការិយាល័យធ្វើលិខិតឆ្លងដែននៅខេត្តជាប់ព្រំដែន។ ប៉ុន្តែលោក សន ជ័យ បន្តផ្ដល់យោបល់ថា ក្រសួងគួរតែប្រមើមើល ដោយសិក្សាទៅលើការដាក់ការិយាល័យធ្វើលិខិតឆ្លងដែននេះ នៅចំណុចកណ្ដាលនៃខេត្តជាប់ព្រំដែនបន្តទៀតដូចជាខេត្តក្រចេះ គឺងាយស្រួលពលរដ្ឋឡើងពីខេត្តរតនគិរី និងមណ្ឌលគិរីមកធ្វើលិខិតឆ្លងដែននេះនៅក្រចេះ។ ក្រៅពីក្រចេះ គួរតែចាប់អារម្មណ៍ខេត្តកោះកុងមួយទៀតនៅក្នុងការដាក់ការិយាល័យធ្វើលិខិតឆ្លងដែន។ នេះបើតាមលោក សន ជ័យ ។ តែអ្នកនាំពាក្យក្រសួងមហាផ្ទៃបានឲ្យដឹងថា មន្ត្រីជំនាញកំពុងសិក្សាលើគម្រោងដាក់ការិយាល័យក្នុងខេត្តបាត់ដំបង និងបន្ទាយមានជ័យសិន។

ចំពោះលោកឧបនាយករដ្ឋមន្ត្រី ស ខេង បានគូសបញ្ជាក់ថា នៅពេលដាក់ឲ្យដំណើរ ការិយាល័យធ្វើលិខិតឆ្លងដែននេះហើយ គឺមន្ត្រីជំនាញត្រូវធ្វើឯកសារចំនួនពីរជូនពលរដ្ឋក្នុងរយៈពេលតែមួយថ្ងៃទេ ត្រូវធ្វើឲ្យហើយចំពោះវីសាការងារ និងលិខិតឆ្លងដែន។ លោក ស ខេង ក៏បានរម្លឹកទៅអាជ្ញាធរមិនត្រូវប្រថុយប្រថានទៀតទេលើរឿងនេះពេលបើមានលិខិតឆ្លងដែន ក៏ត្រូវមានវីសាការងារដែរ។ លោកឧបនាយករដ្ឋមន្ត្រី ស ខេង ក៏បានលើកទឹកចិត្តទៅអាជ្ញាធរឲ្យរកដំណោះស្រាយកុំឲ្យកើតមានរឿងដដែល នៅពេលទៅធ្វើការនៅក្រៅប្រទេស ត្រូវបានបញ្ជូនត្រឡប់មកវិញ ក្រោមមូលហេតុថា គ្មានលិខិតស្នាមត្រឹមត្រូវ។ លោករដ្ឋមន្ត្រីទទួលស្គាល់ថា ពលរដ្ឋដែលទៅធ្វើការខុសច្បាប់នៅថៃ មិនមែនទៅតាមច្រកអន្តរជាតិទេ ពួកគេបានធ្វើដំណើរលួចលាក់តាមច្រករបៀង។

ចំណែក លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារឲ្យដឹងថា បច្ចុប្បន្នពលរដ្ឋខ្មែរកំពុងធ្វើការនៅប្រទេសថៃមានចំនួន១លាន៥ម៉ឺននាក់។ ក្នុងនោះ៣០ម៉ឺននាក់នៅមិនទាន់មានឯកសារត្រឹមត្រូវនៅឡើយទេ ប៉ុន្តែក្រសួងការងារបានសម្រេចបង្កើតការិយាល័យផ្ដល់ភាពស្របច្បាប់ដល់ពលករខ្មែរ នៅក្នុងទីតាំងបីកន្លែងនៅក្នុងប្រទេសថៃរួមមានៈ ខេត្តស៊ុងក្លា រ៉ាក់យ៉ង និងបាងកក។ ដំណើរការផ្ដល់ភាពស្របច្បាប់នេះនឹងចាប់ផ្ដើមនៅថ្ងៃទី១២ខែតុលាស្អែកនេះ៕

## បើកធ្វើប៉ាស្ព័រជូនពលករខ្មែរថ្ងៃដំបូង មនុស្សឡើងណែន

http://pheaktraprak.com/archives/ By เพียะตรา ประ October 12, 2017

បើកធ្វើប៉ាស្ព័រជូនពលករកម្ពុជាថ្ងៃដំបូង មនុស្សឡើងទីតាំងទីក្រុងបាងកកប្រទេសថៃ ថ្ងៃទី12.10.2017 ថ្ងៃនេះជាថ្ងៃដំបូងដែលគណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជា ចាប់ផ្តើមបើកត្រួតអត្តសញ្ញាណជូនបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅធ្វើការក្នុងប្រទេសថៃ ដោយឡែកនៅក្នុងទីតាំងនីមួយៗដែលគណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជា បានកំណត់នៅក្នុងខេត្តរ៉ាក់យ៉ង, ទីក្រុងបាងកក, ស្រុកហាត់យៃខេត្តសង់ក្លា ។ នៅវេលាព្រឹកនេះទីតាំងដែលមាននិយោជកជូនពលករទៅធ្វើប៉ាស្ព័រច្រើនជាងគេគឺទីតាំងហាង(អីមផូលៀបឡាតប្លាវ)ជាន់ទី4 យើងឃើញថាទីតាំងនេះមានមនុស្សច្រើនជាងទីតាំងខេត្តរ៉ាក់យ៉ង។ ហើយព្រឹកនេះ គណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជា បានធ្វើប៉ាស្ព័រជូនបងប្អូនពលករកម្ពុជាដែលមានប័ណ្ណស៊ីជម្ពូធ្វើការទូទៅ,ប័ណ្ណស៊ីជម្ពូធ្វើការនេសាទ, និងបងប្អូនពលករ កម្ពុជាដែលបានសម្ភាសន៍រួចរាល់ ។ ដូចការជំរាបជូនខាងលើសូមបងប្អូនពលករកម្ពុជាយើងទាំងអស់ត្រៀមខ្លួននិងឯកសារដើម្បីទៅធ្វើប៉ាស្ព័រអោយបានត្រឹមត្រូវដូចដែល គណៈកម្មការផ្តល់ភាពស្របច្បាប់កម្ពុជាបានប្រកាស។

## សមត្ថកិច្ចថៃជួយរំដោះពលការនីអាយុក្រោម 18ឆ្នាំ ចំនួន 8នាក់ ពីហាងលក់គុយទាវ

http://pheaktraprak.com/archives/ By เพียะตรา ประ October 11, 2017

ខេត្តឆាកឈើងសៅ÷ កាលពីថ្ងៃទី06 ខែតុលា ឆ្នាំ2017 កន្លងទៅថ្មីនេះកម្លាំងសមត្ថកិច្ចថៃ សហការជាមួយភ្នាក់ងារអង្គការLPN ក្នុងប្រទេសថៃ បានធ្វើចុះអន្តរាគមន៍រំដោះពលការនីសញ្ជាតិភូមា ជាអនីតិជនចំនួន 10នាក់ នៅក្នុងហាងលក់គុយទាវមួយកន្លែង ស្ថិតនៅក្នុងឃុំខៅជីន ស្រុកបាងប៉ាកុង ខេត្តឆាកឈើងសៅប្រទេសថៃ។ ក្នុងការចុះអន្តរាគមន៍ហាងលក់គុយទាវខាងលើនេះបានធ្វើឡើង បន្ទាប់ពីកម្លាំងសមត្ថកិច្ចមូលដ្ឋានថៃបានស្រាវជ្រាវដឹងថាហាងលក់គុយទាវ ខាងលើនេះបានជួលពលករដែលមានអាយុក្រោម18 ឆ្នាំចំនួន 8នាក់ និងគិតប្រាក់ឈ្នួលធ្វើការអោយពលករក្នុងតំលៃទៀប ខុសពីតំលៃដែលរាជរដ្ឋាភិបាលថៃបានកំណត់។ តាមការស្រាវជ្រាវរបស់សមត្ថកិច្ចថៃ បានឲ្យដឹងថា ម្ចាស់ហាងលក់គុយទាវខាងនេះ បានធ្លាប់ប្រើអំពើហឹង្សាលើនារីពលករបរទេសនោះផងដែរ បច្ចុប្បន្នសមត្ថកិច្ចថៃកំពុងកសាងសំណុំរឿងដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីចាត់វិធានការវិធានការលើម្ចាស់ហាងលក់គុយទាវខាងលើនេះ។

## ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧

## ពលករខ្មែរជាង1លាននាក់កំពុងរស់នៅ និងធ្វើការក្នុងប្រទេសថៃ

https://kohsantepheapdaily.com.kh/ ដោយ ៖ អ៊ាង ប៊ុនរិទ្ធ ថ្ងៃសុក្រ ( 13-10-2017 12:30 )

រាជធានីភ្នំពេញ ៖ ពលករទេសន្តប្រវេសន៍ខ្មែរជាង១លាននាក់កំពុងរស់នៅ និងធ្វើការងារក្នុងប្រទេសថៃ ក្នុងនោះមាន១ភាគ៣រស់នៅស្របច្បាប់ និង២ភាគ៣មិនស្របច្បាប់ ។ ទោះបីយ៉ាងណា ពេលនេះរាជរដ្ឋាភិបាលកំពុងខិតខំធ្វើឲ្យពលករខ្មែរទាំងនោះបានរស់នៅស្របច្បាប់ក្នុងប្រទេសជិតខាងមួយនេះ ។ នេះបើតាមការលើកឡើងរបស់លោកទេសរដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នារសៀលថ្ងៃ

ទី៩ តុលា កន្លងទៅ នៅទីស្តីការក្រសួង ក្នុងជំនួបជាមួយលោកស្រី Nenete Motus ប្រធានអង្គការទេសន្តប្រវេសន៍(IOM) ប្រចាំនៅតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។

លោក ជុំ សុន្ទរី អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានប្រាប់អ្នកសារព័ត៌មានថា ក្នុងជំនួបនេះភាគីទាំង២បានលើកឡើងពីបញ្ហាជនទេសន្តប្រវេសន៍កម្ពុជានិងបរទេស ដែលតែងតែផ្លាស់ប្តូរកន្លែងរស់នៅទាំងស្របច្បាប់ និងមិនស្របច្បាប់នៅលើពិភពលោកនេះ ដោយសារតែសង្គ្រាម ។

ក្នុងជំនួបនោះ លោកទេសរដ្ឋមន្ត្រី បានថ្លែងថា វត្តមានរបស់ពលករកម្ពុជានៅក្នុងប្រទេសថៃមានជាង១លាននាក់ ក្នុងនោះប្រមាណ១ភាគ៣ប៉ុណ្ណោះដែលជាពលករស្របច្បាប់ និង២ភាគ៣ទៀតជាពលករមិនទាន់មានលក្ខណៈស្របច្បាប់នៅឡើយ ។ ទោះបីយ៉ាងណា រាជរដ្ឋាភិបាលកម្ពុជា បានខិតខំក្នុងដំណើរការធ្វើឲ្យពលករខ្មែរនៅក្នុងប្រទេសថៃទាំងអស់ទទួលបានភាពស្របច្បាប់ក្នុងការរស់នៅ និងបំពេញការងារ ។

លោកទេសរដ្ឋមន្ត្រីបានបញ្ជាក់ជូនថា ៖« មូលហេតុដែលនាំឲ្យមានទេសន្តប្រវេសន៍កើតឡើង ដោយសារសាកលភាវូបនីយកម្ម និងគ្រោះមហន្តរាយដែលបង្កឡើងដោយធម្មជាតិ ធ្វើឲ្យប្រជាជនមួយចំនួនទៅកាន់ប្រទេសផ្សេងទៀត » ។

ក្នុងឱកាសនោះ លោកទេសរដ្ឋមន្ត្រីបានស្វាគមន៍ចំពោះលោកស្រីដែលត្រូវបានតែងតាំងជាប្រធានអង្គការ IOM ប្រចាំនៅតំបន់អាស៊ីនិងប៉ាស៊ីហ្វិកនេះ ក៏ដូចជាអបអរសាទរដែលអង្គការIOM បានក្លាយទៅជាអង្គការទេសន្តប្រវេសន៍របស់អង្គការសហប្រជាជាតិ(UNIOM) ។ លោកទេសរដ្ឋមន្ត្រីបានរំឭកថា អង្គការនេះបានសហការនិងជួយដល់ពលរដ្ឋកម្ពុជាដែលបានភៀសខ្លួននៅពេលមានសង្គ្រាមស៊ីវិលនៅកម្ពុជា ។ លោកទេសរដ្ឋមន្ត្រីបានអះអាងថា ៖« កិច្ចសហប្រតិបត្តិការរបស់អង្គការIOM គឺមានសារសំខាន់ណាស់ចំពោះពលករខ្មែរដែលកំពុងធ្វើការងារនៅប្រទេសថៃ » ។ លោកបានលើកឡើងពីការលំបាករបស់ស្ត្រីខ្មែរ និងពលករ ដែលបានរងគ្រោះដោយសារការជួញដូរមនុស្សទៅរស់នៅប្រទេសផ្សេងៗ ដែលប្រឈមនឹងការរំលោភបំពាន ។ ស្ថានទូតខ្មែរនៅទីនោះបានជួយពលកររងគ្រោះ និងអរគុណអង្គការIOM ដែលបានផ្តល់សំបុត្រយន្តហោះដល់ពលករខ្មែររងគ្រោះបានមកកម្ពុជាវិញ ។

លោកស្រីប្រធានអង្គការ IOM ថ្លែងថាលោកស្រីធ្លាប់ជាប្រធានអង្គការ IOM នៅកម្ពុជាពីឆ្នាំ១៩៩៨ដល់ឆ្នាំ២០០២ ។ ពេលនេះលោកស្រីបានមកកម្ពុជាម្តងទៀត និងបន្តសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា។ កម្ពុជាបានសហការល្អជាមួយ IOM ហើយអង្គការនេះនឹងបន្តជួយនិងសហការជាមួយរាជរដ្ឋាភិបាលកម្ពុជាទៀត ។ លោកស្រីបានលើកឡើងថា លោកស្រីក៏ដូចអង្គការIOM ប្តេជ្ញាបន្តកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការជួយដល់ជនទេសន្តប្រវេសន៍ ៕

## បើកយុទ្ធនាការបញ្ជាក់អត្តសញ្ញាណជូនពលកម្ពុជានៅថៃចាប់ពីថ្ងៃទី១២ ខែតុលា

http://www.rasmeinews.com/ October 13, 2017

ភ្នំពេញៈ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានប្រកាសឲ្យដឹងថា គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នឹងបើកយុទ្ធនាការបញ្ជាក់អត្តសញ្ញាណ ជូនពលករកម្ពុជាចាប់ពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧។ការបញ្ជាក់អត្តសញ្ញាណ គឺដើម្បីឲ្យពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ទទួលបានលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC)។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃបានឲ្យដឹងថា យោងតាមសេចក្តីជូនដំណឹងរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដដែលកំពុងស្នាក់នៅនឹងធ្វើការនៅប្រទេសថៃ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅថៃ សូមជូនដំណឹងដល់ពលករទាំងអស់ជ្រាបថា គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដដែលកំពុងស្នាក់នៅនឹងធ្វើការនៅប្រទេសថៃ នឹងធ្វើយុទ្ធនាការបញ្ជាក់អត្តសញ្ញាណជូនបងប្អូនពលករកម្ពុជា ដើម្បីទទួលបានលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស(TD)និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស(OCWC)ចាប់ពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ តទៅ ។

លោកទេសរដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិធ្លាប់បានបញ្ជាក់ថា ពលករកម្ពុជានៅប្រទេសថៃមានចំនួនជាងមួយលាននាក់ដែលក្នុងនោះមានប្រមាណ១ភាគ៣ប៉ុណ្ណោះដែលជាពលករស្របច្បាប់ និង២ភាគ៣ទៀត គឺជាពលករដែលមិនទាន់មានលក្ខណៈស្របច្បាប់នៅឡើយ។ ការថ្លែងបញ្ជាក់នេះ បានធ្វើឡើងនៅក្នុងជំនួបពិភាក្សាជាមួយលោកស្រី Nenette MOTUS នាយកប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការទេសសន្តរប្រវេសន៍អន្តរជាតិ (IOM) នៅទីស្តីការក្រសួងការបរទេស កាលពីរសៀលថ្ងៃទី៩ ខែតុលាកន្លងទៅ។ លោករដ្ឋមន្ត្រីបានបន្តថា រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែង ក្នុងដំណើរការធ្វើឲ្យពលករខ្មែរនៅប្រទេសថៃទាំងអស់ទទួលនៅស្ថានភាពស្របច្បាប់ ក្នុងការរស់នៅ និងការបំពេញការងារនៅប្រទេសថៃ៕MN/ដោយៈមុនីរ័ត្ន

## ដំណឹងត្រួតអត្តសញ្ញាណ ធ្វើប៉ាស្ព័រជូនពលករកម្ពុជា នៅទីស្នាក់ BigC ឡាតប្លាវ

http://pheaktraprak.com/archives/ By เพียะตรา ประ October 12, 2017

ទីស្នាក់ការត្រួតអត្តសញ្ញាណជូនពលករកម្ពុជានៅក្នុងក្រុងបាងកក ឈប់សម្រាករៀងរាល់ថ្ងៃសៅរ៍និងអាទិត្យ។ យោងតាមប្រភពព័ត៌មានពីសំណាក់និយោជកថៃ ដែលបាននាំពលករទៅត្រួតសញ្ជាតិនៅទីស្នាក់ការហាង BigC ឡាតប្លាវ បានអោយដឹងថា នៅរៀងរាល់ថ្ងៃអាទិត្យ គណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជានៅក្នុងទីតាំងខាងលើ មិនបានបើកដំណើរទេ ហើយគណៈកម្មការនិងបើកម្តងទៀតចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍ រៀងរាល់ម៉ោងធ្វើការ។ ក៏ប៉ុន្តែបងប្អូនពលករកម្ពុជាអាចមកធ្វើការទំនាក់ទំនងសុំលេខរៀង ដើម្បីចូលត្រួតសញ្ជាតិនៅថ្ងៃបន្តបន្ទាប់ ដែលគណៈកម្មការបើកដំណើរការអាស្រ័យហេតុនេះសូមបងប្អូនពលករកម្ពុជាទាំងអស់មេត្តាជ្រាបជាដំណឹង។

## រ៉ាក់យ៉ងបើកធ្វើប៉ាស្ព័រជូនពលករខ្មែរថ្ងៃដំបូង ឡើងណែនដល់យប់

http://pheaktraprak.com/archives/ By เพียะตรา ประ October 13, 2017

ពលករខ្មែរធ្វើការនៅក្នុងខេត្តរ៉ាក់យ៉ង ជិតមួយពាន់នាក់នាំគ្នាមករងចាំបញ្ជាក់អត្តសញ្ញាណធ្វើប៉ាស្ព័រ។ កាលពីថ្ងៃព្រហស្បតិ៍ ទី12 ខែតុលា ឆ្នាំ 2017 គណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជានៅក្នុងប្រទេសថៃ បានចាប់ផ្តើមបញ្ជាក់អត្តសញ្ញាណជូនបងប្អូនពលករកម្ពុជាដែលស្នាក់នៅធ្វើការក្នុងប្រទេសថៃ នៅថ្ងៃដំបូងមានដូចជានៅខេត្តរ៉ាក់យ៉ង,ទីក្រុងបាងកក, ខេត្តសង់ក្លា។ ក្នុងការបើកបញ្ជាក់អត្តសញ្ញាណជូនបងប្អូនពលករកម្ពុជានៅក្នុងប្រទេសថៃនាថ្ងៃនេះ បងប្អូនពលករកម្ពុជាស្នាក់នៅធ្វើក្នុងប្រទេសថៃ មកពីខេត្តផ្សេងចំនួនរាប់ពាន់នាក់នាំគ្នាមក បញ្ជាក់អត្តសញ្ញាណនៅទីតាំងនីមួយដែលគណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាបានប្រកាសនាពេលកន្លងមក។

ជាក់ស្តែងដូចជានៅទីស្នាក់ការផ្តល់ភាពស្របច្បាប់នៅហាង OTOP ម៉ាកយ៉ង ខេត្តរ៉ាក់យ៉ង មានបងប្អូនពលករខ្មែរយើងប្រមាណជិតមួយពាន់នាក់ បានមករងចាំបញ្ជាក់អត្តសញ្ញាណ តាំងពីយប់រហូតដល់ភ្លឺលុះដល់វេលាម៉ោងកំណត់គណៈកម្មការផ្តល់ភាពស្របច្បាប់កម្ពុជា ចាប់បើកបញ្ជាក់អត្តសញ្ញាណធ្វើប៉ាស្ព័រជូនបងប្អូនពលករកម្ពុជា រហូតដល់ម៉ោង០៩យប់ចប់លេខរៀង នេះបើតាមការបកស្រាយរបស់និយោជកថៃដែលបាននាំពលករនៅបញ្ជាក់អត្តសញ្ញាណនៅទីតាំងខេត្តរ៉ាក់យ៉ង។ ចំណែកឯបងប្អូនពលករកម្ពុជាយើង ដែលបានទៅបញ្ជាក់ អត្តសញ្ញាណនៅក្នុងខេត្តរ៉ាក់យ៉ង បានសម្តែងការត្រេកអរយ៉ាងខ្លាំងបន្ទាប់ពីបានទទួលប៉ាស្ព័រការងារស្របច្បាប់ដែល គណកម្មការផ្តល់ភាពស្របច្បាប់ផ្តល់ជូន ព្រមទាំងអរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានជួយសម្រួលថ្លៃប៉ាស្ព័រដ៏សមរម្យជូនដល់ពួកគាត់។

## ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧

## រដ្ឋមន្ត្រី អ៊ិត សំហេង៖ ពលករខ្មែរនៅថៃសាទរយ៉ាងខ្លាំង ចំពោះក្រុមការងារដែលចុះធ្វើលិខិតផ្តល់ភាពស្របច្បាប់

http://freshnewsasia.com/index.php/en/ 2017-10-15

**(ឈុនប៊ូរី)៖** ពលករខ្មែរដែលកំពុងបម្រើការនៅប្រទេសថៃ មានការសាទរយ៉ាងខ្លាំងចំពោះក្រុមការងារកម្ពុជា-ថៃ ដែលបានចុះធ្វើលិខិតផ្តល់ភាពស្របច្បាប់ជូនពួកគេ ព្រមទាំងថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបានជួយសម្របសម្រួលជាមួយថៃ ក្នុងការពន្យារពេលអនុវត្តច្បាប់ការងារថ្មីរបស់ថៃ ដែលគេដឹងថាមានការរឹតបន្តឹងខ្លាំង។ នេះបើតាមលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការសាទរនេះ ធ្វើឡើងក្នុងឱកាសលោករដ្ឋមន្ត្រី អញ្ជើញចូលជួបសំណេះសំណាលជាមួយពលករខ្មែរ ដែលកំពុងបម្រើការងារក្នុងរោងចក្រផលិតសាច់មាន់ GFPT ស្ថិតក្នុងខេត្តឈុនប៊ូរី ប្រទេសថៃ នាថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧។

លោករដ្ឋមន្ត្រី អ៊ិត សំហេង បានឲ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានតាមដានយ៉ាងយកចិត្តទុកដាក់បំផុត ចំពោះសុខទុក្ខរបស់បងប្អូនពលករខ្មែរ។ ជាក់ស្តែង កាលពីខែកក្កដា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលថៃ បានបញ្ជូនពលករខ្មែរមកកម្ពុជាវិញយ៉ាងគំហុក រហូតដល់២៧ម៉ឺននាក់ ត្រឹមតែរយៈពេលអាទិត្យប៉ុណ្ណោះ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានទទួលស្វាគមន៍ ក៏ដូចជាជួយដឹកជញ្ជូន និងជួយរកការងារធ្វើនៅក្នុងប្រទេស ក្នុងនោះក៏មានការផ្តល់លិខិតឆ្លងដែនដោយមិនគិតថ្លៃ រៀបចំគណៈកម្មការផ្តល់ភាពស្របច្បាប់ទៅប្រទេសថៃ ដើម្បីដោះស្រាយជូនបងប្អូនពលករខ្មែរ។

លោករដ្ឋមន្ត្រីបានបន្តថា កាលពីខែកក្កដា ឆ្នាំ២០១៧ អាជ្ញាធរថៃបានកែទម្រង់ច្បាប់រឹតបន្តឹងចំពោះនិយោជកថៃ និងកម្មករបរទេសខុសច្បាប់ក្នុងប្រទេសរបស់ខ្លួន។ ឆ្លើយតបនឹងបញ្ហាចំពោះមុខនោះ ក្រោមការចង្អុលបង្ហាញពីសម្តេចតេជោ ហ៊ុន សែន លោករដ្ឋមន្ត្រី អ៊ិត សំហេង បានដឹកនាំប្រតិភូកម្ពុជាចូលជួបជាមួយសមភាគីថៃ ដើម្បីដោះស្រាយបញ្ហាខាងលើនេះ ហើយជាលទ្ធផលបានព្រមព្រៀងលើដំណោះស្រាយបញ្ហាមួយចំនួន ក្នុងនោះមានការធានាសុវត្ថិភាពជូនបងប្អូនពលករ និងការពន្យាការអនុវត្ត៦ខែ ក្នុងការអនុវត្តច្បាប់ថ្មីនោះ (សុពលភាពដល់ខែមករា ឆ្នាំ២០១៨)។

មិនតែប៉ុណ្ណោះ ភាគីថៃបានបង្កើតមណ្ឌលចំនួន១០ នៅរាជធានីបាងកក និងនៅគ្រប់ខេត្ត ដើម្បីចុះបញ្ជីពលករខ្មែរយើង ចាប់ពីថ្ងៃ២៤ ខែកក្កដា ដល់ថ្ងៃទី៧ ខែសីហា មាន២៤ម៉ឺននាក់ ដែលខុសច្បាប់។ ចំណែកភាគីកម្ពុជាវិញ បានបើកយុទ្ធនាការ១០០ថ្ងៃ ដើម្បីចុះផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័

ណ្ណពលករកម្ពុជាទៅធ្វើនៅបរទេស (OCWC) ក្នុងនោះផ្តល់ជូនពលករបានចំនួន ១៦ម៉ឺននាក់។ ធ្វើលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើនៅបរទេស (OCWC) ថ្មី ដោយចំណាយពេលត្រឹមតែ១ថ្ងៃ និងថវិកា ២,៣៥០បាតប៉ុណ្ណោះ នឹងទទួលបានប័ណ្ណទាំងនោះភ្លាម ដោយបានបញ្ជូនបុគ្គលិក ៣៦០នាក់ មកបំពេញបេសកកម្មនេះផងដែរ។

សូមជម្រាបថា ពលករខ្មែរនៅប្រទេសថៃ មានជាង១លាន៥ម៉ឺននាក់ នៅប្រទេសជប៉ុន មានជិត៥,០០០នាក់ នៅកូរ៉េខាងត្បូង មានជាង៥ម៉ឺននាក់ ក្នុងនោះបងប្អូនខ្មែរមានគ្រួសារកូរ៉េ ១៥,០០០នាក់។ ចំណូលមធ្យមជិត ២ពាន់លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ។ ពលករនៅថៃ មាន១លាន៥ម៉ឺននាក់ ប្រាក់ឈ្នួលជាង៣០០បាត ក្នុងមួយថ្ងៃ។ លោករដ្ឋមន្ត្រី បានផ្តាំផ្ញើដល់ពលករខ្មែរឲ្យចេះបង្កើនទំនាក់ទំនងមិត្តភាព តាមរយៈការទទួលបានមិត្តភក្តិ គ្រួសារ និងសង្គម មានប្រយោជន៍សម្រាប់សហប្រតិបត្តិការមិត្តភាពប្រជាជន និងប្រជាជន។ ពេលត្រឡប់មកកម្ពុជាវិញ បងប្អូនពលករ គឺជាធនធានមនុស្សដែលមានជំនាញខ្ពស់ ដើម្បីកសាងប្រទេស តាមរយៈការងារនៅក្នុងស្រុក៕

## មានដឹងទេថា.? ពលករខ្មែរដែលទទួលបានលិខិត សម្គាល់រួចអាចស្នាក់នៅក្នុងប្រទេសថៃត្រឹមតែ 2ខែប៉ុណ្ណោះ

http://pheaktraprak.com By เพียะตรา ประ October 16, 2017

មានដឹងទេថា ពលករខ្មែរដែលបានសម្គាសន៍រួចរាល់ទទួលបានលិខិតបញ្ជាក់ពីក្រសួងការងារថៃ អាចធ្វើការស្នាក់នៅធ្វើការក្នុងប្រទេសថៃត្រឹមតែឆ្នាំ2017នេះតែប៉ុណ្ណោះ.! ÷ចំពោះបងប្អូនពលករខ្មែរដែលបានចុះឈ្មោះថ្មីរួចបានសម្គាសន៍រួចរាល់ ព្រមទាំងទទួលបានលិខិតបញ្ជាក់ចេញពីក្រសួងការងារថៃយ៉ាងត្រឹមត្រូវ ក៏ប៉ុន្តែលិខិតអនុញ្ញាតនេះ អាចអោយបងប្អូនស្នាក់នៅធ្វើការក្នុងប្រទេសថៃបណ្តោះអាសន្នបានត្រឹមតែថ្ងៃទី31.12.2017 តែប៉ុណ្ណោះ។ ព្រោះច្បាប់មាត្រា44 បានអនុគ្រោះអោយពលករបរទេសខុសច្បាប់នៅក្នុងប្រទេសថៃ អាចស្នាក់នៅបណ្តោះអាសន្នបានត្រឹមត្រូវថ្ងៃទី31.12.2017 ហើយនិងចាប់ផ្តើមអនុវត្តនៅច្បាប់ការងារថ្មីនៅថ្ងៃទី01.01.2018 ខាងមុខនេះ ដោយចាប់ផ្តើមបង្ក្រាបពលករដែលធ្វ ីការរស់នៅខុសច្បាប់នៅក្នុងប្រទេសថៃ ដោយមានទោសទាន់កំរិតធ្ងន់ធ្ងរបំផុត។ ដូច្នេះហើយបងប្អូនដែលបានសម្គាសន៍រួចរាល់ ត្រូវប្រញាប់ប្រញាល់ទៅត្រួតសញ្ជាតិធ្វើប៉ាស្ព័រ និងវីសាការងារអោយបានចប់សព្វគ្រប់នៅទីស្នាក់ការត្រួតសញ្ជាតិទាំងបីកន្លែងក្នុងប្រទេសថៃ ដែលបានប្រកាសដោយគណៈកម្មការផ្តល់ភាពស្របច្បាប់ក្នុងប្រទេសថៃ អោយបានមុនថ្ងៃទី01.01.2018 បើមិនដូច្នេះទេនិងត្រូវសមត្ថកិច្ចថៃចាប់ឬផាកពិន័យតាមច្បាប់ការងាររបស់ប្រទេសថៃដែលបានកំណត់។

## តំលៃVisaការងារ, ច្បាប់អនុញ្ញាតធ្វើការ ចំពោះប៉ាស្ព័រត្រួតសញ្ជាតិ

http://pheaktraprak.com By เพียะตรา ประ October 15, 2017

នេះជាតំលៃសេវាកម្ម visaការងារនិងច្បាប់អនុញ្ញាតធ្វើការ(e work permit) ចំពោះប៉ាស្ព័រការងារពណ៌ខ្មៅ(TD)នៅក្រោយពេលត្រួតសញ្ជាតិទទួលបានប៉ាស្ព័រ៖

1-តំលៃសេវាកម្មវីសារការងារចំនួនទឹកប្រាក់:500បាត

2-តំលៃសេវាកម្មពិនិត្យសុខភាពនិងរក្សាសុខភាពចំនួនទឹកប្រាក់:500បាត

3-តំលៃសេវាកម្មស្នើសុំច្បាប់អនុញ្ញាតការងារ( e work permit )ចំនួនទឹកប្រាក់:550 បាត

សរុបតំលៃទឹកប្រាក់ថ្លៃសេវាកម្មការស្នើសុំវីសារនិងច្បាប់អនុញ្ញាតការងារទាំងអស់គឺ2050បាត

បញ្ជាក់÷ចំពោះ( visaការងារ ) ត្រូវទៅស្នើសុំនៅស្ថានីតម្រួត( ต.ม)ក្នុងខេត្តក្រុងដែលយើងស្នាក់នៅធ្វើការ។

-ចំពោះច្បាប់អនុញ្ញាតធ្វើការងារត្រូវទៅស្នើសុំនៅមន្ទីរការងារថៃ( สำนักจัดหาจังหวัด) ដែលធ្វើរស់នៅស្នាក់ធ្វើការ។

## កម្មករខ្មែរធ្វើការនៅខេត្តអយុធ្យា ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យទាំងយប់

http://pheaktraprak.com By เพียะตรา ประ October 14, 2017

បុរសពលករខ្មែរវ័យ 39ឆ្នាំម្នាក់ ត្រូវបានអ្នកជិតខាងបញ្ជូនយកទៅសង្គ្រោះបន្ទាន់ភ្លាមបន្ទាប់ពីដួលសន្លប់បែកក្បាលមិនដឹងខ្លួន។ ករណីគ្រោះថ្នាក់នេះបានកើតឡើងកាលពីវេលាម៉ោង11:40នាទីយប់ នាថ្ងៃសុក្រទី13 ខែតុលា ឆ្នាំ2017 នៅកន្លែងស្នាក់នៅរបស់រោងចក្រផលិតជីស្ថិតនៅក្នុងភូមិប៉ាកចាន់ ស្រុកខ្លងលួង ខេត្តអយុធ្យា ប្រទេសថៃ ។

នៅកន្លែងកើតហេតុប្រទះឃើញជនរងគ្រោះម្នាក់ឈ្មោះសន សុភី ភេទប្រុស អាយុ 39ឆ្នាំ សញ្ជាតិខ្មែរ កំពុងស្ថិតក្នុងស្ថានភាពសន្លប់មិនដឹងខ្លួនត្រូវបានពលករខ្មែរដូចគ្នាជួយគ្រា តាមការត្រួតពិនិត្យនៅលើខ្លួនប្រាណជនរងគ្រោះឃើញមានស្នាមរបួសបែកក្បាលមួយធ្លុត ជនរងគ្រោះត្រូវបានភ្នាក់ងារសង្គ្រោះស្រុកខ្លងលួង ជួយរុំស្នាមរបួសរួចបញ្ជូនតាមរថយន្តយកទៅព្យាបាលនៅមន្ទីរពេទ្យសម្តេចសាំងរាជ។ ប្រភពពីពលករខ្មែរនៅក្បែរនោះ បានប្រាប់អោយដឹងថា មូលហេតុធ្វើឲ្យជនរងគ្រោះសន្លប់បែកក្បាលនេះ គឺដោយសារជនរងគ្រោះដើរអិលដួលបោកក្បាលទើបបណ្តាលអោយរងគ្រោះថ្នាក់ធ្ងន់ធ្ងរដូច្នេះ។

## ពលករកម្ពុជា និងប្រទេស២ទៀត ត្រូវក្រសួងការងារថៃ ហាមមិនឲ្យធ្វើការនៅតាមទីផ្សារ

http://kleykley.sabay.com.kh/ សុក្រ, 13 តុលា 2017 15:59

កាលពីពេលថ្មីៗនេះ ក្រសួងការងារប្រទេសថៃ បានចេញសារាចរមួយ ធ្វើការណែនាំដល់បណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ពិសេសគឺពលរដ្ឋថៃទាំងអស់ ពាក់ព័ន្ធនឹងពលករឆ្លងដែនដែលមកពីប្រទេសកម្ពុជា ឡាវ និង ភូមា។ នេះបើយោងតាមការចុះផ្សាយរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ។ ដោយសារចំនួនកើនឡើងខ្លាំងនៃពលករចូលរកការងារធ្វើនៅក្នុងប្រទេស ក្រសួងការងារថៃបានប្រកាសថា ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ នឹងមិនអនុញ្ញាតឲ្យពលករឆ្លងដែនមកពីប្រទេសចំនួន៣ខាងលើ ទៅបម្រើការងារនៅតាមទីផ្សារឡើយ ដូចជាអ្នកលក់ផ្លែឈើ លក់បន្លែ និងតាមបណ្តាភោជនីយដ្ឋាន អាហារដ្ឋាន ជាដាច់ខាត។ បន្ថែមពីនេះ ក្រសួងការងារថៃ បញ្ជាក់ថា ការងារនេះជាការងាររបស់ជនជាតិថៃតែមួយគត់៕ អត្ថបទ៖ ឈាង.

# ជនជាតិថៃ 2នាក់ ត្រូវសមត្ថកិច្ចភូមាចាប់ខ្លួន ពីបទបោកប្រាស់ពលករ

http://pheaktraprak.com By เพียะตรา ประ October 15, 2017

យោងតាមប្រភពព័ត៌មានពីភ្នាក់ងាររដ្ឋការរៀង នៃសហភាពប្រទេសមីយ៉ាន់ម៉ា បានចុះផ្សាយអោយដឹងថា កាលពីពេលថ្មីកន្លងទៅនេះសមត្ថកិច្ចប៉ូលិសអន្តោប្រវេសន៍មីយ៉ាន់ម៉ានៅក្នុងខេត្តមីយ៉ាវ៉ាឌីត បានធ្វើការចាប់ខ្លួនបុរសជនជាតិថៃ 2នាក់ ពីបទសង្ស័យជាប់ពាក់ព័ន្ធជាមួយការជួញដូរមនុស្ស។ ការចាប់ខ្លួនបុរសជនជាតិទាំងពីរនាក់នេះបានកើតឡើងនៅត្រង់ចំណុចស្ពានច្រកអន្តរជាតិថៃ-ភូមា ស្ថិតក្នុងខេត្តតាក ខណៈពេលដែលជនជាតិថៃទាំងពីរនាក់កំពុងបើកបររថយន្តឆ្លងចូលទៅក្នុងទឹកដីភូមា។

ប្រភពព័ត៌មានពីប្រទេសថៃ បានរាយការណ៍ថាបុរសជនជាតិថៃទាំងពីរនាក់ បានបើកក្រុមហ៊ុននាំចេញពលករពីប្រទេសភូមាទៅធ្វើការនៅប្រទេសថៃ ដោយមានភាគហ៊ុនជាមួយជនជាតិភូមា។ បច្ចុប្បន្នជនជាតិថៃទាំងពីរនាក់ត្រូវបានកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ភូមា នាំខ្លួនយកទៅធ្វើការសាកសួរនៅអធិការដ្ឋានប៉ូលិសស្រុកនៀវឌីភ្លាមៗបន្ទាប់ពីចាប់ខ្លួនរួច។

មូលហេតុដែលជនជាតិថៃទាំងពីរនាក់ត្រូវប៉ូលិសអន្តោប្រវេសន៍ភូមាចាប់នេះ គឺដោយសារក្រុមហ៊ុននាំចេញពលករភូមារបស់ជនជាតិថៃនេះ បានបោកប្រាស់កម្មករភូមាដែលយកមកធ្វើការនៅទីក្រុងបាងកក តែមិនបានរកការងារអោយទេគឺយកមកប្រោះចោល រហូតដល់មានការប្តឹងផ្តល់ដល់ស្ថានទូតភូមាចាំប្រទេសថៃ និងមានពាក្យបណ្តឹងនៅប្រទេសភូមា លុះដល់ជនជាតិថៃទាំងពីរនាក់ឆ្លងដែនទៅខាងទឹកដីភូមាក៏ត្រូវបានសមត្ថកិច្ចអន្តោប្រវេសន៍ភូមាចាប់ខ្លួនតែម្តង។

## ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧

# រដ្ឋមន្ត្រីក្រសួងការងារ៖ ពលករខ្មែរ នៅថៃ មាន១លាន៥ម៉ឺននាក់

http://www.everyday-news.html ថ្ងៃ ចន្ទ ទី ១៦ ខែ តុលា ឆ្នាំ ២០១៧ ម៉ោង ១៨:៣៩

រដ្ឋមន្ត្រីក្រសួងការងារបានធ្វើការអំពាវនាវដល់ បងប្អូនពលករខ្មែរឱ្យរស់នៅ ធ្វើការងារដោយគោរពច្បាប់របស់ប្រទេសថៃ រក្សាសាមគ្គីភាព ទំនាក់ទនងល្អជាមួយថៃ និងខិតខំរៀនបច្ចេកទេសវិជ្ជាជីវៈ សម្រាប់ពេលចប់កិច្ចសន្យា វិលទៅប្រទេសវិញ នឹងមានជំនាញ និងលទ្ធភាព ប្រកបរបរខ្លួនឯង ឬស្វែងរកការងារធ្វើ ដែលប្រកបដោយភាពថ្លៃថ្នូរ និងប្រាក់កម្រៃខ្ពស់។ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយប្រជាពលករខ្មែរ ដែលកំពុងបម្រើការងារក្នុងរោងចក្រផលិតសាច់មាន់ GFPT ស្ថិតក្នុងខេត្តឈុនប៊ុរី ប្រទេសថៃ ។ ការចុះជួបសំណេះសំណាលជាពលករខ្មែរនៅក្រុមហ៊ុននេះ ជាលើកទី២ហើយ ដោយលើកទី១ បានធ្វើឡើងនៅខេត្តសមុទ្របាកាន។

លោករដ្ឋមន្ត្រី បានថ្លែងថា បងប្អូនពលករខ្មែរជាពលរដ្ឋដ៏ឆ្នើមរបស់ជាតិ ដោយបានរួមចំណែករកចំណូលជូនជាតិ បងប្អូនពលករខ្មែរនៅប្រទេសថៃ មានជាង១លាននាក់ នៅប្រទេសជប៉ុន មានជិត៥០០០នាក់ នៅកូរ៉េខាងត្បូង មានជាង៥ម៉ឺននាក់ ក្នុងនោះបងប្អូនខ្មែរមានគ្រួសារកូរ៉េ ១៥០០០នាក់។ ចំណូលមធ្យមជិត២ពាន់លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ។ ពលករនៅថៃ មាន១លាន៥ម៉ឺននាក់ ប្រាក់ឈ្នួលជាង៣០០បាត ក្នុងមួយថ្ងៃ។ បានរក

ការងារល្អដែលការងារមួយកន្លែង យើងចំណាយលើការអនុគ្រោះដល់អ្នកវិនិយោគទុន ២០០០ដុល្លារអាមេរិក។ បានរៀនសូត្រជំនាញដែលការបណ្តុះបណ្តាលជំនាញម្នាក់ចំណាយ ១០០០ដុល្លារ។ បានរកចំណូលជួយគ្រួសារ តាមរយៈការកសាងជីវភាពគ្រួសារ កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ភូមិឃុំ។ បានបង្កើនទំនាក់ទំនងមិត្តភាព តាមរយៈការទទួលបានមិត្តភ័ក្តិ គ្រួសារ និងសង្គម មានប្រយោជន៍សម្រាប់សហប្រតិបត្តិការមិត្តភាពប្រជាជន និងប្រជាជន។ ពេលត្រឡប់មកកម្ពុជាវិញ បងប្អូនពលករ គឺជាធនធានមនុស្សដែលមានជំនាញខ្ពស់ ដើម្បីកសាងប្រទេស តាមរយៈការងារនៅក្នុងស្រុក។

លោករដ្ឋមន្ត្រី អ៊ិត សំហេង បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានតាមដានយ៉ាងយកចិត្តទុកដាក់បំផុត ចំពោះសុខទុក្ខរបស់បងប្អូនពលករខ្មែរ។ ជាក់ស្តែង កាលពីខែកក្កដា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលថៃបានបញ្ជូនពលករខ្មែរមកកម្ពុជាវិញយ៉ាងគំហុក រហូតដល់២៧ម៉ឺននាក់ ត្រឹមតែរយៈពេលអាទិត្យប៉ុណ្ណោះ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានទទួលស្វាគមន៍ ក៏ដូចជាជួយដឹកជញ្ជូន និងជួយរកការងារធ្វើនៅក្នុងប្រទេស ក្នុងនោះក៏មានការផ្តល់លិខិតឆ្លងដែនដោយមិនគិតថ្លៃ រៀបចំគណៈកម្មការផ្តល់ភាពស្របច្បាប់ទៅប្រទេសថៃ ដើម្បីដោះស្រាយជូនបងប្អូនពលករខ្មែរ។ លោករដ្ឋមន្ត្រី មានប្រសាសន៍បន្តថា កាលពីខែកក្កដា ឆ្នាំ២០១៧ អាជ្ញាធរថៃបានកែទម្រង់ច្បាប់រឹតបន្តឹងចំពោះនិយោជកថៃ និងកម្មករបរទេសខុសច្បាប់ក្នុងប្រទេសរបស់ខ្លួន។ បញ្ហានេះនាំឲ្យពលករខ្មែរ និងក្រុមគ្រួសារមានបារម្ភខ្លាំង ព្រោះខ្លាចមានការបណ្តេញចេញដូចកាលពីឆ្នាំ២០១៤។

ឆ្លើយតបនឹងបញ្ហាចំពោះមុខនោះ ក្រោមការចង្អុលបង្ហាញពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន លោករដ្ឋមន្ត្រី អ៊ិត សំហេង បានដឹកនាំប្រតិភូកម្ពុជាចូលជួបជាមួយសមភាគីថៃ ដើម្បីដោះស្រាយបញ្ហាខាងលើនេះ ហើយជាលទ្ធផលបានព្រមព្រៀងលើដំណោះស្រាយបញ្ហាមួយចំនួន ក្នុងនោះមានការធានាសុវត្ថិភាពជូនបងប្អូនពលករ និងការពន្យាការអនុវត្ត៦ខែ ក្នុងការអនុវត្តច្បាប់ថ្មីនោះ (សុពលភាពដល់ខែមករា ឆ្នាំ២០១៨)។ មិនតែប៉ុណ្ណោះ ភាគីថៃបានបង្កើតមណ្ឌលចំនួន១០ នៅរាជធានីបាងកក និងនៅគ្រប់ខេត្ត ដើម្បីចុះបញ្ជីពលករខ្មែរយើង ចាប់ពីថ្ងៃ២៤ ខែកក្កដា ដល់ថ្ងៃទី៧ ខែសីហា មាន២៤ម៉ឺននាក់ ដែលខុសច្បាប់។ ចំណែកភាគីកម្ពុជាវិញបានបើកយុទ្ធនាការ១០០ថ្ងៃ ដើម្បីចុះផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើនៅបរទេស (OCWC) ក្នុងនោះផ្តល់ជូនពលករបានចំនួន ១៦ម៉ឺននាក់។ ធ្វើលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើនៅបរទេស (OCWC) ថ្មី ដោយចំណាយពេលត្រឹមតែ១ថ្ងៃ និងថវិកា ២,៣៥០បាតប៉ុណ្ណោះ នឹងទទួលបានប័ណ្ណទាំងនោះភ្លាម ដោយបានបញ្ជូនបុគ្គលិក ៣៦០នាក់មកបំពេញបេសកកម្មនេះផងដែរ។

អត្ថប្រយោជន៍ដែលពលករកម្ពុជាកម្ពុជាទទួលបានពីការផ្តល់ភាពស្របច្បាប់ រួមមាន៖ ក. លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD)៖ ១. មានសិទ្ធិធ្វើដំណើរឆ្លងកាត់ព្រំដែន កម្ពុជា-ថៃ ២. អាចធ្វើដំណើរបានទូទាំងខេត្ត-ក្រុង នៅក្នុងប្រទេសថៃ ៣. ងាយស្រួលសម្គាល់ពីអត្តសញ្ញាណជាពលករកម្ពុជា ដែលទទួលអត្ថប្រយោជន៍ និងការយកចិត្តទុកដាក់ពីអាជ្ញាធរពាក់ព័ន្ធ ខ. អត្ថប្រយោជន៍របស់ប័ណ្ណពលករកម្ពុជាទៅធ្វើនៅបរទេស (OCWC)៖ ១. សិទ្ធិទទួលស្គាល់ជំនាញ អតីតភាពការងារ ដែលអាចឱ្យពលរកស្វែងរកការងារធ្វើនៅពេលត្រឡប់មកប្រទេសកម្ពុជាវិញ។ ២. អត្ថប្រយោជន៍ធានារ៉ាប់រង៖ នៅពេលមានគ្រោះថ្នាក់ការងារ តំណាងស្របច្បាប់របស់ពលករមានសិទ្ធិទទួលបាននូវប្រាក់ធានារ៉ាប់រង រួមមាន ប្រពន្ធ ឬកូនចៅ ឬឪពុកម្តាយ ទៅតាមលំដាប់សន្តតិជន។

៣. អត្ថប្រយោជន៍របបសន្តិសុខសង្គម និងប្រាក់សោធននិវត្ត។ គ.អត្ថប្រយោជន៍ដែលទទួលបានពីលិខិតធ្វើដំណើរ TD និងប័ណ្ណ OCWC៖ ១. លក្ខខណ្ឌទទួលបានភាពស្របច្បាប់ ក្នុងស្នើសុំទិដ្ឋាការស្នាក់នៅ (Stay Permit) និងសៀវភៅការងារ (Work Permit) ពីអាជ្ញាធរថៃ។ ២. ទទួលបានសិទ្ធិពេញលេញក្នុងការការពារសិទ្ធិ និងអត្ថប្រយោជន៍ ដូចពលករថៃ ដូចជាប្រាក់ឈ្នួល សិទ្ធិបើកបញ្ជីធនាគារ ប័ណ្ណបើកបរ និងឯកសារផ្សេងៗទៀត។

លោករដ្ឋមន្ត្រី បានបន្តទៀតថា ប្រទេសកម្ពុជាយើងកំពុងមានសុខសន្តិភាព និងការអភិវឌ្ឍ។ អត្រាកំណើនសេដ្ឋកិច្ចមាន ៧% អត្រាការងារធ្វើមាន ៩៩,៣%។ ជីវភាពប្រជាជនធូធារ ប្រាក់ខែមន្ត្រីរាជការឡើងបាន ៨០ម៉ឺន ប្រាក់ឈ្នួលអប្បបរមារបស់កម្មករ ១៥៣ដុល្លា ហើយនៅឆ្នាំ២០១៨ ខាងមុខ ប្រាក់ឈ្នួលអប្បរមារបស់កម្មករនឹងឡើងដល់ ១៧០ដុល្លារ។ មានរបបសន្តិសុខសង្គម គ្រោះថ្នាក់ការងារ ថៃទាំសុខភាព និងរបបចូលនិវត្តន៍។ បងប្អូននារីៗដែលសម្រាលកូន ទទួលបានប្រាក់ឧបត្ថម្ភពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ថែមទៀត៕

## ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧

## ពេលអញ្ជើញជួបសំណេះសំណាលជាមួយកម្មករក្នុងស្រុកជាង១ម៉ឺននាក់ សម្តេចតេជោ មិនភ្លេចកម្មករ-ពលករនៅក្រៅប្រទេសទេ

http://www.rasmeinews.com/ October 18, 2017

(ភ្នំពេញ)៖«ក្នុងពេលដែលពូកំពុងជួបសួរសុខទុក្ខក្មួយៗកម្មករនៅក្នុងប្រទេស ក៏ពូបាននឹងកំពុងគិតដល់ក្មួយៗដែលកំពុងធ្វើការនៅក្រៅប្រទេសដែរដូចជានៅ ប្រទេសថៃ កូរ៉េខាងត្បូង ជប៉ុន ម៉ាឡេស៊ី...ជាដើម។ពូខិតខំសម្របសម្រួលជាមួយប្រទេសដែលក្មួយៗកំពុងធ្វើការដើម្បីអោយកូនក្មួយៗទទួលបាននូវអត្ថប្រយោជន៍ជាច្រើនថែមទៀត»។នេះជាជាសារដែលសម្តេចតេជោ ហ៊ុន សែន សរសេរបង្ហោះផ្ញើជូនក្មួយៗកម្មករ ពលករដែលកំពុងធ្វើការនៅក្រៅប្រទេសនៅព្រឹកនេះ។ សម្តេចប្រមុខរាជរដ្ឋាភិបាលបានបន្តថា «ក្មួយៗមិនត្រូវគិតថាមកធ្វើកញ្ចះគេទេ ឬចំណាកស្រុកខុសគេខុសឯងនោះទេ។ប្រទេសណាក៏មានពលរដ្ឋចេញទៅធ្វើការនៅបរទេសដែរ សូម្បីតែនៅប្រទេសថៃ ហ្វីលីពីន ម៉ាឡេស៊ី វៀតណាម ឡាវ សិង្ហបូរី ឥណ្ឌា ហុងកុង ...ជាដើម។ នេះគឺបានបង្ហាញពីសមត្ថភាពនិងមានឱកាសដែលក្មួយបានមកធ្វើការនៅបរទេស។ សំខាន់បំផុតនោះ គឺក្មួយៗមានការងារធ្វើល្អ និងមានប្រាក់ខែល្អ ទោះបីនៅក្នុងឬក្រៅប្រទេសក្តី ដែលជាមោទនៈភាពរបស់ក្រុមគ្រួសារ»។ ការផ្ញើសារដ៏រំជួលចិត្តនោះធ្វើឡើងចំពេលសម្តេចតេជោនៅព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧នេះបានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខបងប្អូនកម្មករកម្មការិនីជាង១៥.២១១ នាក់ នៅរោងចក្រតំបន់កំបូល តាមបណ្តោយផ្លូវជាតិលេខ៤ ដែលមកពីរោងចក្រចំនួន១០ ក្នុងខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ នេះជាលើកទី១៣ ហើយដែល សម្តេចតេជោ បានអញ្ជើញចុះជួបសួរសុខទុក្ខបងប្អូនកូនក្មួយកម្មករបូករួមទាំងការជួបសំណេះសំណាលនៅរៀងរាល់ថ្ងៃអាទិត្យនៅកោះពេជ្រ ហើយ សម្តេចតេជោ នឹងអញ្ជើញទៅជួបកម្មករកូនក្មួយជាបន្តបន្ទាប់ទៀត។

ហ្វេសប៊ុកសម្តេចបានបញ្ជាក់ថា៖ដោយសារស្ថេរភាពនយោបាយ និងសន្តិសុខសង្គមព្រមទាំងការអនុគ្រោះពន្ធដល់វិនិយោគទុនគឺកម្ពុជាបានទាក់ទាញអ្នកវិនិយោគគិនយ៉ាងច្រើន ដែលបានផ្តល់ការងារនឹងប្រាក់ចំណូលសមរម្យដល់កម្មករ។ទាំងអស់នេះគឺបានមកពីសន្តិភាព ដែលមានតែគណបក្សប្រជាជនតែមួយគត់ដែលបានខិតខំធ្វើតាំងពីមុនរហូតមកទល់ពេលនេះគឺគ្មានបក្សប្រឆាំងណាចូលរួមនោះទេ។ សម្តេចតេជោ ហ៊ុន សែន ក៏បានបញ្ជាក់ផងដែរថា សម្តេចនឹងបន្តដឹកនាំប្រទេសជាតិមិនតិចជាង១០ឆ្នាំ ដើម្បីការពារសន្តិភាព ការពាររោងចក្រ ការពារ

ផលប្រយោជន៍បងប្អូនកម្មករកម្មការនី និងសូមអោយបងប្អូនប្រជាពលរដ្ឋគាំទ្រនិងបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជាជាបន្តទៀត។ សម្តេចតេជោ ក៏បានប្រកាសសាជាថ្មីផងដែរថា នៅឆ្នាំ២០១៨ ប្រាក់ខែកម្មករកម្មការនីជាអប្បរមាគឺ ១៧០ ដុល្លារ ក្នុងមួយខែ(គឺរាជរដ្ឋាភិបាលបានបន្ថែម ៥ដុល្លារ ដែលសាច់ប្រាក់នេះបានមកពីពន្ធកាត់ទុក និងពន្ធនាំចេញ ដែលរាជរដ្ឋាភិបាលត្រូវចំណាយជាង ៤០ លានដុល្លារ)។ ដូច្នេះចាប់ពីខែ មករា ឆ្នាំ ២០១៨ តទៅ ប្រាក់ខែអប្បរមារបូកបន្ថែមនឹងប្រាក់អត្ថប្រយោជន៍ផ្សេងៗគឺលើសពី២០០ដុល្លារ/១ខែ។ជាមួយគ្នានេះដែរ គឺបងប្អូនកម្មករកូនក្មួយនឹងទទួលបានការបញ្ចុះតំលៃទឹកភ្លើងនិងថ្លៃឈ្នួលផ្ទះដែលនឹងជួយដោះស្រាយជីវភាពរស់នៅអោយកាន់តែប្រសើរឡើង។ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីបានផ្តល់នូវអនុសាសន៍សំខាន់ៗ៥ចំណុចដល់និយោជកនិងនិយោជិតដើម្បីធ្វើការរួមគ្នាធានាដល់ល័ក្ខខ័ណ្ឌការងារនិងប្រាក់ចំណូលល្អ:

១)ត្រូវរួមគ្នាថែរក្សាសន្តិភាព ស្ថេរភាព និងសុវត្ថិភាពសណ្តាប់ធ្នាប់សង្គមអោយបានល្អ។

២)រួមគ្នារក្សាការងារ និងបង្កើតការងារថ្មីៗច្រើនថែមទៀត ដោយធ្វើការពង្រីកនិងបង្កើនទីផ្សារបន្ថែម។

៣)រួមគ្នាបង្កើនប្រាក់ចំណូលដោយការបណ្តុះបណ្តាលចំណេះដឹងបន្ថែមដល់កម្មករ។ រាជរដ្ឋាភិបាល នឹងបន្តតម្លើងប្រាក់ខែកម្មករជារៀងរាល់ឆ្នាំ កើនទាំងប្រាក់បៀវត្សន៍អប្បរិមា និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ។ ចំពោះតម្លៃទឹក ភ្លើងវិញ គឺចាប់តាំងពីថ្ងៃទី១ កញ្ញា ឆ្នាំ២០១៧ នេះតទៅគឺថ្លៃភ្លើងបញ្ចុះមកនៅត្រឹម៤៥០៛ ក្នុង១គីឡូវ៉ាត់ម៉ោង (សម្រាប់ការប្រើក្រោម៥០គីឡូវ៉ាត់ម៉ោងក្នុង១ខែ)។ ចំពោះថ្លៃទឹកគឺថ្លៃតែ ៧០០៛ ប៉ុណ្ណោះក្នុងមួយម៉ែត្រគូប ។ សម្តេចតេជោ បានអំពាវនាវដល់ម្ចាស់ផ្ទះកុំតម្លើងថ្លៃឈ្នួលផ្ទះរយៈពេល១ឆ្នាំ (២០១៨) ដើម្បីជួយកម្មករយើងអោយមានលទ្ធភាពរកប្រាក់ចំណូលបន្ថែមក្នុងការសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃអោយកាន់តែប្រសើរឡើង។

៤)ផ្តល់របបគាំពារសន្តិសុខសង្គមដល់កម្មករចាប់ពីខែ មករា ឆ្នាំ២០១៨ នេះទៅ គឺនិយោជក (ម្ចាស់ក្រុមហ៊ុន) នឹងបង់ថ្លៃរបបសន្តិសុខសង្គម ១០០% ដល់កម្មករកម្មការនី។ ពេលនោះបងប្អូនអាច នៅសល់ប្រាក់ប្រមាណពី (៨,០០០៛-១២,០០០៛ក្នុង១ខែ)។ ជាមួយគ្នានេះដែរ កម្មការនីយើងទាំងអស់ (រួមទាំងកម្មករសំណង់ សណ្ឋាគារ ដឹកជញ្ជូនបើកបរ និងកសិកម្មជាដើម...) គឺទទួលបានការពិនិត្យព្យាបាលជំងឺនៅមន្ទីរពេទ្យរដ្ឋដោយមិនគិតថ្លៃតាមរយៈមូលនិធិសមធម៌។ សម្តេចតេជោ បានណែនាំអោយម្ចាស់ក្រុមហ៊ុនរោងចក្ររៀបចំបង្កើត Clinic បន្ថែមនៅតាមរោងចក្ររបស់ខ្លួនដើម្បីជួយដល់កម្មករ។ គ្រប់ស្ត្រីកម្មករិនីមានផ្ទៃពោះទាំងអស់ត្រូវបានអនុញ្ញាតិអោយចេញមុនម៉ោង ១៥នាទី។ ចំពោះស្ត្រីមានផ្ទៃពោះសំរាលកូន គឺនឹងទទួលបានពេលវេលាឈប់សម្រាក ពីការងាររយៈពេល៣ខែហើយ ហើយនៅទទួលបានប្រាក់ខែ ១២០% (៥០% ដោយក្រុមហ៊ុន និង ៧០% ដោយបេឡាជាតិ)។

នៅថ្ងៃនេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានប្រកាសជូនដំណឹងដល់បងប្អូនកម្មការនីអំពីអត្ថប្រយោជន៍មួយទៀតដែលនឹងទទួលបានពីបេឡាសង្គមគឺ:- ចំពោះស្ត្រីសម្រាលកូនទោះក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធដែលសម្រាលបានកូន(១)គឺទទួលថវិកា៤០ម៉ឺនរៀល និងពិនិត្យផ្ទៃពោះដោយឥតគិតថ្លៃ។ បើ សម្រាលបានកូនភ្លោះ (២) គឺទទួលបានថវិកា៨០ម៉ឺនរៀល។ បើសម្រាលបានកូន(៣) គឺទទួលបាន ថវិកា១លាន២សែនរៀល ហើយបូកប្រាក់ឧបត្ថម្ភមួយចំនួនទៀតពី សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត។ ថវិកានេះនឹងផ្តល់ជូនដោយបេឡាសន្តិសុខសង្គមរបស់រាជរដ្ឋាភិបាលដែលនឹងត្រៀមថវិកាប្រមាណជាង១០លានដុល្លារ ក្នុង១ឆ្នាំៗ (ទោះបីកូននោះកើតរស់ឬស្លាប់គឺនៅទទួលបានថវិកាគាំពារដូចគ្នា)។

កម្មករកម្មការនីទូទាំង ប្រទេស នឹងទទួលបានសេវាជិះឡានក្រុងសាធារណៈ FREE រយៈពេល២ឆ្នាំ (ពីខែសីហា ២០១៧-សីហា ២០១៩)។ ចំពោះកីឡាករ កីឡាការិនីទាំងអស់ក៏ទទួលបានការជិះរថយន្តក្រុងសាធារណៈដោយមិនគិតថ្លៃផងដែរសម្រាប់រយៈពេល២ឆ្នាំ ហើយទទួលបានបានពិនិត្យថែទាំសុខភាពដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យរដ្ឋ។

ចំពោះកីឡាការនីដែលសម្រាលកូនក៏ទទួលបានអត្ថប្រយោជន៍ដូចកម្មការិនីផងដែរ ចាប់ពីខែមករា ឆ្នាំ ២០១៨ នេះទៅ ។ នៅឆ្នាំ ២០១៩ ខាងមុខនេះ កម្មករទាំងអស់នឹងមានប្រាក់សោធននិវត្តន៍ (ប្រាក់រ៉ឺត្រែត) ដែលនឹងទទួលបានចំនួន ៨០% នៃប្រាក់ខែដែលខ្លួនធ្លាប់បានទទួលពេលនៅធ្វើការចុងក្រោយ។

ចំពោះស្ត្រីជាមន្ត្រីរាជការស៊ីវិល នគរបាល កងទ័ព គឺចាប់ពីខែ មករា ឆ្នាំ ២០១៨ នេះទៅ បើសម្រាលបានកូន ១ ត្រូវទទួលបាន ៨០០,០០០៛ បើបានកូនភ្លោះ២គឺទទួលបាន ១,៦០០,០០០៛ បើបានកូនភ្លោះ៣ គឺទទួលបាន ២,៤០០,០០០៛ ។ ចំពោះគ្រូបង្រៀន និងគ្រូពេទ្យជាស្ត្រី ក៏ទទួលបានប្រាក់ឧបត្ថម្ភដូចខាងលើនេះផងដែរ។

ទី៥) រាជរដ្ឋាភិបាលបន្តយកចិត្តទុកដាក់ផ្តល់កិច្ចគាំពារចំពោះកម្មករកម្មការិនីដែលកំពុងធ្វើការនៅក្រៅប្រទេស ដោយធ្វើការសម្របសម្រួលជាមួយប្រទេសដៃគូដើម្បីផ្តល់នូវល័ក្ខខ័ណ្ឌការងារល្អៗ ដែលមានប្រាក់ខែល្អសមរម្យដល់កម្មករ ព្រមទាំងជួយសម្រួលនូវបែបបទលិខិតបទដ្ឋានផ្លូវច្បាប់នានាដែលពាក់ព័ន្ធ នឹងការងាររបស់បងប្អូនកូនក្មួយកម្មករ។ ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលនឹងបន្តជជែកជាមួយប្រទេស ផ្សេងៗដូចជាកូរ៉េខាងត្បូង ម៉ាឡេស៊ី និងប្រទេសថៃដើម្បីផ្តល់នូវល័ក្ខខ័ណ្ឌការងារ និងប្រាក់ខែល្អៗសម្រាប់បងប្អូនកូនក្មួយកម្មករខ្មែរ៕ដោយ៖*FBសម្តេច/sn*

## រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា៖ សិង្ហបុរីនឹងបន្តបើកទូលាយដើម្បីទទួលយកពលករកម្ពុជាទៅធ្វើការ

http://www.everyday-news.html ថ្ងៃ អង្គារ ទី ១៧ ខែ តុលា ឆ្នាំ ២០១៧ ម៉ោង ១៨:៥៧

ភ្នំពេញ៖ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា និងរដ្ឋមន្ត្រីការបរទេសសិង្ហបុរី បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នារវាងក្រសួងការបរទេស នៃប្រទេសទាំង២ ស្តីពីការពិគ្រោះយោបល់ផ្នែកនយោបាយ។ ការចុះកិច្ចព្រមព្រៀងនេះ បានធ្វើឡើងក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់លោក វីវៀន បាឡាគ្រីស្សស្នាន (Vivivan Balakrishnan) រដ្ឋមន្ត្រីការបរទេសសិង្ហបុរី មកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា កាលពីព្រឹកថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងការបរទេសរដ្ឋមន្ត្រីការបរទេសសិង្ហបុរី មកបំពេញតស្សនកិច្ចនៅកម្ពុជា រយៈពេល២ថ្ងៃ គឺចាប់ពិថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០១៧ តបតាមការអញ្ជើញរបស់លោកទេសរដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

លោកជុំ សុន្ទរី អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានថ្លែងថា នៅក្នុងកិច្ចប្រជុំទ្វេភាគីរវាងរដ្ឋមន្ត្រី នៃប្រទេសទាំងពីរ គឺបានរម្លឹកឡើងវិញអំពីទំនាក់ទំនងមិត្តភាពជយូរលង់ដែលត្រូវបានកសាងឡើងដោយថ្នាក់ដឹកនាំជាន់ខ្ពស់របស់ប្រទេសទាំងពីរ ជាពិសេសត្រូវបានកសាងឡើងដោយព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ និងអតីតនាយករដ្ឋមន្ត្រី លី ក្វាន់យូ ហើយទំនាក់ទំនងនេះ បានបង្កមូលដ្ឋានសម្រាប់ការពង្រឹង និងពង្រីកនៅទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីររហូត

មកដល់បច្ចុប្បន្ននេះ។ ហើយក៏បានវាយតម្លៃខ្ពស់ចំពោះការផ្លាស់ប្តូរទស្សនកិច្ចរវាងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ប្រទេសទាំងពីរក្នុងរយៈកាលកន្លងមកនេះ។

លោកបានបន្តថា នៅក្នុងកិច្ចប្រជុំ ភាគីទាំងពីរក៏បានពិភាក្សាផ្លលាស់ប្តូរយោបល់គ្នា និងបានឯកភាពគ្នា ធ្វើការពង្រឹងបន្ថែមទៀតលើកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យមួយចំនួនដូចជា ពាណិជ្ជកម្ម និងការវិនិយោគ អប់រំការអភិវឌ្ឍន៍ធនធានមនុស្ស វិស័យទេសចរណ៍ វប្បធម៌ និងវិស័យការងារ កិច្ចសហប្រតិបត្តិការលលការតភ្ជាប់ផ្លូវអាកាសរវាងប្រទេសទាំងពីរ និងកិច្ចសហប្រតិបត្តិការលើវិស័យសុខាភិបាល។ ហើយក៏បានពិភាក្សាផ្លាស់ប្តូរទស្សនគ្នានៅលើបញ្ហាតំបន់ និងអន្តរជាតិមួយចំនួនដែលជាផលប្រយោជន៍រួមរបស់ភាគីទាំងពីរ។ អ្នកនាំពាក្យបានបន្តទៀតថា រដ្ឋមន្ត្រីការបរទេស នៃប្រទេសទាំងពីរ បានសម្តែងនៅការរីករាយពេញចិត្តចំពោះការកើនឡើងគួរឲ្យកត់សម្គាល់នៅបរិមាណផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។ លោកទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ក៏បានស្នើសុំឲ្យរដ្ឋមន្ត្រីការបរទេសសិង្ហបុរីជួយជម្រុញក្នុងការនាំចូលនៅផលិតផលកសិកម្មរបស់កម្ពុជាមួយចំនួន ជាពិសេសអង្ករម្រេច និងផ្លែស្វាយ។ នៅក្នុងផ្នែកសហប្រតិបត្តិការលើសេដ្ឋកិច្ចនេះ លោកទេសរដ្ឋមន្ត្រី ក៏បានសម្តែងនៅការរីករាយពេញចិត្តចំពោះការចុះហត្ថលេខាកន្លងមកលើកិច្ចព្រមព្រៀងក្នុងវិស័យប្រេង សម្រាប់ការអភិវឌ្ឍន៍ប្រេងក្នុងដែនសមុទ្រប្លុក A របស់កម្ពុជា ដែលបានចុះហត្ថលេខារវាងកម្ពុជាជាមួយក្រុមហ៊ុនសឹង្ហបុរី។

ជាមួយគ្នានេះ លោកទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ក៏បានស្នើសុំឲ្យប្រទេសសិង្ហបុរី ពិនិត្យអំពីលទ្ធភាពក្នុងការបង្កើនថែមទៀតនៅវិនិយោគទុនរបស់សិង្ហបុរី នៅក្នុងវិស័យដែលមានសក្តានុពលរបស់កម្ពុជា។ នៅក្នុងការពិភាក្សាគឺរដ្ឋមន្ត្រីក្រសួងការបរទេស នៃប្រទេសទាំងពីរ បានធ្វើការកត់សម្គាល់ដោយពេញចិត្តនៅកំណើនក្នុងការផ្លាស់ប្តូរផ្នែកទេសចរណ៍រវាងប្រទេសទាំងពីរដែលបានកើតឡើងជារៀងរាល់ឆ្នាំ។ ហើយភាគីទាំងពីរក៏បានសម្តែងការពេញចិត្តចំពោះវិស័យសុខាភិបាល ពិសេសគឺការពិនិត្យសុខភាពរបស់ប្រជាជនកម្ពុជានៅសិង្ហបុរី។ លើផ្នែកសហប្រតិបត្តិការវប្បធម៌ លោកទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ក៏បានលើកជាយោបល់ចង់ឲ្យប្រទេសទាំងពីរពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ការជួញដូរខុសច្បាប់នៅសម្បត្តិវប្បធម៌។ ហើយរដ្ឋមន្ត្រីក្រសួងការបរទេសសិង្ហបុរី បានសម្តែងការស្វាគមន៍ និងបានសន្យាថា ប្រទេសសិង្ហបុរីបានត្រៀមខ្លួនជាស្រេច ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការជាមួយកម្ពុជានៅលើបញ្ហានេះ។

រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា និងសិង្ហបុរី ក៏បានពិភាក្សាគ្នាផងដែរ អំពីកិច្ចសហប្រតិបត្តិការអាកាសចរណ៍ស៊ីវិល ពិសេសលើការបណ្តុះបណ្តាលមន្ត្រីរបស់អាកាសចរណ៍ស៊ីវិលកម្ពុជានៅសិង្ហបុរី។ នៅក្នុងការពិភាក្សាលើផ្នែកកិច្ចសហប្រតិបត្តិការលើវិស័យការងារ លោកទេសរដ្ឋមន្ត្រី ក៏បានសម្តែងនៅអំណរគុណចំពោះរដ្ឋាភិបាលសិង្ហបុរី ដែលបានទទួលយកពលករកម្ពុជា និងបានសម្តែងក្តីសង្ឃឹមថា ប្រទេសសិង្ហបុរី នឹងបន្តបើកទូលាយដើម្បីទទួលយកពលករកម្ពុជាក្នុងពេលខាងមុខទៀត។ ចំណែករដ្ឋមន្ត្រីក្រសួងការបរទេសសិង្ហបុរី ក៏បានធានាអះអាងថា សិង្ហបុរីនឹងមានការប្រព្រឹត្តដល់ល្អចំពោះពលករកម្ពុជា។

សូមជម្រាបថា នៅក្នុងអំឡុងពេលទស្សនកិច្ចនេះ លោក វីវៀន បាឡាគ្រីស្សស្នាន នឹងចូលក្រាបបង្គំគាល់ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅប្រាសាទទេវាវិនិច្ឆ័យ នៃព្រះបរមរាជវាំង។ លោក វីវៀន បាឡាគ្រីស្សស្នាន នឹងចូលជួបសំដែងការគួរសមជាមួយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ជួបចរចាផ្លូវការជាមួយលោកទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ព្រមទាំងបន្តដោយពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នារវាងក្រសួងការបរទេស

និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេសនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការពិគ្រោះយោបល់ផ្នែកនយោបាយ ។

ចាប់តាំងពីការភ្ជាប់ទំនាក់ទំនងការទូតនៅឆ្នាំ១៩៦៥ ប្រទេសទាំងពីរមានកិច្ចសហប្រតិបត្តិការល្អប្រសើរ ដូចដែលបានឃើញតាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចកំរិតខ្ពស់ និងកំណើនពាណិជ្ជកម្មទៅវិញទៅមក ប្រចាំឆ្នាំ គួរឲ្យកត់សំគាល់។ ដំណើរទស្សនកិច្ចផ្លូវការរបស់លោក វីវៀន បាឡាគ្រឹស្សន្នាន មកកាន់ព្រះរាជាណាចក្រកម្ពុជា នឹងបង្កើនការប្តេជ្ញាចិត្តរបស់ប្រទេសទាំងពីរ ក្នុងការលើកកំពស់ទំនាក់ទំនងមិត្តភាពដ៏ល្អប្រសើរ និងកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធ ទាំងនៅក្នុងក្របខ័ណ្ឌទ្វេភាគី និងតំបន់៕

## ខ្សែរភ្លើងឆក់កម្មករសំណង់ខ្មែរស្លាប់1នាក់ របួស 2នាក់

http://pheaktraprak.com/archives/ By เพียะตรา ประ October 18, 2017

កាលពីថ្ងៃទី17 ខែតុលា ឆ្នាំ2017 មានករណីកម្មករសំណង់ចំនួន3នាក់ ត្រូវខ្សែរឆក់នក្នុងបន្ទប់ស្នាក់នៅ បណ្តាលឲ្យរបួសធ្ងន់2នាក់ និងបាត់បង់ជីវិតម្នាក់នៅកន្លែងកើតហេតុ។ ហេតុការណ៍នេះបានកើតឡើងនៅក្នុងបន្ទប់ស្នាក់ របស់កម្មករសំណង់ខ្មែរមួយក្រុម ស្ថិតនៅភូមិសុខសារវ៉ាត់78 ឃុំខ្លងប្រាកត់ ស្រុកប្រាក់សាមុតចេឌី ប្រទេសថៃ។

នៅកន្លែងកើតហេតុសមត្ថកិច្ចថៃកំពុងធ្វើការត្រួត ពិនិត្យសាសពពលករខ្មែរ1 នាក់មិនស្គាល់អត្តសញ្ញាណ ត្រូវខ្សែភ្លើងឆក់ស្លាប់ និងមានមនុស្ស2នាក់ទៀតបានរបួសស្រាលនៅក្នុងហេតុការនេះដែរ។ ប្រភពពីកន្លែងកើតហេតុបានឲ្យដឹងថាមូលហេតុដែលបង្កខ្សែរភ្លើងឆក់មនុស្សស្លាប់និងរបួសនេះគឺដោយសារខ្សែរភ្លើងដែលជាប់និងជញ្ជាំងសាំងកាសីបាំងបន្ទាប់ស្នាក់នៅ បានឆ្លងចរន្តភ្លើងមកលើដែកសាំងកាសីនៅដែលកម្មករស្នាក់នៅយកថៃចាប់ទើបត្រូវខ្សែភ្លើងឆក់ស្លាប់តែម្តង។

## ពលករខ្មែររាប់ពាន់នាំគ្នាសម្រុកទៅធ្វើប៉ាស្ព័រ នៅBigC. ឡាតប្លាវ

http://pheaktraprak.com/archives/ By เพียะตรา ประ October 18, 2017

កាលពីថ្ងៃអង្គារទី17 ខែតុលា ឆ្នាំ2017 បងប្អូនពលករខ្មែរចំនួនរាប់ពាន់នាក់ បានសម្រុកនាំគ្នាទៅទទួលលេខរៀងដើម្បីរងចាំត្រួតសញ្ជាតិធ្វើប៉ាស្ព័រការងារស្របច្បាប់ដែលគណៈកម្មការកម្ពុជាផ្តល់ជូន។ យោងតាមទំព័រហ្វេសប៊ុករបស់និយោជកថៃម្នាក់ បានបង្ហោះទិដ្ឋភាពខណៈដែលមានពលករខ្មែរចំនួនរាប់ពាន់នាក់បានគ្នាមកសុំលេខរៀងដើម្បីបញ្ជាក់អត្តសញ្ញាណនៅក្នុងហាងទំនើប(អីមផូលៀបឡាតប្លាវ ឬ BigC ជាន់ទី4) យ៉ាងច្រើនកុះករ បើតាមរៀបរាប់របស់និយោជកខាងបានអោយដឹងថា ពលករកម្ពុជាចំនួនរាប់ពាន់នាក់មកពីខេត្តផ្សេងៗជុំវិញទីក្រុងបាងកក បាននាំគ្នាមកបញ្ជាក់អត្តសញ្ញាណដើម្បីធ្វើប៉ាស្ព័រការងារដែល គណៈកម្មការកម្ពុជាបើកធ្វើនៅក្នុងទីតាំងហាងទំនើបខាងលើនេះ។

# ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧

## សម្តេចតេជោ ហ៊ុន សែន៖ ប្រទេសណាក៏បញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសដែរ កុំបន្ទោសខ្ញុំថាបញ្ជូនមនុស្សឲ្យទៅធ្វើខ្ញុំគេ ព្រោះអ្នកថានោះក៏ធ្វើការឲ្យគេដែរ

http://www.freshnewsasia.com/index.php/en/localnews/ 2017-10-18

**(ភ្នំពេញ)៖** ឆ្លើយតបនឹងការតិះដៀលផ្តេសផ្តាសពីបុគ្គលមួយចំនួន ដែលមិនយល់ពីទិដ្ឋភាពសកលលោកអ្វីសោះនោះ សម្តេចតេជោ ហ៊ុន សែន ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា បានថ្លែងពន្យល់ថា ការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស មិនមែនមានតែកម្ពុជានោះទេ ប្រទេសដទៃក៏បញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសដែរ ដើម្បីឲ្យពលកររបស់ខ្លួនទទួលបានប្រាក់ឈ្នួលខ្ពស់ និងទទួលបានជំនាញពិតប្រាកដពីការងារក្រៅប្រទេសនោះ មិនមែនជាការបញ្ជូនមនុស្សឲ្យទៅធ្វើខ្ញុំគេនោះឡើយ។ **សូមស្តាប់ប្រសាសន៍របស់សម្តេចតេជោ ហ៊ុន សែន។**

ការថ្លែងបែបនេះរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងពិធីសំណេះសំណាលជាមួយកម្មករ-កម្មការិនី ជាង១ម៉ឺននាក់ ក្នុងតំបន់កំបូល ស្ថិតក្នុងពោធិ៍សែនជ័យ រាជធានីភ្នំពេញ នាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧។ សម្តេចតេជោ ហ៊ុន សែន បានបង្ហើបថា កន្លងមក មានបុគ្គលមួយចំនួនធ្លាប់បានបន្ទោសបង្អាប់សម្តេចថា បញ្ជូនមនុស្សទៅឲ្យធ្វើខ្ញុំគេនៅក្រៅប្រទេស ប៉ុន្តែបានបញ្ចេញប្រតិកម្មវិញថា មិនមែនមានតែប្រទេសកម្ពុជាទេ ដែលបញ្ជូនពលករ-ពលការិនីទៅធ្វើការនៅក្រៅប្រទេសនោះ ប្រទេសដទៃក៏រដ្ឋាភិបាលគេបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសដែរ តួយ៉ាងហ្វីលីពីន ជាប្រទេសដែលបញ្ជូលពលករច្រើនជាងគេ រហូតដល់ជាង១២លាននាក់ ក្នុងនោះមានប្រមាណ១ម៉ឺននាក់ធ្វើការនៅកម្ពុជា ប្រទេសថៃដែលយកពលករពីកម្ពុជាទៅ ក៏បញ្ជូនពលករគេទៅធ្វើការនៅកូរ៉េខាងត្បូង ជប៉ុន កោះតៃវ៉ាន់ និងនៅមជ្ឈិមបូព៌ាដែរ។ ប្រទេសដែលមិនមានការបញ្ជូនពលករចេញ គឺមានតែប្រទេសសិង្ហបុរី ម៉ាឡេស៊ី តែប៉ុណ្ណោះ។

សម្តេចថ្លែងយ៉ាងដូច្នេះថា **«អញ្ចឹងសូមកុំតិះដៀលខ្ញុំថា បញ្ជូនមនុស្សទៅឲ្យធ្វើខ្ញុំគេ កន្លងទៅមានការបន្ទោសបង្អាប់ថា ក្មួយៗនេះ (កម្មករ-កម្មការិនី) សុទ្ធតែជាអ្នកមកធ្វើកញ្ចះគេ ក្នុងពេលដែលក្មួយៗស្វែងរកឱកាសការងារយ៉ាងលំបាក គេមកបន្ទោសថា ពូដឹកនាំគ្រាន់តែធ្វើឲ្យមនុស្សធ្វើកញ្ចះគេ ក៏ប៉ុន្តែអ្នកនិយាយនោះ ក៏ធ្វើការឲ្យគេដែរ គាត់មិនមែនធ្វើថៅកែទេ បើដូច្នោះមានអ្វីខុសគ្នា»**។

ប្រមុខរាជរដ្ឋាភិបាល បានលើកឡើងថា មិនមែនក្នុងប្រទេសកម្ពុជាគ្មានការងារធ្វើនោះទេ ឱកាសការងារក្នុងប្រទេសក៏មានច្រើនសន្ធឹកសន្ធាប់ដែរ ប៉ុន្តែដើម្បីផ្តល់ជម្រើសការងារជូនប្រជាពលរដ្ឋ រាជរដ្ឋាភិបាលបានខិតខំធ្វើយ៉ាងណាបើកឱកាសការងារក្រៅប្រទេស ជាមួយតម្លៃប្រាក់ឈ្នួលខ្ពស់ និងសម្របសម្រួលដល់ពលករខ្មែរខុសច្បាប់ ឲ្យក្លាយជាពលករស្របច្បាប់វិញ ជាក់ស្តែងដូចពលករខ្មែរនៅប្រទេសថៃ មានទាំងពលករស្របច្បាប់ និងខុសច្បាប់ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសេនាធិការ បាននិងកំពុងខិតខំធ្វើការជាមួយរាជរដ្ឋាភិបាលថៃ ដើម្បីបង្កលក្ខណៈឲ្យពលករខ្មែរដែលធ្វើការដោយខុសច្បាប់ ក្លាយទៅជាពលករស្របច្បាប់វិញ ហើយក៏កំពុងតែខិតខំធ្វើយ៉ាងណាឲ្យពលករខ្មែរ ទទួលបានអត្ថប្រយោជន៍កាន់តែច្រើនដូចកម្មករថៃទៀតផង។ ក្រៅពីនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏កំពុងសម្របសម្រួលបញ្ហាគ្រប់បែបយ៉ាងជូនពលករខ្មែរ ដែលធ្វើការនៅកូរ៉េខាងត្បូង ជប៉ុន និងនៅប្រទេសដទៃទៀតផងដែរ។

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីស្វែងរកសន្តិភាព និងថែរក្សាសន្តិភាពនៅកម្ពុជា ក៏បានប្រាប់ឲ្យកម្មករ-កម្មការិនីកាប់ថ្មចំណាំ ហើយចាំទុកថា មានសន្តិភាព ទើបប្រជាពលរដ្ឋមានការងារធ្វើ និងមានប្រាក់ចំណូល តែបើបាត់សន្តិភាពហើយ កម្មករ-កម្មការិនី និងប្រជាពលរដ្ឋទាំងអស់នឹងបាត់ការងារធ្វើ និងប្រាក់ចំណូលភ្លាមដែរ អ្នកដែលខាតបង់មុនគេ គឺកម្មករ-កម្មការិនីនេះឯង។ សម្តេចតេជោ ហ៊ុន សែន បានគូសបញ្ជាក់ប្រាប់កម្មករ-កម្មការិនី ក្នុងឱកាសនោះថា «អ្នកណាក៏ដោយ ដែលទៅប្រាប់បរទេសថា កុំឲ្យផ្តល់ជំនួយដល់កម្ពុជា កុំឲ្យវិនិយោគនៅកម្ពុជា កុំឲ្យទិញទំនិញពីកម្ពុជា គឺជាអ្នកក្បត់នឹងផលប្រយោជន៍របស់កម្មករ-កម្មការិនី ក្បត់នឹងផលប្រយោជន៍របស់ប្រជាជាតិកម្ពុជា មិនមែនសមហេតុសមផលធ្វើជាមេដឹកនាំរបស់កម្ពុជានោះទេ»។

សម្តេចនាយករដ្ឋមន្ត្រីបានសម្តែងនូវក្តីសង្ឃឹមថា កម្មករ-កម្មការិនីនឹងបន្តការខិតខំរួមចំណែក ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិដ៏កំសត់មួយនេះ ឲ្យទៅជាប្រទេសដែលមានការរីកចម្រើន។ ឱកាសដ៏ស្និទ្ធស្នាលនោះ សម្តេចតេជោ ហ៊ុន សែន ពិតជាមានមោទនភាពជាមួយកម្មករ-កម្មការិនី និងប្រជាពលរដ្ឋកម្ពុជាខ្លាំងណាស់ ដែលបានរួមដំណើរជាមួយសម្តេច អស់រយៈពេលជិត៤០ឆ្នាំមកនេះ ក្នុងការពួតដៃគ្នាវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ក៏ដូចជាដើម្បីទប់ស្កាត់របបដ៏ខ្មៅងងឹតនេះ កុំឲ្យកើតឡើងជាថ្មីលើទឹកដីកម្ពុជាដ៏កំសត់ និងដើម្បីស្វែងរកសន្តិភាព និងអភិវឌ្ឍន៍ប្រទេសជាតិឆ្ពោះទៅភាពរីកចម្រើនរុងរឿង។ សូមជម្រាបថា ពលករខ្មែរដែលកំពុងធ្វើការនៅក្រៅប្រទេសមានប្រមាណ ១,០៥០,០០០នាក់ ក្នុងនោះប្រទេសថៃមានជាង១លាននាក់៕

## ចាប់ខ្លួនជនទី៣បញ្ជូនឡើងតុលាការ ក្នុងសំណុំរឿងលក់ទិញក្រលៀន

http://www.cen.com.kh/local/ (ថ្ងៃទី 19 តុលា 2017, ម៉ោង 01:28:PM) | ដោយ: ដាលី

ភ្នំពេញ: រឿងក្តីទិញ លក់ក្រលៀនឆ្លងដែន ដែលបានធ្វើអោយល្បីកក្រើកកាលពីចុងខែឧសភា ឆ្នាំ២០១៧ កន្លងទៅ ខណៈជនជាប់ចោទ២នាក់ កំពុងជាប់ឃុំឃាំងក្នុងពន្ធនាគារពីបទជួញដូរសរីរាង្គមនុស្សដោយខុសច្បាប់នោះ ឥឡូវនេះត្រូវបានសមត្ថកិច្ចចាប់ខ្លួនជនទី៣ម្នាក់ទៀតហើយ បញ្ជូនមកតុលាការដើម្បីសាកសួរ ។

មន្ត្រីនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញបានអោយដឹងថា ជនសង្ស័យទី៣ដែលត្រូវឃាត់ខ្លួននេះឈ្មោះ ជឿន ធី ហៅធីក្បាលធំ ភេទប្រុសអាយុ៣៨ឆ្នាំ មានមុខរបរជាកម្មករ និងជាអ្នករត់ការឯកសារបញ្ជូនមនុស្សឆ្លងដែនទៅប្រទេសឥណ្ឌាដើម្បីវះកាត់ដូរសរីរាង្គ ( ដូរក្រលៀន ) ។ នៅក្នុងសំណុំរឿងទិញ-លក់ក្រលៀន ដែលសមត្ថកិច្ចបានបង្ក្រាបកាលពីថ្ងៃទី ២៤ឧសភា ឆ្នាំ២០១៧កន្លងទៅនោះ ឈ្មោះ ជឿន ធី គឺជាអ្នករត់ការឯកសារអោយជនរងគ្រោះ និងជាអ្នកនាំជនរងគ្រោះមកជួប ឡាច ម៉េងហុង និងអឿ ឡាត ។ ប៉ុន្តែក្រោយចាប់ខ្លួនជនសង្ស័យ២នាក់នេះ ឈ្មោះ ជឿន ធី បានរត់គេចខ្លួនបាត់រហូតមកដល់ថ្ងៃចាប់ខ្លួនកាលពីថ្ងៃទី១៧តុលា ឆ្នាំ២០១៧នេះ ។ ឥឡូវនេះឈ្មោះ ជឿន ធី ត្រូវបានបញ្ជូនមកអោយលោក ខៀវ ផល្លា ព្រះរាជអាជ្ញារងកំពុងធ្វើការសាកសួរនាំព្រឹកថ្ងៃទី ១៩តុលានេះ ។

គួររំលឹកថាចៅក្រមសើបសួរសាលាដំបូងរាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី ៣០ឧសភា ២០១៧ នេះបានសម្រេចចេញដីកាឃុំខ្លួន ជនសង្ស័យប្រុសស្រី២នាក់ពាក់ពន្ធករណីជួញដូរក្រលៀន ដាក់ពន្ធនាគារជាបណ្តោះអាសន្ន ក្រោមការចោទប្រកាន់ពីបទជួញដូរមនុស្សឆ្លងដែនដោយខុសច្បាប់ (ដកហូតសរីរាង្គ) តាមមាត្រា១០ និងមាត្រា១៥ នៃច្បាប់ស្តីពីអំពើប្រឆាំងការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ។ ជនជាប់ចោទដែលតុលាការឃុំខ្លួនឈ្មោះ ឡាច ម៉េងហុង ភេទប្រុស អាយុ៣៤ឆ្នាំ មានអាស័យដ្ឋាននៅភូមិព្រែកឯក សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ

រាជធានីភ្នំពេញ( ជាមេខ្យល់) និងម្នាក់ឈ្មោះ អើ ឡាត ភេទស្រី អាយុ៣៨ឆ្នាំ ស្នាក់នៅផ្ទះជួលក្នុងសង្កាត់ចោមចៅ រាជធានីភ្នំពេញ ។

គួរបញ្ជាក់ថាជនសង្ស័យប្រុសស្រី ២នាក់ ម្នាក់ជាមេខ្យល់ និងម្នាក់ជាអ្នកគួកជេរ(រកមនុស្ស) ក្នុងករណីជួញដូរក្រលៀន កាលពីថ្ងៃទី២៤ ឧសភា ត្រូវបានសមត្ថកិច្ចនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជនរាជធានីភ្នំពេញធ្វើការស្រាវជ្រាវ រហូតឈានដល់ការឃាត់ខ្លួន ជនសង្ស័យម្នាក់ឈ្មោះ ឡាច ម៉េងហុង ភេទប្រុស អាយុ៣៤ឆ្នាំ មានអាស័យដ្ឋាននៅភូមិព្រែកឯក សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ( ជាមេខ្យល់ )និងម្នាក់ឈ្មោះ អើ ឡាត ភេទស្រី អាយុ៣៨ឆ្នាំ ស្នាក់នៅផ្ទះជួលក្នុងសង្កាត់ចោមចៅ រាជធានីភ្នំពេញ ។

ទាក់ទិន និង ការឃាត់ ខ្លួនសង្ស័យទាំង២នាក់ខាងលើនេះត្រូវបានលោកវរៈសេនីយ៍ឯក កែវ ជា ប្រធានការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងកាពារអនិតិជន រាជធានីភ្នំពេញឲ្យដឹងថា កន្លងទៅការិយាល័យធ្លាប់បានទទួលព័ត៌មាន និងពាក្យបណ្ដឹងជាញឹកញ៉ាប់ ពីករណីមានជនល្មើសមួយក្រុមរកស៊ីជួញដូរក្រលៀន ក្នុងរូបភាពនាំមនុស្សពីស្រុកខ្មែរទៅវះដោះដូរនៅប្រទេសឥណ្ឌា ។

ក្រោយពីទទួលបានព័ត៌មាននោះសមត្ថកិច្ចជំនាញ បានធ្វើការស្រាវជ្រាវ រហូតដល់រសៀលថ្ងៃទី២៤ ឧសភា ឈានដល់ការឃាត់ខ្លួនស្ត្រីម្នាក់ នៅខាងក្រោយផ្សារឯករាជ្យ២ តាមផ្លូវវែងស្រេង សង្កាត់ចោមចៅ ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ លុះវេលាម៉ោងជា៧យប់ថ្ងៃដដែលចាប់បានបុរសម្នាក់ទៀតជាមេក្លោង នៅម្តុំស្តុបបូកគោ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ។ លោកវរៈសេនីយ៍ឯក កែវ ជា បន្តថា ក្រោយពេលចាប់ខ្លួនជនសង្ស័យបានសារភាពថា ពួកគេគឺជាមុខសញ្ញាជួញដូរក្រលៀនពិតប្រាកដមែន និងធ្លាប់បានធ្វើសកម្មភាពជាង១ឆ្នាំហើយ និងធ្វើបានជាង១០នាក់ ដែលនាំមនុស្សយកទៅវះកាត់ដោះដូរក្រលៀន នៅប្រទេសឥណ្ឌា ដែលមានទីតាំងនៅទីក្រុងញូដាលី ។ តាមចម្លើយជនសង្ស័យបានប្រាប់សមត្ថកិច្ចទៀតថា ជាមួយឆ្នាំនេះបុរសឈ្មោះ ឡាច ម៉េងហុង បានទាក់ទងធ្វើសកម្មភាពប្រើមនុស្សឲ្យដើររកអ្នកជម្ងឺដែលត្រូវការក្រលៀន ហើយក៏គេត្រូវការរកមនុស្ស ឬជនក្រីក្រត្រូវការប្រាក់ដើម្បីទ្រទ្រង់ជីវភាព( លក់ក្រលៀន) ។

ក្នុងនោះជនសង្ស័យបានប្រើល្បិចខ្ពស់ តាមរូបភាពពីរ១.ដំបូងត្រូវការពិនិត្យឈាមជនរងគ្រោះអ្នកលក់ក្រលៀន ឲ្យត្រូវគ្នាជាមួយអ្នកជម្ងឺត្រូវដោះដូរក្រលៀន ២.ត្រូវការកែឆ្នៃឯកសារជនរងគ្រោះ(អ្នកលក់ក្រលៀន)ធ្វើជាសាច់ញាតិអ្នកដែលត្រូវការ( ទិញក្រលៀន)ប៉ុន្តែជាអ្នកដ៏ទៃទេ ដើម្បីងាយស្រួលគេរៀបចំធ្វើឯកសារជាលក្ខណៈធ្វើមនុស្សធម៌ ក្នុងការនាំចេញទៅដោះដូរនៅប្រទេសឥណ្ឌានោះ ។ ចម្លើយបញ្ជាក់ថា ក្រលៀនមួយឈ្មោះ ឡាច ម៉េងហុង យកពីអ្នកជម្ងឺតម្លៃជាង ៤ម៉ឺនដុល្លារអាមេរិក តែក្នុងតម្លៃជាង៤ម៉ឺនដុល្លារនោះ គេបានយកទៅចំណាយលើការកែឆ្នៃឯកសារ ដើម្បីដាក់ចូលស្ថានទូតឥណ្ឌាសម្រាប់នាំមនុស្សចេញ និងថ្លៃយន្តហោះ ការហូបចុក និងការស្នាក់នៅ ។ ដូច្នោះខ្លួននៅសល់ប្រាក់ពីការចំណាយត្រឹម៥ ៨០០ ដុល្លារក្នុងម្នាក់តែប៉ុណ្ណោះ ។

ចំណែកចម្លើយស្ត្រីដែលជាជនសង្ស័យឈ្មោះ អើ ឡាត បានសារភាពប្រាប់សមត្ថកិច្ចថា ខ្លួនទើបតែចូលរួមធ្វើសកម្មភាពជាមួយឈ្មោះ ឡាច ម៉េងហុង ២ដងទេ និងដើររកបានមនុស្ស២នាក់ប្រគល់ឲ្យ ម៉េងហុង នាំទៅវះកាត់ដោះដូរក្រលៀននៅប្រទេសឥណ្ឌានោះ ។ ជនសង្ស័យបន្តថា មនុស្ស២នាក់នោះ ត្រូវបានឈ្មោះ ម៉េងហុង ឲ្យសេវាម្នាក់៤០០ទៅ៥០០ដុល្លារអាមេរិក តែក៏បានកុម្មុយស្យុងពីអ្នកលក់ក្រលៀន និងអ្នកជម្ងឺត្រូវការទិញក្រលៀនខ្លះទៀតដែរ ។ បានជាមានការរៀបចំ និងរកមនុស្ស(អ្នកលក់ និងអ្នកទិញក្រលៀន) ទៅធ្វើការវះកាត់ ដោះដូរនៅប្រទេសឥណ្ឌានោះ ព្រោះវេជ្ជបណ្ឌិតនៅទីនោះយកតម្លៃថោក ពោលគឺធ្វើការវះកាត់ដោះដូរក្រលៀនមនុស្សម្នាក់អស់តែ១៥.០០០ ទៅ១៧.០០០ដុល្លារអាមេរិក(ថ្លៃកាំបិត) មិនមែនថ្លៃក្រលៀនទេ ថ្លៃក្រលៀន៥.៨០០ដុល្លារផ្សេង ។ លោក កែវ ជា បន្តថា ជនសង្ស័យជាមេខ្យល់ឈ្មោះ ឡាច ម៉េងហុង គេមានបណ្ដាញទំនាក់ទំនងនៅក្នុង

ស្រុករហូតដល់ប្រទេសឥណ្ឌា រីឯស្ត្រីម្នាក់នោះគ្រាន់តែជាមនុស្សដែលឈ្មោះ ឡាច ម៉េងហុង ប្រើ និងឲ្យដើរអូសទាញជនក្រីក្រត្រូវការប្រាក់(លក់ក្រលៀន) ប៉ុណ្ណោះ ៕

## ប៉ូលីសថៃស្ទាក់ចាប់រថយន្តដឹកពលករអន្តោប្រវេសន៍ខ្មែរឆ្លងដែនខុសច្បាប់ ដើម្បីយកទៅលក់កម្លាំងពលកម្មនៅបាងកក និងខេត្តសមុទ្រសង្គ្រាម បង់ប្រាក់ថ្លៃដឹកក្នុងម្នាក់ៗ ចំនួន ២០០០-២៤០០បាត

http://www.khmeryouthnews.com/article ១៨-តុលា-២០១៧

(ប្រទេសថៃ) យោងតាមប្រភពកាសែត Naewna ភាសាថៃបានផ្សាយឲ្យដឹងថា កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ លោកវរសេនីយ៍ត្រី ប៉េញចៈគុន រ៉ែតសាវ៉ាត មេបញ្ជាការប៉ូលីសអន្តោប្រវេសសន៍ថៃប្រចាំខេត្តស្រះកែវ បានដឹកនាំកម្លាំងស៊ើបអង្កេត និងបង្ក្រាប ព្រមតាំងកម្លាំងយោធាថៃប្រចាំស្រុកគោគស៊ូង ខេត្តស្រះកែវ ដើម្បីយាមល្បាតនៅក្នុងស្រុកគោកស៊ូង ព្រោះបានទទួលព័ត៌មានថា មានក្រុមលក់កម្លាំងពលករខុសច្បាប់ខ្មែរលួចចូលមកក្នុងដីថៃ ដោយមានរថយន្តតួរីសមកទទួលពួកគាត់ នៅបរិវេណព្រំដែនស្រុកគោកស៊ូង ដើម្បីដឹកយកទៅលក់កម្លាំងពលកម្មនៅម្តុំទីក្រុងបាងកក និងបរិវេនខ័ណ្ឌពុទ្ធមណ្ឌល ហើយភាគច្រើនពួកមេខ្យល់ទាំងនោះ តែងតែលួចដឹកពលករខ្មែរចេញពីតំបន់ព្រំដែនចាប់ពីវេលាម៉ោង៣-៥ទៀបភ្លឺ ដើម្បីធ្វើដំណើរឆ្ពោះទៅកាន់ទីក្រុងបាងកក ។

រថយន្តដែលសមត្ថកិច្ចថៃស្ទាក់ចាប់បាននោះ ម៉ាកតូយ៉ូតា ពណ៌ទឹកប្រាក់ ស្លាកលេខឧឃ6884 (បាងកក) បានបើកចេញពីចុងភូមិណូនសំប៊ូន ឃុំគោកស៊ូង ស្រុកគោកស៊ូង ខេត្តស្រះកែវ ជាភូមិដែលស្ថិតនៅជាប់ព្រំដែនកម្ពុជា-ថៃ បានបើកសំដៅទៅរកផ្លូវបំបែកភូមិគោកម៉ែង៉ាម មកកាន់ស្រុកវ៉ាត់ថាណា ជាកន្លែងដែលសមត្ថកិច្ចថៃបាននឹងកំពុងតែរង់ចាំស្ទាក់ចាប់រថយន្តនោះ ហើយរថយន្តនោះបានបើកដោយល្បឿនលឿន ពេលដែលឃើញសមត្ថកិច្ច ប៉ុន្តែមិនអាចគេចខ្លួនរួចបានឡើយ ។

អ្នកបើកបររថយន្តឈ្មោះផារិច ផានិចភិរម្យ អាយុ៤៥ឆ្នាំ មានដើមកំណើតនៅឃុំសួនលួង ស្រុកអាំផាវ៉ា ខេត្តសមុទ្រសង្គ្រាម ដោយមានពលករខុសច្បាប់កម្ពុជាមកជាមួយចំនួន១៧នាក់ ។ សមត្ថកិច្ចថៃបានធ្វើការត្រួតពិនិត្យ ពុំមានឃើញឯកសារអ្វីឡើយ ហើយបានចឃាត់ខ្លួនពលករខ្មែរទាំងនោះជាបុរសចំនួន១១នាក់ និងស្ត្រីចំនួន ៦នាក់ ព្រមទាំងបាននាំអ្នកបើកបរ និងរថយន្តមកសាកសួរ ព្រមទាំងរក្សាទុករថយន្តនោះ នៅស្នងការប៉ូលីស្រុកគោគស៊ូង ខេត្តស្រះកែវ ។

បឋមពលករអន្តោប្រវេសន៍កម្ពុជាទាំង១៧នាក់នោះ បានទទួលសារភាពថា ពួកគាត់នឹងចេញដំណើរ ទៅរកកន្លែងធ្វើការងារសំណង់នៅម្តុំទីក្រុងបាងកក និងខេត្តសមុទ្រសង្គ្រាម មុននឹងមកពួកគាត់បានទំនាក់ទំនងទៅកាន់ក្រុមដឹកជញ្ជូនពលករជាជនជាតិថៃ ហើយក៏បានណាត់គ្នារួចដើម្បីយករថយន្តតួរីស មកទទួលនៅចុងភូមិណូនសំប៊ូនជាប់ព្រំដែនកម្ពុជា-ថៃ ដោយពួកគាត់លួចចូលមកប្រទេសថៃតាមច្រកធម្មជាតិ ហើយត្រូវបង់ប្រាក់ថ្លៃឈ្នួលដឹកក្នុងម្នាក់ៗ ពី២០០០-២៤០០បាត ។

អ្នកបើកបរឈ្មោះផារិច ផានិចភិរម្យ បានសារភាពថា ខ្លួនគ្រាន់តែជាអ្នកទទួលស៊ីឈ្នួលបើករថយន្តតែប៉ុណ្ណោះ ហើយក៏មិនព្រមប្រាក់ថា ថៅកែ ឬ មេខ្យល់ជាអ្នកណាឡើយ ទោះបីជាយ៉ាងណាក៏ដោយ សមត្ថកិច្ចថៃនៅមិនជឿលើពាក្យសារភាពរបស់អ្នកបើកបររថយន្តឡើយ ហើយបានឃុំខ្លួនអ្នកបើករថយន្តដើម្បីដំណើរការតាមនីតិ

វិធីដោយបានចោទប្រកាន់បទ "ផ្តល់ការជួយ ឬ ជាជំនួយឲ្យជនអន្តោប្រវេសន៍បរទេសរួចផុតពីការចាប់ខ្លួនរបស់សមត្ថកិច្ចថៃ" ។

ចំណែកពលអន្តោប្រវេសន៍ខ្មែរទាំង១៧នាក់ សមត្ថកិច្ចថៃបានកសាងសំណុំរឿងបណ្តឹងពីបទ "ជនអន្តោប្រវេសន៍ ចូលមក និងស្នាក់នៅព្រះរាជាណាចក្រថៃ ដោយបានទទួលការអនុញ្ញាត" មិនតែប៉ុណ្ណោះ សមត្ថិថៃនឹងសាកសួរពលករទាំងនោះបន្ត ដើម្បីស្វែងរកថៅកែ និងមេខ្យល់នាំដែលបាននាំពលករខុសច្បាប់ចូលមកប្រទេសថៃយកមកផ្តន្ទាទោសតាមផ្លូវច្បាប់ មានន័យថា ទាំងអ្នកធ្វើ អ្នកចូលរួម ព្រមទាំងអ្នកនាំក៏ត្រូវមានទោសដូចគ្នា ។

ចំពោះនីតិវិធីជួយសម្រួលដល់ពលករខ្មែរ ដើម្បីឲ្យពួកគាត់មានភាពធូរស្រាល ឬដើម្បីឲ្យសមត្ថកិច្ចថៃធាប់ដោះលែងពួកគាត់ទាំង១៧នាក់នោះ ខាងមជ្ឈមណ្ឌលព័ត៌មាន "យុវជនខ្មែរព័ត៌មាន" និងទំនាក់ទំនងទៅកាន់ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ ដើម្បីចង់ដឹងអំពីការជួយសម្រួលដល់ពលករខ្មែរទាំង១៧នាក់នោះ ដើម្បីពួកគាត់ធាប់បានត្រឡប់ទៅស្រុកវិញ ហើយយើងខ្ញុំនឹងរាយការណ៍បងប្អូនបានជ្រាបជាបន្តទៀត ។ (ដោយ ស សែនជ័យ)

## តំណាងឯកអគ្គរាជទូតកម្ពុជា ចុះសួរសុខទុក្ខពលករកម្ពុជា ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យប្រទេសថៃ បន្ទាប់ពីរងគ្រោះថ្នាក់ចរាចរ

http://pheaktraprak.com/archives/ By เพียะตรา ประ October 18, 2017

កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ ទីប្រឹក្សាទទួលបន្ទុក តំណាងផ្នែកកុងស៊ុល និងសហការី តំណាងឲឯកឧត្តម ឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសថៃ បានចុះមកសួរសុខទុក្ខ ពលករកម្ពុជាដែលបានជួបគ្រោះថ្នាក់ចរាចរណ៍កាលពីយប់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ នៅមន្ទីរពេទ្យពីរផ្សេងគ្នា គឺមន្ទីរពេទ្យកុយបុរី និងមន្ទីរពេទ្យប្រាជួបគីរីខាន់ ស្ថិតក្នុងខេត្តប្រាជួបគីរីខាន់ ប្រទេសថៃ។ នៅក្នុងហេតុការណ៍នេះបណ្តាលអោយពលករនិងអ្នកនៅក្នុងបន្ទុកចំនួន១6នាក់រងរបួសស្រាលនិងបានវិលត្រឡប់ទៅព្រះរាជាណាចក្រកម្ពុជាវិញអស់ហើយ។ ដោយឡែកពលករ0២រូបទៀតរងរបួសដែល តម្រូវអោយសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងស្លាប់ទារក0១រូប ដែលមានអាយុទើបតែ0៧ថ្ងៃ។ នាពេលនេះស្ថានភាពអ្នកជំងឺទាំង0២នាក់បានធូរស្រាលបន្តិចហើយ ហើយស្ថានទូតក៏បានទំនាក់ទំនងទៅសាច់ញាត្តិជនរងគ្រោះ ជូនព័ត៌មានអំពីករណីនេះ និងបន្តសហការជួបសម្របសម្រួលជាមួយអាជ្ញាធរថៃពាក់ពន្ធ័ក្នុងការព្យាបាលអ្នកជំងឺដោយយកចិត្តទុកដាក់។

## ហេតុតែចង់ឲ្យស្របច្បាប់ សុខចិត្តដេករង់ចាំធ្វើប៉ាស្ព័រ

http://pheaktraprak.com/archives/ By เพียะตรา ประ October 18, 2017

បងប្អូនពលករខ្មែរមកពីខេត្តផ្សេងៗនៅក្នុងប្រទេសថៃ បាននាំគ្នាក្រាលឡេលដេកដើម្បីរងចាំតម្រង់ជួរ យកលេខរៀងចូលបញ្ជាក់អត្តសញ្ញាណធ្វើប៉ាស្ព័រនៅថ្ងៃស្អែក។ បើយោងតាមទំព័រហ្វេសប៊ុករបស់និយោជកថៃម្នាក់ បានបង្ហោះរូបភាពពលករខ្មែរមួយចំនួនដែលកំពុងដេកចាំបញ្ជាក់អត្តសញ្ញាណនៅទីតាំងធ្វើប៉ាស្ព័រនៅក្នុងហាង (អូចប៉យ៉ា)ស្ថិតខេត្តរ៉ាក់យ៉ង កាលពីវេលាម៉ោង10យប់នាថ្ងៃពុធទី 18 ខែតុលា ឆ្នាំ2017។

## ពលករខ្មែរ១៩នាក់ ទុក្ខជាន់លើទុក្ខពេកហើយ ! រថយន្តប៉ូលីសអន្តោប្រវេសន៍ថៃបើកបុកបង្គោលភ្លើងបណ្តាលឲ្យទារកខ្មែរម្នាក់ដែលទើបតែកើតបាន៧ថ្ងៃស្លាប់ រងរបួសធ្ងន់ និងស្រាលជាច្រើននាក់

http://www.khmeryouthnews.com/article ១៦-តុលា-២០១៧

(ប្រទេសថៃ) រថយន្តប៉ូលីសអន្តោប្រវេសន៍ថៃចេញដំណើរពីទីរួមស្រុកសុងែ-គោលុក ដឹកបញ្ជូនពលករអន្តោប្រវេសន៍ខ្មែរមកកាន់ប៉ូលីសអន្តោប្រវេសន៍ខេត្តស្រះកែវ ដើម្បីបញ្ជូនបន្តមកកាន់ប្រទេសកម្ពុជាវិញ ដល់ពាក់កណ្តាលផ្លូវបានបើកធ្លាក់ផ្លូវបុកជាមួយបង្គោលភ្លើង និងរបងផ្ទះដ៏សែនរន្ធត់ជាទីបំផុត បានធ្វើឲ្យកុមារដែលទើបតែកើតបាន៧ថ្ងៃ ខ្ទាតចេញពីរថយន្តបានស្លាប់ភ្លាមៗ នៅកន្លែងកើតហេតុ ។

នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ នេះ លោកអនុសេនីយ៍ទោ ស៊ុមម៉ាយ បានយ៉េន សមត្ថកិច្ចថៃប្រចាំស្នងការកុយបុរី ខេត្តប្រាជួបគីរីខាន់ បានទទួលរបាយការណ៍ថា មានរថយន្ត០១គ្រឿងបានជួបឧបទ្ទវហេតុបើកធ្លាក់ផ្លូវបណ្តាលឲ្យមានអ្នករងរបួសធ្ងន់ និងស្រាលជាច្រើននាក់ នៅលើដងផ្លូវចូលផេកាសេមចន្លោះគីម៉ែត្រលេខ២៧៩-២៨០ ភូមិបានជួនប៊ុន ឃុំកុយបុរី ស្រុកកុយបុរី ខេត្តប្រាជួបគីរីខាន់ បន្ទាប់មកលោកបានដឹកនាំកម្លាំងទៅត្រួតពិនិត្យដោយមានក្រុមជួយសង្គ្រោះមូលនិធិលោកតាវត្តកុដិកុយបុរី ទៅជាមួយផងដែរ ។

នៅកន្លែងកើតហេតុឃើញមានរថយន្តឯកជនម៉ាក Toyota ចំនួន០១គ្រឿង ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ មខ1420 ខេត្តនរ៉ាធិវ៉ាត ជារថយន្តជួលដោយប៉ូលីសអន្តោប្រវេសន៍ថៃ បានបើកធ្លាក់ផ្លូវដោយបុកជាមួយបង្គោលភ្លើង ហើយបន្តទៅបុកនិងរបងផ្ទះប្រជាជនដែលស្ថិតនៅទីនោះទទួលរងការខូចខាត ចំណែករថយន្តក៏រងការខូចខាតស្ទើទាំងស្រុងដែរ ។ ក្រោយពេលកើតឧបទ្ទវហេតុ អ្នកដំណើរព្យាយាមចេញពី រថយន្ត ក្នុងនោះមានអ្នកដំណើរ២នាក់ទៀត មិនអាចចេញរថយន្តបានឡើយ ដែលជាអ្នកបើកបរឈ្មោះ សរិះ សីនិ (ជនជាតិថៃម៉ូស្លីម) អាយុ៤៧ ឆ្នាំ ចំណែកម្នាក់ទៀតជាស្ត្រីជនជាតិខ្មែរ ក្រុមអ្នកជួយសង្គ្រោះមន្ទីរពេទ្យកុយបុរី បានដឹកយកអ្នករងរបួសចេញពីរថយន្ត ហើយបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យកុយបុរីជាបន្ទាន់ ។

អ្នកដំណើរសរុបទាំងអស់ចំនួន២២នាក់ មនុស្សធំពេញវ័យ១៧នាក់ កុមារ៥នាក់ ក្នុងនោះមានទារកម្នាក់ដែលទើបតែកើតបាន៧ថ្ងៃ បានខ្ទាតចេញពីរថយន្តបណ្តាលឲ្យស្លាប់ភ្លាមៗនៅកន្លែងកើតហេតុ ហើយស្ត្រីរងរបួសធ្ងន់ជាងគេដែលចេញពីរថយន្តមិនរួច ត្រូវជាម្តាយរបស់សពទារកដែលស្លាប់នោះ ។ មិនតែប៉ុណ្ណោះ ថែមទាំងមានស្ត្រីម្នាក់ទៀតដែលកំពុងតែមានផ្ទៃពោះផងដែរ បានប៉ះទង្គិចហើយចុកពោះជាខ្លាំង ពេទ្យបានព្យាយាមជួយសង្គ្រោះជាបន្ទាន់ដើម្បីជួយដល់អ្នកមានផ្ទៃពោះមុនគេ ចំណែកអ្នកដទៃទៀត បានរងរបួសស្រាល ។

មន្ត្រីប៉ូលីសថៃ បានសាកសួរទៅលោក យ៉ារ៉ូសាឡែម ស្មាអ៊ែ (ជនជាតិថៃម៉ូស្លីម) អាយុ៤៦ ឆ្នាំ ដែលធ្វើដំណើរមកជាមួយរថយន្តបានឲ្យដឹងថា គាត់ជាអ្នកបើករថយន្តទី២ (អ្នកចាំផ្លាស់វេនបើកបរ) ដោយមានឈ្មោះ សរិះ សីនិ (ជនជាតិថៃម៉ូស្លីម) ជាអ្នកបើកបរទី១ បានធ្វើដំណើរចេញមកពីប៉ូលីសអន្តោប្រវេសន៍ខេត្តនរ៉ាធិវ៉ាត ដឹកពលករអន្តោប្រវេសន៍ខ្មែរសរុបចំនួន១៩នាក់ រួមជាមួយកុមារ ដើម្បីដឹកបញ្ជូនទៅកាន់ប៉ូលីសអន្តោប្រវេសន៍ខេត្តស្រះកែវថៃ (ខេត្តជាប់ព្រំដែនកម្ពុជាខេត្តបន្ទាយមានជ័យ) ហើយមានលោកព្រឹទ្ធបាលប៉ូលីស សឡុះ សារៈកាស៊ុម មន្ត្រីប៉ូលីសអន្តោប្រវេសន៍ជាអ្នកមើលការខុសត្រូវ ។ អ្នកបើកបរឈ្មោះ យ៉ារ៉ូសាឡែម ស្មាអ៊ែ បានប្តូរឲ្យឈ្មោះសរិះ សីនិ បើកបរបន្តពីខ្លួនចាប់ពីខេត្តឈុំផន ក្រោយពីប្តូរវេនខ្លួនរួច គាត់ក៏បានអង្គុយលក់ក្នុងរថយន្ត ពេលដឹងខ្លួនមក

ម្តងទៀតបន្ទាប់ពីបានលឺសំឡេងផ្ទុះជាខ្លាំងដោយរថយន្តបានបើកបុកនិងបង្កោលភ្លើង ព្រមទាំងរបងផ្ទះលាន់ពេញរថយន្ត ហើយក៏ពុំបានដឹងអំពីមូលហេតុអ្វី ហេតុអ្វីបានជាកើតហេតុការណ៍យ៉ាងដូច្នេះឡើង ? ។

ចំណែកមន្ត្រីប៉ូលីសអន្តោប្រវេសន៍ថៃ លោកសឡុះ សារៈកាស៊ុម បានទទួលរងរបួសបែកក្បាលបន្តិចបន្តួចដោយអាចរាយការណ៍ជូនថ្នាក់លើបាន សមត្ថកិច្ចថៃបន្តថា នឹងបន្តការសាកសួរអំពីមូលហេតុបន្តទៀត បន្ទាប់ពីធ្វើការព្យាបាលរបួសអ្នកទាំងអស់នោះរួចសិន ។

មជ្ឈមណ្ឌលសារព័ត៌មាន "យុវជនខ្មែរព័ត៌មាន" នឹងធ្វើការសាកសួរទៅកាន់មន្ត្រីស្ថានទូតកម្ពុជា ប្រចាំទីក្រុងបាងកកទទួលបន្ទុកផ្នែកពលករ ដើម្បីសាកសួរអំពីនិតីវិធីនៃការជួយសម្រួលដល់ពលករខ្មែរខុសច្បាប់ទាំងនោះ និងជាពិសេសការចុះស្រង់យកព័ត៌មានលម្អិតរបស់មន្ត្រី ដើម្បីមន្ត្រីស្ថានទូតបានរាយការណ៍ជូនសាច់ញាតិនៅស្រុកខ្មែរបានជ្រាបបន្តទៀត។ (រាយការណ៍ដោយ ស សែនជ័យ ។

## ស្ថានទូតកម្ពុជា ប្រចាំម៉ាឡេស៊ីជួយអន្តរាគមន៍ពលរដ្ឋខ្មែរ៨នាក់ ត្រឡប់មកកម្ពុជាវិញ

http://www.freshnewsasia.com/index.php/en/localnews/ 2017-10-18

**(ភ្នំពេញ)៖** ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានអន្តរាគមន៍ជួយដោះស្រាយពលរដ្ឋខ្មែរចំនួន៨នាក់ឲ្យត្រឡប់មកស្រុកកំណើតវិញ។ នេះបើតាមសេចក្តីជូនដំណឹងរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧នេះ។

លោក ជុំ សុន្ទរី អ្នកនាំពាក្យ ក្រសួងការបរទេស និងសហប្រតិបត្តិការ បានបញ្ជាក់ថា ពលរដ្ឋខ្មែរទាំង៨នាក់ខាងលើនេះ មានស្រុកកំណើត ខេត្តកំពង់ធំ, ខេត្តត្បូងឃ្មុំ, ខេត្តក្រចេះ។ លោក ជុំ សុន្ទរី បានបន្ថែមទៀតថា មានពលរដ្ឋខ្មែរចំនួន២នាក់ហើយ បានមកដល់អាកាសយានដ្ឋាន អន្តរជាតិភ្នំពេញ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង១៥៖៥៥នាទី តាមជើងយន្តហោះ AK534។

## ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧
## អាជ្ញាធរខេត្តរំលឹកដល់កងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែន ទប់ស្កាត់ពលរដ្ឋតាមរយៈមេខ្យល់អូសទាញឲ្យលួចចូលកាប់ឈើគ្រញូងក្នុងទឹកដីថៃ

http://cambodiapolice.com/blog/archives/ 3:00 pm 19 តុលា 2017

បន្ទាយមានជ័យ ៖ អាជ្ញាធរខេត្តបន្ទាយមានជ័យបានដាស់តឿនរំលឹក ដល់កងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនទប់ស្កាត់ប្រជាពលរដ្ឋតាមរយៈមេខ្យល់ លួចចូលកាប់ឈើគ្រញូងឲ្យបាន ការពារសុវត្ថិភាពពួកគាត់ ។ នេះជាការលើករបស់ឯកឧត្តម អ៊ុង អឿន ប្រធានក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ នៅកិច្ចប្រជុំកាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ ។

ឯកឧត្តម អ៊ុង អឿន បានមានប្រសាសន៍បន្តថា កាលពីកន្លងទៅថ្មីនេះ សមត្ថកិច្ចថៃបានចាប់ប្រជាពលរដ្ឋខ្មែរជាច្រើននាក់ ពាក់ព័ន្ធលួចចូលកាប់ឈើគ្រញូងនៅតាមបន្ទាត់ព្រំដែន ក្នុងប្រទេសថៃ ហើយត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនដាក់ពន្ធនាគារ និងចាត់ការតាមច្បាប់ ។ ឯកឧត្តមបានបញ្ជាក់ថា បញ្ហាដែលប្រពលរដ្ឋខ្មែរត្រូវសមត្ថកិច្ច

ចាប់ខ្លួន ពាក់ព័ន្ធលួចចូលកាប់ឈើគ្រញូង គឺភាគច្រើនតាមរយៈមេខ្យល់ខ្មែរ និងថៃបានអូសទាញចូលលួចកាប់ឈើគ្រញូងប្រឈមគ្រោះថ្នាក់ និងជាប់គុកច្រវាក់កើតមានច្រើនករណីមកហើយ ។

ឯកឧត្តម អ៊ុង អឿន បានដាស់តឿនក្រើនរំលឹកដាល់កងកម្លាំងដែលឈរជើងតាមបន្ទាត់ព្រំដែន ដូចជាកម្លាំងយោធា និងកម្លាំងនគរបាលការពារព្រំដែនគោក ត្រូវមានវិធានការរឹតបន្តឹង ទប់ស្កាត់ឲ្យបានចំពោះពលករខ្មែរដែលលួចចូលកាប់ឈើគ្រញូងតាមបន្ទាត់ព្រំដែននៅប្រទេសជិតខាង ដែលប្រឈមគ្រោះថ្នាក់ ហើយកម្លាំងជំនាញគួរតែរកមុខសញ្ញាមេខ្យល់អូសទាញពលករខ្មែរ ដើម្បីចាត់ការតាមច្បាប់ឲ្យបាន ៕ ដោយៈចន្ទ្រា

## ពលករខ្មែរម្នាក់ចង.ក សម្លាប់ខ្លួននៅថៃសង្ស័យវិបត្តិគ្រួសារ

http://www.phnompenh-thmey-news.html ចេញផ្សាយ ថ្ងៃទី 19/10/2017

ខេត្តបន្ទាយមានជ័យ ៖ សពពលករម្នាក់ត្រូវភាគីថៃដឹកបញ្ជូនឲ្យសាច់ញាតិតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត នាព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧ បន្ទាប់ពីបញ្ចប់ជីវិតលើទឹកដីថៃ ដោយចង.ក សម្លាប់ខ្លួនសង្ស័យវិបត្តិគ្រួសារ ។ ជនរងគ្រោះឈ្មោះ ផុន មាស ភេទប្រុស អាយុ៣០ឆ្នាំ ជាកម្មករសំណង់ និងមានទីលំនៅភូមិថ្មគោល ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង ។ ឈ្មោះ ព្រឿន សុផាន់នី អាយុ៣៤ឆ្នាំ ជាប្រពន្ធជនរងគ្រោះប្រាប់ថា គាត់និងប្តី បានទៅរស់នៅធ្វើការលើទឹកដីថៃជាមួយគ្នា ហើយប្តីគាត់បានចង.ក សម្លាប់ខ្លួននៅរសៀលថ្ងៃទី១៥ ខែតុលាថ្មីៗនេះ ដោយមិនដឹងពីមូលហេតុ ។

ស្ត្រីដដែលបញ្ជាក់ថា មុនកើតហេតុ គាត់មានជម្លោះក្នុងគ្រួសារ ហើយគាត់ខឹងនឹងប្តីក៏ចាកចេញទៅរកការងារធ្វើនៅកន្លែងផ្សេង មិនបាននៅជុំគ្នា៨ថ្ងៃ លុះរសៀលថ្ងៃកើតហេតុ មានគេទាក់ទងប្រាប់តាមទូរស័ព្ទទើបនាងដឹង ។ យ៉ាងណាក៏ដោយនាងមិនបានលម្អិតពីរឿងរ៉ាវផ្ទុះជម្លោះក្នុងគ្រួសារ ថាផ្តើមចេញពីរឿងអ្វីនោះទេ ។ សពត្រូវបានគាត់ជាប្រពន្ធ និងសាច់ញាតិជួលរថយន្តដឹកបន្តទៅស្រុកកំណើត ដើម្បីធ្វើបុណ្យតាមប្រពៃណី ៕

## តម្រួតឆែកបន្ទប់កម្មករ ខ្មែរ រកឃើញសុទ្ធតែថ្នាំញៀន

http://pheaktraprak.com/archives/ By เพียะตรา ประ October 20, 2017

កាលពីថ្ងៃទី19 ខែតុលាឆ្នាំ2017 កម្លាំងសមត្ថកិច្ចបង្ក្រាបគ្រឿងញៀនថៃ បានធ្វើការចុះបង្ក្រាបក្រុមកម្មករខ្មែរ4 នាក់ជាមួយវត្ថុតាងថ្នាំញៀនប្រភេទយ៉ាម៉ាមួយចំនួនធំ។ ការចុះបង្ក្រាបនេះបានធ្វើឡើងនៅថ្ងៃទី19ខែតុលានៅក្នុងបន្ទប់ជួលលេខ271/116 ភូមិ6 ឃុំប៉ារីន ស្រុកស៊ីរាចធា ខេត្តឈុនបុរី ក្នុងការ ចុះបង្ក្រាបឆែកឆេរបន្ទាប់ជួលខាងលើកម្លាំងសមត្ថកិច្ចថៃ បានធ្វើការឃាត់ខ្លួនជនជាតិខ្មែរ 4នាក់ ខណៈពេលកំពុងប្រើប្រាស់ថ្នាំញៀននៅក្នុងបន្ទប់កើតហេតុ។ ក្នុងការឆែកឆេរក្នុងបន្ទប់ខាងលើសមត្ថកិច្ចបានរកឃើញថ្នាំញៀនប្រភេទយ៉ាម៉ាជិត1.000គ្រាប់និងទឹកកកមួយកញ្ចប់ធំ។ ជនជាតិខ្មែរទាំង4នាក់ត្រូវកម្លាំងសមត្ថកិច្ចថៃចាប់ខ្លួនរួមមាន៖

1-ឈ្មោះហឿន ហាត ភេទប្រុសអាយុ34ឆ្នាំសញ្ជាតិខ្មែរ ធ្វើការនៅក្នុងផ្សារ( មានថ្នាំញៀន170 គ្រាប់ )

2-ឈ្មោះសន វ៉ាន់នី ភេទប្រុសអាយុ39ឆ្នាំ សញ្ជាតិខ្មែរ

3-ឈ្មោះហៃ ហៀកភេទប្រុសអាយុ 18ឆ្នាំ សញ្ជាតិខ្មែរ

4-ឈ្មោះធាត សំឡីភេទប្រុសអាយុ29ឆ្នាំ សញ្ជាតិខ្មែរ ជាបុគ្គលិកលក់ឥវ៉ាន់ (មានថ្នាំញៀនចំនួន292គ្រាប់ លាក់ទុកក្នុងប្រអប់ស្ករគ្រាប់និងថ្នាំញៀប្រភេទទឹកចំនួន 9ក្រាម)។

តាមការសួររបស់សមត្ថកិច្ចថៃ ជនជាតិខ្មែរទាំង4នាក់ បានសារភាពថា ថ្នាំញៀនទាំងអស់ ពួកគេទិញកម្មករខ្មែរដូចគ្នានៅក្នុងស្រុកប៉ុកដែងខេត្តរ៉ាយ៉ង ក្នុងតំលៃបោះដុំអោយក្នុងថង់300គ្រប់តំលៃ14.000បាត ហើយលក់ចេញក្នុង1គ្រាប់170-200បាត និងទឹកកកចំនួន300ថង់តូចលក់ចេញក្នុង500បាត ដោយថ្នាំញៀនទាំងអស់ពួកគេបានចែកគ្នាលក់អោយកម្មករធ្វើការនៅផ្សារ និងក្រុមស្ទាវថៃ។ ជនជាតិខ្មែរទាំង4នាក់ ត្រូវកម្លាំងសមត្ថកិច្ចថៃបញ្ជូនយកទៅធ្វើការសាកសួរបន្តនៅអធិការដ្ឋានប៉ូលិសស្រុកស៊ីរាចថា ខេត្តឈុនបុរី ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការអោយចាត់វិធានការតាមផ្លូវច្បាប់។

## ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

## អគ្គស្នងការនគរបាលជាតិ៖ ដើម្បីឲ្យប្រតិបត្តិការទទួលបានជោគជ័យទាមទារឲ្យមន្ត្រីរបស់យើងត្រូវមានសមត្ថភាព និងការយល់ដឹងខ្ពស់ផ្នែកច្បាប់

http://cambodiapolice.com/blog/archives/ 10:56 am 24 តុលា 2017 8

**ភ្នំពេញ ៖** អគ្គស្នងការនគរបាលជាតិ លោកជំទាវឧត្តមសេនីយ៍ឯក យក់ សុខា លើកឡើងថា ដើម្បីឲ្យប្រតិបត្តិការទទួលបានជោគជ័យទាំមទារឲ្យមន្ត្រីរបស់យើងត្រូវមានសមត្ថភាព និងការយល់ដឹងខ្ពស់ផ្នែកច្បាប់។

នៅក្នុងវគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ នាព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១៧ នេះ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន លោកជំទាវឧត្តមសេនីយ៍ឯក យក់ សុខា មានប្រសាសន៍ថា វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងសំខាន់ គឺដើម្បីពង្រឹងសមត្ថភាពជំនាញ ក្នុងការប្រើប្រាស់អាវុធ ដូចនេះដើម្បីឲ្យប្រតិបត្តិការក្នុងការបង្ក្រាបបទល្មើសទទួលជោគជ័យទៅបានកម្លាំងនគរបាលត្រូវមានសមត្ថភាព និងការយល់ដឹងខ្ពស់ទាំងផ្នែកច្បាប់ ទ្រឹស្តី ទាំងការអនុវត្តជាក់ស្តែងលើបច្ចេកទេស ការប្រើប្រាស់ឧបករណ៍ សម្ភារៈ ដែលត្រូវបម្រើដល់ជំនាញប្រតបត្តិការ ក្នុងការចាប់ចងជនល្មើស សង្គ្រោះជនរងគ្រោះ និងវិធីសាស្ត្រការពារខ្លួន។

លោកជំទាវឧត្តមសេនីយ៍ឯក យក់ សុខា មានប្រសាសន៍ទៀតថា វគ្គបណ្តុះបណ្តាលនឹងធ្វើឲ្យមន្ត្រីនគរបាលទាំងអស់ទទួលបាននូវចំណេះដឹងបទពិសោធន៍ល្អៗបន្ថែមទៀតក្នុងប្រតិបត្តិការចាប់ខ្លួន ពិនិត្យកន្លែងកើតហេតុ ការសង្គ្រោះបន្ទាន់ និងរបៀបនៃការប្រើប្រាស់អាវុធ។ ក្នុងឱកាសនេះដែរ លោកជំទាវអគ្គស្នងការនគរបាលជាតិ ក៏បានផ្តាំផ្ញើឲ្យសិក្ខាកាមទាំងអស់ត្រូវគោរពវិន័យឲ្យបានម៉ឺងម៉ាត់ ត្រូវប្រើពេលវេលាដ៏មានតម្លៃនេះក្រេបយកចំណេះដឹង និងបទពិសោធន៍ថ្មីទៅបម្រើអង្គភាពរបស់ខ្លួនទទួលបានជោគជ័យ ៕

# ជនជាតិចិន៣៧នាក់ចោទអនុប្រធានមន្ទីរការងារខេត្តមណ្ឌលគិរីបោកប្រាស់

http://nokorwatnews.com/ ថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០១៧

ខេត្តមណ្ឌលគិរី៖ អនុប្រធានមន្ទីរការ ងារខេត្តមណ្ឌលគិរីទទួលរងការចោទប្រកាន់បោកលុយពីជនជាតិចិនដែលចង់បានបណ្ណការងារស្របច្បាប់ថា បានយកលុយពីតំណាងក្រុមហ៊ុនចិនជិត១០.០០០ ដុល្លារសម្រាប់ថ្លៃរត់ការធ្វើបណ្ណឲ្យជន ជាតិចិន៣៧នាក់ប៉ុន្តែមិនព្រមធ្វើឲ្យបាន សម្រេច និងចង់ស៊ីដាច់ប្រាក់មិនព្រមសង វិញ ។

លោក លាង លីដា តំណាងក្រុមហ៊ុន បានអះអាងថា ខ្លួនបានប្រគល់ប្រាក់ចំនួន៩.១១០ដុល្លារឲ្យលោក ណយ ច័ន្ទដារា អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈខេត្តមណ្ឌលគិរីដើម្បីរត់ការធ្វើប័ណ្ណការងារឲ្យជនជាតិចិន៣៧នាក់ដែលកំពុងធ្វើការនៅក្នុងក្រុមហ៊ុនយូប៊ីអុ៊ី ឌីវីឡុបមិន ដែលក្រុមហ៊ុនវិនិយោគទុនក្នុងប្រទេសកម្ពុជា។ ប៉ុន្តែអស់រយៈពេលជិតមួយឆ្នាំ កន្លងហើយលោក ណយ ច័ន្ទដារា មិនទាន់ ប្រគល់ឯកសារឲ្យលោកឡើយ ។ តំណាងក្រុមហ៊ុនយូប៊ីអ៊ី ឌីវីឡុបមិន បានអះអាងទៀតថា ក្រុមហ៊ុនចិនបានមកវិនិយោគនៅក្នុងប្រទេសកម្ពុជា និងចង់ឲ្យបុគ្គលិកនៅក្នុងក្រុមហ៊ុនទទួលបានសិទ្ធិធ្វើការងារដោយស្របច្បាប់ដូច្នេះក៏បាន ចំណាយថវិកាជូនលោក ណយ ច័ន្ទតារា ជួយរត់ការឲ្យជនជាតិចិនទាំង៣៧នាក់ ប៉ុន្តែរហូតមកដល់ពេលនេះពួកគេមិនទាន់ទទួលបានប័ណ្ណការងារនៅឡើយ។ ចំណែក មន្ត្រីអន្តោប្រវេសន៍វិញតែងតែគំរាមចាប់ពួក គេជាបន្តបន្ទាប់ ព្រោះខ្វះឯកសារអនុញ្ញាតឲ្យធ្វើការងារ។ ជនជាតិចិនទាំង៣៧នាក់ត្រូវបាននគរបាលអន្តោប្រវេសន៍ផាកពិន័យអស់ទឹកប្រាក់ជាច្រើនដោយសារខ្វះឯកសារការងារ ។

លោក ណយ ស្រួន ប្រធានមន្ទីរការងារ និងបណ្តុបណ្តាលវិជ្ជាជិវៈនិងត្រូវជាឪពុកបង្កើតរបស់លោក ណយ ច័ន្ទដារា នៅថ្ងៃ ទី២៣ ខែតុលា ឆ្នាំ២០១៧ បានទទួល ស្គាល់ថា កូនរបស់លោកពិតជាបានទទួលលុយរត់ការធ្វើប័ណ្ណឲ្យជនជាតិ៣៧នាក់ ពិតប្រាកដមែន ប៉ុន្តែដំណើរការដល់ណា នោះលោកដឹងមិនច្បាស់ទេ ។

ចំណែកលោក ណយ ច័ន្ទដារា បានថ្លែង ទទួលថា លោកពិតជាបានទទួលលុយពី ជនជាតិចិនទាំង៣៧នាក់មែននិងមិនមែនជាការបោកប្រាស់ទេគឺលោកកំពុងតែធ្វើការងារដោយសង្ឃឹមថា អាចរួចរាល់នា ពេលឆាប់ៗខាងមុខ ។ លោកបានរៀបរាប់ថា ជនជាតិចិនទាំង ៣៧នាក់នេះមិនមែនរស់នៅ ឬធ្វើការនៅក្នុងខេត្តមណ្ឌលគិរីទេ មាន៩នាក់កំពុងតែធ្វើការនិងរស់នៅក្នុងខេត្តក្រចេះ។ ចំណែក ២៨នាក់ទៀតកំពុងតែស្នាក់នៅ និងធ្វើការ នៅក្នុងខេត្តព្រះសីហនុ ។ លោក ណយ ច័ន្ទដារា បានអះអាងថា លោកបានយកថ្លៃរត់ការធ្វើប័ណ្ណការងារពីជនជាតិម្នាក់ចំនួន១៨០ដុល្លារ និង២០០ដុល្លារថែមទៀតសម្រាប់បំពេញបែបបទ ឬឯកសារផ្សេងសម្រាប់ក្រុមហ៊ុននីមួយៗដើម្បីឲ្យស្របតាមតម្រូវការនៅក្នុងច្បាប់។ ចំណែកការងារដែលលោកកំពុងធ្វើឲ្យជនជាតិចិនទាំងនេះមិនមានជាប់ពាក់ព័ន្ធនឹងតួនាទីក៏ដូចជាមន្ទីរការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរីឡើយ។ ពោលគឺលោកធ្វើដើម្បីទទួលបានកម្រៃសេវាដូចករណីរត់ការបំពេញបែបបទសុំ ទិដ្ឋាការ ឬធ្វើលិខិតឆ្លងដែនដែរ ។ លោកបានត្អូញត្អែរថា «ខ្ញុំមិនបានផល ចំណេញអ្វីទេ ប៉ុន្តែដោយសារដាប់មាត់ថា ធ្វើឲ្យគេហើយត្រូវតែធ្វើឲ្យចប់។ ការងារ រៀបចំបំពេញបែបបទ និងបញ្ចូលឯកសារក្នុងប្រព័ន្ធការងារនេះនរណាក៏អាចធ្វើបានដែរព្រោះវាជាសេវាបង់ថ្លៃតាមរដ្ឋកំណត់»។ លោកបានបន្ថែមថា ករណីយឺតយ៉ាវ មិនមែនបណ្តាលមកពីលោកតែម្នាក់ឯងទេ។ រីឯក្រុមហ៊ុនទើបតែប្រគល់ជូនឯកសារចាំបាច់តាមលក្ខខណ្ឌតម្រូវនៅចុងខែសីហាប៉ុណ្ណោះ ហើយលោកនឹងពន្លឿនការ ងារនេះបន្តទៀត ។ លោកបានរំលឹកថា ករណីជនជាតិចិនសម្រេចចិត្តឲ្យលោករត់ការសុំប័ណ្ណការងារ ដោយសារលោកធ្លាប់ធ្វើបានជោគជ័យជូន ជនជាតិចិនមួយចំនួនដែលកំពុងរស់នៅនិងធ្វើការឲ្យក្រុមហ៊ុនវិនិយោគរបស់ចិននៅ ក្នុងខេត្តមណ្ឌលគិរីនាពេលកន្លងមក ៕ ហេង សូរិយា

## ឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន ដឹកនាំគណៈប្រតិភូ ទៅសួរសុខទុក្ខពលករខ្មែរ ដែលកំពុងបំរើការងារ នៅខេត្តឈុនបុរី ប្រទេសថៃ

http://www.freshnewsasia.com/index.php/en/localnews 2017-10-21

**(ភ្នំពេញ)៖** នៅព្រឹកថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៧នេះ លោកស្រីឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានដឹកនាំគណៈប្រតិភូរាជ រដ្ឋាភិបាល អញ្ជើញទៅសួរសុខទុក្ខពលករខ្មែរប្រមាណ៣ពាន់នាក់ ដែលកំពុងបំរើការងារ នៅខេត្តឈុនបុរី ប្រទេសថៃ។

លោក ចាប សុថារិទ្ធ នាយកខុទ្ទកាល័យ លោកឧបនាយករដ្ឋមន្ត្រីម៉ែន សំអន បានថ្លែងឲ្យដឹងថា លោកស្រីឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន បានដឹកនាំគណៈប្រតិភូមួយក្រុម ដែលមានសមាជិកសភា អភិបាលរងសាលារាជធានីភ្នំពេញ អភិបាលរងខេត្តសៀមរាប និងអភិបាលរងខេត្តមួយចំនួនទៀតផងដែរ ទៅសួរសុខទុក្ខកម្មករ-កម្មការិនីកម្ពុជា ដែលកំពុងធ្វើការនៅក្នុងរោងចក្រសាច់មាន់មួយកន្លែង នៅប្រទេសថៃ ដែលមានកម្មករកម្ពុជាធ្វើការនៅទីនោះ មានចំនួនប្រមាណ៣ពាន់នាក់។ នៅក្នុងឱកាសជួបសួរសុខទុក្ខកម្មករខ្មែរ ធ្វើការនៅរោងចក្រសាច់មាន់ លោកស្រីឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន និងនាំយកនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ជូនដល់កម្មករទាំងអស់បំរើការនៅទីនោះ។ នាឱកាសនោះដែរ លោកស្រីឧបនាយករដ្ឋមន្ត្រី សន្យាជួយកម្មករកម្ពុជា នៅពេលបំពេញការងារ ជួបការលំបាកពេលបំពេញការងារ។

បច្ចុប្បន្ននេះ រាជរដ្ឋាភិបាល បានបង្កើតក្រុមការងារចំនួន៥ក្រុម សម្រាប់ចុះដោះស្រាយបញ្ហាលំបាក នៅពេលកម្មករជួបប្រទះបញ្ហាលំបាកពេលធ្វើការនៅថៃ។ រាជរដ្ឋាភិបាលកម្ពុជា បានសហការជាមួយរាជរដ្ឋាភិបាលថៃ បានផ្តល់លិខិតការងារស្របច្បាប់នៅប្រទេសថៃ បានប្រមាណ៧០% ហើយរួមទាំងឯកសារចេញចូលប្រទេសថៃ។ សព្វថ្ងៃនេះមានកម្មករ-កម្មការិនីខ្មែរកំពុងធ្វើការក្នុងវិស័យផ្សេងៗ នៅប្រទេសថៃមានចំនួនជាង១លាននាក់។

គណៈកម្មការរាជរដ្ឋាភិបាល នៅបន្តសហការជាមួយអាជ្ញាធរថៃ ក្នុងការផ្តល់ប័ណ្ណការងារស្របច្បាប់ជូនដល់កម្មករ-កម្មការិនីខ្មែរ នៅសេសសល់ឲ្យទៅបាននូវភាពស្របច្បាប់ជាបន្តទៀត និងមានសិទ្ធិទទួលបាននូវផលប្រយោជន៍ផ្សេងៗ ដូចជាទទួលបានប្រាក់ខែសមរម្យពីថៅកែថៃ និងមានយកចិត្តទុកដាក់មើលថែរក្សាផងដែរ ពីរដ្ឋាភិបាលថៃ៕

## ថៃចាប់ខ្លួនជនជាតិខ្មែរ៦នាក់ លួចកាប់ឈើគ្រញូងនៅប៉ាងស៊ីដា

http://cambodiapolice.com/blog/archives/ 1:39 pm 22 តុលា 2017

ប្រទេសថៃ ៖ ជនជាតិខ្មែរចំនួន៦នាក់ ក្នុងចំណោមបក្ខពួក ប្រមាណជាង២០នាក់ត្រូវបានក្រុមតម្រួតថៃ សហការជាមួយកំលាំង រដ្ឋបាលព្រៃឈើ នៃសួនឧទ្យានជាតិប៉ាងស៊ីដា ក្នុងខេត្តស្រះកែវ ធ្វើការចាប់ខ្លួន ព្រមទាំងបានរឹបអូសនូវវត្ថុតាងជាច្រើនផងដែរខណៈ ដែលពួកគេបានធ្វើដំណើរចូលទៅក្នុងតំបន់ហាមឃាត់ តាមការនាំផ្លូវពីជានជាតិថៃដើម្បីចូលទៅស្ពាយឈើគ្រញូងចេញមកក្រៅ ។ កិច្ចប្រតិបត្តិការរបស់កំលាំងជំនាញដែលមានក្រុមតម្រួតថៃ និង កំលាំងមេព្រៃប្រចាំតំបន់ឧទ្យានជាតិ ប៉ាងស៊ីដា បានធ្វើឡើងអស់ រយៈពេលជាច្រើនម៉ោង រហូតដល់ម៉ោង៦ល្ងាចថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៧ ទើបចាប់ខ្លួនពួកគេបាននៅចំណុច ទឹកធ្លាក់ផាតាខៀន ក្នុងភូមិ១១ ឃុំថាយ៉ែក ស្រុកមឿង ខេត្តស្រះកែវ ។

តាមសេចក្តីរាយការណ៍ដែលយើងទទួលបានគឺនៅវេលាម៉ោង១រសៀល ថ្ងៃ ខែ ខាងលើកំលាំងបានចូលទៅកាន់តំបន់ខាងលើដោយសារ តែទទួលបានព័ត៌មាន ពាក់ព័ន្ធនឹងករណីលួចកាប់ឈើគ្រញូង ក្នុង តំបន់ហាមឃាត់ ដោយនៅទីនោះ កំលាំងបានរកឃើញស្នាមដាន ជើងជាច្រើន ព្រមទាំងបានស្នាមអូស រំកិលឈើចេញពីព្រៃថៃម ទៀតផង ទើបកំលាំងបានតាមដានរហូតបានប្រទះឃើញមានឈើ គ្រញូងជាច្រើនផ្ទាំង ដែលជនមិនស្គាល់មុខយកទៅលាក់ក្នុងគុម្ពោធ ព្រៃ ទើបកំលាំងបានរៀបចំផែនការដាក់អន្ទាក់តែម្តង ។ លុះនៅវេលាម៉ោង៦ល្ងាច ស្រាប់តែមានរថយន្តចំនួនពីរគ្រឿង រួមជា មួយនឹងមនុស្សប្រមាណជាង២០នាក់ បានជិះរថយន្តមកឈប់ត្រង់ ចំណុចខាងលើ ដោយពួកគេម្នាក់ៗបានចុះសំដៅទៅលើកឈើទាំង នោះដាក់រថយន្ត តែត្រូវកំលាំងចេញប្រតិបត្តិការស្ទាក់ចាប់បានតែ មនុស្ស៦នាក់ ឈើគ្រញូងចំនួន ២៦ ផ្ទាំង រណាយន្ត១គ្រឿង និងរថយន្ត១គ្រឿង ម៉ាកតូយ៉ូតា វីហ្គូ ព៌ណខ្មៅ ពាក់ស្លាកលេខ បាងកក ៦៥៧៩ ដោយឡែករថយន្តមួយគ្រឿងទៀត និងមនុស្ស មួយចំនួនបានបើករត់គេចខ្លួនបាត់ស្រមោល រីឯក្នុងរថយន្តដែលចាប់ បានមានប័ណ្ណបើកបរមួយសន្លឹកឈ្មោះ សនរ៉ាម ប្រាបណាក ។

ជនទាំង៦នាក់ដែលសមត្ថកិច្ចថៃចាប់ខ្លួនគឺជាជនជាតិកម្ពុជាទាំងអស់ ដោយពួកគេបានសារភាពថា កាលពីថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ ពួកខ្លួនមានគ្នាចំនួន២៧នាក់ត្រូវបានជនជាតិថៃទាក់ទងអោយចូលទៅលីឈើគ្រញូងចេញពីព្រៃមកខាងក្រៅ ដោយគេអោយតម្លៃ ក្នុង១គីឡូក្រាម ២០០ បាត ហើយពួកក៏បានឡើងរថយន្តចំនួន២ គ្រឿងដែលទៅទទួលនៅប៉ោយប៉ែត វេលាម៉ោង៨យប់ ។ ក្រោយពីបានដល់ទីតាំងខាងលើ ពួកគេបានដើរក្នុងព្រៃអស់រយៈ ពេល ៧ថ្ងៃ ទើបបានទៅដល់កន្លែងអារឈើ ដោយនៅទីនោះមាន ជនជាតិថៃជាអ្នកអារឈើ ហើយពួកគេមានត្រឹមតែជាអ្នកស្ពាយ និង ដឹកជញ្ជូនមកខាងក្រៅតែប៉ុណ្ណោះ លុះថ្ងៃទី១៨ ខែតុលា ទើបត្រូវដឹកជញ្ជូនចេញពីព្រៃ ដោយមានថៃម្នាក់ជាអ្នកនាំផ្លូវ ហើយក៏បានយកឈើ ទាំងនោះ មកលាក់ទុកជាបណ្តោះអាសន្ន នៅត្រង់ចំណុចក្បែទឹកធ្លាក់ ក្រោយពីមានសភាពស្ងាត់ ទើបនៅម៉ោង៦ល្ងាច ពួកគេក៏បានវិល ត្រឡប់មកវិញ បម្រុងលើកឈើទាំងនោះឡើងរថយន្ត ក៏ត្រូវ សមត្ថកិច្ចចាប់បានតែម្តង ។ បច្ចុប្បន្នជនសង្ស័យរួមជាមួយនឹងវត្ថុតាង ត្រូវបានបញ្ជូនទៅកាន់ អធិការដ្ឋាន តម្រួតប៉ាងស៊ីដា ដើម្បីសាកសួរមុននឹងបញ្ជូនទៅអោយ កំលាំងជំនាញ ក្នុងការចាត់វិធានការតាមផ្លូវច្បាប់ ៕

## សមត្ថកិច្ចថៃបន្តចាប់បញ្ជូនពលករខ្មែរមកកម្ពុជាជារៀងរាល់ថ្ងៃតាមច្រកប៉ោយប៉ែត

http://www.rfa.org/khmer/news/ ដោយ អាស៊ីសេរី 2017-10-22

សមត្ថកិច្ចថៃនៅតែចាប់បញ្ជូនពលករខ្មែរ ដែលធ្វើការខុសច្បាប់ក្នុងប្រទេសថៃជាច្រើននាក់ ត្រឡប់កម្ពុជាវិញ តាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នៅឡើយ ខណៈលោក ហ៊ុន ម៉ាណែត ដែលថ្មីៗនេះ បានទៅជួបសំណេះសំណាលជាមួយពលករនៅប្រទេសនេះ ដើម្បីជួយសម្រួលឲ្យពួកគេបានធ្វើការស្របច្បាប់ក្តី។ មន្ត្រីទទួលបន្ទុកពលករត្រឡប់ពីប្រទេសថៃ ប្រចាំច្រកព្រំដែនប៉ោយប៉ែត អះអាងថា ពលករខ្មែរដែលថៃចាប់បញ្ជូនមកនេះ មានទាំងអ្នកលួចធ្វើការខុសច្បាប់ និងអ្នកដែលមកធ្វើលិខិតឆ្លងដែន ដើម្បីទៅធ្វើការស្របច្បាប់។

មន្ត្រីទទួលបន្ទុកពលករនៅច្រកព្រំដែនប៉ោយប៉ែត អ្នកស្រី ស៊ិន ណាំយ៉ុង ឲ្យដឹងនៅថ្ងៃទី២២ តុលា ថា យ៉ាងហោចណាស់សមត្ថកិច្ចថៃចាប់បញ្ជូនពលករខ្មែរតាមច្រកមួយនេះ ប្រគល់មកឲ្យអ្នកស្រី ចន្លោះ ពី១ ទៅ ៥រថយន្តក្នុងមួយថ្ងៃ ដោយរថយន្តខ្លះដឹកពលករប្រមាណពី១៥ ទៅ ៥០នាក់ក្នុងមួយរថយន្តនោះ។ អ្នកស្រីបន្ថែមទៀតថា ពលករដែលបញ្ជូនត្រឡប់មកវិញនោះ អ្នកខ្លះលួចធ្វើការខុសច្បាប់ ហើយត្រូវបានសមត្ថកិច្ចថៃចាប់ ខណៈពួក

គាត់កំពុងធ្វើការនៅប្រទេសថៃ និងខ្លះទៀតត្រឡប់មកធ្វើលិខិតឆ្លងដែននៅខ្មែរ ដើម្បីចូលទៅធ្វើការស្របច្បាប់នៅកន្លែងដើមវិញ។ អ្នកស្រីអះអាងថា ខណៈពួកគេត្រឡប់មកវិញនោះ ពលករក៏បានដើរចូលឲ្យប៉ូលិសថៃចាប់ ដើម្បីងាយស្រួលបញ្ជូនពួកគេឆ្លងដែនមកកម្ពុជា៖ «ដែលនៅតិចៗនេះជួនកាលគាត់ធ្វើការនៅព្រំដែន អ្នកខ្លះទៅពីរបីថ្ងៃត្រឡប់មកវិញក៏មាន។ ឥឡូវថៃចាប់បញ្ជូនច្រើន ពួកអ្នកដែលចុះមកធ្វើលិខិតឆ្លងដែន បើពួកគាត់មិនមកតាមផ្លូវនេះទេ វាពិបាកឆ្លងដែន ដូច្នេះហើយបានជាពួកគាត់ឲ្យប៉ូលិសថៃចាប់ដឹកមកខ្មែរ»។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា ហៅ ការចាប់បញ្ជូនពលករមកឲ្យអាជ្ញាធរកម្ពុជានេះថា ជារឿងដដែលៗ កើតឡើងជារៀងរាល់ឆ្នាំ។ លោកអះអាងទៀតថា នៅពេលសមត្ថកិច្ចថៃបញ្ជូនពលករមកនេះ ពេលខ្លះគេដឹកពលករ មានទាំងមនុស្សចាស់និងកុមាររួមគ្នា ដោយដាក់បញ្ចូលក្នុងរថយន្តទ្រុងយ៉ាងណែនទៀតផង៖ «ដូច្នេះអ្វីទាំងនេះរដ្ឋាភិបាលគួរតែពិចារណា យកចិត្តទុកដាក់ដល់ពលករទាំងអស់នេះ ឲ្យពួកគាត់រួចផុតពីទុក្ខលំបាក ដោយសារការចាប់បញ្ជូនមកវិញនេះ ព្រោះពេលខ្លះពួកគាត់មានលិខិតឆ្លងដែនហើយក៏គេចាប់ដែរ»។

កាលពីពេលថ្មីៗនេះ លោក ហ៊ុន ម៉ាណែត បានទៅជួបសំណេះសំណាលជាមួយពលករនៅទីក្រុងបាងកក និងនៅខេត្តមួយចំនួនទៀតក្នុងប្រទេសថៃ។ នៅក្នុងពេលសំណេះសំណាលនោះ លោក ហ៊ុន ម៉ាណែត ថែមទាំងបានសន្យាជាមួយពលករថា នឹងជួយសម្រួលឲ្យពួកគេបានធ្វើការនៅក្នុងប្រទេសថៃស្របច្បាប់ ដូចជា ការជំរុញឲ្យមន្ត្រីពាក់ព័ន្ធធ្វើលិខិតឆ្លងដែននៅប្រទេសថៃចំនួន៣កន្លែង ដើម្បីធ្វើជូនពលករមួយថ្ងៃរួចជាដើម៖ «កន្លងទៅភាពមិនស្របច្បាប់នេះរដ្ឋាភិបាលបានជួយ គឺបានចុះអនុស្សារណៈយោគយល់គ្នាជាមួយភាគីថៃ ដោយកាលពីឆ្នាំ ២០១៣ ជួយផ្លាស់ប្តូរពលករដើម្បីឲ្យស្របច្បាប់ ដើម្បីឲ្យយើងមានលទ្ធភាពបញ្ជូនពលករមកធ្វើការ ហើយយើងបានបញ្ជូនមករាប់សែនហើយ។ ហើយរាល់ពេលដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជួបជាមួយថ្នាក់ដឹកនាំថៃ គេថា ធ្វើយ៉ាងមិចឲ្យរដ្ឋាភិបាលថៃ ជួយការពារពលករខ្មែរមកទីនេះផង។ ហើយក៏អរគុណដល់រដ្ឋាភិបាលថៃ ក្រសួងការងារថៃ និងអាជ្ញាធរថៃ ក៏ដូចជាក្រុមហ៊ុនដែលបានយកចិត្តទុកដាក់ជួយការពារ និងជួយពលករខ្មែរយើងដែលបានធ្វើការនៅប្រទេសថៃ»។

បច្ចុប្បន្នពលករធ្វើការនៅប្រទេសថៃ មានជាង ១លាននាក់ ក្នុងនោះពលករធ្វើការស្របច្បាប់ប្រមាណ៧០ម៉ឺន (៧០០.០០០) និងពលករខុសច្បាប់មានជាង៣០ម៉ឺននាក់។ អ្នកស្រី ស៊ិន ណាំយ៉ុង ឲ្យដឹងថា សមត្ថកិច្ចថៃចាប់បញ្ជូនពលករខ្មែរតាមច្រកព្រំដែនប៉ោយប៉ែត កាលពីខែកញ្ញាកន្លងទៅ មានជាង ៣ពាន់នាក់៕

## ជួយសង្គ្រោះកម្មករនេសាទខ្មែរ

http://pheaktraprak.com/archives/ By เพียะตรา ประ October 21, 2017

យោងទៅតាមទំព័រហ្វេសប៊ុកសារព័ត៌មានថៃបានបង្ហោះរូបភាពកម្មករខ្មែរនិងថៃចំនួន5នាក់ បន្ទាប់ពីត្រូវបានកម្លាំងទាហានជើងទឹកថៃប្រចាំខេត្ត ត្រាត ជួយអន្តរាគមន៍និងសង្គ្រោះជីវិត បន្ទាប់ពីជួប ឧបទ្ទវហេតុលិចទូកនេសាទត្រីមួយគ្រឿង នៅកណ្តាលសមុទ្រថៃ កាលពីថ្ងៃទី21.10.2017 ស្ថិតនៅក្នុងឃុំហាតឡេក, ស្រុកខ្លងយ៉ៃ, ខេត្តត្រាត ប្រទេសថៃ ប្រទេសថៃ ។

## ក្រសួងការងារថៃ ប្រកាសចាត់វិធានការលើពលករមានប័ណ្ណស៊ីជម្ពូ នៅដើមខែ4 ឆ្នាំ2018

http://pheaktraprak.com/archives/ By เพียะตรา ประ October 21, 2017

ក្នុងកិច្ចប្រជុំបូកសរុបការងាររបស់ក្រសួងការងារថៃកាលពីពេលថ្មីៗកន្លងទៅនេះ លោក Sirichai Ditthakul រដ្ឋមន្រ្តីក្រសួងការងារថៃ បានចេញសេចក្តីសម្រេចអនុម័តច្បាប់ចំនួនបីលក្ខខ័ណ្ឌស្តីពីបញ្ហាពលករបរទេសមានដូចខាងក្រោម។

1-សម្រេចអនុម័តអោយពលករទាំងបីសញ្ជាតិ, កម្ពុជា ,ឡាវ ,ភូមា ដែលបញ្ជាក់អត្តសញ្ញាណ ហើយទទួលបានឯកសារស្របច្បាប់ពីប្រទេសរបស់ខ្លួន អាចស្នាក់នៅធ្វើការការងារក្នុងប្រទេសថៃបានផ្តល់រហូតដល់ថ្ងៃទី 31 ខែមីនាឆ្នាំ 2018 និងបន្តរយៈពេលបន្ថែម 2 ឆ្នាំទៀតរហូតដល់ថ្ងៃទី 31 ខែមីនាឆ្នាំ 2018។

2-មិនអនុញ្ញាតអោយពលករទាំងបីសញ្ជាតិដែលមានប័ណ្ណស៊ីជម្ពូផុតកំណត់ថ្ងៃទី 31 ខែមីនាឆ្នាំ 2018 មិនអាចស្នាក់នៅបន្តបានទៀតឡើយដោយសារតែរដ្ឋាភិបាលថៃគ្មានគោលនយោបាយបន្តឬបើកអោយពលករបរទេសទាំងអស់នោះតសពុលភាពទៀតទេ ពោលគឺត្រូវឡប់ទៅប្រទេសដើមវិញភ្លាម។

3-មិនបន្តអនុញ្ញាតអោយពលករដែលមានប័ណ្ណស៊ីជម្ពូ(ធ្វើការនេសាទ, ផ្នែកការងារសមុទ្រ) ដាច់អាយុនៅថ្ងៃ01.11.2017 ស្នាក់នៅបន្តក្នុងប្រទេសថៃទៀតបានឡើយ។

4-អនុម័តវិធានការរយៈពេលវែងដើម្បីអនុញ្ញាតឱ្យពលករដែលបានផ្លាស់ប្តូរឯកសាររបស់ CI ទៅជា TD លិខិតឆ្លងដែន (PP) អាចប្តូរទៅជាប៉ាស្ព័ការងារMOU នៅថ្ងៃទី 31 ខែមីនាឆ្នាំ 2020 ខាងមុខទៀត។

## ទីតាំងធ្វើប៉ាស្ព័រក្នុងខេត្តរ៉ាក់យ៉ង ប្រកាសផ្អាកចែកលេខរៀង បណ្តោះអាសន្ន

http://pheaktraprak.com/archives/ By เพียะตรา ประ October 24, 2017

យោងតាមលិខិតប្រកាសនៅក្នុងទីតាំងត្រួតសញ្ជាតិជូនបងប្អូនពលករកម្ពុជា នៅក្នុង ខេត្តរ៉ាក់យ៉ង ប្រទេសថៃបាន អោយដឹងថា ចាប់តាំងពីថ្ងៃទី25 ខែតុលា ឆ្នាំ2017 ខាងមុខនេះ គណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជានិងផ្អាកចែកលេខរៀងជូនបងប្អូនពលករកម្ពុជាដែលធ្វើដំណើរមកម បញ្ជាក់អត្តសញ្ញាណ (ត្រួតសញ្ជាតិ)ធ្វើប៉ាស្ព័រ នៅទីតាំងOTOP ម៉ាកយ៉ងខេត្តរ៉ាក់យ៉ង បណ្តោះអាសន្ន។ ដោយចាប់ផ្តើមចែកលេខរៀងជូនបងប្អូនពលករកម្ពុជាម្តងទៀតនៅថ្ងៃទី 02.11.2017 ខាងមុខទៀត។ ដោយចាប់ផ្តើមដំណើរការធ្វើប៉ាស្ព័រជូនបងប្អូនពលករកម្ពុជាក្នុងមួយថ្ងៃចំនួន 450នាក់ អាស្រ័យហេតុនេះសូមបងប្អូនមេត្តាជ្រាបជាដំណឹង ។

## ថៃចាប់ព្រះសង្ឃខ្មែរ 2 រូបប្រើប៉ាស្ព័រក្លែងក្លាយ ឆ្លងដែនទៅបិណ្ឌបាតបច្ច័យពីពលរដ្ឋថៃ

http://pheaktraprak.com/archives/ By เพียะตรา ประ October 24, 2017

កាលពីពេលថ្មីៗកន្លងទៅនេះកម្លាំងអាជ្ញាធរខេត្តឧដនថានី ប្រទេសថៃ បានធ្វើការឃាត់ខ្លួនព្រះសង្ឃខ្មែរចំនួន 2 រូបបន្ទាប់ពីលួចឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ ។ ករណីសមត្ថកិច្ចថៃឃាត់ខ្លួនព្រះសង្ឃខ្មែរ នេះបានកើតឡើងកាលពីថ្ងៃច័ន្ទទី23 ខែតុលា ឆ្នាំ 2017 ស្ថិតនៅក្នុងខេត្តឧថីថានី ការចាប់ខ្លួនព្រះសង្ឃទាំងពីររូបនេះបាន

ធ្វើឡើងខណៈពេលដែលព្រះសង្ឃទាំងពីររូបកំពុងដើរបិណ្ឌបាតប្រាក់ពីប្រជាពលរដ្ឋថៃក្នុងខេត្តខាងលើ ។ ព្រះសង្ឃខ្មែរទាំងពីររូបត្រូវសមត្ថកិច្ចថៃចាប់ខ្លួននោះមានឈ្មោះដូចខាងក្រោម៖

1-ឈ្មោះ ម៉ៅ អាយុ 25ឆ្នាំ សញ្ជាតិខ្មែរ កាន់លិខិត ឆ្លងដែន ក្លែងក្លាយ

2 – ឈ្មោះចាន់ អាយុ 24ឆ្នាំ សញ្ជាតិខ្មែរ កាន់លិខិត ឆ្លងដែន ក្លែងក្លាយ

យោងតាមប្រភពពីប្រទេសថៃបានអោយដឹងថា ព្រះសង្ឃខ្មែរទាំងពីររូបបានឆ្លងដែនខុសច្បាប់ ចូលប្រទេសថៃ តាមរយៈច្រកព្រំដែនខេត្តចាន់បុរីប្រទេសថៃ ដោយប្រើប្រាស់ប៉ាស្ព័រក្លែងក្លាយ ដើម្បីបំភាន់ភ្នែកសមត្ថកិច្ចថៃនៅពេលត្រូវហៅត្រួតពិនិត្យ។ ព្រះសង្ឃខ្មែរទាំងពីររូបត្រូវបានសមត្ថកិច្ចថៃបញ្ជូនយកផ្សឹកនៅក្នុងវត្តថាំមសូរធិត ក្នុងខេត្តឧបីថានី រួចយកទៅប្រគល់អោយតម្រួតអន្តប្រវេសន៍ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## អាជ្ញាធរថៃបញ្ជូនពលរដ្ឋខ្មែរ៥នាក់ឲ្យអាជ្ញាធរកម្ពុជាវិញ

http://cambodiapolice.com/blog/archives/ 1:36 pm 23 តុលា 2017 21

ឧត្តរមានជ័យ ៖ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១៣និង០០នាទី អាជ្ញាធរថៃ បានបញ្ជូនប្រជាពលរដ្ឋខ្មែរ តាមច្រកអន្តរជាតិជាំសាងាំ ចំនួន៥នាក់ មកឲ្យភាគីកម្ពុជា ដែលត្រូវទាហានប៉ារ៉ាថៃចាប់ខ្លួនកាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០១៦ ពីបទកាប់ឈើក្រញូងក្នុងទឹកដីថៃ ចូលតាមចំណុច អូខ្សាច់ ក្នុងឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្ត ឧត្តរមានជ័យ មានឈ្មោះ ដូចខាងក្រោម ៖

១- ឈ្មោះ មិន មាស ភេទប្រុស អាយុ៣៨ឆ្នាំ រស់នៅភូមិ អូរទឹកថ្លា ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរ មានជ័យ។

២- ឈ្មោះ អ៊ី ជីន ភេទប្រុស អាយុ៣៤ឆ្នាំ រស់នៅភូមិឃុំជាមួយ គ្នា

៣- ឈ្មោះ កែវ រឿន ភេទប្រុស អាយុ៣០ឆ្នាំ រស់ភូមិឃុំជា មួយគ្នា

៤-ឈ្មោះ បាន សុក ភេទប្រុស អាយុ៣៥ឆ្នាំ រស់នៅភូមិឃុំ ជាមួយគ្នា

៥- ឈ្មោះ ឈួន ទីន ភេទប្រុស អាយុ៤៨ឆ្នាំ រស់នៅភូមិឃុំជា មួយគ្នា ។

បច្ចុប្បន្ន សមត្ថកិច្ចនៅនឹងច្រកអន្តរជាតិជាំ បានធ្វើការអប់រំ រួចក៏បានវិលទៅលំនៅដ្ឋានវិញរៀងៗខ្លួន៕

## ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧
## ស្នងការនគរបាលខេត្តប្រជុំដាក់វិធានការដល់កម្លាំងត្រួវទប់ស្កាត់បទល្មើសតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ

http://cambodiapolice.com/blog/archives/ 3:20 pm 24 តុលា 2017 21

**បន្ទាយមានជ័យ ៖** នៅក្នុងកិច្ចប្រជុំប្រចាំខែតុលា នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ស្នងការនគរបាលខេត្តបន្ទាយមានជ័យដាក់វិធានការដល់កម្លាំងត្រូវទប់ស្កាត់បទល្មើសតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃនិងការពារសន្តិសុខស

ណ្តាប់ធ្នាប់ថ្ងៃអុំទូក។ ក្នុងកិច្ចប្រជុំលោកឧត្តមសេនីយ៍ទោ **អាត់ ខែម** ស្នងការនគរបាលខេត្តបន្ទាយមានជ័យបានមានប្រសាសន៍ថា រយៈពេលកន្លងមកកម្លាំងនគរបាលនៃស្នងការដ្ឋាននគរបាលខេត្តនិងស្រុក/ក្រុងនិងកម្លាំងនគរបាលវរៈការពារព្រំដែនគោកបានខិតខំបម្រើប្រជាពលរដ្ឋនិងប្រទេសជាតិបានល្អប្រសើរ។

តែទន្ទឹមការកោតសរសើរពីប្រជាពលរដ្ឋកងកម្លាំងនគរបាលត្រូវខិតខំថែមទៀតដើម្បីសន្តិសុខនិងសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋនិងភូមិ-ឃុំអោយមានសុវត្ថិភាព។ លោកបានមានប្រសាសន៍ដាក់វិធានការដល់កងកម្លាំងនគរបាលដែលឈរជើងតាមបន្ទាត់ព្រំដែនត្រូវទប់ស្កាត់បទល្មើសតាមបន្ទាត់ព្រំដែនមានដូចជា: ពលករចំណាក់ស្រុកខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសជិតខាង, ពលករទៅតាមរយៈមេខ្យល់ចូលលួចកាប់ឈើក្រញូងតាមបន្ទាត់ព្រំដែន, ទំនិញគេចពន្ធនិងខូចគុណភាព, ម៉ូតូរថយន្តគេចពន្ធល្មើសច្បាប់, គ្រឿងញៀងឆ្លងដែន, វត្ថុបុរាណនិងបទល្មើសផ្សេងៗទៀតត្រូវមានវិធានការទប់ស្កាត់អោយបាន។

លោកឧត្តមសេនីយ៍ទោ **អាត់ ខែម** បានមានប្រសាសន៍តឿនរំលឹកដល់កម្លាំងនគរបាលត្រូវការពារសន្តិសុខនិងសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋនៅថ្ងៃបុណ្យអុំទូកបណ្តែតប្រទីបអកអំបុកសំពះព្រះខែនៅខេត្តបន្ទាយមានជ័យខាងមុខនេះ ៕ ដោយៈចន្ទ្រា

## កម្មករខ្មែរមួយគ្រួសារត្រូវរថយន្តបុកស្លាប់ បន្ទាប់ពីវិលត្រឡប់មកពីធ្វើប៉ាស្ព័រនៅខេត្តរ៉ាក់យ៉ង

http://pheaktraprak.com/archives/ By เพียะตรา ประ October 25, 2017

ពលករខ្មែរមួយគ្រួសារជិះម៉ូតូត្រឡប់មកពីត្រួតសញ្ជាតិធ្វើប៉ាស្ព័រ ត្រូវរថយន្តដឹកទឹកកកបុកស្លាប់យ៉ាងអាណោចអាធ័មនៅក្នុងប្រទេសថៃ។ ករណីគ្រោះថ្នាក់ចរាចរនេះបានកើតឡើងនៅវេលាម៉ោង4 ល្ងាចនាថ្ងៃច័ន្ទទី23 ខែតុលា ឆ្នាំ2017 នៅត្រង់ចំណុចមុខរោងចក្រកៅស៊ូ ផ្លូវបានបឹង-ក្លែង ស្ថិតនៅក្នុងឃុំក្រះសែរប៊ុន ស្រុកក្លែង ខេត្តរ៉ាក់យ៉ង។ ជនរងគ្រោះដែលស្លាប់នៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរនេះរួមមាន៖

1-ឈ្មោះ អូន ទៃ ភេទស្រី អាយុ40 ឆ្នាំសញ្ជាតិខ្មែរ រស់នៅខេត្តព្រៃវែង

2-ឈ្មោះ ម៉ោក វា (ត្រូវជាប្តី) ភេទប្រុស អាយុ 40ឆ្នាំសញ្ជាតិខ្មែរ រស់នៅខេត្តព្រៃវែង

3-កុមារ អាយុ10 ឆ្នាំសញ្ជាតិខ្មែរត្រូវជាកូន

ប្រភពពីសមត្ថកិច្ចនៅកន្លែងកើតហេតុបានឲ្យដឹងថា ខណៈពេលកើតហេតុក្រុមគ្រួសារជនរងគ្រោះបានជិះម៉ូតូម៉ាកហុងដា ពណ៌ក្រហម-ខ្មៅពាក់ស្លាកលេខ1กธ1389 រ៉ាក់យ៉ង ជិះម៉ូតូនៅត្រង់ចំណុចកើតហេតុ ស្រាប់តែមានឡានដឹកទឹកកកម៉ាកហ៊ីណូ ពាក់ស្លាកលេខ80-6704 ត្រាត បានបត់កាត់មុខយ៉ាងទាន់ហន់ បណ្តាលអោយម៉ូតូជាន់ហ្វ្រាំងមិនទាន់បុកចំពីមុខពេញទំហឹងបណ្តាលអ្នកជិះម៉ូតូទាំងបីស្លាប់ភ្លាមនៅនិងកន្លែង។ ក្រោយពេលពិនិត្យកន្លែងកើតហេតុសមត្ថកិច្ចថៃបានឃាត់ខ្លួនអ្នកបើកបរឡានដឹកទឹកកកខាងលើយកទៅការសាកសួរ ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការអោយធ្វេ◌ីការកាត់ទោសតាមផ្លូវច្បាប់។

# ក្រសួងការងារថៃ ប្រកាសតឿនដល់ពលករដែលត្រួតសញ្ជាតិរួចឲ្យប្រញាប់សុំVisaនិងច្បាប់ការងារ

http://pheaktraprak.com/archives/ By เพียะตรา ประ October 25, 2017

ក្រសួងការងារថៃ ប្រកាសតឿនពលករដែលត្រួតសញ្ជាតិរួច ប្រញាប់សុំច្បាប់អនុញ្ញាតធ្វើការឲ្យបានមុនថ្ងៃទី31.12.2017។ កាលពីថ្ងៃអង្គារទី24 ខែតុលា ឆ្នាំ2017នេះ លោកWaranon Petitwan មន្ត្រីអគ្គនាយកដ្ឋាននៃក្រសួងការងារថៃ បានចេញសេចក្តីប្រកាសតឿនដល់ពលករបរទេសទាំងបីសញ្ជាតិមាន,កម្ពុជា,ឡាវ,ភូមា ដែលមានប័ណ្ណស៊ីជម្ពូផុតកំណត់ថ្ងៃទី01.11.2017 និងប័ណ្ណស៊ីជម្ពូផុតកំណត់ថ្ងៃទី31.12.2017 ។ ហើយបានត្រួតសញ្ជាតិរួចរាល់ និងទទួលបានលិខិតធ្វើដំណើរពលករបរទេស, ប៉ាស្ព័រ (TD) អោយប្រញាប់ទៅស្នើសុំវីសា(visa) ការងារ (Non-immigrant L-A) នៅឯប៉ុស្តិ៍ប៉ូលិសអន្តោប្រវេសន៍ថៃ ឬភាសាថៃហៅថា( สถานีตำรวจตรวจคนเข้าเมือง) ក្នុងតំបន់ខេត្តក្រុងដែលយើងរស់នៅ និងលិខិតច្បាប់អនុញ្ញាតធ្វើការងារនៅមន្ទីរការងារខេត្ត ឬភាសាថៃហៅថា( สำนักจัดหางานจังหวัด) អោយបានមុនពេលកំណត់ បើមិនដូច្នេះទេនិងត្រូវមានទោសខុសច្បាប់ តាមលក្ខខ័ណ្ឌនៃច្បាប់ការងារប្រទេសថៃ។ ដូច្នេះបងប្អូនពលករកម្ពុជាដែលមានប័ណ្ណស៊ីជម្ពូជិតផុតកំណត់ដូចខាងលើត្រូវប្រញាប់រួសរាន់មកបញ្ជាក់អត្តសញ្ញាណ (ត្រួតសញ្ជាតិ) អោយបានត្រឹមត្រូវ និងសុំច្បាប់អនុញ្ញាតធ្វើការអោយបានទាន់ពេលវេលា។

## សេចក្តីជូនដំណឹងអំពីការឈប់សម្រាក

ttps://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧

គណៈកម្មការផ្តល់ភាពស្របច្បាប់ សូមជូនដំណឹងដល់បងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ ឱ្យបានជ្រាបថា៖ គណៈកម្មការនឹងឈប់សម្រាកចំនួន ០១ថ្ងៃ នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ ក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងរបស់អតីតព្រះមហាក្សត្រ ព្រះអង្គម្ចាស់ BHUMIBOL ADULYADEJ ហើយនឹងចូលធ្វើការវិញនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧។ ដូច្នេះ គណៈកម្មការមិនមានការបើកផ្តល់លិខិតឆ្លងដែន(PP)/លិខិតធ្វើដំណើរ (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) និងបញ្ជាក់អត្តសញ្ញាណ(ត្រួតសញ្ជាតិ) ជូនបងប្អូនពលករនោះទេ។ សូមបងប្អូនពលករទាំងអស់ជ្រាបជាព័តមាន និងជួយផ្សព្វផ្សាយបន្ត។ សូមអគុណ

## សេចក្តីជូនដំណឹងស្តីពីការកែសម្រួលនីតិវិធីនៃការបញ្ជាក់អត្តសញ្ញាណ (ត្រួតសញ្ជាតិ) ជូនបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ

ttps://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

ដើម្បីជួយសម្រួលដល់បងប្អូនពលករ គណៈកម្មការផ្តល់ភាពស្របច្បាប់ បានធ្វើការកែសម្រួលពីការតម្រូវអោយមានច្បាប់ដើមចំពោះអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ទៅត្រឹមតែសុំអោយមានច្បាប់ថតចម្លងនៃឯកសារទាំងនោះវិញ។ ដើម្បីបញ្ជាក់ឱ្យបានច្បាស់ ស្ថានទូតនឹងធ្វើការផ្សាយជាវីដេអូសំលេង (FB live) នាយប់នេះ វេលាម៉ោង ៩យប់។ សូមបងប្អូនពលករមេត្តាជួយផ្សព្វផ្សាយបន្ត សូមអគុណ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**
លេខៈ........០៤២/១៨........គ.ផ.ប / ល.ក.ថ

# សេចក្តីជូនដំណឹង
# ស្តីពីការកែសម្រួលនីតិវិធីនៃការបញ្ជាក់អត្តសញ្ញាណ ជូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ

ដើម្បីសម្រួលដល់បងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានកែសម្រួល និងកំណត់នីតិវិធីដូចខាងក្រោម៖

I. ការផលិតលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) **និងឯកសារតម្រូវនានា៖**

១. ការផលិត និងបើកផ្តល់ លិខិតធ្វើដំណើរ(TD) និងប័ណ្ណ(OCWC) ជូនពលករ គឺធ្វើឡើងក្នុងថ្ងៃតែមួយ

២. ពលករត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ សំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ ឬ លិខិតឆ្លងដែន ឬ ប័ណ្ណបើកបរ **ច្បាប់ថតចម្លង ចំនួន ២ច្បាប់**
- ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) ឬ លិខិតបញ្ជាក់ទំនាក់ទំនងរវាងនិយោជក និងពលករ ចេញដោយក្រសួងការងារថៃ ឬ មន្ទីរការងារថៃ **ច្បាប់ថតចម្លង ចំនួន២ច្បាប់។**

៣. ពលករត្រូវមកដោយផ្ទាល់ និងថតរូបដោយផ្ទាល់ ព្រមទាំងត្រូវផ្តល់ព័ត៌មានដូចខាងក្រោម៖

- ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់និយោជក នៅប្រទេសថៃ
- ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់អ្នកត្រូវទទួលសំណងជានាវ៉ាប់រង នៅពេលមានគ្រោះថ្នាក់។

**II. ទីកន្លែង ថ្ងៃម៉ោងធ្វើការ និងតម្លៃសេវា**

១.ទីកន្លែង ៖

- ទីក្រុងបាងកក ៖ អាសយដ្ឋាន អ៊ីមផើរៀល(Imperial World Ladphrao)ឡាតព្រាវ ជាន់៤

ទី៤, លេខ២៥៣៩, ច្រក៨១-៨៣ ផ្លូវឡាតប្រាវ, សង្កាត់ ចៅយុនស៊ីង, ខណ្ឌ ចុងឡាង, ទីក្រុងបាងកក ១០៣១០

- ខេត្តរ៉ាក់យ៉ង ៖ អាសយដ្ឋាន ផ្សារ អូថប់ម៉ាយ៉ង(OTOP MA YONG) -២០១ ភូមិ ៧, ឃុំ ម៉ាខាមយ៉ូ, ស្រុក និយ៉ុំផាត់តាណា, ខេត្ត រ៉ាក់យ៉ង២១១៨០
- ខេត្តសុងក្លា ៖ អាសយដ្ឋាន ផ្សារ ហ្វុកទៀន(Fuk Thian), ៩៩គុមិ៣, ឃុំ ខ្លងហែរ, ស្រុក ហ៉ាត់យៃ, ខេត្ត សុងក្លា

២.ថ្ងៃម៉ោងធ្វើការ ៖ ថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍

- បាងកក ៖ ព្រឹកម៉ោង ១០:០០ ដល់ ៦:៣០ ល្ងាច<br>ពលករត្រូវមកដល់មុនម៉ោង ៥:០០ ល្ងាច
- ខេត្តរ៉ាក់យ៉ង ៖ ព្រឹកម៉ោង ៨:៣០ ដល់ ៥:៣០ល្ងាច<br>ពលករត្រូវមកដល់មុនម៉ោង ៣:៣០ ល្ងាច
- ខេត្តសុងក្លា ៖ ព្រឹកម៉ោង ៨:៣០ ដល់ ៥:៣០ ល្ងាច<br>ពលករត្រូវមកដល់មុនម៉ោង ៣:៣០ ល្ងាច

៣.តម្លៃសេវាផ្លូវការក្នុងការធ្វើ និងបើកផ្តល់សំណុំឯកសារក្នុងថ្ងៃតែមួយដែលភាគីថៃ និងកម្ពុជាបានឯកភាពគ្នាគឺ ២ ៣៥០ (ពីរពាន់បីរយហាសិប)បាត។

## III. អ្នកក្នុងបន្ទុករបស់ពលករអាយុក្រោម ១៥ឆ្នាំ មិនយកកម្រៃសេវា

១. ត្រូវនាំកូន ឬអ្នកក្នុងបន្ទុកមកដោយផ្ទាល់ និងថតរូបដោយផ្ទាល់

២. សំបុត្រពេទ្យ ឬ សំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាអនុវត្តទៅតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១៧

រដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការ

**អ៊ិត សំហេង**

# បទយកការណ៍ខ្លាតខែឧ៖ ពលរដ្ឋធ្វើចំណាកស្រុកនៅខេត្តបន្ទាយមានជ័យ រងគ្រោះ ដោយសារការធ្វើលិខិតឆ្លងដែនសុតស្មាញ

http://www.v-o-d-news.html ដោយ លោក បូ សាវី | ថ្ងៃអង្គារ ទី២៤ ខែតុលា ឆ្នាំ២០១៧ ម៉ោង 10:49 AM

**ខេត្តបន្ទាយមានជ័យ**: ឃុំពន្លៃ មានចំងាយ ប្រហែលជាង៣០គូឡីម៉ែត្រ ពីស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ ឃុំនេះ មានភូមិចំនួន៦ភូមិ ដែលមានពលរដ្ឋរស់នៅ៣ ១០៨គ្រួសារ។ ពួកគេ ប្រមាណ៦០ភាគរយ ជាពលករចំណាកស្រុកនៅប្រទេសថៃ ទាំងស្របច្បាប់ និងខុសច្បាប់។

ផ្លូវចូលទៅភូមិ កន្លែងខ្លះ ក្រាលដោយគ្រួសក្រហម និងផ្លូវខ្លះទៀត មានការខូចខាតពិបាកធ្វើដំណើរ។ អ្នកភូមិខ្លះប្រើប្រាស់គោយន្ត ជាសម្ភារៈសម្រាប់បង្កបង្កើនផលដំណាំកសិកម្ម។ ប៉ុន្តែ បន្ទាប់ពីបញ្ចប់ការធ្វើស្រែចំការ ពលរដ្ឋភាគច្រើន បានទៅធ្វើការនៅតាមព្រំដែនកម្ពុជាថៃ និងធ្វើចំណាកស្រុកនៅក្រៅប្រទេស។

ពលរដ្ឋ «*ត្រូវតែរើបំរះ រកខ្ចីអង្គការ ហើយកូនក៏ទៅដាំចេក កាច់ពោត នៅតាមជាយដែន! ទើបទៅបានប៉ុន្មានថ្ងៃនេះ អត់ទៅក៏រត់ទៅខ្ចីអង្គការ ខ្ចុំខ្ចី តែបីម៉ឺនបាត លក់អាកូនដីត្រពាំងនោះណាស់ យកទៅឲ្យគេ។ គេមិនដឹងទេ មកសព្វថ្ងៃនេះ គេថា កន្លះខែបាន។ ដល់សព្វថ្ងៃនេះ ដល់ពេលធ្វើទៅគេថៃ គេរវល់បិទមិនទាន់ចេញ បានទេបាទ*»។ នេះ ជាការរៀបរាប់ពីការលំបាករបស់ពលរដ្ឋមួយចំនួន នៅឃុំពន្លៃ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យនេះ ដែលបានជំពាក់បំណុលគេ ដោយសារ យកថវិកាទៅធ្វើលិខិតឆ្លងដែនសម្រាប់ទៅរកការងារធ្វើនៅក្រៅប្រទេស។

អ្នកស្រី អ៊ុក ជួន មានអាយុ៥៦ឆ្នាំ ហើយ គាត់រស់នៅក្នុងភូមិពន្លៃ ជាមួយនឹងកូនចំនួន៦នាក់។ អ្នកស្រី អ៊ុក ជួន បានអះអាងថា គាត់បានខ្ចីលុយពីអ្នកស្រុក ជាង៦លានរៀល យកទៅធ្វើលិខិតឆ្លងដែន។ អ្នកស្រី ជួនកាលរំលឹកឡើងវិញ ពីដំណើរការនៃការធ្វើលិខិតឆ្លងដែននេះ ថាមានរយៈពេលច្រើនខែ ប៉ុន្តែមិនទាន់បានទទួលលទ្ធផលនោះឡើយ។ អ្នកស្រីបន្តថា «*ទៅចង់ធ្វើ Passport! ធ្វើ Passport! ធ្វើតាំងពីខែ៣ រហូតដល់ពេលនេះ! គ្នាសួរទៅថា ២អាទិត្យគ្នា ក៏រង់ចាំ! ថៅកែ ហៅទៅបេះផ្លែឈើ ក៏មិនហ៊ានទៅ ត្រូវតែចាំ! លុះដល់សព្វថ្ងៃ មិនឃើញបាន*»។ ស្ត្រីសម្បុរខ្មៅ រូបនោះ បានឲ្យដឹងថា ការធ្វើការធ្វើលិខិតឆ្លងដែននេះ អ្នកស្រី បានខ្ចីលុយពីអ្នកស្រុកនៅតំបន់នោះ យកទៅឲ្យកូនពីរនាក់ ក្នុងតម្លៃប្រមាណជាង ៦លានរៀល តាមរយៈតំណាងក្រុមហ៊ុនមួយគ្មានឈ្មោះ និងគ្មានអាស័យដ្ឋានច្បាស់លាស់។ អ្នកស្រីបន្តថា ក្នុងមួយខែ អ្នកស្រី ត្រូវចំណាយថ្លៃការប្រាក់ប្រមាណ២០ម៉ឺនរៀល ដល់ម្ចាស់បំណុល។ អ្នកស្រីបន្តថា «*ខ្ចីអ្នកស្រុក គេយកការមួយខែ៨០បាត ក្នុងមួយពាន់បាត។ ចុះទៅ៦ខែ ពីខែមិនាមក។ ខ្ញុំចេះ តែពង្រឹងកូនអោយសួរថា ចាំមើលពីរអាទិត្យ ដល់ពេលសួរចុងក្រោយនេះ ថា Passport នៅក្រុមហ៊ុន នៅទូតថៃ មិនទាន់ធ្លាក់មកហើយ ទៅណោះហើយម៉េចធ្លាក់មក*»។

អ្នកស្រី ហួន ផលឡែន ត្រូវជាកូនអ្នកស្រី អ៊ុក ជួន ក៏បានសម្តែងការខកចិត្តចំពោះក្រុមហ៊ុន ដែលបានទទួលថវិកាពីអ្នកស្រី និងស្វាមី ដោយមិនបានផ្តល់លិខិតឆ្លងដែនតាមការកំណត់។ អ្នកស្រី បានបន្តថា គ្រួសារគាត់បានចំណាយថវិកាជិត៥ម៉ឺនបាត ទៅឲ្យតំណាងក្រុមហ៊ុនមួយ បាននាំទៅធ្វើលិខិតឆ្លងដែននៅទីក្រុងភ្នំពេញ ប៉ុន្តែអ្នកស្រីថា រូបគាត់មិនបានស្គាល់កន្លែង និងអាស័យដ្ឋានក្រុមហ៊ុននោះពិតប្រាកដទេ។ ក្រុមហ៊ុននោះ បានសន្យាថា តែរយៈពេលមួយសប្តាហ៍ប៉ុណ្ណោះ ប៉ុន្តែជិត៦ខែហើយ មិនឃើញតំណាងម្នាក់ទាក់ទងមកស្រីសោះ។ អ្នកស្រីបន្តថា «*ទេ មិនបានប្រាប់អីផង ទៅតាមក្រុមហ៊ុនទៅដល់បើកឡានគេយកយើងទៅដាក់នៅកន្លែងបេនឡានភ្នំពេញ រួចគេអោយយើងជិះម៉ូតូកង់បីទៅ ហើយធ្វើអីរួចគេនាំមកដាក់កន្លែងបេនឡាននោះវិញ ហើយ*

*គេឲ្យជិះឡានក្រុមហ៊ុន(ឡានក្រុង)នោះវិញ។ ប្អូនថ្លៃខ្ញុំ គេឲ្យទៅតាមខ្សែរយៈប៉ោយប៉ែតគេនាំទៅណាស់ ដែលវាធ្លាប់ធ្វើបានទៅធ្វើការហើយ*»។

អ្នកស្រី ហួន ផលឡែន បានរៀបរាប់ទៀតថា ការធ្វើចំណាកស្រុកខុស វាប្រឈមគ្រោះថ្នាក់គ្រប់បែបយ៉ាង ទើបពួកគេសម្រេចធ្វើលិខិតឆ្លងដែន ប៉ុន្តែផ្ទុយទៅវិញ បែជាមានបញ្ហាមិនប្រក្រតីកើតឡើងចំពោះពួកគេទៅវិញ។ នៅពេលអ្នកស្រី សួរតំណាងក្រុមហ៊ុននោះ គេឆ្លើយថា មិនទាន់រួចរាល់ទេ ដោយសារក្រុមហ៊ុនទទួលធ្វើលិខិតឆ្លងដែនអោយពលករច្រើននាក់ ទើបមានការយឺតយ៉ាវ។ អ្នកស្រីបន្តថា «*គេទៅគាត់ថា Passport មិនទាន់ធ្លាក់បើបានគាត់តេការឲ្យ វាច្រើនតាមលេខរៀង។ ម្នាក់ពីរម៉ឺនបាតប៉ុណ្ណឹង ឯងណា៥ពាន់ យើងដាក់ទៅហូបចុកខ្លួនយើងណាចាំ។ ប្រាក់ខែអី ដល់ខែគាត់ បើកអោយក្នុងមួយអាទិត្យបើកអោយ ១៥០០បាត។ ការងារមិនពិបាកទេ ប៉ុន្តែ វាចេញចូលដើរទៅណាទៅវាពិបាក*»។

កាលពីថ្ងៃទី៦កក្កដាឆ្នាំ២០១៧ ក្រសួងការបរទេសកម្ពុជា បានសេចក្តីប្រកាសព័ត៌មាន ថា រដ្ឋាភិបាលបានដាក់ចេញវិធានការមួយចំនួន ដើម្បីជានាដោះស្រាយបញ្ហាពលករខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃ ដែលពួកគេមិនមានលិខិតស្នាមត្រឹមត្រូវ ដើម្បីឲ្យបានស្នាក់នៅនិងធ្វើការបន្តនៅទីនោះ។ បើតាមសេចក្តីប្រកាសព័ត៌មានក្រសួងការបរទេសកម្ពុជាថា ខ្លួនបានចាត់ឲ្យអាជ្ញាធរពាក់ព័ន្ធជួយដោះស្រាយ និងពិភាក្សាបញ្ហានេះ ហើយថា ភាគីថៃក៏បានឆ្លើយតប ដោយពន្យារការអនុវត្តរាជ្យក្រិត្យប្រតិបត្តិរបស់ខ្លួន ក្នុងរយៈពេល ១៨០ថ្ងៃ ឬស្មើ នឹង៦ខែទៀត។ ក្រសួងការបរទេស ក៏បានណែនាំដល់អគ្គរាជទូតកម្ពុជាប្រចាំនៅទីក្រុងបាងកក និងស្ថានកុងស៊ុលកម្ពុជានៅខេត្តស្រះកែវ ដើម្បីបង្កើនការសហការជាមួយអាជ្ញាធរគ្រប់ជាន់ថ្នាក់របស់បណ្តាខេត្តកម្ពុជា ដែលជាប់ព្រំដែនជាមួយថៃ។

អតីតពលករមួយរូបគឺ លោក ឃ្លីញ ភក្ត្រា បានឲ្យដឹងថា លោកត្រូវបាលក្រុមសមត្ថកិច្ចប្រទេសថៃ បណ្តេញឲ្យត្រឡប់មកកម្ពុជាវិញ ខណៈដែលលោកឆ្លងដែនធ្វើពលករដោយខុសច្បាប់ តាមរយៈមេខ្យល់នៅតាមព្រំតាមដែនខ្មែរ ថៃ។ លោកបានវិលត្រឡប់មកកម្ពុជានាពេលនេះ ដើម្បីធ្វើលិខិតឆ្លងដែនស្របច្បាប់ តាមរយៈក្រុមហ៊ុននាំពលករមួយឈ្មោះ អ៊ែនជេស៊ី នៅរាជធានីភ្នំពេញ។ លោកថា មកដល់ពេលនេះ នៅទាន់មានទទួលឯកសារពីក្រុមហ៊ុននោះនៅឡើយទេ ដោយតំណាងក្រុមហ៊ុនសន្យា៤៥ថ្ងៃ។ សំឡេងលោកបន្តថា «*រឿង Passport នេះ វាស៊ីសង និងអាស្រ័យលើថៅកែយើងដែរ បើថៅកែយើង មានឯកសារដើររឿងអោយគេគ្រប់គ្រាន់ គេជួយអោយយើងឆាប់បាន ទៅតែរយៈពេលតែ៤៥ថ្ងៃបាន។ ក្រុមហ៊ុនបងក្រុមហ៊ុនគេ តម្រូវអោយើង។ ធម្មតាក្រុមហ៊ុន មិនមែនសុទ្ធតែល្អទាំងអស់ទេ មានខ្លះបោកប្រាស់ តែក្រុមហ៊ុនខ្លះ គេធ្វើត្រឹមត្រូវ គេតម្រូវអោយយើងធ្វើ ហើយមានវីសារការងារត្រឹមត្រូវ ធម្មតាថៅកែ នៅថៃគេចង់ បានពលករស្របច្បាប់*»។

បុរសវ័យ៣៦ឆ្នាំ សម្បុរសស្រអែមរូបនោះ បានបន្តថា ពលករខ្មែរ ដែលធ្វើលិខិតឆ្លងដែនទៅក្រៅប្រទេសមានភាពស្មុគស្មាញច្រើន។ ចំណែកតម្លៃសេវាកម្មលិខិតឆ្លងដែន និងឯកសារផ្សេងៗ មានតម្លៃខ្ពស់ ដោយលោកថា រហូតដល់ជិត ៣ម៉ឺនបាតក្នុងម្នាក់។ លោកភក្ត្រាបន្តថា «*ខ្ញុំមកនេះ មកធ្វើPassport តែម្តងតម្លៃ២ម៉ឺន៥០០០ពាន់បាត ម្នាក់មានវិសារ ការងារមានប៉ៃវ៉ៃ៉ានត្ត (លិខិតបញ្ជាក់ការងារ) មានគ្រប់យ៉ាងបានគេអនុញ្ញាអោយធ្វើការនៅប្រទេសថៃបាន។ ធ្វើការងារស្របច្បាប់ប្រទេសគេ បើថាយើងធ្វើលិខិតឆ្លងដែនទៅរដ្ឋាភិបាលកម្ពុជាត្រូវបញ្ជាក់ថា យើងជាពលករស្របច្បាប់ហើយស្ថានទូតថៃ គេអនុញ្ញាតអោយធ្វើការនៅក្នុងប្រទេសថៃ។ គេបញ្ជាក់ថា យើងជា ពលករឆ្លងដែនស្របច្បាប់ដែលទទួលស្គាល់ដោយរដ្ឋាភិបាលថៃ និងរដ្ឋាភិបាលកម្ពុជាគេអនុញ្ញាតអោយទៅ*»។

ជំទប់ទី១ នៃឃុំពន្លៃ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យលោក ធែម លឿត មានប្រសាសន៍ថា ពលរដ្ឋធ្វើចំណាកស្រុក នៅឃុំពន្លៃមានចំនួន១ ២៣៨នាក់ ។ តួលេខនេះ ចាប់ពីឆ្នាំ២០១៦ ដល់ខែសីហាឆ្នាំ២០១៧នេះ។

លោកទទួលស្គាល់ថា ការធ្វើចំណាកស្រុកខុសច្បាប់ ដោយសារពួកគេខ្វះខាតជីវភាពគ្រួសារ។ លោកបន្តថា បន្ទាប់ពីការលំបាកនៃការធ្វើលិខិតឆ្លងដែនស្របច្បាប់ អាជ្ញាធរ បានបញ្ជាក់ពីទីលំនៅស្របច្បាប់ដល់ពួកគាត់ ដើម្បីងាយស្រួលឲ្យក្រុមហ៊ុន ឬរដ្ឋាភិបាល ធ្វើសំណុំឯកសារ។ ប៉ុន្តែលោកថា លោកមិនដឹងការធ្វើលិខិតឆ្លងដែន ជាមួយក្រុមហ៊ុនឬ ជាមួយមន្ត្រីរដ្ឋាភិបាល ហើយក៏ធ្លាប់ឮ ពលរដ្ឋការចាញ់បោកពីក្រុមហ៊ុនណាមួយពីការធ្វើលិខិតនោះដែរ។ លោកបន្ថែមថា «*ប៉ាស្ព័រគាត់មាន មេខ្យល់គាត់មាន មេខ្យល់គាត់រត់ការអោយ ប៉ុន្តែក្រោយថ្មីៗនេះ គាត់ទៅផ្ទាល់ដោយបញ្ជាក់ពីឃុំបំពេញសុំបែបបទ ទៅគាត់ទៅធ្វើ ផ្ទាល់នៅទីក្រុងភ្នំពេញ*»។

អាជ្ញាធរខេត្តបន្ទាយមានជ័យ អោយដឹងថា ខេត្តនេះ មានសាខាក្រុមហ៊ុនជ្រើសរើសពលករធ្វើការនៅក្រៅប្រទេសមានចំនួនបីក្រុមហ៊ុន រួមមានក្រុមហ៊ុន 168 Manpower Supply Co Ltd ក្រុមហ៊ុន SPTSE & C Cambodia Resources Co Ltd និងក្រុមហ៊ុន Anny Rita Best Manpower Co Ltd ។

មន្ត្រីក្រុមហ៊ុនជ្រើសរើសពលករមួយរូបរបស់ក្រុមហ៊ុន 168 Manpower Supply Co Ltd ក្នុងចំណោមក្រុមហ៊ុនចំនួន៣ សាខាក្រុមហ៊ុន ក្នុងខេត្តបន្ទាយមានជ័យលោក ឌុច សុភារិទ្ធ អោយដឹងថា ក្រុមហ៊ុនរបស់ទទួលពលករធ្វើការនៅប្រទេសថៃ ប្រទេសម៉ាឡេស៊ី និងជប៉ុន ដោយស្របច្បាប់ ប៉ុន្តែលោកមិនបានប្រាប់ពីតម្លៃនៃការធ្វើលិខិតឆ្លងដែននោះ។ លោកបន្តថា ការធ្វើលិខិតឆ្លងដែនជូនពលករ ទាន់ពេល ដែលក្រុមហ៊ុនបានកំណត់រយៈពេល ប៉ុន្តែការធ្វើឯកសារនោះ គឺធ្វើនៅទីក្រុងភ្នំពេញ។ សំឡេងលោកបន្តថា «*ទាន់ពេល គាត់ដាក់ពាក្យដាក់អី យើងប្រាប់ពីពេលវេលា នៃការដំណើរការឯកសារទៅ យើងជម្រាប់គាត់ថា ឥឡូវដាក់ពាក្យនៅពេលនេះ ហើយនៅថ្ងៃនេះ ទើបគាត់បានចេញទៅធ្វើការ*»។

សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការងារកម្ពុជា ផ្សាយនៅថ្ងៃទី៧ខែសីហាឆ្នាំ២០១៧ ឲ្យដឹងថា ពលករខ្មែរខុសច្បាប់ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ មានជាង៣០ម៉ឺន ប៉ុន្តែក្នុងរយៈពេលដែល តម្រូវចុះបញ្ជីទទួលភាពស្របច្បាប់ ចាប់ពីថ្ងៃទី២៤ខែកក្កដា ដល់ថ្ងៃទី៧ខែសីហាឆ្នាំ២០១៧ មានអ្នកចុះឈ្មោះបានតែ២០ម៉ឺននាក់ (២ ០៣ ៧៣២នាក់) នៅសល់ប្រមាណ ១០ម៉ឺននាក់ទៀត។ ពលករមួយរូបទៀត នៅភូមិស្វាយខ្មៅ ឃុំពន្លៃ ស្រុកភ្នំស្រុក អ្នកស្រី មិន ហឿត ដែលមានវ័យជាង៤០ឆ្នាំ បានសម្តែងក្តីបារម្ភ ពីការធ្វើលិខិតឆ្លងដែន ខ្វះការទទួលខុសត្រូវពីក្រុមហ៊ុនជ្រើសរើសពលករ និងរដ្ឋាភិបាល ដោយអ្នកស្រីប្រាប់ថា រូបគាត់ធ្លាប់ចាញ់បោកក្រុមហ៊ុនជ្រើសរើសពលករម្តងរួចហើយ កាលពីឆ្នាំ២០១៤។ អ្នកស្រីបន្តថា ក្រុមហ៊ុនខ្លះ ធានារ៉ាប់រងធ្វើលិខិតឆ្លងដែនឲ្យពលករ ប៉ុន្តែបើពលករ មិនចូលធ្វើការតាមក្រុមហ៊ុននោះទេ គេបង្កកទុកលិខិតឆ្លងដែនរបស់ពួកគាត់។

អ្នកស្រី មិន ហឿត «*ខ្ញុំទៅពីរនាក់ប្អូន បដិសេធមិនអោយទេ ទាល់ខ្ញុំជួលគេពីខ្មែរទៅ យកប្រាក់ពីប្រទេសថៃម្ចាស់ប៉ាស្ព័រនៅថៃតែគេអោយខ្ញុំចុះប៉ាស្ព័រ។ ប៉ុន្តែខ្ញុំមកប៉ាស្ព័រម្នាក់ឯកទេ នៅភ្នំពេញដល់មកម្នាក់ឯង ហើយគេអត់សុខចិត្តគេថា ទាល់តែមានម្ចាស់ខ្លួនមក ហើយម្ចាស់ខ្លួន មិនបានមកទេមានវិក័យបត្រ តែវិក័យបត្រគេមិនយកខ្ញុំបើមិនយកចង់បានអីទៀត គេចង់អោយផ្ទេរសិទ្ធិ អោយផ្ទេរសិទ្ធិផ្តិតមេដៃ ខ្ញុំជួលគេទៅអស់៦ពាន់បាត*»។

ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបន្ទាយមានជ័យ លោក រស់ សារុំ មានប្រសាសន៍ថា យោងតាមសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមហ៊ុនឯកជនជ្រើសរើសពលករមានចំនួន៧៧ក្រុមហ៊ុន សម្រាប់ជ្រើសរើសពលករទៅក្រៅប្រទេសនៅទូទាំងប្រទេស ប៉ុន្តែសម្រាប់នៅខេត្តបន្ទាយមានជ័យ មានសាខាក្រុមហ៊ុនស្របច្បាប់ ចំនួន៣ក្រុមហ៊ុនប៉ុណ្ណោះ រួមមានក្រុមហ៊ុន Manpower Supply Co Ltd ក្រុមហ៊ុនSPTSE & C Cambodia Resources Co Ltd និងក្រុមហ៊ុន Anny Rita Best Manpower Co Ltd។

លោកបានបន្តទៀតថា «*ក្រសួងការងារលោក បានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋខ្មែរ មេត្តាប្រុងប្រយ័ត្ន ចំពោះជនខិលខូច ជនឆ្លៀតឱកាស ជាពិសេសក្រុមហ៊ុន និងអង្គការមួយចំនួនគ្មានឈ្មោះ ក្នុងតារាងខាងលើហើយធ្វើសកម្មភាពបោកប្រាស់ ក្រោមរូបភាពបណ្តុះបណ្តាលបញ្ជូនពលករខ្មែរ ទៅធ្វើការនៅបរទេសខុសច្បាប់*»។

លោក រស់ សារុំ មានប្រសាសន៍បន្តទៀតថា បើសិនក្រុមហ៊ុន បានទទួលថវិកាពីពលករ ធ្វើបំពេញសុំណុំឯកសារធ្វើការងារត្រឹមត្រូវហើយនោះ បែរជាបោកប្រាស់ពលរដ្ឋវិញ លោកថា ពលរដ្ឋអាចដាក់ពាក្យប្តឹងដល់មន្ទីរការងារនិងបណ្តុះបណ្តាលតាមរិជ្ជាជីវៈ ដើម្បីអាជ្ញាធរមានចំណាត់ការ។ លោកបន្តថា «*ទាក់ទងទៅហ្នឹងទទួលថវិកាហើយ ទាក់ទងនិងផ្តល់ជូននូវលិខិតស្របច្បាប់ និងផ្តល់ការងារទៀតហើយក្រុមហ៊ុននោះ ធ្វើមិនបានច្រើនខែ ច្រើនថ្ងៃ យើងចង់និយាយចេះ ពលករត្រូវដាក់ពាក្យប្តឹងមកមន្ទីរ ទើបមន្ទីរមានសិទ្ធិអញ្ជើញក្រុមហ៊ុន មកដោះស្រាយអោយភាគីទាំងពីរ ទទួលយកបានទៅវិញ*»។

កាលពីខែកក្កដាកន្លងទៅ រដ្ឋាភិបាលថៃរៀបចំឲ្យពលករខុសច្បាប់ ដែលធ្វើនៅក្នុងប្រទេសនេះ ទាំងអស់បំពេញលក្ខខណ្ឌដើម្បីទទួលបានភាពច្បាប់។ យោងតាមសេចក្តីសម្រេចនោះអោយដឹងថា នីតិវិធីបំពេញលក្ខខណ្ឌមាន ៣ដំណាក់កាល គឺទី១ ថៅកែថៃ ទៅចុះឈ្មោះពលករពីថ្ងៃទី២៤កក្កដា ដល់ថ្ងៃទី០៧សីហា ទី២ ពីថ្ងៃទី០៨សីហា ដល់ថ្ងៃទី០៩កញ្ញា ពលករត្រូវទៅបង្ហាញខ្លួននៅការិយាល័យទាំង៩៧កន្លែង និង ចុងក្រោយពលករ ស្នើសុំលិខិត ស្នាក់នៅ និងបណ្ណការងារ ពីគណៈកម្មការផ្តល់ភាពស្របច្បាប់ និងមន្ត្រីអន្តោប្រវេសន៍ និងក្រសួងការងារថៃ។

អភិបាលខេត្តបន្ទាយមានជ័យ លោក សួន បវរ លោកទទួលស្គាល់ថា ប្រជាពលរដ្ឋរស់នៅតាមមូលដ្ឋានជនបទ ពិតជាមានការលំបាក ក្នុងការទំនាក់ទំនងស្វែងរកសេវា ធ្វើលិខិតឆ្លងដែន និងវិសារការងារពិតមែន និងទទួលរងការចាញ់បោកពីតំណាងក្រុមហ៊ុននិងមេខ្យល់។ ជាមួយគ្នានោះ លោកថា តម្លៃក៏ថ្លៃ ដែលពួកគាត់គ្មានលទ្ធភាពធ្វើវា ទើបធ្វើចំណាកស្រុកខុសច្បាប់។ លោកបន្តថា «*ប៉ុន្តែបញ្ហា វាកើតឡើង គឺទី១ តម្លៃថ្លៃ អ្នករត់ការយកសួយសារអាករថ្លៃពេក អ្នកខ្លះគាត់អត់មានលទ្ធភាព ធ្វើអោយគាត់ប្រថុយប្រាន ធ្វើចំណាកស្រុកខុសច្បាប់។ បញ្ហាទី២ មានខ្លះមិនមែនទូទៅទេ គឺចាញ់បោកគេ គឺឲ្យលុយទៅហើយ ទៅធ្វើអត់ទទួលបានប៉ាស្ព័រ ឬវីសារការងារ នឹងមកទេអត់បានទេ នេះជាបញ្ហា*»។

ប៉ុន្តែ លោក សួន បវរ បញ្ជាក់ថា រដ្ឋាភិបាលកំពុងរៀបចំមណ្ឌលសំចតមួយកន្លែង នៅក្រុងប៉ោយប៉ែត្រ ខេត្តបន្ទាយមានជ័យ នៅពេលឆាប់ខាងមុខនេះ សម្រាប់សម្រួលធ្វើលិខិតឆ្លង និងវីសារការងារដល់ប្រជាពលរដ្ឋ។ ជាមួយគ្នានោះថា លោកថា អាជ្ញាធរនឹងរឹតបន្តឹងតាមច្រករបៀងតាមព្រំដែន រវាងប្រទេសទាំងពីរគឺ ថៃនិងកម្ពុជា ឲ្យមានប្រសិទ្ធិភាព។ លោកបន្តថា «*ដូច្នេះ យើងឃើញថា បញ្ហានេះ ជាការលំបាកមួយ ដែលក្នុងនាមរដ្ឋបាលខេត្ត សូមស្នើស្ថាប័នថ្នាក់ជាតិដើម្បីធ្វើយ៉ាងឲ្យសេវានេះ រំកិលមកជៀកនិងប្រជាពលរដ្ឋយើង ដើម្បីបង្កលក្ខណៈងាយស្រួលឲ្យគាត់អាចធ្វើលិខិតឆ្លងដែននេះ ហើយនឹងទទួលវិសាការងារ បានដោយងាយស្រួល។ ហើយមណ្ឌលសំចតនៅប៉ោយប៉ែតនេះដែលយើងគ្រោងធ្វើគឺមានទីធ្លាធំទូលាយ ដែលអាចយន្តការ បោះទីតាំងងាយស្រួលបំរើប្រជាពលរដ្ឋយើង*»។

ប្រធានអង្គការសម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា លោក សន ជ័យ មានប្រសាសន៍ថា ការធ្វើលិខិតឆ្លងដែននៅកម្ពុជា មានតម្លៃថ្លៃនិងប្រើរយៈពេលយូរជាងនៅតាមបណ្តាប្រទេសជិតខាងកម្ពុជា។ លោកប្រៀបធៀបថា តម្លៃលិខិតឆ្លងដែននៅប្រទេសកម្ពុជាតម្លៃជាង១០០ដុល្លា ប្រទេសឡាវមានតម្លៃ ៣៥ដុល្លា ប្រទេសថៃ ៣៥ដុល្លា ខណៈប្រទេសវៀតណាមតម្លៃជាង ៣០ដុល្លា។ លោក សន ជ័យ «*ជាអំណាចប្រមូលផ្តុំ ជាពិសេសសេវាប្រមូលផ្តុំ នៅថ្នាក់ជាតិហ្នឹង។ របៀបនេះ ធ្វើអោយយឺយ៉ាវ អត់មានអីធ្វើអោយ គេកំណត់*

*យូរ ហើយតម្លៃវាថ្លៃ។ តម្លៃនឹងយើងមើលទៅ សម្រាប់ប្រជាពលរដ្ឋបង់អោយ ទៅការិយាល័យលិខិតឆ្លងដែន ហ្នឹងណាវាថ្លៃរួចទៅហើយ វាមិនទាន់គិតប្រជាពលរដ្ឋឡើងមកជិះតាក់ស៊ីជិះឡានក្រុងមកស្នាក់នៅមួយយប់ ហើយបានទៅវិញទៀតផង យើងចង់អោយធ្វើវិមជ្ឈការទៅដល់ថ្នាក់ខេត្ត*»។

ចំពោះ លោក មឿន តុលា នាយកនៃអង្គការសង់ត្រាល់ មានប្រសាសន៍ថា តាមការប៉ាន់ប្រមាណពលករខ្មែរនៅក្រៅប្រទេស មានចំនួនប្រមាណ ១លាន៩សែននាក់ ក្នុងនោះ១លាន៦សែននាក់នៅក្នុងប្រទេសថៃ ដែលលោកថា អ្នកស្របច្បាប់មានចំនួន ៦០ភាគរយ និងអ្នកខុសច្បាប់ចំនួន៤០ភាគរយ។ លោកបន្តថា «*ហើយរងគ្រោះទី៣ យើងឃើញពលរដ្ឋយើងដែលទៅធ្វើការនៅថៃដោយខុសច្បាប់ហើយ។ហើយថៃបើកអោយចុះបញ្ជីឲ្យទៅជាពលករស្របច្បាប់អីហ្នឹងខាងរដ្ឋាភិបាលយើងចេញទៅធ្វើប៉ាស្ព័រចឹងមែនក៏ប៉ុន្តែអ្នកដែលបានធ្វើប៉ាស្ព័រនៅក្នុងឆ្នាំ២០១៧ មកដល់ពេលនេះ អ្នកខ្លះមិនទាន់បានទទួលនៅឡើយទេ ហើយលុយគេបង់ហើយចឹងណា ប្រាក់ក៏បង់ថង់ក៏ដាច់ទាំងអស់នឹងជាចំណុចសំខាន់ៗនៃប៉ាស្ព័រនឹងបាទ*»។ លោក មឿន តុលា មានប្រសាសន៍ទៀតថា ករណីនេះ ដោយសារការធ្វើលិខិតឆ្លងដែន មាននីតិវិធីវែងឆ្ងាយ។ លោក មឿន តុលា ផ្តល់អនុសាសន៍ថា រដ្ឋាភិបាលគួរបង្កើតកន្លែងធ្វើលិខិតឆ្លងដែន នៅតាមច្រកចេញចូលតែមួយ ក្នុងស្រុកក្រុង នៅតាមបណ្តាខេត្តឲ្យបានច្រើន ដែលលោកថា អាចជួយបង្កើនល្បឿន និងកាត់បន្ថយការចំណាយដល់ពលករ។

ជាមួយគ្នានោះដែរ ប្រជាពលរដ្ឋ នៅខេត្តបន្ទាយមានជ័យ ជាប់ព្រំដែនខ្មែរ ថៃ ក៏បានអំពាវនាវដល់រដ្ឋាភិបាល ស្នើឲ្យមានកន្លែងធ្វើលិខិតឆ្លងដែននៅទីតាំងជិតតំបន់ពួកគេរស់នៅ ដូចជានៅទីរួមខេត្ត ហើយមានតម្លៃថោក និងឆាប់រហ័ស ឲ្យដូចប្រទេសដទៃទៀត នៅក្នុងតំបន់អាស៊ានដូចគ្នា៕

## ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧
## ស្ត្រីពលករខ្មែរម្នាក់ត្រូវប្តីដឹកយកមកបោះបង់ចោលនៅខេត្តបន្ទាយមានជ័យ

http://cambodiapolice.com/blog/archives/ 6:45 pm 25 តុលា 2017 24

ខេត្តបន្ទាយមានជ័យ ៖ ស្ត្រីពិការជើងម្ខាងម្នាក់ធ្វើកម្មករនៅក្នុងប្រទេសថៃ ហើយបានធ្វើដំណើរពីប្រទេសថៃឆ្លងតាមច្រកតំបន់ស្រុកម៉ាឡៃជាមួយនឹងបុរសជាប្តី ដើម្បីឱ្យប្តីជូនដំណើរទៅស្រុកកំណើត នៅខេត្តរតនគិរី លុះធ្វើដំណើរដល់ខេត្តបន្ទាយមានជ័យ ប្តីរូបនោះដឹកយកមកបោះបង់ចោល ហើយស្ត្រីជាប្រពន្ធគ្មានលុយនៅក្នុងខ្លួនត្រូវបានប្រជាពលរដ្ឋ និងសមត្ថកិច្ចជួយឧបត្ថម្ភសម្លៀកបំពាក់ និងថវិកាមួយចំនួនធ្វើជាសោហ៊ុយ ដើម្បីជិះរថយន្តទៅស្រុកណើត ។

ហេតុការណ៍បានកើតឡើងកាលពីវេលាម៉ោង៧ព្រឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ នៅចំណុចភូមិសាស្ត្រ ឃុំកូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ លោកវរសេនីយ៍ត្រី សេះ វិបុល អធិការនគរបាលស្រុកអូរជ្រៅ ប្រាប់ឱ្យដឹងថា ស្ត្រីរូបនោះមានឈ្មោះ រស់ សារី អាយុ៤០ឆ្នាំ មានស្រុកកំណើតនៅស្រុកបកែវ ខេត្តរតនគិរី ចំណែក បុរសជាប្តីនោះមានឈ្មោះ ឈុន ចិត្រ អាយុ៥៣ឆ្នាំ មានស្រុកកំណើតនៅខេត្តពោធិ៍សាត់ ។

បើតាមការរៀបរាប់ពីស្ត្រីឈ្មោះ រស់ សារី ប្រាប់ឱ្យដឹងថា នាងបានប្តីមានឈ្មោះ ឈុន ចិត្រធ្វើការងារជាកម្មករជាមួយគ្នានៅក្នុងប្រទេសថៃអស់រយៈពេល៧ឆ្នាំហើយ ប៉ុន្តែគ្មានកូននោះទេ ។ នៅថ្ងៃមួយនាងក៏ជួបគ្រោះថ្នាក់ចរាចរណ៍ បណ្តាលឱ្យពិការជើងឆ្វេង ។ នៅក្នុងអំឡុងសម្រាកព្យាបាលជម្ងឺនៅក្នុងពេទ្យប្រទេសថៃរយៈពេល៩ខែនាងអស់ប្រាស់លើង ។ លុះបន្ទាប់មកនៅថ្ងៃខាងលើ ក៏បបួលប្តីជូនមកស្រុកកំណើតវិញ ដោយពួកគេទាំង២នាក់បានធ្វើដំណើរពីប្រទេសថៃ ឆ្លងតាមច្រកតំបន់ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ពេលដល់ស្រុកម៉ាឡៃ បុរសជាប្តីបានខ្ចីម៉ូតូអ្នកស្គាល់១គ្រឿង ដឹកនាងប្រាប់ថាទៅស្រុក ។ នៅពេលឌុបនាងដល់ចំណុចផ្សារគុត្តសត ស្រុកអូរជ្រៅ ប្តីរូបនោះបានឈប់ម៉ូតូ ហើយឱ្យនាងចុះចាំមួយភ្លែតថាទៅទិញទឹកផឹក ។ នៅពេលប្តីរូបនោះទៅបាត់កាន់តែយូរទៅៗ រង់ចាំមិនឃើញ ទើបនាងដឹងខ្លួនថា ប្តីនិយាយកុហក ដោយបោះបង់នាងចោលនៅចំណុចផ្សារគុត្តសត ទើបស្រែកយំតែម្តង ព្រោះនៅក្នុងខ្លួនគ្មានលុយទាល់តែសោះ ។ បន្ទាប់មកប្រជាពលរដ្ឋឃើញអាណិតអាសូរក៏បានឱ្យថវិកា និងសម្លៀកបំពាក់មួយចំនួនទៅស្ត្រីរូបនោះ ។ ក្រោយមកនាងត្រូវបាននគរបាលប៉ុស្តិ៍នាំមកស្នាក់នៅអធិការដ្ឋាននគរបាលស្រុកអូរជ្រៅមួយយប់ ។

លុះនៅព្រឹកថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ លោកវរសេនីយ៍ឯក ស៊ីវ សុជាតិ ស្នងការរងទទួល ផែនកស្តុការ និងហិរញ្ញវត្ថុ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការងារទៅជួបចែជន្យ ក៏បានឧបត្ថម្ភថវិកាជូនដល់ស្ត្រីរូបនោះចំនួន១១ម៉ឺនរៀលបន្ថែមទៀត ហើយបានជូននាងឡើងរថយន្ត ដើម្បីធ្វើដំណើរទៅស្រុកកំណើតនៅខេត្តរតនគិរីតែម្តង ៕ សំ វិច្ឆិកា

## ទិចារណាកថា: បទល្មើស ឆ្លងដែន នៅតែកើតឡើង យ៉ាងពេញបន្ទុក

https://www.dap-news.com/kh/ ព្រហស្បតិ៍, ២៦ តុលា ២០១៧ 09:30 ដោយ: វាសនាជាវាវិជ័យ ID:012

តាមសេចក្តី រាយការណ៍ ពីប្រជាពលរដ្ឋ រស់នៅតាមតំបន់ព្រំដែន ក្នុងក្រុងប៉ោយប៉ែត ស្រុកអូរជ្រៅ ស្រុកម៉ាឡៃ ស្រុកថ្មពួក និង ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ បានឲ្យដឹងថា តាមច្រក របៀងមួយចំនួននៅតែមានបទល្មើស ឆ្លងដែន កើតឡើង យ៉ាងពេញបន្ទុកដដែល ។ ប្រភពបានឲ្យដឹងថា នៅតាមច្រករបៀង មួយចំនួន សមត្ថកិច្ច បានឃុប ឃិត ឲ្យឈ្មួញនាំចូល ទំនិញគេចពន្ធ ទំនិញខុសច្បាប់ឬចំណីអាហារខូចគុណភាព ពីទឹកដីថៃចូលទឹកដីខ្មែរ យ៉ាងអនា ធិបតេយ្យ ។ នៅតាមច្រករបៀងខ្លះទៀតសមត្ថកិច្ច បានឃុបឃិតជាមួយមេខ្យល់ បើកឲ្យពលរដ្ឋខ្មែរឆ្លងដែន ខុសច្បាប់ ចូលទៅរកការងារធ្វើលើទឹកដីថៃដូចមុនដដែល ហើយត្រូវសមត្ថកិច្ចថៃ ចាប់បញ្ជូនត្រឡប់ មកស្រុកវិញ ជាបន្តបន្ទាប់ ហើយអ្នកខ្លះត្រូវប្រឈម និង ការលំបាកសព្វបែបយ៉ាង ។

ថ្មីៗកន្លងទៅនេះមានសេចក្តីរាយការណ៍ថា នៅច្រករបៀងក្នុង ស្រុកស្វាយចេក មានករណីនាំចូលម៉ូតូគេចពន្ធ ទំនើបៗពីទឹកដីថៃ ចូលទឹកដីខ្មែរ ហើយក៏មានបទល្មើស នាំរថយន្តចង្កូតស្តាំ ពីទឹកដីថៃ ចូលទឹកដីខ្មែរផងដែរ ។ អ្នកប្រព្រឹត្តបទល្មើស ត្រូវបានគេដឹងថា ជាសាច់ញាតិមន្ត្រី ជាន់ខ្ពស់ក្នុង ខេត្តបន្ទាយមានជ័យ ដូច្នេះហើយទើបគ្មានមន្ត្រីជំនាញ ឬសមត្ថកិច្ចពាក់ព័ន្ធណាចាត់វិធានការ បង្ក្រាបបទ ល្មើសប្រកបដោយប្រសិទ្ធភាព ។ រីឯច្រករបៀងច្រើនកន្លែង តាមតំបន់ព្រំដែន ក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ សមត្ថកិច្ច ប្រចាំច្រករបៀងទាំងនោះនៅតែបើកដៃ ឲ្យឈ្មួញនាំចូលទំនិញគេច ពន្ធនិងទំនិញខុសច្បាប់ដោយគ្មានញញើតអ្វីឡើយ។ ការនាំចូលទំនិញគេចពន្ធយ៉ាងពេញបន្ទុកតាមច្រករបៀងទាំងនោះធ្វើឲ្យរដ្ឋ ខាតបង់ ចំណូលពន្ធយ៉ាង ច្រើនសន្ធឹកសន្ធាប់ក្នុងមួយខែៗ ។

ប្រភពពីប្រជាពលរដ្ឋរស់ នៅតាមតំបន់ព្រំដែន ក្នុងស្រុកភ្នំព្រឹក និងស្រុកសំពៅលូន ខេត្តបាត់ដំបង បានឲ្យដឹងថា នៅតាមច្រករបៀង ជាច្រើនកន្លែង សមត្ថកិច្ចបានបើកដៃឲ្យឈ្មួញ នាំចូលទំនិញគេចពន្ធ ទំនិញខុសច្បាប់ ស្រេច តែអំពើចិត្ត ។ សូម្បីតែគ្រឿង ឧបភោគបរិភោគ ខូចគុណភាព មានលាយសារធាតុគីមីដូចជាសាច់មាន់ស្លាបមាន់ ជង្គង់មាន់ និងប្រហិត ក៏ឈ្មួញ អាចនាំចូលក្នុង មួយថ្ងៃៗជាច្រើនតោន មកបំផ្លាញសុខភាពពលរដ្ឋខ្មែរ។ ជាងនេះទៅ ទៀតនៅតាមច្រក ព្រំដែន ខ្លះមានសេចក្តីរាយការណ៍ថា សមត្ថកិច្ចពាក់ព័ន្ធជាច្រើន ស្ថាប័នគឺជាអ្នកឃុបឃិត ឲ្យឈ្មួញនាំចូល ទំនិញគេចពន្ធនិងទំនិញ ខុសច្បាប់ដើម្បីជាថ្នូរនឹងផលប្រយោជន៍យ៉ាងក្រអឺតក្រទម ។

ទន្ទឹមនឹងនេះ សមត្ថកិច្ចតាមច្រកព្រំដែនបែរជារឹតបន្តឹងយ៉ាងខ្លាំង ចំពោះប្រជាពលរដ្ឋ ដែលរកស៊ីនាំចូលទំនិញបន្តិចបន្តួចពីទឹកដីថៃ ដើម្បីបានប្រាក់ចំណូលដោះស្រាយជីវភាពប្រចាំថ្ងៃ ។

នៅតាមច្រករបៀងមួយចំនួន ក្នុងក្រុងសំរោង ស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ សមត្ថកិច្ច ឈរជើងតាម ព្រំដែន នៅតែឃុបឃិតបើកដៃ ឲ្យពលរដ្ឋខ្មែរឆ្លងដែន ខុសច្បាប់ចូលទៅកាប់ឈើគ្រញូងលើទឹកដី ថៃយកមកលក់ឲ្យឈ្មួញទុច្ចរិតយ៉ាងរលូនដដែល។ ជាងនេះទៅទៀតឈ្មួញឈើគ្រញូងមួយចំនួនក្នុងខេត្តឧត្តរមានជ័យ គឺជាមន្ត្រីយោធានិងមន្ត្រីនគរបាល ហើយមិនដែល ឃើញមន្ត្រីអាជ្ញាធរនិងសមត្ថកិច្ចក្នុងខេត្តឧត្តរមានជ័យ ចាត់វិធានការ តាមច្បាប់លើឈ្មួញឈើគ្រញូងទាំងនោះឡើយ។ មិនតែប៉ុណ្ណោះនៅ ច្រកអូរស្មាច់ ច្រកជប់គគីរ និងច្រកជាំស្រងាំ ខេត្តឧត្តរមានជ័យ នៅតែមានសេចក្តីរាយការណ៍ពីរឿងសមត្ថកិច្ចពុករលួយបើកដៃឲ្យឈ្មួញនាំចូលទំនិញគេចពន្ធ ទំនិញ បង់ពន្ធមិនគ្រប់និងទំនិញខុសច្បាប់ យ៉ាងពេញបន្ទុកដដែល ។ ការហូរចូលទំនិញគេចពន្ធតាមច្រកព្រំ ដែនក្នុងខេត្តឧត្តរមានជ័យ ធ្វើឲ្យរដ្ឋត្រូវខាតបង់ចំណូលពន្ធកាន់តែ ច្រើនឡើងៗ ហើយសមត្ថកិច្ចពុក រលួយកាន់តែមានជីវភាពធូរធារ ។

ដោយឡែកសេចក្តីរាយការណ៍ ពីប្រជាពលរដ្ឋ រស់នៅតាមតំបន់ ព្រំដែនក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ ក៏បានឲ្យដឹងដែរថា តាមច្រក ព្រំដែនមួយចំនួនដូចជាច្រកដូង៧ដើម ច្រកចាន់មូល ច្រកបឹងជ្រោង ច្រកដូនរ័ត្ន និងច្រកទន្លេចាម ជាដើម ឈ្មួញនៅតែអាចនាំចូលទំនិញ គេចពន្ធ ទំនិញបង់ពន្ធមិនគ្រប់យ៉ាងពេញបន្ទុក។ ទន្ទឹមនឹងនេះ សមត្ថកិច្ចប្រចាំច្រក ព្រំដែន ទាំងនោះបានឃុបឃិតឲ្យឈ្មួញដឹកជញ្ជូនឈើ ចេញទៅវៀតណាម យ៉ាងអនាធិបតេយ្យ ដោយសារមាន ការបែងចែកផលប្រយោជន៍យ៉ាងរលូន។ សរុបសេចក្តីមកបទល្មើស ឆ្លងដែនទាំងនៅតាមតំបន់ព្រំដែនខ្មែរ-ថៃ និងតំបន់ ព្រំដែនខ្មែរ-វៀតនាមនៅតែកើតមានយ៉ាងពេញបន្ទុកដដែល ហើយចំណាត់ការ របស់ក្រសួងនិងស្ថាប័នពាក់ព័ន្ធនា ពេលកន្លងមកពុំមានប្រសិទ្ធភាពនោះទេ។ សមត្ថកិច្ចនិងមន្ត្រីជំនាញតាមច្រកព្រំដែននិងច្រករបៀង មួយចំនួនគិត តែពីរឿងប្រព្រឹត្តអំពើពុករលួយប្រមូលលុយដាក់ហោប៉ៅ ហើយបណ្តោយឲ្យបទល្មើសឆ្លងដែនរាលដាលកាន់តែខ្លាំង៕

## ស្ថានទូតកម្ពុជាប្រចាំម៉ាឡេស៊ី និងវៀតណាម ជួយពលករ-ពលការិនីខ្មែរ៦នាក់ឲ្យត្រឡប់មកវិញ

http://ann.com.kh/site/news/.html ថ្ងៃព្រហស្បតិ៍, 26 ខែតុលា 2017 9:30 ព្រឹក

ពលរដ្ឋខ្មែរចំនួន៦នាក់ដែលបានចាញ់បោកមេខ្យល់ ទៅបម្រើការងារនៅប្រទេសម៉ាឡេស៊ី និងប្រទេសចិន ត្រូវបានស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី និងវៀតណាម ជួយអន្តរាគមន៍ និងនិវត្តពួកគាត់ឲ្យបានត្រឡប់មកប្រទេសកំណើតវិញ។

យោងតាមប្រកាសរបស់អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាឲ្យដឹងថា ក្នុងចំណោមពលរដ្ឋខ្មែរទាំង៦នាក់នោះ ៤នាក់ត្រូវបានជួយអន្តរាគមន៍ដោយស្ថានអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ក្រោយពួកគេបានទៅកាន់ប្រទេសម៉ាឡេស៊ីតាមរយៈមេខ្យល់ ក៏ដូចជាក្រុមហ៊ុនដើម្បីបម្រើការងារនៅតាមផ្ទះ និងរោងចក្រ ហើយពួកគេចង់ត្រឡប់មកផ្ទះវិញ ក៏បានស្វែងរកអន្តរាគមន៍ពីស្ថានទូត ។ ក្នុងនោះស្ថានទូតក៏បានចេញលិខិតធ្វើដំណើរ និងបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ីជូនពលករ-ពលការិនីទាំង៤នាក់ ហើយពួកគេបានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៧ កន្លងទៅនេះ។

ជាមួយគ្នានេះ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសវៀតណាម សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចវៀតណាម កាលពីពាក់កណ្តាលខែនេះ ក៏បានជួយសង្គ្រោះនាទីខ្មែរម្នាក់ រួមជាមួយកូនប្រុសអាយុ២ខែ ដែលចាញ់បោកមេខ្យល់ជាស្ត្រីជនជាតិវៀតណាម នាំធ្វើដំណើរពីភ្នំពេញទៅដល់ខេត្តឡាក់សឺន បម្រុងយកទៅលក់នៅប្រទេសចិន។ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងទិញសំបុត្រយន្តហោះជូននារីរងគ្រោះ និងកូន ហើយអ្នកទាំងពីរបានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី១៩ ខែតុលា ៕ ANN

## អនុញ្ញាតឲ្យពលករកម្ពុជា ប្រើឯកសារថតចម្លង យកទៅធ្វើប៉ាស្ព័រ ត្រូតសញ្ជាតិបាន.!

http://pheaktraprak.com/archives By เพียะตรา ประ October 25, 2017

គណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាក្នុងប្រទេសថៃបានចេញសេចក្តីប្រកាសជូនដំណឹងដល់បងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅធ្វើការក្នុងប្រទេសថៃ ដែលកំពុងត្រៀមខ្លួនទៅបញ្ជាក់អត្តសញ្ញាណធ្វើប៉ាស្ព័រនៅទីតាំងផ្តល់ស្របច្បាប់ទាំងបីកន្លែងក្នុងប្រទេសថៃអោយបានជ្រៀបថា។ ដើម្បីជួយសម្រួលដល់បងប្អូនពលករកម្ពុជាក្នុងការបញ្ជាក់អត្តសញ្ញាណ(ត្រួតសញ្ជាតិ)ធ្វើប៉ាស្ព័រ ចាប់ពីពេលនេះតទៅគណៈកម្មការផ្តល់ភាពស្របច្បាប់កម្ពុជាអនុញ្ញាតឲ្យ បងប្អូនពលករកម្ពុជាអាចយកឯកសារបញ្ជាក់សញ្ជាតិខ្មែរច្បាប់ថតចម្លងទៅត្រួតអត្តសញ្ញាណធ្វើប៉ាស្ព័របាន។ ឯកសារដែលគណៈកម្មការផ្តល់ភាពស្របច្បាប់កម្ពុជាអនុញ្ញាត រួមមាន, អត្តសញ្ញាណ, សំបុត្រកំណើត, សៀវភៅគ្រួសារ,ប័ណ្ណបើកបររថយន្តឬម៉ូតូ,លិខិតឆ្លងដែន, ប៉ាស្ព័រកម្ពុជា.។ ល។

## សមត្ថកិច្ចបញ្ជូនជនជាតិចិនម្នាក់ទៅតុលាការពីបទនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន

http://cambodiapolice.com/blog/archives/ 1:23 pm 26 តុលា 2017 10

**ភ្នំពេញ** ៖ នៅព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ នេះ កម្លាំងសមត្ថកិច្ចនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជូនខ្លួនពិរុទ្ធជនជនជាតិចិនម្នាក់ទៅតុលាការ ពីបទចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន។

សមត្ថកិច្ចបានឲ្យដឹងថា ពិរុទ្ធជនខាងលើមានឈ្មោះ LIU WING HING ភេទប្រុស ជនជាតិចិន អាយុ ៤២ ឆ្នាំ ត្រូវបានកម្លាំងកម្លាំងសមត្ថកិច្ចនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចាប់ឃាត់ខ្លួននៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ នៅផ្ទះជួលលេខ៣៧ ផ្លូវ១៦ (បុរីប៉េងហួត) ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ តាមដីកាបង្គាប់ឲ្យចាប់ខ្លួន-ឃុំខ្លួនលេខ៧១០(ដ) ដ.ច.ន ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧។

សមត្ថកិច្ចឲ្យដឹងទៀតថា ពិរុទ្ធឈ្មោះ LIU WING HING កាលពីឆ្នាំ២០១៥ បានឃោសនាបោកប្រាស់នាំពលករខ្មែរចំនួន ២៤នាក់ ថាទៅរៀនជំនាញច្នៃម៉ូតសំលៀកបំពាក់ នៅសាកលវិទ្យាមួយ នៅឯប្រទេសចិន ពេលទៅដល់ប្រទេសចិន បែរជានាំពលករទាំង២៤នាក់ នោះឲ្យទៅធ្វើការជាអ្នកដេរខោអាវនៅរោងចក្រទៅវិញ មិនតែប៉ុណ្ណោះពួកគេត្រូវបានទទួលរងនូវការគៀបសង្កត់ពីថៅកែរោងចក្រ និងបង្ខំឲ្យធ្វើការលើសម៉ោងផងដែរ។

បើតាមដីកាបង្គាប់ឲ្យចាប់ខ្លួន-ឃុំខ្លួន ដែលចេញដោយ ប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ ថ្លាង ផាណែត បញ្ជាក់ថា ពិរុទ្ធជនឈ្មោះ LIU WING HING ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ វិនិច្ឆ័យទោសដាក់ពន្ធនាគារចំនួន ៧ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួនពីបទ៖ នាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន

ប្រព្រឹត្តនៅរាជធានីភ្នំពេញ-ប្រទេសចិន កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ តាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ៕

## ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧

## បង្ក្រាបទីតាំងម៉ាស្សាបង្កប់សេវាផ្លូវភេទ នៅសង្កាត់ទំនប់ទឹកឃាត់ខ្លួនមនុស្ស៩នាក់

http://www.yobminh.com/ October 26, 2017

ភ្នំពេញ៖ នៅវេលាម៉ោង១៩ និង ០០នាទីយប់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ សមត្ថកិច្ច នៃការិយាល័យប្រឆាំងការជួញដូរផ្លូវភេទ និងការពារអនីតិជន សហការជាមួយនគរបាល ប៉ុស្តិ៍ទំនប់ទឹក បានចុះបង្ក្រាបទីតាំងម៉ាស្សាមួយកន្លែងឃើហោ " មហាលាភ " ដែលលួចលាក់បង្កប់បម្រើ សេវាផ្លូវភេទ ស្ថិតតាមបណ្តោយផ្លូវ៤៣០ ក្នុងសង្កាត់ទំនប់ទឹក ខណ្ឌចំការមន ។ ការចុះបង្ក្រាបនេះ ធ្វើឡើងដោយមានការសម្របសម្រួលឯកភាពពីព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ លោកគុជ គឹមឡុង ។ ជាលទ្ធផលចំពោះមុខ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនមនុស្សចំនួន៩នាក់ ក្នុងនោះមាន២នាក់ប្តីប្រពន្ធជាម្ចាស់ទីតាំង ៦នាក់ជាស្ត្រីបម្រើសេវាផ្លូវភេទ និងម្នាក់ទៀតជាភ្ញៀវ ។ ក្នុងនោះដែរ សមត្ថកិច្ចបានដកហូតបានស្រោមអនាម័យដែលប្រើប្រាស់រួច និងមិនទាន់ប្រើមួយចំនួនធំ ផងដែរ ដើម្បីជាវត្ថុតាងនិងម៉ូតូ៤គ្រឿង ។ ក្រោយការឃាត់ខ្លួន ពួកគេទាំង៩នាក់ ត្រូវបានបញ្ជូនទៅកាន់ការិយាល័យប្រឆាំងការជួញដូរផ្លូវភេទ និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដើម្បីបន្តនីតិវិធីនៅពេលក្រោយ ៕

## ករណីថៅកែ រឹបអូសឯកសារសម្គាល់ខ្លួនរបស់ពលករ ត្រូវមានទោសជាប់គុកមិនលើសពី 6ខែ

http://pheaktraprak.com/archives By เพียะตรา ประ October 27, 2017

ករណីនិយោជិត(ថៅកែ)រឹបអូសឬមិនឲ្យប៉ាស្ព័រឯកសាររបស់ពលករ ត្រូវមានទោសពិន័យជាប្រាក់ចំនួន 100,000฿(មួយសែនបាត)ឬ ជាប់ ពន្ធនាគារមិនលើសពី 6ខែ។ តើបងប្អូនពលករកម្ពុជាធ្វើការនៅក្នុងប្រទេសថៃមានដឹងដែរឬទេថា.! ករណីថៅកែថៃរឹបអូសយកឯកសារសម្គាល់ខ្លួនរបស់យើងឬលិខិតឆ្លងដែនរបស់ពលករនិងត្រូវមានទោសជាប់ពន្ធនាគារនិងពិន័យជាប្រាក់ទៀតផង។

-ក្នុងច្បាប់ការងារថៃថ្មី(พศ2560) បានបញ្ជាក់ថា ក្នុងករណីនិយោជិត(ថៅកែ) រឹបអូសយកឯកសារផ្ទាល់ខ្លួនរបស់ពលករមានដូចជា,ប៉ាស្ព័រការងារ,លិខិតអនុញ្ញាតធ្វើការ,ប័ណ្ណសុីជម្ពូ, និងឯកសារផ្សេងទៀតរបស់ពលករ ដើម្បីកុំឲ្យពលកររត់ចេញទៅធ្វើការនៅកន្លែងផ្សេង គឺត្រូវមានទោសតាមច្បាប់ការងារថ្មី(พศ2560)មានទាំងពិន័យមានទាំងជាប់គុក។

-ក្នុងករណីខាងលើនេះបើសិនជានិយោជិត(ថៅកែ)ណាហាន ប្រព្រឹត្តល្មើសពីច្បាប់ការងារខាងលើនេះនិងត្រូវមានទោសចាប់ផាកពិន័យជាទឹកប្រាក់ចាប់ពី100,000฿ (មួយសែនបាត) ឬត្រូវជាប់ពន្ធនាគារមិនលើសពី 6 ខែ ទាំងចាប់ទាំងជាប់។

6 -( สำหรับการคุ้มครองแรงงานต่างด้าว เพื่อป้องกันการค้ามนุษย์นั้น พบว่า หากนายจ้างหรือผู้ใดยึดใบอนุญาตทำงานหรือเอกสารสำคัญประจำตัวคนต่างด้าว มีโทษจำคุกไม่เกิน 6 เดือน หรือปรับไม่เกิน 100,000 บาท หรือทั้งจำทั้งปรับ )

-បើសិនជាបងប្អូនពលករកម្ពុជាធ្វើការក្នុងប្រទេសថៃ ជួបករណីដូចខាងលើនេះ សូមទំនាក់ទំនងមកកាន់ភ្នាក់ងារស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ឬភ្នាក់ងារក្រសួងការងារថៃដោយផ្ទាល់ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ជូនបងប្អូន។ ទំនាក់ទំនងទំព័រហ្វេសប៊ុកស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ:Royal EmbassyofCambodiainBangkok

**ករណីថៅកែបោក, ថៅកែមិនបើក ប្រាក់ខែអោយ, ធ្វើទារុណកម្មលើពលករ, តើនេះអាចជួយបងប្អូនបាន**.!

http://pheaktraprak.com/archives By ភ័ក្ត្រា ប្រាក់ October 27, 2017

ក្នុងករណីបងប្អូនពលករកម្ពុជាជួបបញ្ហាដូចជា,ថៅកែបោក, មិនបើកប្រាក់ខែ,ធ្វើទារុណកម្មលើពលករ, បង្ខំពលករអោយធ្វើការខុសច្បាប់,និងផ្សេងៗទៀតកុំភ្លេចទំនាក់ទំនងភ្នាក់ងារមានសមត្ថកិច្ចដូចខាងក្រោម៖

-នៅពេលដែលបងប្អូនពលករកម្ពុជាធ្វើការនៅប្រទេសថៃជួបបញ្ហាដូចជា ថៅកែមិនបើកប្រាក់ខែអោយ,ធ្វើទារុណកម្មលើពលករ, ប្រើពលករអោយធ្វើការខុសច្បាប់, ឬផ្សេងទៀតនៅក្នុងប្រទេសថៃ។ នៅពេលបងប្អូនជួបបញ្ហាដូចខាងលើនេះ តើមានអ្នកណាអាចជួយបងប្អូនបាន.? បញ្ហាទាំងនេះក្រសួងការងារថៃ និងស្ថានទូតកម្ពុជាអាចជួយដោះស្រាយបញ្ហាជូនបងប្អូនបាន ដោយគ្រាន់តែបងប្អូនមានជារូបភាព, វីដេអូនិងអ្វីផ្សេងទៀត ហើយបងប្អូនអាចទំនាក់ទំនងមកកាន់ភ្នាក់ងារស្ថានទូតកម្ពុជាតាមរយៈទូរស័ព្ទ: 02.9575851, 086.7999957, 0940925905, 0928050561, 064.7547401 ឬទំនាក់ទំនងទៅកាន់ភ្នាក់ងារក្រសួងការងារថៃដោយផ្ទាល់តាមរយ:លេខទូរស័ព្ទ: 1694 ឬលេខទូរស័ព្ទ: 11111 របស់ក្រសួងមហាថៃដោយផ្ទាល់ក៏បាន ឬតាមរយៈវេបសាយ: https://www.doe.go.th/helpme ចុចត្រង់នេះ។ ដូច្នេះចំពោះបងប្អូនពលករកម្ពុជាដែលជួបបញ្ហាដូចការលើកខាងលើកុំភ្លេចទំនាក់ទំនងសុំការអន្តរាគមន៍ពីភ្នាក់ងារមានសមត្ថកិច្ចនៅក្នុងប្រទេសថៃ ដើម្បីជួយដោះស្រាយបញ្ហាជូនបងប្អូន។

**ពលករកម្ពុជា ដែលមានប័ណ្ណស៊ីជម្ពូផុតកំណត់** 01.11.2017 **អាចធ្វើប៉ាស្ព័របាន ដោយមិនចាំបាច់ចាប់លេខរៀង នៅថ្ងៃអាទិត្យនេះ**.!

http://pheaktraprak.com/archives By ភ័ក្ត្រា ប្រាក់ October 26, 2017

គណ:កម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាប្រកាសអនុញ្ញាតឲ្យពលករកម្ពុជា ដែលមានប័ណ្ណស៊ីជម្ពូផុតកំណត់ថ្ងៃទី.01.11.2017 ទៅធ្វើប៉ាស្ព័រត្រួតសញ្ជាតិបាន ដោយមិនចាំបាច់ចាប់លេខរៀង។ គណ:កម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាក្នុងប្រទេសថៃ បានចេញសេចក្តីប្រកាសជូនដំណឹងដល់បងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅធ្វើការក្នុងប្រទេសថៃ អោយបានជ្រៀបថា។ ដើម្បីជួយសម្រួលដល់បងប្អូនពលករកម្ពុជាដែលកាន់ប័ណ្ណស៊ីជម្ពូផុតកំណត់ថ្ងៃទី01.11.2017 ខាងមុខនេះ គណ:កម្មការផ្តល់ភាពស្របច្បាប់ បានអនុញ្ញាតឲ្យពលករកម្ពុជាមានប័ណ្ណស៊ីជម្ពូដូចខាងលើអាចចូលមកធ្វើប៉ាស្ព័រត្រួតសញ្ជាតិបានដោយមិនចាំបាច់មានលេខរៀងឡយ។ ដោយចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី27នេះតទៅ ហើយនៅថ្ងៃអាទិត្យខាងមុខនេះ គណ:កម្មការផ្តល់ភាពស្របច្បាប់កម្ពុជាបើកធ្វើប៉ាស្ព័រជូនបងប្អូនពលករកម្ពុជាក្នុងករណីពិសេស ចំពោះពលករមានប័ណ្ណស៊ីជម្ពូផុតកំណត់ថ្ងៃទី 01.11.2017 ។ អាស្រ័យហេតុនេះសូមបងប្អូនពលករកម្ពុជាទាំងអស់ដែលកំពុងកាន់ប័ណ្ណស៊ីជម្ពូដែលផុតកំណត់ថ្ងៃទី 01.11.2017 ប្រញាប់រួសរាន់មកធ្វើប៉ាស្ព័រត្រួតសញ្ជាតិអោយបានទាន់ពេល។

**ពលករខ្មែរ ធ្វើការនៅកូរ៉េម្នាក់ ស្លាប់បាត់បង់ជីវិតដោយសារគ្រោះថ្នាក់ចរាចរណ៍**

http://www.ariyothom-news.html ថ្ងៃទី 27 October 2017 ម៉ោង 4:37 am

ភ្នំពេញ៖ ពលករខ្មែរម្នាក់បានស្លាប់ហើយ (26.10.2016 នៅកូរ៉េ ) ខ្មែរយើងម្នាក់ឈ្មោះ ឈឹម សារិទ្ធ បានស្លាប់បាត់បង់ជីវិតនៅតំបន់043 ដោយគ្រោះថ្នាក់ចរាចរណ៍)កាលពីយប់មិញប្រហែលជាម៉ោង ១ រំលងអធ្រាត្រ ។ គាត់មានទីលំនៅ ភូមិត្រពាំងឈើទាល ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ៕

## ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧

## សម្តេចក្រឡាហោម ជំរុញឲ្យមន្ត្រីនៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ពង្រឹងការងារនិងទប់ស្កាត់ ពលករឆ្លងដែនខុសច្បាប់

http://www.rasmeinews.com/ October 30, 2017

(បន្ទាយមានជ័យ) ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជំរុញឲ្យសមត្ថកិច្ចជំនាញទាំងអស់នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រូវបិទច្រករបៀងទាំងអស់ និងទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ លើសពីនោះគឺទប់ស្កាត់ពលករលួចចូលកាប់ឈើក្រញូងក្នុងទឹកដីថៃ ព្រោះកន្លងមកនេះ មានពលករស្លាប់និងរបួសដោយសារតែកម្លាំងយោធាថៃបាញ់ក្នុង១ថ្ងៃមិនក្រោមពី១ទៅ២នាក់នោះទេ ដែលថ្ងៃខ្លះដល់រហូតដល់៥នាក់ក៏មានដែរ។ សម្តេចក្រឡាហោម ស ខេង អញ្ជើញក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អគារស្នាក់ការប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ ច្រកទ្វារអន្តរជាតិប៉ោយប៉ែតថ្មី ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នៅព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧នេះ។ សម្តេចក្រឡាហោម ស ខេង ជំរុញបែបនេះ ក្នុងឱកាសសម្តេចជាអធិបតីភាព ក្នុងពិធី បញ្ចុះបឋមសិលាសាងសង់អគារស្នាក់ការប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ ច្រកទ្វារអន្តរជាតិប៉ោយប៉ែតថ្មី ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នៅព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧នេះ។

ក្រៅពីលើកឡើងពីភាពរីកចម្រើននិងសុខសន្តិភាព ពេញលេញទូទាំងប្រទេស នោះ សម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថា ច្រកអន្តរជាតិប៉ោយប៉ែត គឺជាច្រកសេដ្ឋកិច្ចមួយដ៏សំខាន់នៅទិសពាយ័ព្យនៃប្រទេសកម្ពុជាដែលជាប់ព្រំដែនកម្ពុជា-ថៃហើយច្រកនេះសម្រាប់ដោះដូរទំនិញរវាងកម្ពុជា-ថៃ និងជាច្រកភ្ញៀវអន្តរជាតិឆ្លងកាត់ដែលចូលមកកម្ពុជាដ៏សំខាន់។ សម្តេចបានបញ្ជាក់ថា មន្ត្រីនគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតត្រូវបង្កើនការយកចិត្តទុកដាក់ការទំនាក់ទំនងជាមួយប្រទេសជិតខាងធ្វើយ៉ាងណា ឲ្យមានសហប្រតិបត្តិការគ្នាល្អដើម្បីបម្រើប្រជាពលរដ្ឋនិងប្រទេសជាតិស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដែលកំពុងអភិវឌ្ឍប្រទេសជាតិអោយមានការរីកចម្រើន។ សម្តេចក្រឡាហោម ក៏បានជំរុញដាស់តឿនឲ្យមន្ត្រីនគរបាលអន្តោប្រវេសន៍ ត្រូវគោរពនូវតួនាទីរបស់ខ្លួន ឲ្យបានខ្ជាប់ខ្ជួន ត្រូវបំពេញលិខិតស្នាមជូន ប្រជាពលរដ្ឋឲ្យលឿនឆាប់រហ័ស និងអ្វីពិសេសនោះ ត្រូវពង្រឹងកិច្ចសហការល្អជាមួយប្រទេសជិតខាង មិនថាច្រកទ្វារប៉ោយប៉ែតឡើយ ពង្រឹងនូវកិច្ចការការងារបង្ក្រាបទប់ស្កាត់រាល់បទល្មើសទាំងអស់នៅគ្រប់ច្រកទាំងអស់៕ដោយ:*វិបុល/sn*

## ពលរដ្ឋខ្មែរ ៤នាក់លួចឆ្លងដែនខុសច្បាប់ ទៅកាប់ឈើ ក្រញូងដីថៃ ត្រូវសមត្ថកិច្ចឃាត់ខ្លួន

http://cambodiapolice.com/blog/archives/ ម៉ោង 9:00 am 30 តុលា 2017

**ឧត្តរមានជ័យ** ៖ ប្រជាពលរដ្ឋខ្មែរ ៤នាក់ដែលលួចឆ្លងដែនចូលក្នុងទឹកដីថៃ ត្រូវបានកម្លាំងអធិការដ្ឋាននគរបាលស្រុក សហការជាមួយយោធា កងពលតូចអន្តរាគមន៍លេខ៨ ឃាត់ខ្លួនកាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង៣និង៣០នាទី។ សមត្ថកិច្ចបានឲ្យដឹងថាឲ្យដឹងថាពលរដ្ឋខ្មែរទាំង៤នាក់នោះរួមមានៈ ទី១-ឈ្មោះ អ៊ុន អ៊ីម ភេទប្រុស អាយុ ៣៥ឆ្នាំ នៅភូមិផ្អៀកជ្រុំ ឃុំអូរស្វាយ ស្រុកត្រពាំប្រាសាទ, ទី២-ឈ្មោះ វ៉ន វី ភេទប្រុស អាយុ ៣១ ឆ្នាំ, ទី៣-ឈ្មោះ មាស ជុំ ភេទប្រុស អាយុ ៤៨ឆ្នាំ, និងទី៤-ឈ្មោះ ហូ លីន ភេទប្រុស អាយុ ២៧ ឆ្នាំ អ្នកទាំង ៣ នៅភូមិពាមក្នុង ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ជាមួយគ្នា។

មូលហេតុ លួចឆ្លងដែនខុសច្បាប់ចូលកាប់ឈើក្រញូងក្នុងទឹកដីថៃ ត្រង់ចំណុច ទល់មុខប្រកតាថាវ ភូមិសាស្ត្រ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ជាប់និង ភូមិសាស្ត្រ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ក្នុងនោះផងដែរ សមត្ថកិច្ច បានដកហូតវត្ថុងតាងរួមមាន ពូថៅ២, ពិល២, និង សម្ភារៈ អង្រឹង មុង, ផ្លយមួយចំនួនទៀតផង។ បច្ចុប្បន្នលោកវរសេនីយ៍ទោ **អ៊ិន កាយ** អធិការនគរបាលស្រុក បានធ្វើការអប់រំ និង ចុះកិច្ចសន្យាឲ្យមេភូមិ មេឃុំ មកជានាយកទៅមូលដ្ឋានវិញ ៕ ដោយៈ ចាន់ ជី

## រដ្ឋមន្ត្រីក្រសួងការងារ ចុះសម្រួលផ្តល់ភាពស្របច្បាប់ ដល់ពលករខ្មែរ នៅថៃ

http://ann.com.kh/site/news/ ថ្ងៃចន្ទ, 30 ខែតុលា 2017 9:49 ព្រឹក

**រាជធានីភ្នំពេញ៖** ក្រុមមន្ត្រី ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ នឹងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីចុងសប្តាហ៍កន្លងទៅ បានធ្វើដំណើរទៅកាន់ប្រទេសថៃ ដើម្បីត្រួតពិនិត្យ និងកែសម្រួលនីតិវិធីមួយចំនួន ដើម្បីផ្តល់ភាពស្របច្បាប់ ជូនពលករខ្មែរ នៅទីនោះ។ យោងតាមទំព័រហ្វេសប៊ុក របស់ក្រសួងការងារបានឲ្យដឹងថា ឯកឧត្តម អ៊ិត សំហេង ដែលក៏ជាប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា បានអញ្ជើញពិនិត្យមើលដំណើរការផលិតលិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេសជូនពលករកម្ពុជា នៅការិយាល័យផ្តល់ភាពស្របច្បាប់នៅផ្សារ Big C Ladphrao ទីក្រុងបាងកកនៃប្រទេសថៃ។

នៅទីនោះឯកឧត្តម ក៏បានសាកសួរពលករដែលមកទទួលសេវា និងបានស្តាប់នូវសំនូមពរជាក់ស្តែង របស់បងប្អូនពលករ ដើម្បីលើកសំនូមពរនេះ ទៅភាគីថៃ និង កែសម្រួលនីតិវិធី ក៏ដូចជាយន្តការផ្តល់សេវា ជូនបងប្អូនឲ្យកាន់តែប្រសើរថែមទៀត។ ជារួមបងប្អូនពលករបានសម្តែងនូវក្តីរីករាយចំពោះរាជរដ្ឋាភិបាល ដែលបានសហការជាមួយភាគីថៃ ធ្វើយុទ្ធនាការផ្តល់ភាពស្របច្បាប់ និងបញ្ជូនក្រុមការងារចល័តមកផលិតឯកសារដល់បងប្អូនពលករដោយផ្ទាល់នៅប្រទេសថៃ ដែលបានផ្តល់នូវភាពងាយស្រួល និងចំណេញពេលវេលា និងថវិកាយ៉ាងច្រើនដល់ពលករ។ បើតាមឯកឧត្តមរដ្ឋមន្ត្រីថា នេះគឺជាជំហាន និងជាជោគជ័យថ្មីមួយទៀត សម្រាប់ការជួយផ្តល់ភាពស្របច្បាប់ដល់បងប្អូនពលករ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា៕

## រដ្ឋមន្ត្រីក្រសួងការងារ ជំរុញក្រុមការងារ ផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជានៅថៃ

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, ៣០ តុលា ២០១៧ 12:08 ដោយ: សុទីម៉ា ID:014

ភ្នំពេញ៖រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង បានជំរុញឲ្យក្រុមការងារ របស់គណៈកម្មការផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ត្រូវខិតខំបង្កើនផលិតភាពការងារ ជូនពលករខ្មែរបន្ថែមទៀត ដើម្បីពួកគាត់ឆាប់ទទួលបាន ផ្តល់ភាពស្របច្បាប់។

ក្នុងឱកាសជួបប្រជុំ និងត្រួតពិនិត្យការងារ របស់គណៈកម្មការផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជាកំពុងស្នាក់នៅ និងធ្វើការនៅថៃ នារសៀលថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៧ នៅស្ថានទូតកម្ពុជា ប្រចាំនៅទីក្រុងបាងកក លោក អ៊ិត សំហេង បានថ្លែងថា ត្រូវបង្កើនផ្តល់សេវាជូនពលករ ដែលបានមកបើកផ្តល់លិខិតឆ្លងដែន លិខិតធ្វើដំណើរ (TD) និងប័ណ្ណពលករកម្ពុជា ទៅធ្វើការនៅបរទេស (OCWC) និងពលករដែលមកស្នើសុំ បញ្ជាក់អត្តសញ្ញាណ ពីក្រុមការងារអន្តរក្រសួងចល័តទាំង៣ ការិយាល័យ នៅទីក្រុងបាងកក ខេត្តរ៉ាក់យ៉ង និងខេត្តសុងក្លា ឲ្យបានកាន់តែល្អប្រសើរថែមទៀត។

លោករដ្ឋមន្ត្រី ក៏បានលើកទឹកចិត្ត ដល់មន្ត្រីមក ពីគ្រប់ស្ថាប័នពាក់ព័ន្ធ ដែលបានខិតខំបំពេញការងារ ជាពិសេសក្នុងយុទ្ធនាការ បញ្ជាក់អត្តសញ្ញាណដល់ពលករកម្ពុជា ដែលទើបនឹងចាប់ផ្តើម នាពេលថ្មីៗ ប្រកបដោយស្មារតីទទួលខុសត្រូវ។ លោកថា នេះគឺជាជំហាន និងជាជោគជ័យថ្មីមួយទៀត សម្រាប់ការជួយផ្តល់ភាពស្របច្បាប់ ដល់ពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅថៃ ស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា។

សូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងការងារ បានបង្កើតក្រុមការងារអន្តរក្រសួងចល័ត ដែលមាន៣ការិយាល័យ នៅទីក្រុងបាងកក ខេត្តរ៉ាក់យ៉ង និងខេត្តសុងក្លា៕

## រដ្ឋមន្ត្រីក្រសួងការងារ អញ្ជើញពិនិត្យមើល ដំណើរការ ផលិតលិខិតធ្វើដំណើរ និងប័ណ្ណពលករ ជូនពលករកម្ពុជា នៅប្រទេសថៃ

https://www.dap-news.com/kh/ សៅរ៍, ២៨ តុលា ២០១៧ 17:06 ដោយ: ដើមអម្ពិល ID:013

ភ្នំពេញ៖ លោក បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការ ផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា កំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នៅរសៀលថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៧នេះ បានអញ្ជើញពិនិត្យមើលដំណើរការ ផលិតលិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជា ទៅធ្វើការនៅបរទេស ជូនពលករកម្ពុជា នៅការិយាល័យផ្តល់ភាពស្របច្បាប់ នៅផ្សារ Big C Ladphrao ទីក្រុងបាងកក នៃប្រទេសថៃ។

ក្នុងដំណើរចុះពិនិត្យនេះលោករដ្ឋមន្ត្រីបានសាកសួរពលករ ដែលមកទទួលសេវា និងបានស្តាប់នូវសំណូមពរជាក់ស្តែង របស់បងប្អូនពលករ ដើម្បីលើកសំនូមពរនេះ ទៅភាគីថៃ និង កែសម្រួលនីតិវិធី ក៏ដូចជាយន្តការផ្តល់សេវា ជូនបងប្អូន ឲ្យកាន់តែប្រសើរថែមទៀត។ ជារួម បងប្អូនពលករ បានសម្តែងនូវក្តីរីករាយ ចំពោះរាជរដ្ឋាភិបាល ដែលបានសហការជាមួយភាគីថៃ ធ្វើយុទ្ធនាការផ្តល់ភាពស្របច្បាប់ និងបញ្ជូនក្រុមការងារចល័ត មកផលិតឯកសារដល់បងប្អូនពលករ ដោយផ្ទាល់ នៅប្រទេសថៃ ដែលបានផ្តល់នូវភាពងាយស្រួល និងចំណេញពេលវេលា និងថវិកាយ៉ាងច្រើនដល់ពលករ។ ក្នុងឱកាសនោះ លោករដ្ឋមន្ត្រី ក៏បានផ្តល់ការលើកទឹកចិត្ត និងថ្លែងអំណរគុណដល់មន្ត្រីមកពីគ្រប់ស្ថាប័នទាំងអស់ ដែលបានខិតខំបំពេញការងារ យុទ្ធនាការនេះ កបដោយស្មារតីទទួលខុសត្រូវ៕

**តម្រួតខេត្តស្រះកែវ ចាប់ប៉ាស្ព័រMOUចំនួន 69ក្បាល ខណៈពេលនាំចូលតាមច្រកព្រំដែន**

http://pheaktraprak.com/archives By ប្រាក់ ភក្រ្តា October 30, 2017

កាលពីថ្ងៃទី28 ខែតុលា ឆ្នាំ2017 កម្លាំងសមត្ថកិច្ចថៃប្រចាំច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតខាងផ្សារលុងគឿរ ស្រុកអារញ្ញ ខេត្តស្រះកែវ បានធ្វើការឃាត់ខ្លួនបុរសជនជាតិខ្មែរម្នាក់ បន្ទាប់ពីឆែកឆេររកឃើញប៉ាស្ព័រ MOU សញ្ជាតិខ្មែរ ចំនួន 69ក្បាល នៅវ៉ាលីត្រៀមយកទៅប្រគល់ជូនពលករនៅឯខេត្តសាមុតប្រាកាន។ នៅវេលាបន្តបន្ទាប់កម្លាំងទាហានឈុតខ្មៅថៃចាប់បានចាប់ខ្លួនពលករខ្មែរចំនួនជិត20នាក់ នៅត្រង់ចំណុចមុខហាង 7-11 ផ្សារលុងក្លឿរ ។ តាមការសាកសួររបស់សមត្ថកិច្ចថៃ បានឲ្យដឹង ពលករខ្មែរទាំងអស់ធ្វើដំណើរមកពីខេត្តសាមុតប្រាកាន និងណាខនប៉ាធុម បន្ទាប់ពីទទួលដំណឹងពីថៅកែ អោយមកទទួលប៉ាស្ព័រMOUនៅត្រង់ចំណុចណាត់ជួបមុខហាង 7-11 ផ្សារលុងក្លឿរ។

**អាកាសធាតុក្តៅ ធ្វើឲ្យពលករខ្មែរម្នាក់ដួលសន្លប់ ខណៈពេលកំពុងរង់ចាំចូលធ្វើប៉ាស្ព័រ**

http://pheaktraprak.com/archives By ប្រាក់ ភក្រ្តា October 30, 2017

ពលករខ្មែរម្នាក់ទៀតហើយបានបានដួលសន្លប់ខណៈកំពុងឈរតម្រង់ជួរចាំចូលត្រួតសញ្ជាតិធ្វើប៉ាស្ព័រនៅទីតាំងខេត្តរ៉ាក់យ៉ង ប្រទេសថៃ។ ហេតុការណ៍នេះបានកើតឡើងកាលពីថ្ងៃអាទិត្យទី29 ខែតុលា ឆ្នាំ2017 បន្ទាប់ពីមានករណីបុរសខ្មែរវ័យ40 ឆ្នាំរបានសន្លប់ ខណៈពេលដែលរូបគាត់កំពុងឈរតម្រង់ជួរចាំចូលថតប៉ាស្ព័រ។

យោងតាមប្រភពព័ត៌មានពីបងប្អូនពលករខ្មែរដែលកំពុងរង់ចាំធ្វើប៉ាស្ព័រនៅក្នុងទីតាំងត្រួតសញ្ជាតិខេត្តរ៉ាក់យ៉ងខាងលើបានអោយបានដឹងថា ពលករខ្មែរដែលដួលសន្លប់នៅកន្លែងធ្វើប៉ាស្ព័រនោះ ជាមនុស្សប្រុស អាយុប្រហែល 40ឆ្នាំ បានសន្លប់បាត់ស្មារតីខណៈពេលកំពុងឈរតម្រង់ជួរ។ តាមការបញ្ជាក់របស់ពលករដដែលបន្តទៀតថា មូលហេតុដែលបណ្តាលមានពលករខ្មែរដួលសន្លប់បែបនេះ គឺបណ្តាលមកពីអាកាសធាតុក្តៅខ្លាំងពេកបូករួមទាំងមានមនុស្សតម្រង់ជួរច្រើនផងនោះ ទើបធ្វើអោយមានមនុស្សកើតខ្យលដួលសន្លប់តែម្តង។ ពលករខ្មែរដែលដួលសន្លប់រូបនោះ ត្រូវបានភ្នាក់ងារសង្គ្រោះថៃបញ្ជូនយកទៅព្យាបាលនៅមន្ទីរពេទ្យខេត្តរ៉ាក់យ៉ង។

**ច្បាប់ស្តីពីការគ្រប់គ្រងការធ្វើការរបស់ពលករបរទេសឆ្នាំ 2017 បន្ថែមទោសឱ្យមានកំរិតកាន់តែធ្ងន់**

http://pheaktraprak.com/archives By ប្រាក់ ភក្រ្តា October 29, 2017

នេះជាច្បាប់គ្រប់គ្រងការធ្វើការរបស់ពលករបរទេសឆ្នាំ2017 ក្នុងប្រទេសថៃ ដែលនិងប្រកាសអោយអនុវត្តច្បាប់នេះ នៅថ្ងៃច័ន្ទទី01 ខែមករា ឆ្នាំ2018 ខាងមុខនេះ។ បន្ថែមទោសឱ្យមានកំរិតកាន់តែធ្ងន់៖

1-បុគ្គលទាំងឡាយណាដែលទទួលពលករបរទេសមកក្នុងប្រភេទការងារ ដែលហាមមិនអោយពលករបរទេសធ្វើ ឬទទួលពលករបរទេសមកធ្វើ ដោយមានប័ណ្ណអនុញ្ញាតការងារ ឬទទួលពលករបរទេសដែលមិនមានប័ណ្ណអនុញ្ញាតសម្រាប់ធ្វើការជាមួយខ្លួន ត្រូវមានទោសពិន័យជាប្រាក់តាំងតែ 400,000 បាតដល់ 800,000 បាតក្នុងការជួយពលករម្នាក់។

2-បុគ្គលទាំងឡាយណា ដែលឱ្យពលករពលករបរទេសធ្វើ ដោយមិនត្រឹមត្រូវទៅនឹងប្រភេទការងារនៅក្នុងប័ណ្ណអនុញ្ញាតការងារ ត្រូវមានទោសពិន័យជាប្រាក់មិនលើសពី 400,00 បាត ក្នុងពលករម្នាក់។

3-ពលករបរទេសដែលធ្វើការដោយមិនមានការអនុញ្ញាត ឬធ្វើការក្នុងប្រភេទការងារដែលហាមឃាត់មិនឱ្យពលករបរទេសធ្វើ ត្រូវមានទោសជាប់ឃុំមិនលើសពី 5ឆ្នាំ ឬពិន័យជាប្រាក់តាំងតែពី 2000 បាតដល់ 100,000 បាត ឬទាំងជាប់ទាំងពិន័យ។

4-ពលករបរទេសធ្វើការចាំបាច់ ឬបន្ទាន់ ដោយមិនបានជូនដំណឹងដល់មកអាជ្ញាធរ ត្រូវមានទោសពិន័យជាប្រាក់តាំងតែពី 2000 បាតដល់ 100,000 បាត។

5-ពលករបរទេសដែលធ្វើការមិនត្រឹមត្រូវទៅនឹងប្រភេទការងារនៅក្នុងប័ណ្ណអនុញ្ញាតការងារ ត្រូវមានទោសពិន័យជាប្រាក់មិនលើសពី 100,000 បាត។

6-បុគ្គលទាំងឡាយណាដកហូតប័ណ្ណអនុញ្ញាតការងារ ឬឯកសារប្រចាំខ្លួនរបស់ពលករ ត្រូវមានទោសជាប់ឃុំមិនលើសពី6ខែ ឬពិន័យជាប្រាក់មិនលើសពី 100,000 បាត ឬទាំងឃុំទាំងពិន័យ។

7-បុគ្គលទាំងឡាយណាដែលបោកប្រាស់អ្នកដ៏ទៃ ថាអាចនាំពលករបរទេសមកធ្វើការជាមួយនិយោជកនៅក្នុងប្រទេសថៃបាន ត្រូវមានទោសជាប់ឃុំតាំងតែពី3ឆ្នាំដល់10ឆ្នាំ ឬពិន័យជាប្រាក់តាំងតែពី 600,000 បាតដល់ 1000,000 បាតក្នុងពលករម្នាក់ ឬទាំងឃុំទាំងពិន័យ។

8-បុគ្គលទាំងឡាយណាដែលប្រកបអាជីវកម្មនាំពលករបរទេសមកធ្វើការ ដោយមិនមានការអនុញ្ញាតពីអគ្គនាយកដ្ឋានការងារ ត្រូវមានទោសជាប់ឃុំពី3ឆ្នាំដល់10ឆ្នាំ ឬពិន័យជាប្រាក់តាំងតែពី 200,000 បាតដល់ 600,000 បាត ឬទាំងឃុំទាំងពិន័យ។

**ឱកាសចុងក្រោយ ចំពោះពលករដែលមានប័ណ្ណស៊ីជម្ពូ ផុតកំណត់ខែ11ខាងមុខនេះ**

http://pheaktraprak.com/archives By ប្រាក់ ភក្រ្តា October 28, 2017

នៅថ្ងៃអាទិត្យទី 29 ខាងមុខនេះគណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាក្នុងប្រទេសថៃ បានត្រួតអត្តសញ្ញាណជូនបងប្អូនពលករកម្ពុជា ក្នុងថ្ងៃពិសេសចំពោះពលករដែលមានប័ណ្ណស៊ីជម្ពូផុតកំណត់នៅថ្ងៃទី 01.11.2017 ខាងមុខនេះ ដើម្បីជួយសម្រួលដល់បងប្អូនពលករខ្មែរយើង។ ក្នុងការបើកធ្វើប៉ាស្ព័រជូនបងប្អូនពលករកម្ពុជានៅថ្ងៃអាទិត្យខាងមុខនេះ ដោយមិនចាំបាច់ទទួលលេខរៀងឡើយគ្រាន់បងប្អូនរៀបចំឯសារអោយបានត្រឹមត្រូវប៉ុណ្ណោះគឺអាចចូលថតប៉ាស្ព័របាភ្លាម។ បញ្ជាក់÷ការធ្វើប៉ាស្ព័រជូនបងប្អូនពលករកម្ពុជានៅថ្ងៃអាទិត្យនេះ គឺចំពោះពលករដែលមានប័ណ្ណស៊ីជម្ពូផុតកំណត់ថ្ងៃទី 01.11.2017 ប៉ុណ្ណោះ។ ចំពោះបងប្អូនពលករកម្ពុជាដែលលិខិតបញ្ជាក់ពីក្រសួងការងារថៃ និង មានប័ណ្ណស៊ីជម្ពូផុតកំណត់ 31.12.2017 គឺទទួលលេខរៀងធម្មត្តា។

**ចាប់ផាក 1នាក់ 1 សែនបាត ករណីធ្វើខុសលក្ខខ័ណ្ឌ**

http://pheaktraprak.com/archives By ប្រាក់ ភក្រ្តា October 27, 2017

ចំពោះករណីបងប្អូនពលករបរទេសដែលមានច្បាប់អនុញ្ញាតធ្វើការនៅក្នុងប្រទេសថៃយ៉ាងត្រឹមត្រូវហើយ។ ប៉ុន្តែក្នុងករណីបងប្អូនធ្វើការខុសលក្ខខ័ណ្ឌនៃច្បាប់អនុញ្ញាតការងារ ដែលបានកំណត់នៅក្នុងប័ណ្ណអនុញ្ញាតការងាររបស់បងប្អូននោះគឺខុសច្បាប់ អាចនិងត្រូវសមត្ថកិច្ចចាប់ផាកពិន័យជាប្រាក់មិនលើសពី 100,000฿ (មួយសែនបាត) ក្នុងមនុស្សម្នាក់។ ច្បាប់នេះចែងទុកនៅក្នុងមាត្រាច្បាប់ការងារចំនួន 39អាជីព ដែលមិនអនុញ្ញាតឲ្យពលករបរទេសធ្វើ។

**ពលរដ្ឋខ្មែរ៧នាក់បានលួចឆ្លងដែនខុសច្បាប់ ទៅកាប់ឈើប្រណិតត្រូវបានកម្លាំងយោធាថៃចាប់បាន បញ្ជូនទៅកាន់តុលាការថៃ**

http://freshnewsasia.com/index.php/en/localnews/ 2017-10-27

**(ប៉ៃលិន)៖** នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧នេះ ភាគីថៃបានផ្តល់ព័ត៌មានថា ខាងទាហានថៃ បានចាប់ឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរ ក្នុងករណីលួចឆ្លងដែនអាឈើខុសច្បាប់ នៅក្នុងទឹកដីថៃ ចន្លោះបង្គោលសីមាលេខ៦៧ និង៦៨ ស្ថិតក្នុងភូមិសាស្រ្តភូមិបរហ៊ុយត្បូង សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន ខេត្តប៉ៃលិន ហើយក៏បានទំនាក់ទំនង និងធ្វើរូបភាពជនសង្ស័យមកឲ្យភាគីខ្មែរ ដែលមានគ្នាចំនួន០៧នាក់។ នេះបើយោងតាមការឲ្យដឹង ពីមន្រ្តីឈរជើងតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ថា ពលរដ្ឋកម្ពុជាបានឆ្លងដែនខុសច្បាប់ ដើម្បីចូលទៅលួចកាប់ឈើប្រណិត ក្នុងភូមិសាស្រ្តប្រទេសថៃ។

សមត្ថកិច្ចបន្តថា ពលរដ្ឋទាំង៧នាក់៖ ទី១៖ឈ្មោះ ខ្លឹម ចិត្រ ភេទប្រុស អាយុ៤៣ឆ្នាំរស់នៅ ភូមិបរតាំងស៊ូ សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន, ទី២៖ឈ្មោះ ហ៊ិន សុខសាន្ត ភេទប្រុស អាយុ៣៤ឆ្នាំ រស់នៅភូមិបរតាំងស៊ូ សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន, ទី៣៖ឈ្មោះ យ៉ាប់ ជា ភេទប្រុស អាយុ៣២ឆ្នាំ រស់នៅភូមិបរតាំងស៊ូ សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន, ទី៤៖ឈ្មោះ អឹម ភីន ភេទប្រុស អាយុ២៥ឆ្នាំ រស់នៅភូមិបរតាំងស៊ូ សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន, ទី៥៖ឈ្មោះ ទិត រិន ភេទប្រុស អាយុ២៤ឆ្នាំ រស់នៅភូមិបរហ៊ុយត្បូង សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន, ទី៦៖ឈ្មោះ រ៉ុន ភេទប្រុស អាយុ៤៥ឆ្នាំ រស់នៅភូមិបរហ៊ុយជើង សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន និងទី៧៖ឈ្មោះ សិទ្ធ ភេទប្រុស អាយុ២៥ឆ្នាំ រស់នៅភូមិបរហ៊ុយជើង សង្កាត់បរយ៉ាខា ក្រុងប៉ៃលិន។ បច្ចុប្បន្នជនសង្ស័យទាំង៧នាក់ ត្រូវបានទាហានថៃបានបញ្ជូនទៅ ស្រុកពោងណាំរ៉ន ខេត្តចាន់បូរី ប្រទេសថៃ ជនសង្ស័យទាំងអស់កម្លាំងនគរបាលកម្ពុជាបានធ្លាប់ធ្វើការហាមឃាត់ និងអប់រំមិនឲ្យទៅអាឈើខុសច្បាប់នៅក្នុងទឹកដីថៃម្តងរួចមកហើយ។

លោកឧត្តមសេនីយ៍ទោ ពេជ្រ វណ្ណា ប្រធានការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ បានថ្លែងថា សូមឲ្យប្រជាពលរដ្ឋដែលមានគោលបំណង លួចឆ្លងដែនទៅកាប់ឈើក្នុងទឹកដីបន្តទៀត ព្រោះនៅប្រទេសគេមានច្បាប់មានកម្លាំងប្រដាប់អាវុធការពារឈើព្រៃ នេះសំណាងណាស់កម្លាំងយោធាថៃ មិនបានធ្វើបាញ់ប្រហាអាយុជីវិតដូច្នេះហើយសូមឲ្យប្រជាពលរដ្ឋត្រូវឈប់ចាញ់បោកក្រុមមេខ្យល់ញុះញង់បន្តទៀតអី ត្រូវចេញស្រលាញ់អាយុជីវិតខ្លួនឯង ជាពិសេសក្រុមគ្រួសាររបស់ខ្លួន៕

## ជនន្ដោប្រវេសន៍វៀតណាមខុសច្បាប់១០នាក់ ត្រូវបានរកឃើញលាក់ខ្លួនក្នុងរថយន្តដឹកទំនិញមួយនៅព្រំដែនបារាំង-អង់គ្លេស

http://www.rasmeinews.com/ October 30, 2017

ជនន្តោប្រវេសន៍វៀតណាមខុសច្បាប់ចំនួន១០នាក់ ត្រូវបានរកឃើញលាក់ខ្លួននៅផ្នែកខាងក្រោយនៃរថយន្តដឹកទំនិញមួយនៅកន្លែងត្រួតពិនិត្យផ្លូវធំព្រំដែន បន្ទាប់ពីរថយន្តធំនេះ បានឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យព្រំដែនចំនួន២។ ក្រុមជនន្តោប្រវេសន៍វៀតណាមនេះ ត្រូវបានរកឃើញលាក់ខ្លួនក្នុងកន្លែងតូចចង្អៀតដោយមានឡាំងដាក់ទំនិញជាច្រើននៅផ្នែកខាងក្រោយនៃយន្តធំ HGVនេះ បន្ទាប់ពីអ្នកបើករថយន្តនេះ បានឈប់រថយន្តដើម្បីឈប់សម្រាកបន្តិច ហើយបានឮសំឡេងសូរក្តូងក្តាំងចេញពីផ្នែកខាងក្រោយនៃរថយន្តនោះ។ អ្នកបើករថយន្តនេះមានការភ្ញាក់ផ្អើលជាខ្លាំង។ បុរស១០នាក់ ត្រូវបានទាញចេញពីផ្នែកក្រោយនៃរថយន្តនោះ ទោះបីជាគាត់បានធ្វើការពិនិត្យមើលច្បាស់អស់ហើយក្តី នៅពេលដែលមានមនុស្សលាក់ខ្លួន ត្រូវបានរកឃើញក្នុងអំឡុងពេលមានការពិនិត្យមើល នៅពេលមុននេះ នៅប្រទេសបារាំង។

លោកប៉េត្រូ អ្នកបើករថយន្តនេះ បានហៅប៉ូលិសភ្លាមៗដែលបានមកធ្វើការស៊ើបអង្កេត។ វីដេអូដែលថតបានកាលពីថ្ងៃសុក្រនៅទីក្រុងប៊ីខុនស្វៀល (Beaconsfield) ប្រទេសអង់គ្លេស បានបង្ហាញបុរសវៀតណាមទាំងនេះលាក់ខ្លួនតាមប្រឡោះតូចៗនៅផ្នែកខាងលើនៃឡាំងធំៗដាក់ទំនិញក្នុងរថយន្តនោះ ។ ប៉ូលិសបានចាប់ឃាត់ខ្លួនពួកគេ។ អ្នកបើករថយន្តនេះ បាននិយាយថា "ខ្ញុំបើករថយន្តពីប្រទេសអាល្លឺម៉ង់ជាមួយនឹងទំនិញទាំងនេះ នៅពេលខ្ញុំបើកទៅកាន់ទីក្រុងកាឡាអ៊ីស ប្រទេសបារាំងនោះ ខ្ញុំមានអារម្មណ៍ថាវាដូចមានសំឡេងអ្វីមួយនៅផ្នែកខាងក្រោយនៃរថយន្ត។ មានការត្រួតពិនិត្យដោយមន្ត្រីប៉ូលិសនៅតាមផ្លូវឆ្លងកាត់ព្រំដែននៅខាងទឹកដីបារាំង ហើយ ខ្ញុំបានទៅដល់ទឹកដីខាងអង់គ្លេស"៕ ដោយ៖ សុខា

## ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧

## សម្តេចក្រឡាហោមស ខេងឧបនាយករដ្ឋមន្ត្រីប្រកាសឲ្យមន្ត្រីបិទច្រករបៀងនៅតាមបន្ទាត់ព្រំដែន បើនៅតែបើកទៀតនោះ មានតែនគរបាលការពារព្រំដែន និងទាហាន

http://nokorwatnews.com/ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៧

ប៉ោយប៉ែត: សម្តេចក្រឡាហោម ស ខេងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានប្រកាសឲ្យមន្ត្រីបិទច្រករបៀងនៅតាមបន្ទាត់ព្រំដែន បើនៅតែបើក មានតែនគរបាលការពារព្រំដែនគោក និងទាហានតែប៉ុណ្ណោះ ។ ការមានប្រសាសន៍បែបនេះ នៅក្នុងពិធីបញ្ចុះបឋមសិលាសាងសង់ស្នាក់ការប៉ុស្តិ៍នគរបាល ច្រកទ្វារអន្តជាតិប៉ោយប៉ែត មានកម្ពស់បីជាន់ ដែលមានសមាជិក សមាជិកា មន្ត្រីក្រោមឱវាទគ្រប់ស្ថាប័ន ប្រជាពលរដ្ឋប្រមាណ៣០០០នាក់ កាលពីព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ នៅចំណុចច្រកទ្វារអន្តជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

សម្តេចក្រឡាហោម ស ខេងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានប្រសាសន៍បញ្ជាក់បន្ថែម: ច្រករបៀងគឺជាច្រកលួចលាក់ អត់មានសមត្ថកិច្ចដើម្បីយាមការពារនៅទីតាំងនោះឡើយ។ ដោយមិនដូចនៅកន្លែងច្រកទ្វារអន្តជាតិនោះទេ ព្រោះច្រកទ្វារមានកម្លាំងសមត្ថកិច្ចគ្រប់ស្ថាប័ននៅចាំត្រួតពិនិត្យ។ តែនៅពេលនេះ រាជរដ្ឋាភិបាលបានកសាងច្រកទ្វារអន្តជាតិជាច្រើនរួមទាំងច្រកទេ្វភាគី តើយើងចាំបាច់អ្វីនៅតែទុកច្រករបៀងនេះ ហើយអ្នកទទួលខុសត្រូវចំពោះច្រករបៀងនោះ មានតែពីរស្ថាប័នប៉ុណ្ណោះ គឺនគរបាលការពារព្រំដែន និងទាហាន ព្រោះពីរស្ថាប័ននេះ ជាអ្នកគ្រប់គ្រងព្រំដែន។

ជាគោលការណ៍ ឲ្យសមត្ថកិច្ចទាំងអស់ថ្នាក់ក្រោមជាតិត្រូវតែបិទច្រករបៀង ព្រោះបើមិនបិទច្រករបៀងនោះទេ ភ្ញៀវចេញ ចូលតាមច្រករបៀងនោះ ម្យ៉ាងទៀតការជួញដូរមនុស្សរត់ពន្ធគ្រប់ប្រភេទ ក៏ទៅតាមច្រករបៀងនោះដែរ ហើយធ្វើច្រកទ្វារអន្តរជាតិ និងច្រកទេ្វភាគីបានន័យអ្វី ។ នេះហើយជាបញ្ហា បើច្រករបៀងនៅតែមាន គឺមានតែស្ថាប័នពីរយោធា និងនគរបាលការពារព្រំដែនគោក ។ ដូច្នេះសូមឲ្យមេបញ្ជាការយោធា និងមេបញ្ជាការនគរបាល រួមជាមួយអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសគ្រប់ខេត្ត ស្រុកដើម្បីបិទច្រករបៀងនេះ ងាយស្រួលក្រុមការងារបង្រ្កាប រួមទាំងទប់ស្កាត់បទល្មើសផ្សេងៗ ដែលយកច្រករបៀងនេះមកប្រើប្រាស់។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏មានប្រសាសន៍ទាក់ទិនទៅនឹងប្រជាពលរដ្ឋខ្មែរចូលទៅប្រទេសថៃកាប់ឈើគ្រញូងនៅក្នុងប្រទេសថៃ ដែលពីមុន ១ថ្ងៃយ៉ាងតិចស្លាប់២នាក់ មានពេលខ្លះរហូតដល់ទៅ៥នាក់ នេះដោយសារតែភាគីថៃអនុវត្តច្បាប់របស់គេរឿងបរិស្ថាននិងព្រៃឈើប្រហារជីវិត ប៉ុន្តែរយៈពេលពីរឆ្នាំកន្លងមកនេះ គឺនៅមិនទាន់ឡើយ៕ វណ្ណា

## រាជរដ្ឋាភិបាលបញ្ជូនមន្ត្រីជិត ៤០០នាក់ទៅកាន់ប្រទេសថៃ ដើម្បីធ្វើយុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់ពលករខ្មែរនៅទីនោះ

http://www.freshnewsasia.com/index.php/en/localnews/ 2017-10-31

**(ភ្នំពេញ)៖** លោក ហេងសួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានថ្លែងឲ្យដឹងថា រាជរដ្ឋាភិបាលបានបញ្ជូនមន្ត្រីជិត ៤០០នាក់ទៅកាន់ ប្រទេសថៃ ដើម្បីធ្វើយុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់ពលករខ្មែរនៅទីនោះ ហើយមន្ត្រីដែលចូលរួមយុទ្ធនាការនេះត្រូវធ្វើការយ៉ាងតិច៩ម៉ោង ក្នុង១ថ្ងៃ និងធ្វើការ៦ថ្ងៃ ក្នុង១សប្តាហ៍។ ក្រៅពីការបញ្ជូនមន្ត្រី ថ្នាក់ដឹកនាំ នៃគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករខ្មែរនៅថៃ ក៏បានខិតខំ

ឆ្លៀតពេលវេលាដ៏មមារញឹកចុះដឹកនាំប្រជុំ ត្រួតពិនិត្យ និងកែសម្រួលការងារជាបន្តបន្ទាប់ទៅតាមសំណូមពរជាក់ស្តែងរបស់បងប្អូនពលករផង និងរបស់ភាគីថៃផង។

ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងនេះគិតត្រឹមថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៧កន្លងទៅនេះ គណៈកម្មការបានបើក ផ្តល់លិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជា ដល់បងប្អូនពលករបានចំនួនជាង១០ម៉ឺននាក់ ដើម្បីបងប្អូនយកទៅបន្តនីតិវិធីទទួលបានភាពស្របច្បាប់ពីភាគីថៃ។ ទន្ទឹមនឹងនេះគណៈកម្មការ ក៏បានធ្វើការបញ្ជាក់អត្តសញ្ញាណ ផលិត និងបើកផ្តល់ លិខិតធ្វើដំណើ និងប័ណ្ណពលករកម្ពុជា ក្នុងថ្ងៃតែ១តែម្តង ដល់បងប្អូនពលករ ដែលបានចុះបញ្ជីជាមួយភាគីថៃ នាអំឡុងខែសីហា និងខែកញ្ញា ឆ្នាំ២០១៧កន្លងទៅនេះបានចំនួន១.២០០នាក់ ក្នុង១ថ្ងៃផងដែរ។ គណៈកម្មការបានស្នើសុំការសហការបន្ថែមជាមួយភាគីថៃ ឱ្យបង្កើនចំនួនការចេញលេខរៀងណាត់ជួបឱ្យកើនដល់ ១.៤០០នាក់ ក្នុង១ថ្ងៃ ចាប់ពីថ្ងៃទី១ ខែវិច្ឆិការ ឆ្នាំ២០១៧នេះ តទៅ។

លោក ហេង សួរ បានគូសបញ្ជាក់បន្ថែមថា ពលករកម្ពុជា ដែលមកទទួលសេវាពីមន្ត្រីផ្តល់ភាពស្របច្បាប់គឺមានសេចក្តីរីករាយចំពោះកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រី ជាពិសេសបានសម្តែងនូវការអរគុណយ៉ាងជ្រាលជ្រៅដល់សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានគិតគូរសុខទុក្ខរបស់បងប្អូននៅទីនេះ ដោយរៀបចំឲ្យមានយុទ្ធនាការនេះ និងបញ្ជូនមន្ត្រីមកផ្តល់សេវាដល់ប្រទេសថៃតែម្តង ដែលធ្វើឲ្យបងប្អូនចំនេញទាំងពេលវេលា សន្សំបានថវិកា និងជានានិរន្តរភាពការងារ ក៏ដូចជាចំណូលលរបស់ខ្លួន។ រីឯភាគីថៃក៏បានកោតសរសើរ ដល់មន្ត្រីរបស់យើង ដែលខិតខំធ្វើការក្នុង១ថ្ងៃ លើស ៩ម៉ោង និងធ្វើការរហូតដល់ទៅ ៦ថ្ងៃ ក្នុង១អាទិត្យផងដែរ។

សូមបញ្ជាក់ថា ក្រៅពីការផ្តល់សេវាជូនពលករ សម្តេចតេជោ ហ៊ុន សែន ក៏បានចាត់ឲ្យមានក្រុមការងារថ្នាក់ជាតិចំនួន ៥ក្រុម ចុះសួរសុខទុក្ខបងប្អូនពលករ នៅក្នុងប្រទេសថៃ ជារៀងរាល់ខែផងដែរ៕

## ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងាររបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ

https://www.mlvt.gov.kh/index.php/km/ ច័ន្ទ, 30 តុលា 2017 10:00 Written by MLVT

នារសៀលថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៧នេះ នៅស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជានៅទីក្រុងបាងកក ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងាររបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ។

ក្នុងកិច្ចប្រជុំនាឱកាសនោះ ឯកឧត្តមបណ្ឌិត ប្រធានគណៈកម្មការ បានទទួលដោះស្រាយនូវសំណូមពរ និងជំរុញក្រុមការងារទាំងអស់ត្រូវបង្កើនការផ្តល់សេវាជូនបងប្អូនពលករដែលបានមកបើកផ្តល់លិខិតឆ្លងដែន/លិខិតធ្វើដំណើរ (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) និងបងប្អូនដែលមកស្នើសុំបញ្ជាក់អត្តសញ្ញាណពីក្រុមការងារអន្តរក្រសួងចល័តទាំងបីការិយាល័យ នៅទីក្រុងបាងកក ខេត្តរ៉ាក់យ៉ង និងខេត្តសុងក្លាឱ្យបានកាន់តែល្អប្រសើរថែមទៀត។

ឯកឧត្តមរដ្ឋមន្ត្រី ក៏បានផ្តល់ការលើកទឹកចិត្ត និងថ្លែងអំណរគុណដល់មន្ត្រីមកពីគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ដែលកន្លងមកបានខិតខំបំពេញការងារ ជាពិសេសក្នុងយុទ្ធនាការបញ្ជាក់អត្តសញ្ញាណជូនបងប្អូនពលករកម្ពុជាដែលទើបនឹងចាប់ផ្តើមនាពេលថ្មីៗនេះ ប្រកបដោយស្មារតីទទួលខុសត្រូវ។ នេះគឺជាជំហាន និងជាជោគជ័យថ្មី

មួយទៀតសម្រាប់ការជួយផ្តល់ភាពស្របច្បាប់ដល់បងប្អូនពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

## យុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់ពលករខ្មែរនៅថៃ

http://www.cen.com.kh/archives/4301.html October 30, 2017

ភ្នំពេញ៖ យុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់ពលករខ្មែរនៅថៃ ដើម្បីដោះស្រាយនូវសំណូមពរ និងជំរុញក្រុមការងារទាំងអស់ ត្រូវបង្កើនការផ្តល់សេវាជូនបងប្អូនពលករ ដែលបានមកបើកផ្តល់លិខិតឆ្លងដែន ខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជា ទៅធ្វើការនៅបរទេស និងបងប្អូនដែលមកស្នើសុំ បញ្ជាក់អត្តសញ្ញាណ ពីក្រុមការងារអន្តរក្រសួងចល័ត ទាំងបីការិយាល័យ នៅទីក្រុងបាងកក ខេត្តរ៉ាក់យ៉ង និងខេត្តសុងក្លា ឱ្យបានកាន់តែល្អប្រសើរថែមទៀត។

បើតាមលោកហេង សួរ អ្នកនាំពាក្យក្រសួងការងារបណ្តុះបណ្តាលនិងវិជ្ជាជីវៈ សរសេរក្នុងផេកហ្វេសប៊ុកផ្លូវការ កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧នេះ ចាប់ពីខែតុលា ឆ្នាំ២០១៧នេះ គេបានឃើញវត្តមានមន្ត្រីកម្ពុជាប្រមាណជា ៣៥០នាក់ បានបង្ហាញខ្លួន ក្នុងស្ថានទូតកម្ពុជា ប្រចាំទីក្រុងបាងកក ផ្សារ BIG C Ladphrao ក្នុងទីក្រុងបាងកក ផ្សារអូចប៉ម៉ាយ៉ង ក្នុងខេត្តរ៉ាកយ៉ង ផ្សារហ្មុកទៀន ក្នុងខេត្តសុងក្លា ខេត្តឆាក់ជើងសាវ និងខេត្តផាធុមថានី នៃប្រទេសថៃ។

បើតាមអ្នកនាំពាក្យ បានបន្តថា ជារៀងរាល់ថ្ងៃមន្ត្រីទាំងអស់ ត្រូវក្រោកពីព្រលឹម ដើម្បីរៀបចំការិយាល័យ និងឧបករណ៍ សម្ភារៈបរិក្ខាអេឡិកត្រូនិក របស់ខ្លួននៅមុនម៉ោង ៨ព្រឹក (មុនម៉ោង ៩:៣០នាទី សម្រាប់នៅផ្សារ BIG C) និងបញ្ចប់ការងាររបស់ខ្លួន នៅម៉ោងប្រមាណជាង ៧យប់ (ម៉ោង៩យប់ សម្រាប់នៅផ្សារ BIC C)។ មន្ត្រីទាំងអស់ត្រូវធ្វើការយ៉ាងតិច ១០ម៉ោង ក្នុង១ថ្ងៃ និងធ្វើការ ៦ថ្ងៃ ក្នុង១អាទិត្យ។ នេះគឺជារឿងពិត នៃយុទ្ធនាការផ្តល់ភាពស្របច្បាប់ ដល់ពលករខ្មែរនៅប្រទេសថៃ។ ថ្នាក់ដឹកនាំនៃគណៈកម្មការ ផ្តល់ភាពស្របច្បាប់ ក៏បានខិតខំឆ្លៀតពេលវេលា ដ៏មមារញឹកចុះដឹកនាំប្រជុំ ត្រួតពិនិត្យ និងកែសម្រួលការងារជាបន្តបន្ទាប់ ទៅតាមសំណូមពររបស់ពលករកម្ពុជាផង និងសំណូមពររបស់ភាគីថៃផង។

លោកបានបន្តថា គិតត្រឹមថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៧នេះ គណៈកម្មការ បានបើកផ្តល់លិខិតធ្វើដំណើ TD និងប័ណ្ណពលករកម្ពុជា OCWC ក្នុងថ្ងៃតែមួយដល់ពលករកម្ពុជា ដែលបានចុះបញ្ជីជាមួយភាគីថៃ នាអំឡុងខែសីហា និងកញ្ញា ឆ្នាំ២០១៧ កន្លទៅនេះ បានចំនួន ១.២០០នាក់ ក្នុងមួយថ្ងៃផងដែរ។ គណៈកម្មការ នឹងស្នើសុំការសហការ ជាមួយភាគីថៃ ឱ្យបង្កើនការចេញលេខរៀងណាត់ជួបឱ្យកើនដល់ ១.៤០០នាក់ ក្នុង១ថ្ងៃ ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧នេះ តទៅ។ លោកហេង សួរ បានបន្ថែមថា "ពលករកម្ពុជា ដែលមកទទួលសេវា គឺមានភាពរីករាយចំពោះកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីយើង រឺ TD និងប័ណ្ណពលករកម្ពុជា (OCWC) ដល់ពលករកម្ពុជាបានចំនួនជាង ១០ម៉ឺននាក់ ដើម្បីយកទៅបន្តនីតិវិធី ទទួលបានភាពស្របច្បាប់ពីភាគីថៃ។ ទន្ទឹមនឹងនេះ យើងក៏បានចាប់ផ្តើមធ្វើការបញ្ជាក់អត្តសញ្ញាណ ផលិត និងបើកផ្តល់លិខិតធ្វើដំណើរ ឯភាគីថៃក៏បានកោតសរសើរដល់មន្ត្រីរបស់កម្ពុជា ដែលសុខចិត្តធ្វើការក្នុង១ថ្ងៃលើសពី ៩ម៉ោង និងធ្វើការចំនួន ៦ថ្ងៃ ក្នុង១អាទិត្យ"។

ទោះជាមានគណៈកម្មការផ្តល់ភាពស្របច្បាប់នៅប្រទេសថៃក៏ដោយ ពីពេលនេះតទៅ ខ្ញុំសូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ ដែលមានបំណងចេញទៅធ្វើការនៅប្រទេសថៃ សូមជ្រើសរើសការធ្វើចំណាកស្រុកដោយស្របច្បាប់ (ជាពលករ MOU) ពីព្រោះការផ្តល់ភាពស្របច្បាប់នៅប្រទេសថៃគឺអាចធ្វើបានតែចំពោះពលករ ដែលមានបណ្ណពណ៌ស៊ីជម្ពូ ឬលិខិតបញ្ជាក់ដែលចេញដោយក្រសួងការងារថៃ ឬមន្ទីរការងារថៃកាលពីខែសីហា និងកញ្ញា ឆ្នាំ២០១៧ កន្លងទៅនេះតែប៉ុណ្ណោះ។ លោកអ្នកនាំពាក្យបានបញ្ជាក់បន្ថែមយ៉ាងដូច្នេះ។

សូមបញ្ជាក់ថា នៅស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជានៅទីក្រុងបាងកក លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការ ផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជា កំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំ ត្រួតពិនិត្យការងារ របស់គណៈកម្មការផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ។ ក្នុងកិច្ចប្រជុំនាឱកាសនោះ លោកបណ្ឌិត ប្រធានគណៈកម្មការ បានទទួលដោះស្រាយនូវសំណូមពរ និងជំរុញក្រុមការងារទាំងអស់ត្រូវបង្កើនការផ្តល់សេវាជូនបងប្អូនពលករដែលបានមកបើកផ្តល់លិខិតឆ្លងដែន/លិខិតធ្វើដំណើរ (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) និងបងប្អូនដែលមកស្នើសុំបញ្ជាក់អត្តសញ្ញាណពីក្រុមការងារអន្តរក្រសួងចល័តទាំងបីការិយាល័យ នៅទីក្រុងបាងកក ខេត្តរ៉ាក់យ៉ង និងខេត្តសុងក្លា ឱ្យបានកាន់តែល្អប្រសើរថែមទៀត។

លោករដ្ឋមន្ត្រី បានថ្លែងថា មន្ត្រីមកពីគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលកន្លងមកបានខិតខំបំពេញការងារជាពិសេសក្នុងយុទ្ធនាការបញ្ជាក់អត្តសញ្ញាណ ជូនបងប្អូនពលករកម្ពុជា ដែលទើបនឹងចាប់ផ្តើមនាពេលថ្មីៗនេះ ប្រកបដោយស្មារតីទទួលខុសត្រូវ។ "នេះគឺជាជំហាន និងជាជោគជ័យថ្មីមួយទៀតសម្រាប់ការជួយផ្តល់ភាពស្របច្បាប់ដល់បងប្អូនពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា"។លោករដ្ឋមន្ត្រីក្រសួងការងារបណ្តុះបណ្តាលនិងវិជ្ជាជីវៈ បានបន្ថែមដូច្នេះ៕ ដោយៈជាលី

## ឯកសារសម្រាប់ស្នើសុំVisa

http://pheaktraprak.com/archives By ប្រាក់ ភក្ត្រា October 31, 2017

ឯកសារសម្រាប់ស្នើសុំវីសារការងារ ចំពោះពលករកម្ពុជាដែលបានទទួលប៉ាស្ព័រ (TD) ចំពោះឯកសារសម្រាប់ស្នើសុំវីសារនិងច្បាប់អនុញ្ញាតធ្វើការនៅក្នុងប្រទេសថៃរបស់ពលករកម្ពុជា មានពីក្រុមដូចតទៅៈ

**1-ចំពោះពលករកម្ពុជាដែលចុះឈ្មោះថ្មី បានត្រួតសញ្ជាតិរួច ទទួលបានប៉ាស្ព័រការងារ (TD)**

ករណីពលករចុះថ្មីក្រោយពេលទទួលបានប៉ាស្ព័រការងារ(TD) អាចស្នើសុំvisa បានភ្លាមនៅកន្លែងធ្វើប៉ាស្ព័រចំពោះទីតាំងខេត្តរ៉ាក់យ៉ង

-អត្តសញ្ញាណប័ណ្ណ, សំបុត្រកំណើត, អត្រានុកូលដ្ឋាន, សៀវភៅគ្រួសារ, ប័ណ្ណបើកបរ,ប៉ាស្ព័រក្រហម, (ឯកសារទាំងអស់នេះយកមួយណាក៏បាន) ចំនួន2 សន្លឹក។

-រូបថត4×6 ត្រៀម6 សន្លឹក

-ប៉ាស្ព័រ(TD)របស់ពលករ ច្បាប់ពិតនិងថតចម្លងចំនួន

-ឯកសារបញ្ជាក់រវាងថៅកែនិងពលករច្បាប់ពិត

-អត្តសញ្ញាណសញ្ជាតិថៃរបស់ថៅកែច្បាប់ពិត

-ឯកសារសៀវភៅគ្រួសាររបស់ថៅកែច្បាប់ថតចម្លងនិងច្បាប់ពិត

-ករណីក្រុមហ៊ុនឯកជនត្រូវមានឯកសារបញ្ជាក់ពីក្រុមហ៊ុនមកជាមួយផង

-ទឹកប្រាក់ចំនួន2050បាត

**2-ចំពោះពលករកម្ពុជាដែលមានប័ណ្ណស៊ីជម្ពូ បានត្រួតសញ្ជាតិរួច ទទួលបានប៉ាស្ព័រការងារ(TD) អាចទៅស្នើសុំVisa នៅក្នុងតំបន់ដែលស្នាក់នៅធ្វើការបាន។**

ឯកសារចំពោះអ្នកមានប័ណ្ណស៊ីជម្ពូៈ

-ប័ណ្ណស៊ីជម្ពូច្បាប់ថតចម្លងចំនួន2 សន្លឹក

-រូបថត4×6 ចំនួន2 សន្លឹក

-ថរ38

-អត្តសញ្ញាណប័ណ្ណសញ្ជាតិថៃរបស់ថៅកែ

-សៀវភៅគ្រួសាររបស់ថៅកែ

-ឯកសារបញ្ជាក់រវាងថៅកែនិងពលករ ឬហៅសន្យាចាង

-ទឹកប្រាក់500បាត

ក្រោយពេលស្នើសុំvisa រួចកុំភ្លេចទៅស្នើសុំច្បាប់អនុញ្ញាតធ្វើការនៅមន្ទីរការងារខេត្តក្រុងពលករធ្វើការ ដោយមានតំលៃសេវាកម្មចំនួន550បាត។

## ឯកសារសម្រាប់ទៅធ្វើប៉ាស្ព័រ ចំពោះពលករកម្ពុជា

http://pheaktraprak.com/archives By ប្រាក់ ភក្ត្រា October 31, 2017

ឯកសារសម្រាប់ពលករកម្ពុជាទៅគ្រួតសញ្ជាតិធ្វើប៉ាស្ព័រនៅក្នុងប្រទេសថៃ។ **ចំពោះពលករកម្ពុជាដែលកំពុងស្នាក់នៅធ្វើការក្នុងប្រទេសថៃ ដើម្បីទៅគ្រួតសញ្ជាតិ ធ្វើប៉ាស្ព័រ នៅទីតាំងទាំងបីកន្លែងក្នុងប្រទេសថៃបានត្រូវមានដូចខាងក្រោម៖**

1-អត្តសញ្ញាណប័ណ្ណថៅកែច្បាប់ថតចម្លងចំនួន 2សន្លឹក

2-ប័ណ្ណស៊ីជម្ពូ របស់ពលករ ច្បាប់ពិតនិងថតចម្លងចំនួន2សន្លឹក

3- សំបុត្រកំណើត, អត្រានុកូលដ្ឋាន, អត្តសញ្ញាណ, សៀវភៅគ្រួសារ, ប័ណ្ណបើកបរ,កាតបោះឆ្នោត,ប៉ាស្ព័រក្រហម ច្បាប់ថតចម្លងចំនួន 2 សន្លឹក (ក្នុងចំណោមទាំងនេះយកមួយណាក៏បាន)

4-រូបថត 4×6 ចំនួន2 សន្លឹក

5-ទឹកប្រាក់សម្រាប់ធ្វើប៉ាស្ព័រចំពោះ2350បាត

**ចំពោះពលករចុះឈ្មោះថ្មី មានឯកសារសម្គាសន៍ ត្រូវត្រៀមឯកសារទៅធ្វើប៉ាស្ព័រ ដូចខាងក្រោម៖**

1-អត្តសញ្ញាណប័ណ្ណសញ្ជាតិថៃរបស់ថៅកែ ច្បាប់ថតចម្លងចំនួន2 សន្លឹក

2-ឯកសារបញ្ជាក់ពីក្រសួងការងារថៃឬហៅថាលិខិតសម្ភាសន៍ច្បាប់ពិត

3-សំបុត្រកំណើត, អត្រានុកូលដ្ឋាន, សៀវភៅគ្រួសារ, សៀវភៅស្នាក់នៅ, អត្តសញ្ញាណ, ប័ណ្ណបើកបរ, កាតបោះឆ្នោត,ប៉ាស្ព័រក្រហម, ច្បាប់ថតចម្លងចំនួន2 សន្លឹក (ក្នុងចំណោមទាំងយកមួយណាក៏បាន)

4-រូបថត4×6 ចំនួន2 សន្លឹក

5-ទឹកប្រាក់សម្រាប់ថ្លៃធ្វើប៉ាស្ព័រចំនួន2350បាត

## ក្រសួងការងារថៃ ប្រកាសជូនដំណឹង កម្មករធ្វើការនេសាទ អោយប្រញាប់ទៅគ្រួតសញ្ជាតិឱ្យបានមុនថ្ងៃទី01

http://pheaktraprak.com/archives By ប្រាក់ ភក្ត្រា October 31, 2017

រដ្ឋមន្ត្រីក្រសួងការងារថៃ ប្រកាសជូនដំណឹងដល់ពលករបរទេសទាំងបីសញ្ជាតិ ធ្វើការផ្នែកនេសាទ,និងការងារសមុទ្រ អោយប្រញាប់គ្រួតសញ្ជាតិឱ្យបានមុនថ្ងៃទី01.11.2017។ ក្រសួងការងារថៃប្រកាសតឿនពលករខ្មែរ,

ឡាវ,ភូមា, ដែលមានប័ណ្ណស៊ីជម្ពូផុតកំណត់ 01.11.2017 ប្រញាប់រួសរាន់ត្រួតសញ្ជាតិអោយបានទាន់ពេលវេលា មិនដូច្នេះទេនិងត្រូវមានទោសចាប់បញ្ជូនទៅប្រទេសរបស់ខ្លួនភ្លាម។

កាលពីថ្ងៃច័ន្ទទី30 ខែតុលា ឆ្នាំ2017នេះ លោករដ្ឋមន្ត្រីក្រសួងការងារថៃ បានប្រកាសជូនដំណឹងដល់ពលករបរទេសទាំងបីសញ្ជាតិ ដែលកាន់ប័ណ្ណស៊ីជម្ពូប្រភេទធ្វើការនេសាទ ផ្នែកការងារសមុទ្រ ប័ណ្ណស៊ីជម្ពូផុតកំណត់នៅថ្ងៃទី01 ខែ11 ឆ្នាំ2017 ខាងមុខនេះ អោយប្រញាប់ប្រញាល់រួសរាន់ទៅធ្វើការត្រួតសញ្ជាតិប្តូរយកប៉ាស្ព័រអោយបានមុនពេលកំណត់។

**ទីតាំងត្រួតសញ្ជាតិជូនពលករកម្ពុជាមានចំនួនបីកន្លែងដូចខាងក្រោម៖**

1.ទីក្រុងបាងកក អាស័យដ្ឋាន អ៊ឹមផើរៀលវើល ឡាតប្រាវ(Imperial World Ladphrao) ជាន់ទី 4 លេខ 2539 ប្រក81-83 ផ្លូវឡាតប្រាវ សង្កាត់ចៅឃុនស៊ីង ខណ្ឌថុងឡាង ទីក្រុងបាងកក 10310។

2.ខេត្តរ៉ាក់យ៉ង. អាស័យដ្ឋានផ្សារ អូថប់យ៉ង(OTOP MA Yong). 201-ភូមិ7 ឃុំម៉ាខាយ,ស្រុក និឃុំផាត់តាណា,ខេត្តរ៉ាក់យ៉ង 21180។

3.ខេត្តសុងក្លា អាស័យដ្ឋាន ផ្សារហុកទៀង(Fuk Thai) 99 ភូមិ3. ឃុំ ខ្លងហែរ ស្រុកហាតយ៉ៃ ខេត្តសុងក្លា

ក្រោយពេលត្រួតសញ្ជាតិប្តូរយកប៉ាស្ព័ររួចពលករបរទេសទាំងបីសញ្ជាតិ អាចធ្វើការស្នើសុំវីសារការងារនិងច្បាប់អនុញ្ញាតធ្វើការស្នាក់នៅក្នុងប្រទេសថៃយ៉ាងត្រឹមត្រូវទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់។